ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- បដិរូបជាផ្លូវការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា
- សវនាការជំបូងគឺជាយុត្តិធម៌សម្រាប់មនុស្សគ្រប់រូប

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៧៣ ខែមករា ឆ្នាំ២០០៦

# ស្វែងរកការពិត

លេខ៧៣ ខែមករា ឆ្នាំ២០០៦


## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
## មាតិកា


◆សំបុត្រ ៖ ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញ ........................១

**ផ្នែកឯកសារ**

◆ហ៊ី សុធារី ៖ អតីតនិស្សិតសាលាច្បាប់.............................................២

◆ញ្ជីឈ្មោះជនរងគ្រោះដែលកម្មេចនៅមន្ទីរ ស-២ .................................៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆រឿងរ៉ាវដែលមិនចេះសាបសូន្យ.......................................................៩

◆សង្ឃឹមថានឹងបានជួបបងប្រុសវិញ...................................................២៣

**ផ្នែកច្បាប់**

◆ការកេណ្ឌកុមារឲ្យធ្វើទាហាននិងឧក្រិដ្ឋកម្មសង្គ្រាម .............................២៥

**វេទិកាពិភាក្សាសាធារណៈ**

◆យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា ...................៣៩

◆សវនាការដំបូងគឺជាយុត្តិធម៌សម្រាប់មនុស្សគ្រប់រូប ...........................៤៨

◆ពិធីប្រគល់អគារធ្វើការនិងបរិវេណសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ .........៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆រឿងរ៉ាវខ្ញុំក្នុងរបប ប៉ុល ពត ...................................................៥៧




ទុន ឈុំ ជាមួយប្រពន្ធនិងកូនទាំងបួន ឆ្នាំ១៩៦៥



បន្ទប់សវនាការបស់អង្គជំនុំជម្រះវិសាមញ្ញ


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ** ៖ ប៉ាង ពីរីន, ស៊ិរិ សាវីណា, ឌី ខាំបូលី, ស៊ួ ប៊ុនស៊ូ, អៀ ម៉េងទ្រី, មុត ចាន់ថា, គីម ជាម **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ លី សុផល, ណយ សុផារី **អ្នកបកប្រែ** ៖ បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយករង** ៖ សាន់ កល្យាណ **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ** ៖ គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ** ៖ រ័ត្ន តារាពិដោ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជាសូមអញ្ជើញប្រជាជនកម្ពុជាចូលរួមក្នុងដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ដែលជាទូទៅហៅថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) ដែលរៀបចំឡើងជារៀងរាល់ខែចាប់ពីខែកុម្ភៈ ឆ្នាំ២០០៦នេះតទៅ ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជានិងការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ដោយមានកិច្ចសហប្រតិបត្តិការ និងគាំទ្រពីក្រសួងមហាផ្ទៃនិងប្រទេសចំនួន៤រួមមាន : សហរដ្ឋអាមេរិក ប្រទេសស៊ុយអែត ន័រវេ និងដាណឺម៉ាក ។ ដំណើរទស្សនកិច្ចនេះសហប្រតិបត្តិការជាមួយនិងសមាគម ដូនជី, សហគមព្រះវិហារឥស្លាមចំនួន៣៩៦ និងសមាគមនិស្សិតស្ម័គ្រចិត្តចំនួន៥០០នាក់ ។

ដំណើរទស្សនកិច្ចនេះរួមមានការទៅទស្សនាទីតាំងអង្គជំនុំជម្រះវិសាមញ្ញ ទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតជើងឯក ព្រមទាំងជួបជាមួយមន្ត្រីតុលាការសំខាន់ៗ ដែលនឹងពន្យល់ប្រាប់អំពីដំណើរការថ្មីៗនៃការរៀបចំអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។

គោលបំណងនៃការរៀបចំដំណើរទស្សនកិច្ចនេះ គឺដើម្បីផ្តល់ឱកាសជូនប្រជាជនកម្ពុជាឲ្យទទួលបានព័ត៌មានអំពីដំណើរការស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះ ក៏ដូចជាបានចូលរួមស្តាប់សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញដែលនឹងចាប់ផ្តើមឡើងនាពេលឆាប់ៗខាងមុខនេះ ។

ដំណើរការនេះគឺជាផ្នែកមួយនៅក្នុងគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា សំដៅដល់ជនរងគ្រោះរាប់លាននាក់នៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃ ហើយដែលស័ក្តិសមនឹងបានទទួលព័ត៌មានទាក់ទងនឹងដំណើរការស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ទោះបីជាកាសែត វិទ្យុ ទូរទស្សន៍ អ៊ីនធឺនែត និងបណ្តាញសារព័ត៌មានផ្សេងៗទៀត អាចផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងទីក្រុងភ្នំពេញនិងនៅខេត្តក្រុងមួយចំនួនក៏ដោយ ក៏ខេត្ត ស្រុក ឃុំ មួយចំនួនទៀត នៅតែជួបការលំបាកក្នុងការស្វែងរកនិងទទួលព័ត៌មានអំពីដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញនៅឡើយ ។ ផលប្រយោជន៍នៃគម្រោងនេះគឺ ÷

◆ប្រជាជនកម្ពុជានឹងទទួលបានព័ត៌មានអំពីដំណើរការស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ សម្មភាពគឺ ជាដំណើរការផ្សះផ្សាមួយ ។

◆ជំរុញនិងលើកទឹកចិត្តឲ្យប្រជាជនកម្ពុជាចូលរួមដោយផ្ទាល់និងដោយប្រយោលនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ការណ៍នេះនឹងជួយឲ្យអង្គជំនុំជម្រះវិសាមញ្ញផ្តល់យុត្តិធម៌បានល្អប្រសើរ ។

◆តាមរយៈសកម្មភាពទាំងឡាយនៃគម្រោងនេះ នឹងបង្ហាញឲ្យឃើញនូវការទទួលស្គាល់ការឈឺចាប់ទាំងអម្បាលម៉ានដែលជនរងគ្រោះទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីរបបនេះដួលរលំទៅអស់រយៈពេលជាង២៧ឆ្នាំមកហើយ ។

ប្រជាជនកម្ពុជាដែលមានចំណាប់អារម្មណ៍និងចង់ចូលរួមក្នុងដំណើរទស្សនកិច្ចនេះសូមទាក់ទងឈ្មោះ វ៉ាន់ថាន់ ពៅដារ៉ា អនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបន្ទុកផ្សព្វផ្សាយ តាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៩ ឬ ០១២ ៨៤៦ ៥២៦ ឬទាក់ទងនៅការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានទីតាំងនៅផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (ខាងកើតវិមានឯករាជ្យ) ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ហ៊ី សុធារី ៖ អតីតនិស្សិតសាលាច្បាប់ក្នុងរបបលន់នល់

ហ៊ី សុធារី ហៅ ធា ជាអតីតនិស្សិតមហាវិទ្យាល័យច្បាប់ ។ សុធារី កើតនៅថ្ងៃទី១២ ខែ២ ឆ្នាំ១៩៥០ នៅភូមិអន្លុងកា ឃុំជាំងទង ស្រុកត្រាំកក់ ខេត្តតាកែវ មានឪពុកឈ្មោះ ហ៊ី លីម និងម្តាយឈ្មោះ ទូច ផែន ។ តាំងពីឆ្នាំ១៩៥៨មក សុធារី សិក្សានៅខេត្តតាកែវ ។ នៅឆ្នាំ១៩៧០ សុធារី បានផ្លាស់មករៀនបន្តថ្នាក់ទីបញ្ចប់នៅវិទ្យាល័យព្រះយុគន្ធររាជធានីភ្នំពេញ ។ សុធារី បានបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅមហាវិទ្យាល័យច្បាប់ពីឆ្នាំ ១៩៧១ដល់១៩៧៣ ។

ក្នុងឆ្នាំ១៩៧៦ សុធារី បានទទួលភារកិច្ចជាប្រធានក្រុមទូរលេខនៅមន្ទីរកងពល៨០១ នៅខេត្តរតនគិរី ។ សុធារី ត្រូវអង្គការកងពលបញ្ជូនពី រតនគិរីមកភ្នំពេញ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៧ និងត្រូវ អង្គការចាប់ខ្លួននៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៧ ។ ខាងក្រោម នេះជាពត៌មានដែលសង្ខេបស្រង់ចេញពីចម្លើយសារភាពរបស់ សុធារី ÷

នៅឆ្នាំ១៩៧១ សុធារី ទៅសុំការងារក្រៅម៉ោងបានទទួលការយល់ព្រមពី ស៊ីន គិមស៊ុយ អតីតសាស្ត្រាចារ្យ និងចាងហ្វាងវង វិទ្យុជាតិ លន់ នល់ ធ្វើជាអ្នកបកប្រែពត៌មានពីកាសែត អា.កា.ប៉េ. សម្រាប់វិទ្យុ ក្រោមការណែនាំការងារជាប្រចាំពី មួង ស៊ីនួន អតីតសាស្ត្រាចារ្យ និងជានាយករៀបចំពត៌មានសម្រាប់ការផ្សាយ ។

ក្នុងរយៈកាលធ្វើការ សុធារី ត្រូវបាន គិមស៊ុយ និង ស៊ីនួន យកចិត្តទុកដាក់ផ្តល់លុយកាក់ឲ្យបន្ថែមលើប្រាក់ខែ និងទទួលបាននូវការអប់រំជាច្រើនទៀត ។ គិមស៊ុយ និង ស៊ីនួន បានពន្យល់ សុធារី ឲ្យជឿថាខ្មែរក្រហមជាជនកុម្មុយនិស្ត ដែលស្ថិតនៅក្រោមដែនការកុម្មុយនិស្តឥណ្ឌូចិនរបស់ហូជីមិញ ដែលចង់បានទឹកដីខ្មែរ ។

បន្ទាប់ពីអប់រំបំពាក់បំប៉នទាំងផ្នែកជីវភាពរស់នៅ និងទស្សនៈយល់ដឹងមក នៅខែ៩ ឆ្នាំ១៩៧១ គិមស៊ុយ និង ស៊ីនួន បានហៅ សុធារី មកជួបនៅផ្ទះរបស់ គិមស៊ុយ ។ ស៊ីនួន បានបញ្ជាក់អំពីគុណសម្បត្តិរបស់ សុធារី ថាស្មោះត្រង់ មានទស្សនៈឯកភាពជាមួយខ្លួន និងស្រលាញ់របបសេរីនិយម ហើយបានខទ្វេសនាម សុធារី ឲ្យចូលក្នុងជួរយុវជនអង្គការ សេ.អ៊ី.អា. ដោយមាន គិមស៊ុយ ជាអ្នកទទួលស្គាល់ ។ សុធារី បានប្តេជ្ញាចិត្តថានឹងស្មោះត្រង់និងបម្រើសេ.អ៊ី.អា.ជារៀងរហូត ។ ពិធីបញ្ចូលបានប្រព្រឹត្តទៅនៅចំពោះមុខទង់ពណ៌ខៀវមានសញ្ញាកងចក្រនៅកណ្តាល ។

សុធារី មានភារកិច្ច ១) សសេរអត្ថបទនយោបាយសម្រាប់វិទ្យុ ២) តាមដានចលនាខ្មែរក្រហមក្នុងអង្គការសមាគមសិស្សនិស្សិតនៅទីក្រុងភ្នំពេញ ៣) ឃោសនាអប់រំសិស្សនិស្សិតឲ្យស្អប់ខ្មែរក្រហម និងធ្វើសកម្មភាពប្រឆាំងនឹងខ្មែរក្រហម ៤) ធ្វើសកម្មភាពបំផ្លិចបំផ្លាញអង្គការបដិវត្តន៍ តាមគ្រប់រូបភាព ចាត់តាំងជាសម្ភារៈក្តី ជាបុគ្គលក្តី ឬជាមនោគមវិជ្ជាក្តី និង៥) ត្រូវបង្កប់ខ្លួនស៊ីរូងផ្ទៃក្នុងអង្គការបដិវត្តន៍ដើម្បីចូលរួមធ្វើសកម្មភាពកម្ទេចរបបកុម្មុយនិស្តពីសង្គមកម្ពុជា ។

នៅខែ២ ឆ្នាំ១៩៧២ សុធារី ត្រូវបាន ស៊ីនួន ខទ្វេសនាមឲ្យស្គាល់ឈ្មោះ ឡុច សឿន ហៅ ដាវ អតីតនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ ។ នៅខែដដែល សឿន បានណែនាំ សុធារី ឲ្យស្គាល់ឈ្មោះ ខៀវ សិរីវុឌ្ឍន៍ ហៅ វាង អតីតនិស្សិតមហាវិទ្យាល័យច្បាប់ ។ សឿន និង សិរីវុឌ្ឍន៍ បានណែនាំ សុធារី ឲ្យយល់កាន់តែច្បាស់ពីសកម្មភាពរបស់ខ្មែរក្រហមក្នុងអង្គការសមាគមសិស្សជាក់ស្តែងដូចជាការបំផុសយុវជននៅទីក្រុងភ្នំពេញឲ្យធ្វើកូដកម្មមិនព្រមចូលរៀនជាដើម ។ សុធារី បានស្គាល់មិត្តភក្តិថ្មីទៀតតាមរយៈការណែនាំរបស់ សឿន និង សិរីវឌ្ឍន៍ ក្នុងពេលធ្វើសកម្មភាពដូចជា គុណ ថុនថាណារ៉ាក់ ហៅ ពេញ អតីតនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ, ជួប រ៉េត ហៅ ហ៊ាន អតីតនិស្សិត

មហាវិទ្យាល័យគរុកោសល្យ, ពែក អន ហៅ អាំ អតីតនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ, មាស សារិន អតីតនិស្សិតមហាវិទ្យាល័យកសិកម្មចម្ការដូង, និង ដួង គីមហុង អតីតនិស្សិតមហាវិទ្យាល័យច្បាប់និងសេដ្ឋកិច្ច ។ សុធារី ប្រជុំពិភាក្សាដកបទពិសោធន៍ការងារជាមួយមិត្តភក្តិថ្មីនេះ នៅរាល់ថ្ងៃអាទិត្យនៅមហាវិទ្យាល័យអក្សរសាស្ត្រ ។ ការប្រជុំដកពិសោធន៍គឺសង្កត់ធ្ងន់ទៅលើការបំផុសនិស្សិតឲ្យឈប់ធ្វើចលនាកូដកម្ម ឈប់ប្រឆាំង នឹងអ្នកកាន់អំណាច ។ នៅខែ៧ ឆ្នាំ១៩៧២ សិរីវុឌ្ឍន៍ និង សឿន បានហៅក្រុម សុធារី ប្រជុំគ្នានៅមហាវិទ្យាល័យអក្សរសាស្ត្រ ។ សិរីវុឌ្ឍន៍ បានប្រកាសផ្សាយផែនការថ្មីប្រាប់អង្គប្រជុំឲ្យខិតខំធ្វើសកម្មភាពទាក់ទាញមនោសញ្ចេតនានិស្សិតតាមមហាវិទ្យាល័យរៀងៗខ្លួនដើម្បីដណ្តើមតួនាទីដឹកនាំតាមមហាវិទ្យាល័យ ។

ខែ២ ឆ្នាំ១៩៧៣ សុធារី, សិរីវុឌ្ឍន៍, គីមហុង ត្រូវបាននិស្សិតមហាវិទ្យាល័យច្បាប់និងសេដ្ឋកិច្ច ជ្រើសតាំងឲ្យដឹកនាំសមាគមនិស្សិតមហាវិទ្យាល័យច្បាប់ ។ បន្ទាប់មក សិរីវុឌ្ឍន៍ បានចាត់តាំង សុធារី មកបង្កប់ខ្លួនស៊ើបផ្ទៃក្នុងអង្គការបដិវត្តន៍នៅជនបទដោយខ្ទេសនាម សុធារី ឲ្យនិសារនាំមកមន្ទីរប្រចាំការទាក់ទងក្រុងនៅស្រុកកណ្តាលស្ទឹង តំបន់១៥ នៅខែ៣ ឆ្នាំ១៩៧៣ ។ ក្នុងការបំពេញការងារនេះ សុធារី ត្រូវធ្វើការជាមួយ **សុខ** ចៅហ្វាយក្រុងភ្នំពេញ ។ សុធារី បានទទួលមេរៀនជាច្រើនពី សុខ ដើម្បីដណ្តើមនាទីដឹកនាំក្នុងអង្គការបដិវត្តន៍ធំឲ្យបានរហ័ស ។

នៅខែ៤ ឆ្នាំ១៩៧៣ សុខ បានខ្ទេសនាម សុធារី ឲ្យមកកាន់មន្ទីរភូមិភាគពិសេស ផ្នែកខាងត្បូងភ្នំពេញ ។ មួយខែក្រោយមក សុធារី ត្រូវបានអង្គការបដិវត្តន៍ចាត់ឲ្យមកកាន់មន្ទីរទទួលភ្ញៀវនៅក្រាំងក្តិប (ខាងជើងផ្លូវជាតិលេខ៤ក្នុងតំបន់១៥) ។ នៅទីនោះ សុធារី បានជួបជាមួយមិត្តភក្តិចាស់ៗ ដូចជា នួន ឈឿន, ទូច សុខផល្លា, ជាត់ ស៊ីដូ, ជួប រ៉េត និង ស្បោង រុន ។


នួន ឈឿន


ទូច សុខផល្លា

ខែ៦ ឆ្នាំ១៩៧៣ សុធារី បានទទួលការកិច្ចថ្មីមកក្តាប់សភាពការណ៍យោធាទាហានប្រចាំមន្ទីរយោធា៣១ភូមិភាគពិសេស ខែ៧ ឆ្នាំ១៩៧៣ អង្គការបដិវត្តន៍ បានឲ្យ សុធារី ដំឡើងគេអូ នៅឈូកសោមកន្លែងមន្ទីរយោធាកងវរសេនាតូចតំបន់១៥ ។ សុធារី បានទទួលលិខិតណែនាំពី សុខ ឲ្យក្តាប់ផែនការយោធារបស់កងទ័ពបដិវត្តន៍ និងត្រូវទាក់ទងតាមគេអូជាមួយ សុខ រៀងរាល់ម៉ោង ១២ថ្ងៃត្រង់ និងតាមសភាពការណ៍ជាក់ស្តែង ។ លើសពីនេះ សុខ បានខ្ទេសនាមឲ្យ សុធារី ស្គាល់ ហាក់ ប្រធានសេដ្ឋកិច្ចតំបន់១៥ ។ ហាក់ បានណែនាំ សុធារី ឲ្យស្គាល់ ដួន បញ្ជាការយោធាកងវរសេនាតូចតំបន់១៥ និង អ៊ី ប្រធាននយោបាយកងវរសេនាតូចភូមិភាគពិសេស ដើម្បីឲ្យ សុធារី មានទំនាក់ទំនងដោយផ្ទាល់ និងមានភាពងាយស្រួលក្នុងការក្តាប់ផែនការយោធាបដិវត្តន៍ផង ។

សុធារី ក៏បានទទួលការណែនាំពី សុខ ឲ្យមកប្រាប់ហាក់ឲ្យរកវិធីបំផុសប្រជាជនឲ្យរត់ទៅនៅដីទាហានលន់នល់កាន់កាប់ និងប្រាប់ហាក់ឲ្យទាក់ទង អ៊ី និង ដួន ឲ្យចលនាយុទ្ធជនរត់ចោលខ្សែត្រៀម ។

ខែ៨ ឆ្នាំ១៩៧៤ សុធារី បានផ្លាស់មកនៅជាមួយគណៈបញ្ជាការរួមពីសមរភូមិឧដុង្គ-កំពង់ហ្លួង-ពាមសេដ្ឋា ក្រោមការចាត់តាំងគ្រប់គ្រងរបស់ កែវ អ្នកក្តាប់ខ្សែទាក់ទងក្រុងតាមច្រកឧដុង្គ ។ សុធារី បានទទួលការចាត់តាំងឲ្យទាក់ទងជាមួយយន្តហោះទាហានដើម្បីផ្តល់ព័ត៌មានអំពីចំណុចដែលត្រូវទម្លាក់គ្រាប់បែក និងបាញ់កាំភ្លើងធំដាក់លើខ្សែត្រៀមរបស់កងទ័ពបដិវត្តន៍ ។ ខែ៧ ឆ្នាំ១៩៧៤ សុធារី មកកាន់គេអូក្តាប់សភាពការណ៍យោធាទាហានប្រចាំមន្ទីរកងពល១៤ និងរាយការណ៍ឲ្យ សុខ ជាប្រចាំ ។ នៅខែ៩ ឆ្នាំ១៩៧៤ សុធារី បានរាយការណ៍ពីចំណុចកន្លែងឃ្លាំងសម្ភារៈដាក់សាំងមួយកន្លែងនៅក្រាំងក្តិបឃ្លាំងក្រណាត់-

ខោអាវ-អង្ករ-ត្រីសាច់ នៅស្តុកគោលមួយកន្លែងទៀត ។ បន្ទាប់ពីរាយការណ៍មានយន្តហោះមកទម្លាក់គ្រាប់លើឃ្លាំងទាំងពីរនេះឆេះសាំងអស់៥ធុង ។

នៅចុងឆ្នាំ១៩៧៤ សុធារី បានរាយការណ៍ប្រាប់ សុខ អំពីការប្រមូលផ្តុំកម្លាំងទ័ពរបស់ភូមិភាគឧត្តរ រួមជាមួយកងពល១៤ ភូមិភាគពិសេស និងកងពលភូមិភាគនិរតីដែលបែកមុខសញ្ញាគ្នាវាយពីអង្គស្នួល-បែកចាន, ទួលសាប-បាសិត, ភូមិធំ-ត្រពាំងព្រាយ-ពាមសេដ្ឋា ។

ដើមឆ្នាំ១៩៧៥ ពេលដែលកងវរសេនាធំ កងពល៨០១ ឆ្លងផុតទំនប់ទឹកកប់ស្រូវទៅឃ្លាញ សុធារី បានទទួលការចាត់តាំងឲ្យធ្វើជាអ្នកជំនួយភូមិសាស្ត្រឲ្យ កែវ សារឿន លេខាវរសេនាធំ ។ ពេលដែលមកនៅជាមួយ សារឿន, សុធារី បានបើកគេអូឲ្យ សារឿន ទាក់ទងជាមួយ សុខ ដោយផ្ទាល់ ដើម្បីឲ្យអ្នកទាំងពីរស្គាល់សំឡេងគ្នា ។ ចាប់ពីពេលនោះមក សារឿន បានចាត់តាំងឲ្យ សុធារី ផ្តល់ចំណុចខ្សែត្រៀមនិងកន្លែងបោះទ័ពរបស់កងទ័ពបដិវត្តនៅមុខព្រួញពាយ័ព្យភ្នំពេញដែលខ្លួនក្តាប់បាន និងទាក់ទងជាមួយយន្តហោះទាហានដែល សុខ កំណត់ពេលឲ្យជួបទាក់ទងដើម្បីផ្តល់ទីតាំងឲ្យយន្តហោះទម្លាក់គ្រាប់បែកដៅងដាក់លើកងទ័ពបដិវត្ត ។

នៅខែ៥ឆ្នាំ១៩៧៥ សុធារី បានទៅប្រជុំនៅមហាវិទ្យាល័យគរុកោសល្យជាន់ខ្ពស់តាមការកោះហៅរបស់ សុខ ។ សុខ បានណែនាំឲ្យ សុធារី ចេញពីកងពល១៤ មកប្រមូលផ្តុំគ្នាកសាងកម្លាំងកម្មករនិងពង្រីកខ្សែសេ.អ៊ី.អា. ។ សុធារី នឹងគ្មានលទ្ធភាពក្នុងការក្តោបក្តាប់កម្លាំងនិងចាត់តាំងកម្លាំងឲ្យចូលក្នុងជួរខ្សែសេ.អ៊ី.អា. បានទេបើគាត់នៅខាងផ្នែកយោធា ព្រោះនៅក្នុងកងទ័ពបដិវត្តន៍ ពួកបញ្ញាជន អនុធន និស្សិត ពុំងាយកសាងខ្លួនដណ្តើមនាទីដឹកនាំជាកម្មាភិបាលថ្នាក់មធ្យមបានឡើយ ដូច្នេះសុធារីត្រូវប្រមូលផ្តុំកម្លាំងមកខាងផ្នែកបច្ចេកទេស-វប្បធម៌វិញ ។

មួយខែក្រោយមក បន្ទាប់ពីដំណើរការបានបន្តិច អង្គការបានដករោងចក្រទាំងអស់ប្រគល់ទៅឲ្យក្រសួងឧស្សាហកម្មគ្រប់គ្រង ហើយ សុខ នៅតែទទួលខុសត្រូវផ្នែករោងចក្រទឹកកកនិងអគ្គិសនី ។ សុធារី ដឹកនាំកម្មករដើរធ្វើភ្លើង ។

ផ្នែកទទួលខុសត្រូវគ្រឿងចក្របានរកវិធីធ្វើឲ្យភ្លើងរលត់ តភ្លើងចូលរោងចក្រក៏ធ្វើឲ្យយូរ និងធ្វើឲ្យគ្រឿងចក្ររលត់បន្តិចម្តងៗ ។ ធ្វើការនៅរោងចក្រអគ្គិសនីបានរយៈពេលមួយខែ សុធារី បានមកប្រជុំម្តងទៀតជាមួយ សុខ នៅសាលាគរុវិជ្ជាជាន់ខ្ពស់ និងបានជួប ឡុច សឿន, គុណ ថុនថាណារ៉ាក់ និង ពែក អន ។ នៅក្នុងកិច្ចប្រជុំនេះ សុធារី និងសមាជិកដទៃទៀតបានទទួលកិច្ចការថ្មីគឺត្រូវទៅបង្កប់ខ្លួននៅតាមក្រសួងដើម្បីកសាងកម្លាំងសេ.អ៊ី.អា. និងបំផ្លាញរដ្ឋអំណាចបដិវត្តន៍ ។ សុធារី បានទៅធ្វើការនៅស្ថានីយវិទ្យុស្ទឹងមានជ័យនៅខែ៨ ឆ្នាំ១៩៧៥ ។

នៅខែ១០ ឆ្នាំ១៩៧៥ សុធារី ផ្លាស់មកធ្វើការនៅកងពល ៨០១ អតីតកងពល១៤ ក្រោមការខុទ្ទេសនាមរបស់សុខ ។

នៅចុងឆ្នាំ១៩៧៥ បន្ទាប់ពី សុធារី បានរៀនសូត្រនយោបាយរបស់បក្សរយៈពេល២ខែមក សុធារី បានចេញដំណើរជាមួយកងពល៨០១ទៅខេត្តរតនគិរី ។ ពេលទៅដល់បានលុងភ្លាម សុធារី មិនទាន់បានទទួលភារកិច្ចថ្មីទេ ។ រហូតដល់ពេលរៀបចំកន្លែងបោះទ័ពជាបណ្តោះអាសន្ន ហើយ សុធារី ក៏ចាប់ផ្តើមរានដីស្រែចម្ការនិងចាប់ផ្តើមបញ្ចុះបញ្ចូលយុទ្ធជននៅក្នុងកងពល ។ សុធារី បានបំផុសឲ្យយុទ្ធជនរត់ទៅផ្ទះ លួចរបស់របរគ្នាឯង និងបំផ្លាញរបស់របររួម និងធ្វើឲ្យយុទ្ធជនថ្នាំងថ្នាក់នឹងបក្សពីរឿងខ្វះខាតថ្នាំសង្កូវព្យាបាលជំងឺនិងខ្វះខាតម្ហូបអាហារ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៦ សុធារី បានមកសម្រាកពេទ្យដើម្បីព្យាបាលជំងឺ និងបានឆ្លៀតឱកាសនេះ អប់រំ ថង និង ហួត យោធាអនុសេនាតូចកងវរសេនាតូច ៨០៥, និង នឹន យុទ្ធជនវាយទូរលេខនៅក្នុងមន្ទីរកងពល៨០១ ឲ្យជឿថាសង្គមបដិវត្តន៍មិនសូវទុកចិត្តអនុធន សិស្ស និស្សិត និងមិនងាយផ្តល់ឱកាសឲ្យបាននាទីដឹកនាំថ្នាក់ខ្ពស់ៗទេទោះបីជាខំធ្វើការយ៉ាងណាក៏ដោយ ។ សុធារី បានធ្វើឲ្យអ្នកទាំងនោះជឿស៊ប់លើគោលការណ៍សេរីភាពបុគ្គលនិងភាពហ៊ឺហាក្នុងសង្គម ដោយបញ្ជាក់ថាមានមនុស្សច្រើនណាស់ដែលមិនពេញចិត្តនឹងការគាបសង្កត់របស់បដិវត្តន៍ ។

នៅពេលទាក់ទងតាមវិទ្យុ សុធារី ត្រូវធ្វើដោយប្រុងប្រយ័ត្នខ្ពស់បំផុត ។ ការរាយការណ៍ត្រូវធ្វើដោយខ្លីនិងរហ័ស ។ បើសភាពការណ៍មិនល្អត្រូវកំណត់ពេលទាក់ទងគ្នានៅពេល

ក្រោយ បើហៅគ្នាមិនឮត្រូវចំហប៉ុស្តិ៍រង់ចាំគ្នាចំនួន១០នាទីទើបបិទម៉ាស៊ីនបញ្ឈប់ការទាក់ទង ។ សុធារី បានទទួលការណែនាំឲ្យរាយការណ៍ដោយផ្ទាល់មាត់ជាភាសាខ្មែរក្នុងមួយអាទិត្យម្តង ហើយមានការកែប្រែតាមសភាពការណ៍ជាក់ស្តែង ។

សុធារី បានផ្តល់ចំណុចទីតាំងទ័ពនៅម្តុំបរកែវ សាលាខេង និងម្តុំអូរតាងទៅឲ្យវៀតណាម ដើម្បីឲ្យវៀតណាមបានរៀបចំផែនការវាយលុកឲ្យទាន់ក្នុងខែ៩ ។ ប៉ុន្តែ ផែនការវាយលុកនេះត្រូវផ្អាកដំណើរការវិញ ដោយសារសភាពការណ៍នៅក្នុងកងពលមានភាពតានតឹង និងម្យ៉ាងខាងភាគីវៀតណាមមិនទាន់អាចក្តាប់ភូមិសាស្ត្របាននៅឡើយ ។ ដូច្នេះ សុធារី ត្រូវបន្តការផ្សព្វផ្សាយផែនការនិងអូសទាញឲ្យយុទ្ធជនមានការមិនពេញចិត្តនឹងអង្គការបដិវត្តន៍រួចចុះចូលជាមួយសេ.អ៊ី.អា.ឲ្យបានកាន់តែច្រើន ។

នៅចុងឆ្នាំ១៩៧៦ សារឿន មកភ្នំពេញ និងបានណែនាំ សុធារី ឲ្យស្គាល់ ស៊ិន សមាជិកកងវរសេនាធំ៨២ ដើម្បីឲ្យ សុធារី ទាក់ទងធ្វើការជាមួយ ស៊ិន ។

នៅខែ៣ ដើមឆ្នាំ១៩៧៧ សុធារី បានទទួលផែនការផ្តួលរំលំរដ្ឋអំណាចបដិវត្តន៍សាជាថ្មី និងបន្តការទាក់ទងជាមួយយួន សេ.អ៊ី.អា.តទៅទៀត ។ សុធារី បានរាយការណ៍ទៅខាងវៀតណាមតាមការណែនាំរបស់ ស៊ិន ថាបរកែវជាមូលដ្ឋានក្រោយរបស់កងវរសេនាធំ៨១ និងជាទីបញ្ជាការធំរបស់កងវរសេនាធំនោះ ហើយសាលាខេង-អូរតាង ជាកន្លែងបោះទ័ពរបស់កងវរសេនា ធំ៨១ និងជាកន្លែងប្រចាំការការពារព្រំដែន ដើម្បីឲ្យវៀតណាម ពិនិត្យទីតាំងឲ្យបានច្បាស់ ។ នៅខែ២ ខាងវៀតណាមបានចុះពិនិត្យពីទីតាំងតាមព្រំដែនហើយត្រូវជួបការពិបាកក្នុងការឆ្លងដែនមកស៊ើបអង្កេតនៅតាមព្រំដែនខ្មែរ ព្រោះនៅទីនោះមានព្រៃក្រាស់ និងមានការដើរល្បាតរបស់កងចល័តការពារព្រំដែនរបស់កងទ័ពបដិវត្តន៍ ។ រយៈពេលក្រោយមកខ្សែរចាត់តាំងសេ.អ៊ី.អា.ត្រូវបក្សវែកមុខឃើញជាបន្តបន្ទាប់ ។ ស៊ិន បានប្រាប់ សុធារី ឲ្យឈប់ធ្វើការទាក់ទងជាមួយវៀតណាម ដើម្បីធានាសុវត្ថិភាព ។

នៅចុងខែ៣ សុធារី ត្រូវអង្គការកងពលដកពីផ្នែកទូរលេខ និងចាត់តាំងឲ្យកាប់ចម្ការសម្រាប់អង្គភាពមន្ទីរកងពលវិញ ។ សុធារី នៅតែបន្តអប់រំនិងអូសទាញយុទ្ធជនឲ្យចូលរួមជាមួយខ្លួនដដែល ។ ជាក់ស្តែង សុធារី បានអប់រំ ខន នៅតំបន់១៥ ប្រធានក្រុមគេអូនៅមន្ទីរកងពល ៨០១ ឲ្យបំផ្លាញវិទ្យុធុនកុឡាំង ១គ្រឿង ដោយធ្វើជាប្រើភ្លើងលើស ។

សុធារី ត្រូវបានអង្គការកងពលបញ្ជូនខ្លួនពីរតនគិរីមកភ្នំពេញនៅថ្ងៃទី៣ខែ៥ ឆ្នាំ១៩៧៧ និងត្រូវចាប់ខ្លួននៅថ្ងៃទី៦ ខែ៥ ឆ្នាំ១៩៧៧ ។ សុធារី ត្រូវបានសួរចម្លើយដោយ អឿន នៅគុកទួលស្លែង ។ នៅក្នុងចម្លើយសារភាពរបស់ សុធារី មានបញ្ជាក់ឈ្មោះអ្នកដែលខ្លួនបានទាក់ទងជាមួយចំនួន៤៦នាក់ ។

### បញ្ជីឈ្មោះដែលមាននៅក្នុងចម្លើយសារភាព ហ៊ី សុធារី

ស៊ិន គិមស៊ុយ (ប) អតីតសាស្ត្រាចារ្យចាងហ្វាងវិទ្យុផ្សាយសម្លេង លន់ នល់ ទៅស្រុកបារាំងតាំងពីឆ្នាំ១៩៧២ ។ ◆ មួង ស៊ុនួន (ប) អតីតសាស្ត្រាចារ្យ នាយករៀបចំព័ត៌មានសម្រាប់វិទ្យុ លន់ នល់ ជម្លៀសចេញពីភ្នំពេញក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ◆ ឡុច សៀន ហៅ ជីវ (ប) អតីតនិស្សិតមហាវិទ្យាល័យ អក្សរសាស្ត្រនៅក្រសួងរោងពុម្ពរដ្ឋ ។ ◆ ខៀវ សិរីវុឌ្ឍ ហៅ វៀង (ប) អតីតនិស្សិតមហាវិទ្យាល័យច្បាប់ប្រធានរោងចក្រអគ្គិសនីផ្សារតូច ។ ◆ គុណ ថុនថានណាវ៉ាក់ ហៅ ពេញ (ប) អតីតនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រធ្វើការនៅក្រសួងរោងពុម្ពរដ្ឋ ។ ◆ ដួប រ៉េត ហៅ ហ៊ាន អតីតនិស្សិតមហាវិទ្យាល័យគរុកោសល្យ ជាបុគ្គលិកពេទ្យនៅមន្ទីរពេទ្យ២៨ ភូមិភាគពិសេស ស្លាប់ឆ្នាំ១៩៧៤ ។ ◆ ពែក អន ហៅ អាំ អតីតនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រធ្វើការនៅក្រសួងរោងពុម្ពរដ្ឋ ។ ◆ មាស សារិន អតីតនិស្សិតមហាវិទ្យាល័យកសិកម្មទៅនៅភូមិភាគបូព៌ា ។ ◆ ដួង គីមហុង អតីតនិស្សិតមហាវិទ្យាល័យច្បាប់នៅរៀនស្រុកបារាំង ។ ◆ អ៊ុង បែល (ប) អតីតនិស្សិតមហាវិទ្យាល័យច្បាប់ទៅរៀននៅស្រុកបារាំងផ្នែកច្បាប់អន្តរជាតិឆ្នាំ១៩៧២ ។ ◆ ចៅ សេង អតីតនិស្សិតមហាវិទ្យាល័យ កសិកម្មធ្វើការនៅរោងចក្រអគ្គិសនីផ្សារតូច ។ ◆ ឡុង ធីន (ប) អតីតនិស្សិតមហាវិទ្យាល័យច្បាប់ធ្វើការនៅរោងចក្រអគ្គិសនីផ្សារតូច ។ ◆ សាធ អតីតនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រធ្វើការនៅរោងចក្រអគ្គិសនីផ្សារតូច ។ ◆ ផុន អតីតនិស្សិតមហាវិទ្យាល័យ

ពេទ្យ ធ្វើការនៅរោងចក្រអគ្គិសនីផ្សារតូច ។ ◆ ង៉ូវ ជីបអ៊ាក អតីតនិស្សិតមហាវិទ្យាល័យច្បាប់ ។ ◆ ប៉ោ លី អតីតនិស្សិតធ្វើការនៅក្រសួងរោងពុម្ពរដ្ឋ ។ ◆ លី អតីតសាស្ត្រាចារ្យ ធ្វើការនៅក្រសួងរោងពុម្ពរដ្ឋ ។ ◆ ប៉ាវ អ៊ិត អតីតសាស្ត្រាចារ្យធ្វើការនៅក្រសួងរោងពុម្ពរដ្ឋ ។ ◆ ប៉ែន ម៉ានីល ហៅ ម៉ែន អតីតសាស្ត្រាចារ្យ ធ្វើការនៅ ក្រសួងរោងពុម្ពរដ្ឋ ។ ◆ ស្បោង រុន (ប) អតីតសាស្ត្រាចារ្យអនុប្រធានមន្ទីរកងពល៨០១ ។ ◆ នួន យឿន (ប) អតីតសាស្ត្រាចារ្យ ធ្វើការនៅខេត្តព្រះវិហារ ។ ◆ ដាត់ ស៊ីជូ អតីតវិស្វករអគ្គិសនី ធ្វើការនៅក្រសួង សាធារណៈការ ។ ◆ ទូន សុខផល្លា អតីតវិស្វករធ្វើការនៅក្រសួងសាធារណៈការ ។ ◆ សុខ គណៈក្រុងភ្នំពេញ ។ ◆ ហាក់ ប្រធានសេដ្ឋកិច្ចតំបន់១៥ ធ្វើការនៅក្រសួងភ័ស្តុភាសេនាធិការ ។ ◆ កែវ លេខាស្រុកខត្តុគ្គ ភូមិភាគបស្ចិម ។ ◆ អ៊ី អតីតកម្មករសេរី ប្រធាននយោបាយកងវរសេនា តូច១១៤ ភូមិភាគពិសេសចូលទាហានឆ្នាំ១៩៧៤ ។ ◆ ជួន បញ្ញាការកង វរសេនាតូច១២៣ តំបន់១៥ ចូលទាហានឆ្នាំ១៩៧៤ ។ ◆ កែវ សារឿន (ប) សមាជិកកងពល៨០១ ប្រចាំចម្ការនៅភូមិភាគឥសាន ។ ◆ ស៊ិន សមាជិកកងវរសេនាធំ៨២ កងពល៨០១ ប្រចាំការភូមិភាគឥសាន ។ ◆ តេង អតីតសិស្សថ្នាក់ទី៣ សមាជិកកងវរសេនាតូច៨០៣ កងពល៨០១ ប្រចាំការភូមិភាគឥសាន ។ ◆ ឆន អតីតកម្មករសេរី សមាជិកកងវរសេនាតូច៨០២ កងពល៨០១ ភូមិភាគឥសាន ។ ◆ អាង នយោបាយកងអនុសេនាធំ៦១ កងវរសេនាតូច៨០៦ កងពល៨០១ ភូមិភាគឥសាន ។ ◆ អ៊ួន នយោបាយកងអនុសេនាធំ កងវរសេនាតូច៨០២ កងពល៨០១ ។ ◆ ប៊ូក សមាជិកកងអនុសេនាធំ កងវរសេនាតូច៨០២ កងពល៨០១ ។ ◆ សារិន ប្រធានក្រុម កងវរសេនាតូច៨០៦ កងពល៨០១ ។ ◆ នឹន យុទ្ធជនទូរលេខនៅមន្ទីរកងពល៨០១ ។ ◆ ខន ប្រធានក្រុមគេអូ មន្ទីរកងពល៨០១ ។ ◆ ហួត យោធាអនុសេនាតូច កងវរសេនាតូច៨០៥ កងពល៨០១ ។ ◆ ថង យោធាអនុសេនាតូច កងវរសេនាតូច៨០៥ កងពល៨០១ ភូមិភាគឥសាន ។

**ណាយ សុផារី**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- ◆វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ល្ងាច ។
- ◆វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។
- ◆វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។
- ◆វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និងឡេង រតនា**

# ពាក្យស្លោកខ្មែរក្រហម

- **ឈរជាប់ខាងនិងគ្រប់កាលៈទេសៈ លើជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន កាន់កាប់វាសនាដោយខ្លួនឯង។**
- **កម្ចាត់ជាច់ខាត ជំហររណបគេ ខ្ញុំគេ សារភាពនិយម ចុះចាញ់និយម។**
- **ប្រយុទ្ធការពារឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីកម្ពុជាប្រជាធិបតេយ្យ។**

(សៀវភៅកំណត់ហេតុលេខ០៧៦)

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៤២៧ | ជា វ៉ន ហៅ ភាព | យុទ្ធជន | ផែកំពង់សោម | ១៥-២-៧៧ | ១២-៥-៧៧ |
| ២៤២៨ | ជឹម សេងហ៊ាង ហៅ ឈាង | យុទ្ធជន | ពាណិជ្ជកម្ម | ១៧-២-៧៧ | ១២-៥-៧៧ |
| ២៤២៩ | ធួក សួន ហៅ យ៉ន | ប្រធាននេសាទ | ពាណិជ្ជកម្ម | ១៧-២-៧៧ | ១២-៥-៧៧ |
| ២៤៣០ | ប្រុក ធឿន ហៅ ជុំ | អនុប្រធានមន្ទីរ | កងពល៣១០ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៤៣១ | សៀង ស៊ីផាន ហៅ និត | យុទ្ធជន | ព-៩៨ | ១៩-២-៧៧ | ១២-៥-៧៧ |
| ២៤៣២ | ធីវ យឿន | សមាជិកពេទ្យ | តំបន់១០៦ | ២-២-៧៧ | ១២-៥-៧៧ |
| ២៤៣៣ | ម៉ៅ ម៉េត ហៅ វ៉ន | អនុវរសេនាតូច | កងពល៣១០ | ១៩-២-៧៧ | ១២-៥-៧៧ |
| ២៤៣៤ | ចាប ធិន ហៅ សាម | លេខាវរសេនាតូច | កងពល៣១០ | ១៨-២-៧៧ | ១២-៥-៧៧ |
| ២៤៣៥ | សុក ហុន | យុទ្ធជន | កងពល៣១០ | ៨-១-៧៧ | ១២-៥-៧៧ |
| ២៤៣៦ | ឃួន ស៊ុយ ហៅ ស៊ឹម | យោធា | កងពល៣១០ | ២៤-២-៧៧ | ១២-៥-៧៧ |
| ២៤៣៧ | ព្រុំ សែឡេក | យុទ្ធជន | ពាណិជ្ជកម្ម | ១៦-១-៧៧ | ១២-៥-៧៧ |
| ២៤៣៨ | ម៉ម សូត្រ | អនុនយោបាយ | កងពល៣១០ | ២៩-២-៧៧ | ១២-៥-៧៧ |
| ២៤៣៩ | យឹម រោន ហៅ វ៉ាវ | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ១៦-១-៧៧ | ១២-៥-៧៧ |
| ២៤៤០ | ម៉ក់ សុខុម | កម្មករចាស់ | មន្ទីរស-៨ | ១-២-៧៧ | ១២-៥-៧៧ |
| ២៤៤១ | ហុង សៀក | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ១៥-២-៧៧ | ១២-៥-៧៧ |
| ២៤៤២ | សំ ឈឿន ហៅ ផេង | លេខាវរសេនាធំ | កងពល៣១០ | ១៩-២-៧៧ | ១២-៥-៧៧ |
| ២៤៤៣ | ជា មៀច ហៅ ចិត្ត | សមាជិក | រោងចក្រជ-៣ | ២៣-១-៧៧ | ១២-៥-៧៧ |
| ២៤៤៤ | ម៉ែន នីថូ ហៅ ជន | គណៈសាលា | សាធារណការ | ១-១-៧៧ | ១២-៥-៧៧ |
| ២៤៤៥ | ពេជ ម៉ាច | លេខាវរសេនាតូច | កងពល៣១០ | ២០-១-៧៧ | ១២-៥-៧៧ |
| ២៤៤៦ | ក្រូច រឿន | អនុប្រធានវ.ត | ផែកំពង់សោម | ?-១-៧៧ | ១២-៥-៧៧ |
| ២៤៤៧ | សួ សុខុន | លេខាវរសេនាតូច | កងពល៣១០ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៤៤៨ | ឈួន ស្រឿន ហៅ សែ | អនុវរសេនាតូច | កងពល៣១០ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៤៤៩ | ព្រុំ ឆួយ ហៅ ចិត្ត | យោធាវរសេនាតូច | កងពល៣១០ | ១៨-២-៧៧ | ១២-៥-៧៧ |
| ២៤៥០ | ញ៉ែម ថុល ហ វ៉ា (ស្រី) | ប្រពន្ធ ម៉េញ សាយ ហ កែវ | ពាណិជ្ជកម្មរដ្ឋ | ២៥-២-៧៧ | ១២-៥-៧៧ |
| ២៤៥១ | នូវ សុវណ្ណ ហៅ ម៉ែ (ស្រី) | យុទ្ធនារី | មន្ទីរក-១៦ | ៤-២-៧៧ | ១២-៥-៧៧ |
| ២៤៥២ | ជុំ ផល | កុមារ | មន្ទីរក-១៥ | ១-២-៧៧ | ១២-៥-៧៧ |
| ២៤៥៣ | សយ គឹមយាត ហៅ ភុំ (ស្រី) | ប្រពន្ធ លួន | កាត់ដេររដ្ឋ | ៧-២-៧៥ | ១២-៥-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៨៥៤ | តាន់ សុហួយ ហៅ ជាតិ (ស្រី) | ប្រពន្ធ ឆៃហេង | ការបរទេស | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៨៥៥ | ចាន់ ធឿន ហៅ ធីម (ស្រី) | អនុកងហ | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៨៥៦ | ជា ឡាំងហ៊ាង (ស្រី) | ប្រពន្ធ កែវ ផាត់ | កងពល៣១០ | ៧-២-៧៧ | ១២-៥-៧៧ |
| ២៨៥៧ | សុក សុខុម (ស្រី) | មេពួក | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៨៥៨ | ឌុច មាញ (ស្រី) | មេក្រុមកាត់ដេរ | សេនាធិការ | ១៣-១-៧៧ | ១២-៥-៧៧ |
| ២៨៥៩ | ចាប ខុំ (ស្រី) | ពេទ្យឃុំញាយ | ភូមិភាគបស្ចិម | ៣-១-៧៧ | ១២-៥-៧៧ |
| ២៨៦០ | ចឹក យន់ ហៅ អែម (ស្រី) | ប្រធាននារីមន្ទីរ | មន្ទីរក-៩ | ៦-២-៧៧ | ១២-៥-៧៧ |
| ២៨៦១ | ឈួន ធត ហៅ រី (ស្រី) | ពេទ្យ | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៨៦២ | អេង គីមឡេង ហៅ ណាត (ស្រី) | សមាជិកមន្ទីរ | ក្រសួងការបរទេស | ៣-២-៧៧ | ១២-៥-៧៧ |
| ២៨៦៣ | ឈុន លុន | យុទ្ធជន | រោងចក្រអ-៣ | ៣-១-៧៧ | ១២-៥-៧៧ |
| ២៨៦៤ | ឃួន សាន ហៅ វឿន | លេខាកងធំទី៣ | ពាណិជ្ជកម្មរដ្ឋ | ៦-២-៧៧ | ១២-៥-៧៧ |
| ២៨៦៥ | កាន់ សុខា ហៅ ជ្រូក | យុទ្ធជន | រោងចក្រអ-៣ | ២៤-១-៧៧ | ១២-៥-៧៧ |
| ២៨៦៦ | ណែម យុន ហៅ ពាន់ | អនុក្រុម | ពាណិជ្ជកម្មរដ្ឋ | ២៥-១-៧៧ | ១២-៥-៧៧ |
| ២៨៦៧ | ឡុង សុខា ហៅ ប៊ុន | ផ្ញើបញ្ញី | ពាណិជ្ជកម្មរដ្ឋ | ២១-២-៧៧ | ១២-៥-៧៧ |
| ២៨៦៨ | ឡុយ លឿន ហៅ ឡុម | យុទ្ធជន | តំបន់១០៦ | ?-២-៧៧ | ១២-៥-៧៧ |
| ២៨៦៩ | គីម ប្រាក់ ហៅ ចាន់ | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៨៧០ | ឈិន ជត | យុទ្ធជន | កសិកម្មរដ្ឋ | ៨-១-៧៧ | ១២-៥-៧៧ |
| ២៨៧១ | យើ ម៉ាត់ ហៅ ឆន | សមាជិកកងរយ | ស-២១ | ២២-២-៧៧ | ១២-៥-៧៧ |
| ២៨៧២ | សុក ផាន់ ហៅ វុធ | និរសារ | តំបន់១០៦ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៨៧៣ | សំ សៀង | យុទ្ធជន | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៨៧៤ | អ៊ុម ម៉ាន់ ហៅ សាន | យុទ្ធជន | រោងចក្រមី | ២៥-១-៧៧ | ១២-៥-៧៧ |
| ២៨៧៥ | វ៉ាំង ស៊ីន | កុមារចោរព្រៃ | ពោធិសាត់ | ?-១-៧៧ | ១២-៥-៧៧ |
| ២៨៧៦ | សឹម ស៊ីន់ ហៅ សួន | យុទ្ធជន | ដែភ្នំពេញ | ៥-២-៧៧ | ១២-៥-៧៧ |
| ២៨៧៧ | នួន អេត | លេខាវរសេនាតូច | កងពល៣១០ | ២៥-២-៧៧ | ១២-៥-៧៧ |
| ២៨៧៨ | ឡឿ វ៉ន ហៅ វ៉ុម | មេក្រុម | ព-៩៨ | ៦-១-៧៧ | ១២-៥-៧៧ |
| ២៨៧៩ | លុន គីម ហៅ សារឿន | យោធាវរសេនាតូច | កងពល៣១០ | ២៤-២-៧៧ | ១២-៥-៧៧ |
| ២៨៨០ | ពាង វីរ ហៅ វង់ | មេពួក | កាត់ដេររដ្ឋ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៨៨១ | កាំ ដាន់យ៉ា ហៅ ដាំ | សមាជិករណសិរ្ស | ប៉េកាំង | ២-១-៧៧ | ១២-៥-៧៧ |
| ២៨៨២ | រស់ សូត្រ ហៅ សាវ៉ាត | យុទ្ធជន | មន្ទីរពិការ | ១-១-៧៧ | ១២-៥-៧៧ |
| ២៨៨៣ | ញ៉ែម ញាណ | លេខាវរសេនាតូច | កងពល៣១០ | ២៩-២-៧៧ | ១២-៥-៧៧ |
| ២៨៨៤ | នង គីម ហៅ កាំ | ជាងភ្លើង | រោងចក្រគ-៣ | ២៩-១-៧៧ | ១២-៥-៧៧ |

**(នៅមានត)**

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

**មាស សារិន**

**អតីតសិស្សថ្នាក់ទី២ទំនើបនៃវិទ្យាល័យយុវជន រាជសង្គមនិយមខ្មែរ និងជាកីឡាការិនីផ្នែកបាល់ទះ**

*រូបថតមួយសន្លឹកដែលថតនៅក្នុងឆ្នាំ១៩៦៥ គឺជារូបថតក្រុមគ្រួសាររបស់ មាស សារិន ថតនៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប ។ មនុស្សដែលនៅក្នុងរូបថតនេះគឺជាបងប្អូនបង្កើត បងប្អូនជីដូនមួយ និងមិត្តភក្តិម្តាយរបស់គាត់ ។ នៅក្នុងចំណោមមនុស្សដែលនៅរូបថតនេះអ្នកខ្លះស្លាប់ ខ្លះបាត់ខ្លួន និងខ្លះទៀតនៅរស់ ។ សារិន ជាអ្នកថែរក្សា រូបថតនេះទុករហូតមកដល់សព្វថ្ងៃ ។ រូបថតមួយសន្លឹកនេះធ្វើឲ្យ សារិន នឹកដល់អតីតកាលដែលធ្លាប់តែរស់នៅជួបជុំជាមួយឪពុកម្តាយនិងបងប្អូន ។ សារិន បានរំឭកអំពីជីវិតរបស់គាត់ថា ÷*

ខ្ញុំជាសិស្សថ្នាក់ទី២ទំនើបនៃវិទ្យាល័យយុវជនរាជសង្គមនិយមខ្មែរនៅទីក្រុងភ្នំពេញ ។ មុនឆ្នាំ១៩៧៥ ខ្ញុំប្រឡងជាប់សញ្ញាប័ត្រឌីប្លូម ។ កាលនោះខ្ញុំជាសិស្សនៅវិទ្យាល័យផងនិងជាកីឡាការិនីបាល់ទះផង ។ ខ្ញុំចូលចិត្តលេងកីឡាណាស់ ហើយក្រុមគ្រួសាររបស់ខ្ញុំក៏លើកទឹកចិត្តឲ្យខ្ញុំលេងកីឡាបាល់ទះនេះ ។ ខ្ញុំបានប្រកួតកីឡាប្រចាំទីក្រុងភ្នំពេញចំនួន២ដង ។ លើកទី១ខ្ញុំប្រកួតចាញ់សិស្សដែលមកពីសាលាកំពង់ត្រាចខេត្តកំពត លើកទី២ខ្ញុំទទួលបានចំណាត់ថ្នាក់លេខ២ទូទាំងប្រទេស ។ ក្រុមរបស់ខ្ញុំមានសមាជិក ១២នាក់ ។ ក្រោយមកខ្ញុំបានដកខ្លួនពីកីឡាពីព្រោះខ្ញុំគ្មានពេលវេលាគ្រប់គ្រាន់ទៅហ្វឹកហាត់ទេ ម្យ៉ាងទៀតខ្ញុំបានចូលបម្រើការងារជាអ្នកវាយអង្គុលីលេខនៅក្រុមហ៊ុនសេងថៃ ។

ប៉ាខ្ញុំជាអ្នកម៉ៅការសំណង់ ចំណែកម៉ាក់របស់ខ្ញុំជាអ្នកទិញ-លក់ក្រណាត់ជជុះ ។ ពេលខ្លះខ្ញុំទៅជួយប៉ានិងម៉ាក់ខ្ញុំ ។ ផ្ទះរបស់ខ្ញុំនៅក្បែរមាត់ទន្លេ បែរមុខទៅខាងកាស៊ីណូនៃទន្លេបួនមុខ ។ ខ្ញុំឃើញកងទ័ពរដ្ឋាភិបាលលន់លល់យ៉ាងច្រើនជិះឡាននិងម៉ូតូល្បាតតាមផ្លូវពុំមានដាច់ ។

នៅមុនក្រុងភ្នំពេញត្រូវកងទ័ពខ្មែរក្រហមកាន់កាប់ ខ្ញុំឃើញកងទ័ពរដ្ឋាភិបាលកាន់តែច្រើនយាមល្បាតនៅតាមផ្លូវ ។ សិស្ស



មាស សារិន (រូបទីបីពីស្តាំមកឆ្វេង) និងក្រុមគ្រួសារ ថតក្នុងឆ្នាំ១៩៦៥

និងនិស្សិតខ្លះត្រូវជាប់កំណែនយោធាដើម្បីចេញច្បាំងជាមួយនឹងទ័ពខ្មែរក្រហម ដែលវាយចូលកាន់តែកៀកទីក្រុងភ្នំពេញ ។ នៅថ្ងៃទី១៧ ខែមេសា កងទ័ពអាវខ្មៅបានដើរពាសពេញផ្លូវ ហើយប្រកាសដេញឲ្យប្រជាពលរដ្ឋទាំងអស់ចាកចេញពីផ្ទះសម្បែងជាបន្ទាន់ ព្រោះកងទ័ពអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកនៅពេលឆាប់ៗខាងមុខនេះ ។ ប៉ានិងម៉ាក់ខ្ញុំរៀបចំអីវ៉ាន់យ៉ាងរួសរាន់ ហើយហៅកូនៗទាំងអស់ដើម្បីប្រញាប់ចាកចេញពីផ្ទះព្រោះកងទ័ពខ្មែរក្រហម២នាក់ដែលស្លៀកសម្លៀកបំពាក់ខ្មៅស្រែកគំរាមដាក់ប៉ាម៉ាក់ថា "យ៉ាងម៉េច នៅស្តាយអ៊ីខ្លះ? ចង់ត្រូវគ្រាប់ឬ យ៉ាងម៉េច?" ។ ម៉ាក់ខ្ញុំស្ទើរតែគាំងបេះដូងដោយសារសម្រែកទាំងនោះ ម្យ៉ាងទៀតគាត់មានជំងឺខ្សោយបេះដូងផង ។ ក្រុមគ្រួសារខ្ញុំបានដាក់អីវ៉ាន់លើរទេះរុញហើយធ្វើដំណើរទៅទិសខាងត្បូង ។ ដោយសារតែមនុស្សម្នាច្រើនដេរដាស ក្រុមគ្រួសារខ្ញុំធ្វើដំណើរយឺតៗពេញមួយថ្ងៃទើបមកដល់ក្បាលថ្នល់ ។ កាលនោះគឺជាខែចេត្រ អាកាសធាតុក្តៅខ្លាំងណាស់ ប្អូនៗខ្ញុំស្រែកទាររកបាយទឹកហូប ធ្វើឲ្យការធ្វើដំណើររឹតតែយឺតមួយកម្រិតទៀត ។ នៅតាមផ្លូវឮសូរសំឡេងស្រែករកសាច់ញាតិបងប្អូនលាយឡំជាមួយសម្រែកបញ្ជារបស់កងទ័ពអាវខ្មៅ ។ ប៉ាម៉ាក់ខ្ញុំសួរទៅកងទ័ពអាវខ្មៅថា "តើឲ្យពួកខ្ញុំទៅណា?" កងទ័ពទាំងនោះ ឆ្លើយថា "ត្រូវតែចេញឲ្យផុតពីទីក្រុងភ្នំពេញ" ។ គ្រួសារខ្ញុំធ្វើដំណើរទៅដល់ភូមិកោះប្រាក់ ហើយស្នាក់នៅទីនោះរយៈពេល៤-៥ថ្ងៃដើម្បីរង់ចាំអង្គការជូនដំណឹងឲ្យចូលមករស់នៅក្នុងទីក្រុងវិញ ។ នៅតាមផ្លូវខ្ញុំចង់ត្រឡប់ទៅយកម៉ូតូរបស់ខ្ញុំដែលចតទុកនៅក្រោមផ្ទះ ប៉ុន្តែបងប្អូនខ្ញុំមិនឲ្យខ្ញុំត្រឡប់មកយកទេ ព្រោះខ្លាចបែកគ្នា ។

អង្គការបានជម្លៀសក្រុមគ្រួសារខ្ញុំទៅដល់ភូមិថ្មី ឃុំស្វាយពល ខេត្តព្រៃវែង ។ ការធ្វើដំណើរលើកំណាត់ផ្លូវដ៏វែងឆ្ងាយបានធ្វើឲ្យយើងអស់កម្លាំងយ៉ាងខ្លាំង ។ យើងស្ទើរតែរកអ្វីហូបមិនបាន ។ ប៉ាម៉ាក់ខ្ញុំយករបស់របរមានតម្លៃទៅដោះដូរយកស្បៀងអាហារជាបន្តបន្ទាប់ ។ បងស្រីខ្ញុំឈ្មោះ ចៅគាយ រើសបានមាសមួយកញ្ចប់ពីមាត់ច្រាំងទន្លេ ។ ២-៣ថ្ងៃក្រោយមកគាត់មកសុំលាម៉ាក់ខ្ញុំថាគាត់ទៅរស់នៅស្រុកកំណើតខាងប្តីរបស់គាត់នៅព្រៃក្មេង ។ ខ្ញុំមិនដឹងថាព្រៃក្មេងនោះនៅទីណាទេ ។ គាត់ក៏បាត់ខ្លួនតាំងពីពេលនោះមករហូត ។ យើងរស់នៅប្រមូលផ្តុំតាមកង ក្រោមការមើលខុសត្រូវរបស់ប្រជាជនមូលដ្ឋាន ។ ចាស់ៗនិយាយថាពេលនេះជាពេលដែលពុទ្ធទំនាយថា "មានផ្ទះអត់មនុស្សនៅ មានផ្លូវអត់មនុស្សដើរ" ។ ប្រជាជនមូលដ្ឋានជាអ្នកប្រាប់យើងពីពេលវេលាធ្វើការងារ ។ បងប្អូនខ្ញុំខ្លះចូលក្រុមយុវជន ប្អូនតូចៗចូលក្នុងកងចល័តកុមារ ចំណែកខ្ញុំត្រូវអង្គការចាត់តាំងឲ្យខ្ញុំធ្វើការជាមួយក្រុមមីងៗ ដាំបន្លែ និង រកបន្លែសម្រាប់ផ្ទះបាយរួម ។ ខ្ញុំប្រឹងប្រែងធ្វើការទាំងយប់ទាំងថ្ងៃស្ទើរគ្មានពេលសម្រាក ។

ពេលមួយ ប្អូនប្រុសខ្ញុំម្នាក់ឈ្មោះ មាស ស៊ីសុផុន មានជំងឺមិនអាចទៅធ្វើការងារបាន ។ ប្អូនខ្ញុំសុំអនុញ្ញាតពីប្រធានក្រុមដើម្បីសម្រាកនៅផ្ទះ ប៉ុន្តែប្រធានក្រុមមិនយល់ព្រម ហើយដេញឲ្យប្អូនខ្ញុំទៅសម្រាកនៅមន្ទីរពេទ្យ ។ សុផុន រងាញាក់ គ្មានកម្លាំងកំហែងដើរទៅមន្ទីរពេទ្យដោយខ្លួនឯងបានទេ ឈ្លបក៏យករទេះគោមកដឹក ។ ប៉ាម៉ាក់ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង ។ គាត់ទាំងពីរចង់នៅមើលថែរក្សាប្អូនខ្ញុំណាស់ ប៉ុន្តែអង្គការបានហៅគាត់ទាំងពីរទៅណែនាំថា "បើកូនឈឺគឺមានអង្គការជាអ្នកមើលថែទាំ ហើយមិនចាំបាច់មានឪពុកម្តាយមើលខុសត្រូវទេ អង្គការនេះហើយជាឪពុកម្តាយ" ។ ប៉ាម៉ាក់ខ្ញុំមានតែលើកដៃសំពះសុំទោសប៉ុណ្ណោះ ។ ប្អូនប្រុសរបស់ខ្ញុំពីរនាក់ទៀតគឺ ស៊ីសុផុន និង ដារ៉ា ត្រូវប្រធានក្រុមស្តីបន្ទោសជាញឹកញាប់ ពីព្រោះវារត់ចោលកងចល័តមករកប៉ាម៉ាក់ខ្ញុំជារឿយៗ ។ ប្អូនខ្ញុំពីរនាក់ទៀត គឺ ស៊ីថា និង បណ្ណាកា ក៏ខ្ជិលច្រអូសចំពោះការងារដែលអង្គការដាក់ឲ្យធ្វើប្រចាំថ្ងៃ ។ ប្រធានក្រុមហៅប៉ាម៉ាក់ខ្ញុំទៅអប់រំជាបន្តបន្ទាប់ ហើយបានមកស្តីបន្ទោសឲ្យខ្ញុំថាជាបងគេតែមិនចេះមើលអប់រំប្អូនទេ និងចោទប្រកាន់ប្អូនខ្ញុំថាមានពុតត្បុត ។

ក្រុមគ្រួសារខ្ញុំរស់នៅទីនោះមានការខ្វះខាតអាហារបរិភោគជាខ្លាំង សុខភាពធ្លាក់ចុះទ្រុឌទ្រោម និងស្គមស្គាំងស្ទើរមើលរូបមិនយល់ ។ ខ្លួនប្រាណរបស់យើងប្រឡាក់ស្រមេកស្រមកព្រោះគ្មានសាប៊ូសម្រាប់ដុសសម្អាតខ្លួន ។ ប្រជាជនមូលដ្ឋានប្រាប់យើងឲ្យយកដើមជ្រៃហាលឲ្យស្ងួតរួចយកទៅដុតយកផេះលាយទឹកធ្វើជាទឹកក្បុងសម្រាប់ដុសខ្លួន ។

នៅឆ្នាំ១៩៧៦ អង្គការបានផ្លាស់ក្រុមគ្រួសារខ្ញុំទៅរស់នៅស្រុកអូររាំងឪ ។ ពេលនោះប៉ាកំពុងតែឈឺ ។ ម៉ាក់បានអង្វរអង្គការសុំពន្យារពេល៣-៤ថ្ងៃទម្រាំតែប៉ាជាពីជំងឺសិន ប៉ុន្តែអង្គការមិនអនុញ្ញាត ។ នៅខែសីហា ឆ្នាំ១៩៧៦ ប៉ាបានស្លាប់បាត់បង់ជីវិតនៅមន្ទីរពេទ្យអូររាំងឪ ។ ពេលនោះយើងគ្មានអ្វីរុំសាកសពប៉ាទេ មានតែកន្ទេលពោះគោមួយដែលខ្ញុំដណ្តប់ជារៀងរាល់យប់យកទៅរុំ ហើយឈ្លបក៏លីសាកសពប៉ាតម្រង់ទៅព្រៃខាងកើតវាលស្រែ ។ ក្រោយពេលប៉ាស្លាប់ទៅក្រុមគ្រួសារខ្ញុំបាត់បង់ទីពំនឹង ប្អូនៗខ្ញុំធ្លាក់ខ្លួនឈឺជាបន្តបន្ទាប់ ។

នៅរដូវទឹកឡើង អង្គការមានផែនការឲ្យប្រជាជន១៧មេសានៅភូមិថ្មីប្តូរទីតាំងទៅរស់នៅខេត្តក្រចេះ ។ ក្រុមគ្រួសារខ្ញុំធ្វើដំណើរតាមកប៉ាល់ដោយសប្បាយរីករាយ ព្រោះយើងបានសម្រាកពេញមួយថ្ងៃពីការងារសហករណ៍ ។ យើងស្រូបយកខ្យល់អាកាសតាមដងទន្លេ ។ ពេលនោះខ្ញុំនឹកស្រមៃដល់មេរៀនដែលធ្លាប់រៀននៅក្នុងថ្នាក់អំពីភូមិសាស្ត្រប្រទេសកម្ពុជា ដែលមានផ្លូវទឹកហូរកាត់ខាត់ខ្វែងពេញផ្ទៃប្រទេស ។ ក្នុងគំនិតខ្ញុំផ្ទាល់ ខ្ញុំមិនសូវចូលចិត្តខេត្តក្រចេះទេ ព្រោះវាជាខេត្តមួយដែលក្រីក្រ ហើយមានជនជាតិភាគតិចរស់នៅច្រើន ។ នៅតាមដងផ្លូវខ្ញុំដណ្តឹងសួរខ្លួនឯងថា តើខេត្តក្រចេះនៅទីណា? ពេលដែលខ្ញុំទៅរស់នៅទីនោះតើជួបមនុស្សល្អឬមនុស្សអាក្រក់? កប៉ាល់បានចូលចតនៅមុខវត្តក្រគរ ហើយអង្គការបែងចែកប្រជាជនជម្លៀសទៅតាមទីកន្លែងផ្សេងៗគ្នា ។ ក្រុមគ្រួសារខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅក្រុមសាមគ្គីភូមិដូនមាស ស្រុកសម្បូណ៌ ចម្ងាយប្រមាណ៤០គីឡូម៉ែត្រ ពីទីរួមខេត្តក្រចេះ ។ នៅទីនោះ សំបូរទៅដោយត្រីគ្រប់ប្រភេទសម្រាប់ធ្វើម្ហូប ។ ខ្ញុំស្ទូងស្រូវនិងធ្វើត្រីប្រហុកសម្រាប់យុទ្ធជន យុទ្ធនារីនៅសមរភូមិមុខ ចំណែកម្តាយរបស់ខ្ញុំស្ទូងស្រូវនៅការដ្ឋាន ។ ប្អូនៗខ្ញុំធ្វើការនៅក្នុងកងចល័តលើកទំនប់និងជីកប្រឡាយឆ្ងាយពីភូមិ ។

អង្គការហៅប្រជាជនទៅប្រជុំក្នុង១ខែ៣ដង គឺនៅថ្ងៃទី១០ ថ្ងៃទី២០ និងថ្ងៃទី៣០ ។ នៅកន្លែងអង្គប្រជុំមានបិទពាក្យស្លោកថា ÷ “ជយោ! បដិវត្តន៍កម្ពុជាដ៏រុងរឿង” “ជយោ! លត់ដំកសាងខ្លួនជាជនបដិវត្តន៍ឆ្អិនឆ្អៅ” “ប្តេជ្ញាបង្កបង្កើនផលដើម្បីបដិវត្តន៍ដ៏មហារុងរឿង និងកម្មាត់សត្រូវផ្ទៃក្នុងកសាងវណ្ណៈអធនជាប់ជានិច្ច” ។ នៅពេលប្រជុំធំចប់ ប្រធានក្រុមបានហៅសមាជិកឲ្យទៅប្រជុំជាក្រុមតូចៗ ទិតៀននិងស្វ័យតិទៀនគ្នាដើម្បីធ្វើឲ្យការងារបង្កបង្កើនផលរីកចម្រើនថែមទៀត ។

ក្រោយប៉ាអនិច្ចកម្មទៅ ប្អូនប្រុសខ្ញុំម្នាក់ឈ្មោះ ស៊ីសុផុន ធ្លាក់ខ្លួនឈឺជាប្រចាំ ។ វាចេះតែឈឺក្នុងទ្រូង ប្រហែលជាវារែកដីធ្ងន់ពេកក៏មិនដឹង ។ ជំងឺរបស់ប្អូនខ្ញុំកាន់តែធ្ងន់ធ្ងរទៅៗ ហើយគ្មានថ្នាំព្យាបាលទៀត រហូតដល់ប្អូនខ្ញុំបាត់បង់ជីវិត ។ ខ្ញុំឆែកឃើញនៅក្នុងបង្វេចខោអាវរបស់ប្អូនខ្ញុំមានអត្តសញ្ញាណប័ណ្ណសិស្សមួយសន្លឹកនិងសៀវភៅមួយក្បាល ។ វារក្សាទុកនៅពេលណាវាមានឱកាសបានចូលរៀនវិញ វានឹងបង្ហាញគ្រូដើម្បីសុំចូលរៀនបន្ត ។ ពេលប្អូនខ្ញុំស្លាប់ ម៉ាក់របស់ខ្ញុំរឹតតែពិបាកចិត្តខ្លាំងឡើងៗ ប៉ុន្តែគាត់មិនអាចជួយអ្វីដល់ប្អូនខ្ញុំបានទេ ចំណែកប្អូនៗខ្ញុំផ្សេងទៀត១០-២០ថ្ងៃទើបបានជួបមុខគ្នាម្តង ហើយក្នុងរយៈពេលខ្លីទៀតផង ។

នៅឆ្នាំ១៩៧៨ មានការផ្លាស់ប្តូរគណៈសហករណ៍ជាច្រើននាក់ ។ មិត្តបែត ត្រូវចាប់ខ្លួនពីបទខុសសីលធម៌ ពីព្រោះគាត់មានគ្រួសារហើយនៅតែយកប្រពន្ធថែមទៀតដែលជាមិត្តនារីនៅក្នុងជួរបដិវត្តន៍ ។ ចំណែកសមមិត្ត ឈូក ក៏ត្រូវអង្គការចាប់ខ្លួនដែរ ដោយចោទប្រកាន់ថាក្បត់ ហើយយកកម្មាភិបាលពីភូមិភាគឧត្តរមកជំនួសវិញ ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំឮសូរគ្រាប់កាំភ្លើងពីទិសខាងកើត ។ ប្រជាជនដែលលួចស្តាប់វិទ្យុបានខ្សឹបខ្សៀវគ្នាថា មានចលនារណសិរ្សជាតិមកពីខាងស្រុកស្នួលដែលមានចម្ងាយ៨០គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ។ ពេលនោះគណៈសហករណ៍និងកម្មាភិបាលខ្មែរក្រហមកាន់តែរឹតបន្តឹងអង្គការវិន័យនៅក្នុងសហករណ៍ ។ ការសម្លាប់មនុស្សក៏កាន់តែច្រើនឡើងៗ ។ ខ្ញុំបានប្រាប់ប្អូនៗខ្ញុំឲ្យប្រុងប្រយ័ត្នជាប់ជានិច្ចកុំឲ្យធ្វើខុសពីការណែនាំរបស់អង្គការដើម្បីរក្សាជីវិតឲ្យរស់ ។ គ្រាប់កាំភ្លើងឮកាន់តែជិតឡើងៗ ។ កម្មាភិបាលខ្មែរក្រហមកៀរប្រជាជនឲ្យធ្វើដំណើរឆ្លងទន្លេឆ្ពោះទៅកោះរងាវ ។ ខ្ញុំលួចបន់ស្រន់សូមឲ្យអ្នកស្នេហាជាតិរំដោះប្រទេសឲ្យមានសេរីភាព ។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ ខ្ញុំឮសំឡេង

មេក្រុលើយៗថា ខេត្តក្រចេះត្រូវបានរំដោះហើយ សូមបងប្អូនត្រឡប់ទៅភូមិកំណើតវិញ ។ សំឡេងទាំងនេះបានធ្វើឲ្យប្រជាជនមានចិត្តសប្បាយត្រេកអរ ហើយហ៊ោកញ្ជ្រៀវកងរំពង ។ ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរមកដល់ផ្លូវជាតិ ។ ភាពអនាធិបតេយ្យបានកើតមានឡើង ប្រជាជននាំគ្នាដណ្តើមអង្ករពីជង្រុករួម ។ ខ្ញុំដណ្តើមបានមេគោពីរក្បាល ហើយរកបានរទេះចាស់មួយឲ្យម៉ាក់ខ្ញុំសម្រាកនៅលើនោះ ។ ខ្ញុំរកបានប្រហុកផ្អកខ្លះពីផ្ទះបាយរួមសម្រាប់ទុកហូបតាមផ្លូវ ។

៣-៤ថ្ងៃក្រោយមកខ្ញុំរកឃើញប្អូនខ្ញុំទាំងអស់ លើកលែងតែបងស្រីខ្ញុំម្នាក់ឈ្មោះ ប៉ោតាយ ដែលបាត់ខ្លួន និងស្លាប់ប្អូនប្រុសម្នាក់ឈ្មោះ ស៊ីសុផុន ។ ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរដោយថ្មើរជើងមកដល់ជាយទីរួមខេត្តក្រចេះ ប៉ុន្តែមិនអាចចូលទីរួមខេត្តបានទេ ព្រោះកងទ័ពវៀតណាមិនអនុញ្ញាត ។ ពេលនោះម៉ាក់ខ្ញុំមានជំងឺហើមជើង ។ ដោយជើងរបស់គាត់មិនទាន់ជាសះស្បើយ គាត់ត្រូវស្វែងរកគ្រូពេទ្យខ្មែរព្យាបាល ។ ក្នុងរយៈពេលព្យាបាលជើងម៉ាក់និងវង់ចាំវិលចូលទីក្រុងភ្នំពេញ ខ្ញុំបានសុំចូលធ្វើការនៅមន្ទីរឃោសនាការខេត្ត ក្នុងភារកិច្ចជាអ្នកវាយអង្គុលីលេខ ។ ចំណែកប្អូនៗខ្ញុំក៏បានចូលបម្រើការងារនៅមន្ទីរនៅតាមមន្ទីរផ្សេងៗនៅទីរួមខេត្តក្រចេះដែរ ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៩ ខ្ញុំបានរៀបការជាមួយអតីតគ្រូបង្រៀនម្នាក់ ។ ពិធីរៀបការរបស់ខ្ញុំ ប្រព្រឹត្តទៅយ៉ាងអធិកអធមតាមទំនៀមទម្លាប់ខ្មែរ ក្រុមគ្រួសារខ្ញុំ ក៏បន្តរស់នៅទីនោះរហូតដល់សព្វថ្ងៃ ។ ◆◆◆

## ទុន ឈុំ

## អតីតវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យព្រះកេតុមាលា

រូបថតក្រុមគ្រួសាររបស់ ទុន ឈុំ មួយសន្លឹកនេះ ស្ទើរតែបាត់បង់នៅក្នុងរបបខ្មែរក្រហម ដោយសារឈ្លបមកឆែកឆេរផ្ទះរបស់គាត់ពេលគាត់ចេញទៅធ្វើការនៅការដ្ឋាន ។ ក្រោយពីរបបខ្មែរក្រហមដួលរលំ រូបថតនេះ ត្រូវបានប្រពន្ធរបស់គាត់នៅសហរដ្ឋអាមេរិកជាអ្នករក្សាទុក ។ ឈុំ បានផ្តាំឲ្យប្រពន្ធរបស់គាត់ផ្ញើរូបថតនេះមកវិញ ។ ពេលឃើញរូបថតនេះ ឈុំ នឹកឃើញដល់កូនរបស់គាត់ដែលស្លាប់នៅក្នុងរបបខ្មែរក្រហម នឹកឃើញដល់ទុក្ខលំបាកដែលក្រុមគ្រួសារគាត់ត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ និងការលំបាកដែលក្រុមគ្រួសារគាត់ឆ្លងកាត់ ។ គាត់មានបំណងចែករំលែកបទពិសោធន៍ដែលគាត់ធ្លាប់បានឆ្លងកាត់សម័យនោះដើម្បីចងក្រងទុកជាឯកសារ ។ រឿងរ៉ាវរបស់ ឈុំ មានដូចតទៅ ÷

ខ្ញុំជាកូនកសិករក្រនៅស្រុកបាទី ខេត្តតាកែវ ។ តាំងពីក្មេងខ្ញុំបានទៅរៀនអក្សរសាស្ត្រនៅវត្តជាមួយបងប្រុសខ្ញុំម្នាក់ឈ្មោះ ឆន ដែលបួសនៅវត្តប្រាសាទនាងខ្មៅ ស្រុកសំរោង ។ កាលណោះ ខ្ញុំរៀននៅតាមកុដិលោក ពីព្រោះអត់ទាន់មានសាលារៀនត្រឹមត្រូវទេ ។ នៅឆ្នាំ១៩៥៩ ខ្ញុំចូលរៀននៅអនុវិទ្យាល័យតាកែវ ។ ផ្ទះខ្ញុំនៅឆ្ងាយពីសាលារៀន ដូច្នេះខ្ញុំត្រូវជួលផ្ទះស្នាក់នៅ ។ មួយសប្តាហ៍ទើបខ្ញុំមកផ្ទះម្តងដើម្បីយកអង្ករនិងម្ហូបអាហារខ្លះទុកសម្រាប់ហូប ។ នៅឆ្នាំ១៩៦២ ខ្ញុំទៅប្រឡងជាប់សញ្ញាបត្រឌីប្លូមនៅខេត្តកំពត ។

មួយឆ្នាំក្រោយមក ខ្ញុំបានដាក់ពាក្យចូលរៀនផ្នែកសុខាភិបាល ។ ខ្ញុំគ្មានចំណង់ចំណូលចិត្តខាងផ្នែកនេះទេ ប៉ុន្តែដោយសារតែពិបាករកការងារធ្វើពេកខ្ញុំក៏ដាក់ពាក្យប្រឡងជាច្រើនផ្នែក ។ ខ្ញុំប្រឡងជាប់ពេទ្យហើយរៀនរយៈពេល៣ឆ្នាំ ។ ពេលខ្ញុំរៀនចប់ខាងក្រសួងសុខាភិបាលចាត់តាំងខ្ញុំឲ្យទៅធ្វើការនៅខេត្តកំពត ។

នៅឆ្នាំ១៩៦៥ ខ្ញុំរៀបការជាមួយនារីម្នាក់ឈ្មោះ ហេង សារ៉ាង ។ ខ្ញុំស្គាល់ប្រពន្ធខ្ញុំដោយសារតែខ្ញុំជួលផ្ទះបងរបស់គាត់ស្នាក់នៅពេលដែលខ្ញុំកំពុងរៀនពេទ្យ ។ ក្រោយពីខ្ញុំរៀបការហើយ ខ្ញុំក៏នាំប្រពន្ធខ្ញុំទៅរស់នៅខេត្តកំពតជាមួយខ្ញុំ ។ ខ្ញុំធ្វើការនៅទីនោះបានរយៈពេល២ឆ្នាំ ក៏ផ្លាស់មកធ្វើការនៅពេទ្យព្រះកេតុមាលានៅទីក្រុងភ្នំពេញ ។ នៅភ្នំពេញខ្ញុំរកលុយបានច្រើនជាងនៅខេត្តកំពត ។ ខ្ញុំធ្វើការនៅភ្នំពេញ ប៉ុន្តែខ្ញុំរស់នៅជាមួយម្តាយក្មេកខ្ញុំនៅឃុំកន្ទួត ខេត្តកណ្តាល ។ ព្រលឹមឡើងខ្ញុំបើកឡានមកធ្វើការនៅភ្នំពេញ ពេលល្ងាចទើបខ្ញុំបើកឡានត្រឡប់ទៅវិញ ។

នៅមន្ទីរពេទ្យ ខ្ញុំធ្វើការខាងផ្នែកអប់រំសុខភាពនិងផ្គត់ផ្គង់ចំណីអាហារដល់កុមារដែលខ្វះជីវជាតិ ។ ខ្ញុំបានចុះអប់រំប្រជាជនឲ្យយល់ដឹងពីការថែទាំកុមារឲ្យមានសុខភាពល្អ ។ ពេលខ្លះខ្ញុំទៅធ្វើការនៅខេត្តកណ្តាលនិងខេត្តកំពង់ស្ពឺ ។

ពេលដែលមានការប្រយុទ្ធគ្នាខ្លាំងនៅកន្ទោតរវាងទាហាន

លន់ នល់ និងកងទ័ពខ្មែរក្រហម គ្រួសារខ្ញុំក៏បានប្តូរមកក្រុងភ្នំពេញ នៅផ្ទះបងថ្លៃដែលនៅក្បែរពោធិចិនតុង ។ អំឡុងពេលខ្ញុំធ្វើការ ប្រាក់ខែខ្ញុំឡើងជាបន្តបន្ទាប់ ប៉ុន្តែមិនបានច្រើនទេ ។ ខ្ញុំអាចរក កម្រៃខាងក្រៅបានខ្លះ ពីព្រោះខ្ញុំអាចព្យាបាលជំងឺនៅតាមផ្ទះ ប៉ុន្តែពេលនោះទំនិញឡើងថ្លៃ ដូច្នេះខ្ញុំនៅតែខ្វះខាត ។ មាស ឡើងថ្លៃមួយទ្វេជាពីរ ។ ពេលខ្លះខ្ញុំចង់ទៅលេង ស្រុកកំណើតក៏ពិបាកដែរ ។

នៅពេលដែលខ្មែរ ក្រហមជម្លៀសប្រជាជន ចេញពីទីក្រុងភ្នំពេញ ខ្ញុំមិន បានយកឡានទៅជាមួយ ទេ ។ ក្រុមគ្រួសារខ្ញុំធ្វើ ដំណើរដោយថ្មើរជើង ។ កងទ័ពខ្មែរក្រហមបញ្ជាឲ្យ ចេញជាប្រញាប់ ។ ខ្ញុំយក បានខោអាវបន្តិចបន្តួច ប្រកថង់ យកអង្ករ និងម្ហូប ក្រៀមខ្លះ ។ រយៈពេល មួយថ្ងៃ យើងធ្វើដំណើរ ទៅដល់វត្តទឹកថ្លា ។ ស្អែក ឡើង យើងធ្វើដំណើរបន្ត ទៅតាមផ្លូវវត្តសំរោង-អណ្តែតឆ្ពោះទៅព្រែក-ព្នៅ ។ ក្រុមគ្រួសារខ្ញុំសម្រាកនៅទីនោះ រយៈពេល៥យប់ ហើយ បន្តដំណើរទៅដល់ភូមិមួយនៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកំពង់ស្ពឺ ។ ប្រជាជនមូលដ្ឋានយករទេះគោមកទទួលយើង ដែលជាប្រជាជន ជម្លៀសចេញពីភ្នំពេញ ហើយអបអរសាទរ ។ បន្ទាប់មក អង្គការ ចាប់ផ្តើមធ្វើជីវប្រវត្តិប្រជាជនថ្មីទាំងអស់ដោយឲ្យតម្រង់ជួរ សួរអំពីប្រវត្តិរូបម្នាក់ៗ និងសួរអំពីរបស់របរដែលយកមកពី ទីក្រុង ។ អង្គការដកយករបស់របរទាំងអស់ទៅដាក់រួម ហើយ ចែកខោអាវខ្មៅឲ្យយើងវិញ ។ អង្គការបានដាក់ទិសឲ្យប្រជាជន ជម្លៀសដែលទើបមកដល់ត្រូវធ្វើផ្ទះឲ្យហើយក្នុងរយៈពេល៥ថ្ងៃ ។ ខ្ញុំចូលព្រៃកាប់ឈើមកធ្វើសសរ រកស្លឹកត្នោតមកធ្វើដំបូលនិង យកឫស្សីមកធ្វើជារនាបផ្ទះ ។ ៥ថ្ងៃក្រោយមកខ្ញុំធ្វើបានកូនខ្ទម មួយសម្រាប់ក្រុមគ្រួសារខ្ញុំ ។ អង្គការសួរខ្ញុំថា "តើខ្ញុំអាចធ្វើអ្វីបាន ខ្លះ?" ខ្ញុំឆ្លើយថា "ខ្ញុំអាចធ្វើការងារពលកម្មបានទាំងអស់" ។ ខ្ញុំចេះ ឈូសឈើធ្វើកីតម្បាញ ពីព្រោះខ្ញុំធ្លាប់នៅជាមួយ ឪពុកម្តាយខ្ញុំធ្វើការនៅ ឯស្រែ ។ អង្គការបាន ចាត់តាំងខ្ញុំឲ្យធ្វើត្បាល់កិន ស្រូវ ។ ដោយសារខ្ញុំធ្វើ បានសម្រេច អង្គការចាត់ តាំងឲ្យខ្ញុំចូលធ្វើការនៅ ក្នុងសហករណ៍ និងទទួល ខុសត្រូវធ្វើកីតម្បាញ ។ ចំណែកប្រពន្ធរបស់ខ្ញុំ អង្គការចាត់តាំងឲ្យធ្វើស្រែ និងជីកប្រឡាយទឹក ។ បន្ទាប់មក អង្គការមានការ សង្ស័យលើខ្ញុំ ក៏ហៅខ្ញុំទៅ ធ្វើជីវប្រវត្តិ ។ ខ្ញុំប្រាប់ថា ពីមុនខ្ញុំធ្វើជាជាងឈើនៅ ក្នុងមន្ទីរពេទ្យ ។ អង្គការ ផ្លាស់ឲ្យខ្ញុំធ្វើការងារបន្ត បន្ទាប់ជាច្រើនផ្នែកទៀតដូចជាធ្វើរហាត់ទឹក កីតម្បាញ នង្គ័ល និងរនាស់ ។



ទុន ឈុំ ជាមួយប្រពន្ធនិងកូនទាំងបួន

នៅចុងឆ្នាំ១៩៧៥ កូនខ្ញុំម្នាក់ស្លាប់ដោយសារខ្វះអាហារ និងជំងឺ ។ ទោះបីជាខ្ញុំចេះព្យាបាលក៏ដោយ ខ្ញុំគ្មានថ្នាំពេទ្យនិង ឧបករណ៍គ្រប់គ្រាន់សម្រាប់ព្យាបាលទេ ហើយម្យ៉ាងទៀត អង្គការមិនអនុញ្ញាតឲ្យកូនខ្ញុំសម្រាកនៅផ្ទះផង គឺតម្រូវឲ្យខ្ញុំយក កូនខ្ញុំទៅមន្ទីរពេទ្យ ។ នៅមន្ទីរពេទ្យ កម្មាភិបាលពេទ្យមិនបានយក ចិត្តទុកដាក់មើលព្យាបាលកូនខ្ញុំឲ្យបានដិតដល់ទេ ។ កូនខ្ញុំស្លាប់នៅ

ក្នុងមន្ទីរពេទ្យ ។

មានពេលមួយអង្គការបានចាត់តាំងខ្ញុំឲ្យទៅកាប់បង្គោលនៅស្រុកឳរ៉ាល់ ។ ពីមុនមកខ្ញុំកត់សម្គាល់ឃើញថា អ្នកដែលត្រូវអង្គការហៅទៅកាប់បង្គោលគឺទៅរហូតមិនដែលឃើញត្រឡប់មកវិញទេ ។ ឥឡូវនេះដល់វេនខ្លួនឯង ខ្ញុំភ័យខ្លាំងណាស់ ។ ខ្ញុំបានត្រៀមកាំបិត ពូថៅ ហើយបររទេះគោចេញទៅ ។ មុនពេលទៅខ្ញុំដាំបន្លែជាច្រើននៅជុំវិញផ្ទះ ។ ពេលខ្ញុំមិននៅផ្ទះ ប្រពន្ធរបស់ខ្ញុំបានលួចបេះល្ពៅមួយមកស្ងោឲ្យកូនហូប ។ អង្គការឃើញក៏ចាប់ទាំងប្រពន្ធទាំងកូនខ្ញុំយកទៅដាក់នៅមន្ទីរឃុំ ។ អង្គការចោទប្រពន្ធខ្ញុំថាលួចបេះបន្លែសមូហភាព ។ បើទោះបីជាបន្លែនេះខ្ញុំជាអ្នកដាំនៅក្នុងដីផ្ទះខ្ញុំក៏ដោយ ក៏ប្រពន្ធខ្ញុំគ្មានសិទ្ធិបេះវាហូបដែរ ។ នៅឯការដ្ឋានកាប់បង្គោលខ្ញុំក៏មានកំហុសដែរ ដោយសារខ្ញុំឃ្លានពេក ខ្ញុំបានលួចដឹកដំឡូងយកមកដុតហូប ។ ពេលកំពុងដុតដំឡូងឈ្លបមកទាន់ឃើញ ខ្ញុំអង្គុយនៅមុខភ្លុក់ភ្លើង ។ ឈ្លបផាក់ខ្ញុំដួលនៅនឹងកន្លែង ចាប់ខ្ញុំចងបណ្តើរយកទៅមន្ទីរឃុំ ហើយឃុំខ្លួនខ្ញុំមួយយប់ជាមួយអ្នកទោសដទៃទៀតដែលទៅកាប់បង្គោលជាមួយគ្នា ។ មួយថ្ងៃក្រោយមកអង្គការដោះលែងខ្ញុំវិញ ដោយសារអ្នកនៅផ្ទះក្បែរខ្ញុំឈ្មោះ ម៉ាង ទៅអង្វរអង្គការ ។ ចំណែកអ្នកទោសផ្សេងទៀតដែលជាប់ជាមួយខ្ញុំត្រូវអង្គការយកទៅបាត់មិនដឹងទៅទីណា ។ ពេលខ្ញុំត្រឡប់មកផ្ទះវិញ អ្នកជិតខាងបានប្រាប់ខ្ញុំពីរឿងប្រពន្ធកូនរបស់ខ្ញុំដែលត្រូវអង្គការចាប់ខ្លួន ។ ដោយមានប្រជាជនមូលដ្ឋានជួយសុំអង្វរទើបអង្គការដោះលែងប្រពន្ធនិងកូនខ្ញុំមកវិញ ។

នៅខែតុលា ឆ្នាំ១៩៧៥ អង្គការមានផែនការផ្លាស់ទីលំនៅប្រជាជនថ្មី ។ ស្ត្រីម្នាក់បានសុំអង្វរឈ្លបសុំរង់ចាំកូនគាត់មកពីការដ្ឋានសិនសឹមចេញដំណើរទៅ ប៉ុន្តែឈ្លបមិនស្តាប់ ហើយបានបាញ់សម្លាប់គាត់នៅនឹងកន្លែង ។ ឡានដឹកមនុស្សពេញណែនហើយបើកលឿនណាស់ ។ ពេលចាប់ហ្វ្រាំងម្តងៗ មនុស្សធ្លាក់ពីលើឡានស្លាប់ក៏មាន ។ ក្រុមគ្រួសារខ្ញុំ ដល់ខេត្តពោធិ៍សាត់ចំពេលដែលមេឃភ្លៀងរលឹមស្រិចៗ អ្នកដំណើរទាំងអស់ទទឹកជោក ។ ខ្ញុំបានយកក្រណាត់កៅស៊ូទៅតាមខ្លួន ហើយប្រក់ជាដំបូលដើម្បីជ្រកជាបណ្តោះអាសន្នសិន ។ នៅពោធិ៍សាត់ ខ្ញុំបានជួបឪពុកខ្ញុំនិងបងប្រុសខ្ញុំម្នាក់ឈ្មោះ ឆន ដែលជម្លៀសមកពីខេត្តតាកែវ ។ ក្រុមគ្រួសារខ្ញុំក៏ធ្វើដំណើររួមគ្នាមកស្រុកព្រះនេត្រព្រះខេត្តបាត់ដំបង ។ រថភ្លើងឈប់ដាក់អ្នកដំណើរចុះ ហើយក្រុមគ្រួសារខ្ញុំជិះត្រាក់ទ័របន្តដំណើរមកទៀត ។ មុនពេលឡើងជិះត្រាក់ទ័រ អង្គការបានសួរប្រវត្តិរូបប្រជាជន បើអ្នកណាធ្វើគ្រូបង្រៀនដាក់ផ្សេង ធ្វើថៅកែដាក់ផ្សេង ចំណែកក្រុមគ្រួសារខ្ញុំប្រាប់ថាធ្វើកម្មករ ។ ដោយនៅតាមផ្លូវពីព្រះនេត្រព្រះទៅភូមិមានភ្លៀងត្រាក់ទ័រមិនអាចបើកទៅមុខបាន យើងក៏ធ្វើដំណើរដោយថ្មើរជើងទៅដល់ភូមិគោកក្រោល ។ នៅទីនោះខ្ញុំរស់នៅក្រោមការគ្រប់គ្រងរបស់ប្រជាជនមូលដ្ឋាន ។ ប្រពន្ធរបស់ខ្ញុំធ្វើចម្ការខ្ញុំធ្វើការនៅកងចល័តបុរសវ័យកណ្តាលលើកទំនប់ដឹកប្រឡាយ កូនៗរបស់ខ្ញុំដាក់នៅក្នុងកងកុមារ ។

ការហូបចុកនៅភូមិគោកក្រោលគឺដូចការហូបចុកនៅខេត្តកំពង់ស្ពឺដែរ ប៉ុន្តែខ្ញុំអាចរកបន្លែបន្ថែមខ្លួនឯងបានខ្លះ ។ អង្គការមិនសូវតឹងរ៉ឹងដូចនៅកំពង់ស្ពឺទេ ។ ពេលខ្លះខ្ញុំហូបបបរ ។ មានជំងឺម្តងៗគ្មានពេទ្យដែលមានជំនាញព្យាបាលទេ ។ ទោះបីខ្ញុំធ្លាប់ជាគ្រូពេទ្យក៏គ្មានលទ្ធភាពព្យាបាលខ្លួនឯងនិងសាច់ញាតិរបស់ខ្ញុំដែរ ព្រោះមានតែថ្នាំឫសឈើនិងថ្នាំគីនីនប៉ុណ្ណោះ ។ ក្រោយមក អង្គការចាត់តាំងឲ្យខ្ញុំទៅក្នុងព្រៃកាប់ឈើ ។ ឈើហ៊ុបធំៗណាស់ ។ ពេលកាប់រួចហើយមានកងផ្សេងមកដឹកជញ្ជូនចេញពីព្រៃ ។ ប្អូនជីដូនមួយរបស់ខ្ញុំក៏ទៅកាប់ព្រៃជាមួយខ្ញុំដែរ ។ ថ្ងៃមួយដោយសារវាមានជំងឺគ្រុនញាក់មិនអាចធ្វើការងារបាន អង្គការបានយកវាទៅសម្លាប់ចោល ។

នៅចុងឆ្នាំ១៩៧៨ អង្គការបានចាត់តាំងឲ្យខ្ញុំធ្វើគ្រូផ្សំថ្នាំបុរាណ និងជាអ្នកដុតសាកសព ។ ខ្ញុំដើររកឫសឈើនៅក្នុងព្រៃដើម្បីចិញ្រ្ចាំធ្វើថ្នាំ ។ នៅទីនោះមានមនុស្សស្លាប់ច្រើន ។ ខ្ញុំដុតសាកសពនៅលើដំបូក ។ ក្នុងមួយថ្ងៃខ្ញុំដុតសាកសពពាងផង ។ ក្រោយមកអត់មានអុសដុត ខ្ញុំយកសាកសពទាំងនោះទៅកប់ ។ មានថ្ងៃមួយ អង្គការបានឲ្យខ្ញុំនិងបងថ្លៃខ្ញុំកប់សាកសពចំនួន២១ ។ មុនពេលអ្នកទាំងនោះស្លាប់ ខ្ញុំឮសំឡេងខ្សឹបខ្សៀវថាមានកងទ័ពវៀតណាមឡើងមករំដោះ ។ អ្នកទាំង២១នាក់នោះរើសបានវិទ្យុមួយ ហើយលួចបើកស្តាប់នៅក្នុងព្រៃ ។ មិនយូរប៉ុន្មាន អ្នកកាប់

អុសទាំង២១ត្រូវអង្គការអារ-កសម្លាប់ទាំងអស់ ។ ខ្ញុំនិងបងថ្លៃខ្ញុំកប់សាកសពនោះក្នុងរណ្តៅតែមួយ ហើយកប់មិនបានជ្រៅទេ ពីព្រោះយើងគ្មានកម្លាំងកំហែងគ្រប់គ្រាន់ ។ យើងចំណាយពេលវេលាតាំងពីព្រលឹមរហូតដល់យប់ទើបកប់រួចរាល់ ។

រូបថតមួយសន្លឹកនេះខ្ញុំលាក់ទុកជាច្រើនកន្លែង ។ ពេលខ្លះខ្ញុំប្រកថង់លាក់ទុកនៅក្នុងដំបូលផ្ទះស្បូវ ពេលខ្លះទៀតខ្ញុំកប់ទុកនៅក្នុងដី ។ ពេលដែលខ្ញុំមិននៅផ្ទះ មានឈ្លបមករុករើរករបស់មានតម្លៃ ។ ឈ្លបយកបានមាសរបស់ខ្ញុំនិងរបស់របរប្រើប្រាស់បន្តិចបន្តួច ប៉ុន្តែរកមិនឃើញរូបថតទេ ។ រូបថតនេះជារូបថតក្រុមគ្រួសាររបស់ខ្ញុំដែលថតជុំគ្នានៅឆ្នាំ១៩៧៣ នៅក្នុងនោះមានប្រពន្ធនិងកូនរបស់ខ្ញុំ៤នាក់ ។

វាជារូបថតតែមួយគត់ដែលសល់ពីជំនាន់នោះ ។ ពេលដែលក្រុមគ្រួសារខ្ញុំទៅរស់នៅសហរដ្ឋអាមេរិក ខ្ញុំបានយករូបថតនេះទៅតាមដែរ ។ រូបថតនេះធ្វើឲ្យខ្ញុំនឹកឃើញដល់ការលំបាករបស់ខ្ញុំក្នុងរបបខ្មែរក្រហម ជាពិសេសគឺការបាត់បង់កូនជាទីស្រលាញ់ម្នាក់និងឪពុករបស់ខ្ញុំ ព្រមទាំងក្រុមគ្រួសារ បងឆន ។ គ្មានអ្វីអាចសងការបាត់បង់ទាំងនេះបានទេ ។ ◆◆◆

## ប៊ុត ចាន់មារតី

ក្នុងចំណោមអ្នកដែលខ្ញុំបានជួប ប៊ុត ចាន់មារតី រក្សាបានរូបថតច្រើនបំផុត (១៩សន្លឹក) ។ នោះគឺជារូបថតក្រុមគ្រួសាររបស់គាត់ដែលរួមមានរូបថតជាគ្រួសារ រូបថតក្នុងពិធីបុណ្យនិងពិធីរៀបការ ។ រូបថតខ្លះសល់ពីការរក្សាទុកដោយខ្លួនឯង និងខ្លះទៀតបានទទួលពីសាច់ញាតិក្រោយសម័យសង្គ្រាម ។ ព័ត៌មានខាងក្រោមនេះ ពិពណ៌នារូបថតនិងរឿងរ៉ាវក្រុមគ្រួសាររបស់ មារតី ។

រូបថតដែលខ្ញុំមានទាំងប៉ុន្មាននេះបានមកពីប្រភពខុសៗគ្នា ។ នៅពេលខ្ញុំត្រូវជម្លៀសពីភ្នំពេញមកដល់ព្រែកពោធិ៍ និងរការកោងនៅឆ្នាំ១៩៧៥ ខ្ញុំបានប្រមូលរូបថតនិងលិខិតឆ្លងដែនដាក់ក្នុងហឹបមួយរួចទម្លាក់ហឹបនោះចោលក្នុងទន្លេ ។

មុនឆ្នាំ១៩៧៥ ឪពុកម្តាយខ្ញុំបានផ្ញើរូបថតខ្លះទៅជីដូនខាងម្តាយខ្ញុំនៅស្រុកចម្ការលើ ។ នៅពេលខ្ញុំជម្លៀសទៅដល់ភូមិស្ពឺ ស្រុកចម្ការលើ ខ្ញុំបាន ប្រមូលរូបថតទាំងអស់ពី



ឪពុកម្តាយខ្ញុំមករក្សាទុក ប៉ុន្តែរូបថតភាគច្រើនខូចអស់ដោយសារទឹកភ្លៀង ក្រោយពេលខ្ញុំផ្លាស់ទៅរស់នៅភូមិស្រល់ ព្រោះខ្ញុំគ្មានកន្លែងរក្សាទុកឲ្យបានត្រឹមត្រូវ ។ ខ្ញុំនៅសល់តែរូបថត ២-៣សន្លឹកប៉ុណ្ណោះដែលរក្សាទុកបានដោយខ្លួនឯង ។ ខ្ញុំបានលាក់រូបថតនេះនិងវិទ្យុចាស់មួយដែលស្តាប់ឮដោយឪណាម៉ូនៅក្នុងពាងមួយរួចកប់ក្នុងដី ។ នៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ភៀសខ្លួនទៅព្រំដែនថៃ ដោយយករូបថត២-៣សន្លឹកនេះទៅតាម ព្រោះជារបស់ស្រាល ងាយស្រួលដាក់តាមខ្លួនហើយ នៅមានរូបថតមួយចំនួនទៀតដែលខ្ញុំប្រមែប្រមូលបានពីបងប្អូនដែលទៅរស់នៅប្រទេសក្រៅ ។ រូបថតដែលខ្ញុំថតជាមួយឪពុកម្តាយ និងប្អូនខ្ញុំម្នាក់សល់ពីស្រុកចម្ការលើ ខេត្តកំពង់ចាម ជាស្រុកកំណើតរបស់ម្តាយខ្ញុំ ។ រូបថត ឪពុកខ្ញុំឈរថតជាមួយសមាជិកសភានៅមុខរដ្ឋសភាខ្ញុំទទួលបានពីអ្នកធ្វើការជាមួយឪពុកខ្ញុំម្នាក់ដែលបានទៅរស់នៅប្រទេសបារាំងតាំងពីមុនឆ្នាំ១៩៧៥ ។ រូបថតនេះបើតាមខ្ញុំចាំប្រហែលជាថតនៅឆ្នាំ១៩៦៣ ឬ១៩៦៤ គឺនៅពេលដែលសម្តេច ព្រះនរោត្តម សីហនុ បើកអង្គប្រជុំរដ្ឋសភាលើកទីមួយ ។

ឪពុកខ្ញុំកើតនៅឆ្នាំ១៩២០ គាត់ជាអ្នកនិយមរបបសាធារណរដ្ឋខ្មែរ ។ គាត់ជាមិត្តភក្តិរបស់ លន់ នល់, សិរិមតៈ និង ទ្រឹញ វ៉ាញ ។ គាត់ចាប់ផ្តើមការងារដំបូងរបស់គាត់នៅការិយាល័យសុរិយោដីស្រុកកំពង់សៀមខេត្តកំពង់ចាម ។ បន្ទាប់មក គាត់បានផ្លាស់ទៅធ្វើការនៅស្ទឹងត្រែង និងចុងក្រោយផ្លាស់មកធ្វើជាតំណាងរាស្ត្រនៅភ្នំពេញ ។ ឪពុកខ្ញុំធ្វើតំណាងរាស្ត្រនៅព្រែកពោធិពីឆ្នាំ១៩៦២ដល់ឆ្នាំ១៩៦៧ ទើបផ្លាស់ទៅធ្វើការនៅក្រសួងដែនការរយៈពេល៥ឆ្នាំ និងចុងក្រោយនៅសាលាក្រុងភ្នំពេញរហូតឆ្នាំ១៩៧៥ ។ ឪពុកខ្ញុំខិតខំធ្វើការណាស់ ។

គាត់ចង់ឲ្យកូនៗទទួលការអប់រំល្អ ។ គាត់តែងតែផ្តល់ផ្ទាន់


ប៊ុត ចាន់មារតី ថតជាមួយឪពុកម្តាយ និងប្អូនស្រី ប៊ុតរស្មី ក្នុងឆ្នាំ១៩៥៦

លើកទឹកចិត្តដល់កូនដែលរៀនបានពិន្ទុល្អជានិច្ច ។ មិនតែប៉ុណ្ណោះ ឪពុកខ្ញុំក៏ជាអ្នកដែលចូលចិត្តការកម្សាន្តដែរ ។ ខ្ញុំចាំបានអ្វីដែលឪពុកខ្ញុំធ្លាប់រំឭកប្រាប់ខ្ញុំថា កាលពីក្មេងគាត់ធ្លាប់សម្តែងជាតួឯកសុជាត ក្នុងល្ខោនរឿងសូជាត ។ ឪពុកខ្ញុំក៏ចូលចិត្តលេងភ្លេងដែរ ប៉ុន្តែខ្ញុំមិន ដឹងច្បាស់ថាគាត់ចេះច្រៀងឬអត់ទេ ។ គាត់លេងស្គរ និងអ័រ ។ ខ្ញុំចាំថានៅពេលល្ងាចខ្ញុំឧស្សាហ៍អង្គុយក្បែរបង្អួចបន្ទប់ទទួលភ្ញៀវដើម្បីលេងអ័ររបស់គាត់ ។ ឪពុកខ្ញុំចេះរាំទាំងចង្វាក់ខ្មែរនិងចង្វាក់បរទេស ។ ខ្ញុំចាំបានថា នៅទសវត្សរ៍១៩៥០ ពេលឪពុកខ្ញុំធ្វើការនៅឃុំជីហែ ខេត្តកំពង់ចាម មិត្តភក្តិគាត់ឧស្សាហ៍មកលេងផ្ទះនៅចុងសប្តាហ៍ ឪពុកខ្ញុំរៀបចំក្រុមភ្លេងឲ្យមិត្តភក្តិគាត់បានចូលរួមរាំលេងសប្បាយ ។ ពេលនោះថ្វីត្បិតតែខ្ញុំនៅក្មេង ប៉ុន្តែខ្ញុំចាំថាកាលនោះសប្បាយណាស់ ។ នៅទសវត្សរ៍ ១៩៦០ ពេលដែលចង្វាក់ទ្វីសត្រូវនាំចូលមកក្នុងស្រុកខ្មែរ ឪពុកខ្ញុំបានទទួលលិខិតអញ្ជើញទៅទស្សនាការសម្តែងតន្ត្រីមួយនៅភ្នំពេញ ។ ខ្ញុំបានទៅមើលការសម្តែងនោះជាមួយឪពុកម្តាយខ្ញុំ ។ ការសម្តែងនោះល្អមើលណាស់ ខ្ញុំនៅចាំមិនភ្លេចទេ ។ ថ្ងៃនោះប្អូនស្រីទីពីរ រស្មី មិនបានទៅមើលជាមួយគ្នាទេ ព្រោះជាប់រវល់ប្រឡង ។ ឪពុកខ្ញុំបាននាំ រស្មី ទៅមើលកម្មវិធីនោះនៅពេលក្រោយ ។

គ្រួសារខ្ញុំមានសមាជិក១៨នាក់ គឺឪពុកម្តាយខ្ញុំ ប្អូនស្រីទីពីរឈ្មោះ ប៊ុត រស្មី ព្រមទាំងប្តីនិងកូនពីរនាក់ ប្អូនស្រីទីបីឈ្មោះ ប៊ុត សួស្តី ប្អូនស្រីទីបួន ប៊ុត ធីតា បូករួមទាំងខ្ញុំ ប្តីខ្ញុំ និងកូនពីរនាក់ និងមេផ្ទះពីរនាក់ទៀត ។ យើងរស់នៅជួបជុំគ្នាទាំងអស់ ព្រោះផ្ទះខ្ញុំធំហើយ ឪពុកខ្ញុំមិនចង់ឲ្យកូនៗនៅផ្ទះផ្សេងពីគាត់ទេ ទោះបីជាខ្ញុំនិងប្អូនស្រីរៀបការរួចក៏ដោយ ។ ខ្ញុំរៀបការតាំងពីខ្ញុំអាយុ ១៥-១៦ឆ្នាំ ។ ខ្ញុំមិនដឹងថាម្តាយខ្ញុំគិតយ៉ាងដូចម្តេចទេទើបផ្សំផ្គុំខ្ញុំឲ្យ មានប្តីទាំងវ័យក្មេងបែបនេះ ។

ខ្ញុំរៀបការនៅឆ្នាំ១៩៦៧ ។ ប្តីខ្ញុំឈ្មោះ ង៉ាក់ មួយឃៀង គឺជាអតីតគ្រូបង្រៀនវិទ្យាល័យបឹងត្របែកនៅឆ្នាំ១៩៦៦-៦៧ បន្ទាប់មកគាត់ផ្លាស់ទៅបង្រៀននៅស្រុកចម្ការលើនៅឆ្នាំ១៩៦៨ ។ នៅឆ្នាំ១៩៧០ គាត់បានផ្លាស់ប្តូរមុខរបរធ្វើជាអ្នកបកប្រែទូរលេខពីភាសាបារាំងមកខ្មែរឲ្យសារព័ត៌មានអាកាសប៉េ ។ គាត់ក៏ជាអ្នកសរសេរអត្ថបទនៅក្នុងកាសែតមួយទៀតរបស់មិត្តភក្តិគាត់ ។ ប្តីខ្ញុំបំពេញការងារនេះរហូតដល់ខ្មែរក្រហមរំដោះភ្នំពេញបាននៅឆ្នាំ១៩៧៥ ។

នៅពេលខ្មែរក្រហមជម្លៀស ឪពុកខ្ញុំមិនព្រមចាកចេញពីផ្ទះទេ គាត់រង់ចាំក្រែងមានដំណឹងថ្មីថាអង្គការឲ្យប្រជាជនត្រឡប់មកភ្នំពេញវិញ ប៉ុន្តែការរំពឹងទុករបស់ឪពុកខ្ញុំបែរជាឥតប្រយោជន៍ ។ កងទ័ពខ្មែរក្រហមបានយកកាំភ្លើងមកភ្ជង់បណ្តេញក្រុមគ្រួសារខ្ញុំឲ្យចេញ ។ យើងចាកចេញពីផ្ទះដោយយករថយន្តតូចពីរគ្រឿងសម្រាប់ដាក់អីវ៉ាន់ ។ យើងបានត្រឹមតែរុញឡានដែលផ្ទុកទៅដោយអីវ៉ាន់ និងដើរតាមផ្លូវដែលមានមនុស្សណែនណាន់តាន់តាប់ ។ យើងធ្វើដំណើរទៅជ្រោយអម្ពិលក្នុងស្រុកកៀនស្វាយ ហើយរស់នៅទីនោះអស់រយៈពេលមួយខែដើម្បីរង់ចាំឱកាសត្រឡប់ចូលមកភ្នំពេញវិញ ។ ចាំបាត់ៗ ពេល

វេលាកាន់តែកន្លងទៅគ្មានតម្រុយអ្វីដែលអាចឲ្យយើងសង្ឃឹមថាបានត្រឡប់ចូលទីក្រុងវិញទេ គ្រួសារខ្ញុំក៏ចាកចេញពីជ្រោយអំពិល សំដៅទៅភូមិស្តី ស្រុកចម្ការលើ ដែលជាភូមិកំណើតរបស់ម្តាយខ្ញុំ។ យើងធ្វើដំណើរទៅតាមកាណូត។ នៅពេលយើងកំពុងជិះកាណូត ប្អូនថ្លៃខ្ញុំបានឮខ្មែរក្រហមនិយាយគ្នានៅលើកាណូតថា ស្គាល់ឪពុកខ្ញុំថាធ្លាប់ជា តំណាងរាស្ត្រនៅមណ្ឌលព្រែកពោធិ៍ ប៉ុន្តែយើងមិនបានយកចិត្តទុកដាក់នឹងសម្តីអ្នកទាំងនោះឡើយ។ ម៉ោងប្រហែល១២អធ្រាត្រ យើងបានមកដល់កំពង់ដៃព្រែកពោធិ៍។ យើងជញ្ជូនអីវ៉ាន់ចេញពីទូកមកដាក់នៅលើច្រាំងបានប្រហែល៥នាទី កងទ័ពខ្មែរក្រហមក្មេងៗ៣-៤នាក់មកហៅឪពុកខ្ញុំទៅជួបអង្គការដើម្បីសាកសួរព័ត៌មាន។ ឪពុកខ្ញុំទៅបាត់យូរណាស់។ យើងទាំងអស់គ្នាអង្គុយចាំគាត់នៅមាត់ច្រាំងរហូតដល់ជិតភ្លឺទើបឃើញកងទ័ពខ្មែរក្រហមចុះមកវិញដោយកាន់សំបុត្រមួយមកបង្ហាញហើយប្រាប់ឲ្យយើងបន្តដំណើរទៅមុខទៀតមិនចាំបាច់ចាំឪពុកខ្ញុំទេ ពីព្រោះអង្គការទុកគាត់ឲ្យនៅរៀនសូត្រសិន។ ក្នុងសំបុត្រឪពុកខ្ញុំផ្តាំមកម្តាយខ្ញុំថាឲ្យនាំកូនចៅទៅភូមិស្តី ស្រុកចម្ការលើទៅ បើគាត់មានវាសនាគាត់អាចទៅជួបម្តាយខ្ញុំនៅចម្ការលើវិញ។ ដោយបានឃើញសំបុត្រផ្តែផ្តាំផង និងដោយខ្វះខាតស្បៀងអាហារផង ក្រុមគ្រួសារខ្ញុំក៏បានបន្តដំណើរទៅភូមិស្តី។ សំបុត្រនោះនៅជាប់នឹងខ្ញុំរហូតទើបតែមកបាត់នៅពេលខ្ញុំទៅដល់សហរដ្ឋអាមេរិក ប៉ុន្តែយើងទាំងអស់គ្នានៅតែចាំពាក្យពេចន៍នៅក្នុងសំបុត្រនោះទាំងអស់ ទោះជាសំបុត្របាត់ទៅហើយក៏ដោយ។

នៅភូមិស្តី ស្រុកចម្ការលើ ខេត្តកំពង់ចាម ម្តាយខ្ញុំមានប្អូនប្រុសពីរនាក់ ប្អូនស្រីម្នាក់ និងលោកយាយខ្ញុំម្នាក់។ យើងទៅដល់ទីនោះបានរយៈប្រហែលជា៤-៥ថ្ងៃអង្គការចាត់ចែងគ្រួសារយើងឲ្យរស់នៅបែកគ្នា។ អង្គការអនុញ្ញាតឲ្យម្តាយនិងប្អូនស្រីខ្ញុំរស់នៅជាមួយគ្នា ចំណែកខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅភូមិជ្រៅ រស់នៅជាមួយជាមួយនឹងគ្រួសារអ្នកភូមិម្នាក់ឈ្មោះ រី ជាគ្រួសារដែលមានបងប្អូនចូលបម្រើក្នុងជួរបដិវត្តន៍។ ខ្ញុំទៅដល់ចំរដូវដកស្ទូងល្មម។ ខ្ញុំមិនចេះធ្វើស្រែទេ ប៉ុន្តែ មីងរី បានផ្ញើខ្ញុំឲ្យចុះទៅដកស្ទូងជាមួយអ្នកស្រុក ខ្ញុំរៀនចេះស្ទូងស្រូវតាំងពីពេលនោះមក។ នៅឆ្នាំ១៩៧៧ ខ្ញុំសម្រាលបានកូនម្នាក់ទៀត។ ពេលនោះអង្គការលែងឲ្យខ្ញុំនៅជាមួយគ្រួសារ មីងរី ទៀតហើយ ប៉ុន្តែឲ្យខ្ញុំចូលក្នុងសហករណ៍រួម។

អំឡុងឆ្នាំ១៩៧៧-៧៨ ពេលកូនខ្ញុំអាយុបាន២-៣ខែ អង្គការបានចាប់ប្តីខ្ញុំទៅមន្ទីរសន្តិសុខវត្តពព្រេង ស្រុកចម្ការលើ។ ជាធម្មតា ប្តីខ្ញុំនិងបុរសដទៃទៀតត្រូវ អង្គការបញ្ជូនឲ្យទៅធ្វើការនៅចម្ការឆ្ងាយពីភូមិ។ ថ្ងៃមួយ មេកងបានប្រាប់ប្តីខ្ញុំឲ្យត្រឡប់មកភូមិវិញមុនម៉ោងកំណត់ ប៉ុន្តែប្តីខ្ញុំមិនបានត្រឡប់មកវិញភ្លាមតាមបញ្ជាមេកងទេ គាត់រង់ចាំដើរមកជាមួយសមាជិកក្រុមនៅពេលល្ងាច។ មេភូមិភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលឃើញប្តីខ្ញុំត្រឡប់មកដល់ភូមិ



ប៊ុក ចាន់មារតី ថតជាមួយប្តីនិងកូនទាំងពីរ ក្នុងឆ្នាំ១៩៧០

វិញដោយសុវត្ថិភាព ។ តាមការពិតអង្គការចង់ចាប់ខ្លួនប្តីខ្ញុំតាមផ្លូវពីចម្ការមកភូមិ ប៉ុន្តែដោយសារមនុស្សច្រើនទើបឈ្លបមិនចាប់គាត់ ព្រោះមិនចង់ឲ្យផ្អើលឆោឡោ ។ យប់បន្ទាប់ មេភូមិបានបង្គាប់មេក្រុមរបស់ប្តីខ្ញុំឈ្មោះ ងឹម ឲ្យទៅហៅប្តីខ្ញុំម្តងទៀត ។ ងឹម បាននាំប្តីខ្ញុំទៅដល់កាច់ជ្រុងវត្តស្ពឺដែលមានឈ្លបពីរបីនាក់ឈរចាំគាត់នៅទីនោះជាស្រេច ។ ឈ្លបបានចាប់ប្តីខ្ញុំចងនឹងខ្សែនីឡុងរួចបណ្តើរចូលក្នុងមន្ទីរសន្តិសុខវត្តពព្រេង ។ មន្ទីរសន្តិសុខនោះនៅមិនឆ្ងាយប៉ុន្មានពីភូមិទេ បើធ្វើដំណើរដោយថ្មើរជើងគឺចំណាយពេលតែមួយម៉ោងប៉ុណ្ណោះ ។ ប្តីខ្ញុំទៅបាត់ប្រហែលជាមួយសប្តាហ៍ ខ្ញុំសួរមិត្តហុក គណៈតំបន់៤១ អំពីមូលហេតុនៃការចាប់ខ្លួនប្តីខ្ញុំ ។ ខ្ញុំបានសុំអង្វរគាត់ឲ្យជួយទៅមើលប្តីខ្ញុំនៅមន្ទីរសន្តិសុខផង ដោយបញ្ជាក់ប្រាប់គាត់ថា ប្តីខ្ញុំធ្វើជាគ្រូបង្រៀនមិនមែនជានាយទុនឬជាទាហានអ្វីទេ ។ មិត្តហុក បានឆ្លើយយល់ព្រម ហើយមិនយូរប៉ុន្មានប្តីខ្ញុំបានត្រូវដោះលែងមកវិញ ។ មិត្តហុក បានឲ្យយោបល់ប្តីខ្ញុំផ្លាស់ចេញពីភូមិស្ពឺ ពីព្រោះប្រជាជននៅភូមិនេះ ភាគច្រើនជាអ្នកមូលដ្ឋាន ហើយមិនចូលចិត្តអ្នកថ្មីមកពីភ្នំពេញទេ ។ គាត់ណែនាំឲ្យយើងផ្លាស់ទៅភូមិត្រពាំងស្រល់ ជាភូមិដែលមានប្រជាជនថ្មីរស់នៅច្រើន ។ ប្តីខ្ញុំមកដល់ផ្ទះបានតែមួយយប់ខ្ញុំឮដំណឹងថាអង្គការបញ្ជូនម្តាយខ្ញុំនិងធីតា (ប្អូនពៅខ្ញុំ) ទៅតំបន់៤២ ។ ខ្ញុំអង្វរករ មិត្តអុន ដែលជាកម្មាភិបាលមកពីភូមិភាគនិរតីឲ្យខ្ញុំបានទៅជាមួយម្តាយខ្ញុំ ប៉ុន្តែ មិត្តអុនរារែក ព្រោះខ្ញុំនិងប្តីត្រូវអង្គការតម្រូវឲ្យទៅរស់នៅភូមិត្រពាំងស្រល់ ។ ដោយខ្ញុំអង្វរខ្លាំង ពេក មិត្តអុន ក៏យល់ព្រមជួយ ក៏ប៉ុន្តែនៅទីបំផុតខ្ញុំនិងប្តីនៅតែមិនអាចទៅតំបន់៤២បាន ព្រោះគណៈភូមិមិនអនុញ្ញាត ។ ម្តាយនិងប្អូនខ្ញុំក៏មិនបានឡើងឡានទៅជាមួយអ្នកភូមិដែរ ។ ៤-៥ថ្ងៃ ក្រោយមក ខ្ញុំបានឃើញខោអាវនិងរបស់របរប្រើប្រាស់របស់ប្រជាជនដែលបានទៅតំបន់៤២ ត្រូវអង្គការរើកកាយចែកគ្នាពាក់ ។ ខ្ញុំសន្និដ្ឋានថាម្ចាស់ខោអាវនោះត្រូវអង្គការវាយសម្លាប់អស់ទៅហើយ ព្រោះខ្ញុំបានឮអ្នកដេកយាមចម្ការម្នាក់និយាយថា គាត់បានឮសូរសំឡេងស្រែកនៅក្នុងចម្ការអណ្តូង ។ នៅពេលដែលខ្ញុំខកខានមិនបានទៅតំបន់៤២ ខ្ញុំ ប្តីខ្ញុំ ព្រមទាំងម្តាយនិងប្អូនខ្ញុំ បានត្រឡប់ទៅផ្ទះនៅភូមិស្ពឺលិចវិញ ។ នៅព្រឹកថ្ងៃបន្ទាប់ អង្គការបានជម្លៀសយើងចេញពីភូមិស្ពឺទៅភូមិត្រពាំងស្រល់ ដែលមានចម្ងាយប្រហែល៣-៤ គីឡូម៉ែត្រ ។

នៅខែមករា ឆ្នាំ១៩៧៩ ខ្ញុំនិងគ្រួសារបានរៀបចំរទេះនិងស្បៀងអាហារខ្លះ ដើម្បីត្រៀមចេញដំណើរពីស្រុកកំណើត ។ គ្រួសារខ្ញុំដែលមានគ្នាទាំងអស់១៣នាក់រួមជាមួយគ្រួសារផ្សេងៗទៀតសរុបគ្នាជិត៣០នាក់ធ្វើដំណើរភៀសខ្លួនមកទិសខាងលិចតម្រង់ទៅប្រទេសថៃ ។ យើងធ្វើដំណើរដោយថ្មើរជើងកាត់ឃុំចម្ការអណ្តូងតាមផ្លូវជាតិលេខ៦ និងឆ្លងកាត់តាមកំពង់ធំរហូតដល់សៀមរាប ។ យើងធ្វើដំណើរផ្សងព្រេងកាត់គ្រាប់កាត់សមរភូមិប្រយុទ្ធទម្រាំដល់ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ នៅពេលធ្វើដំណើរដល់ស្រុកក្រឡាញ់ ប្អូនស្រីទីពីរខ្ញុំឈ្មោះ រស្មី បានគ្រប់ខែសម្រាលកូន ហេតុដូចនេះយើងស្នាក់នៅទីនោះមួយខែទម្រាំប្អូនស្រីខ្ញុំមានសុខភាពរឹងមាំឡើងវិញ ។ យើងបន្តដំណើរទៅដល់ព្រំប្រទល់ខ្មែរ-ថៃ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ហើយស្នាក់នៅទីនោះមួយរយៈទៀតដើម្បីស្វែងរកអ្នកស្គាល់ផ្លូវនាំចេញទៅប្រទេសថៃ ។ រយៈពេលប្រហែលកន្លះខែទើបយើងរកអ្នកនាំផ្លូវបាន ។ យើងធ្វើដំណើរផ្សងគ្រោះថ្នាក់រយៈពេល២ថ្ងៃទើបទៅដល់ព្រំដែនថៃ ។ នៅតាមផ្លូវយើងបានជួបចោរព្រៃថៃដែលព្យាយាមប្លន់ទ្រព្យសម្បត្តិរបស់យើង ប៉ុន្តែចោរទាំងនោះប្លន់បានតែដុំពិលប្រាក់មួយដែលយើងប្រើប្រាស់សម្រាប់ដាំបាយប៉ុណ្ណោះ ។ បន្ទាប់មក ក្រុមចោរបានទុកយើងចោលនៅវត្តណងចាន់ក្នុងទឹកដីថៃ ។ ទាហានថៃបានបញ្ជូនគ្រួសារខ្ញុំនិងអ្នកភៀសខ្លួនដទៃទៀតឲ្យរស់នៅជុំគ្នាក្នុងជំរំជនភៀសខ្លួន ។ ពីរសប្តាហ៍ក្រោយមក សហរដ្ឋអាមេរិកបានចុះបញ្ជីឈ្មោះជនភៀសខ្លួន ដើម្បីធ្វើសំបុត្រស្នាមឆ្លងទៅប្រទេសអាមេរិក ។ វាសនាខ្ញុំល្អដោយប្តីខ្ញុំធ្លាប់ធ្វើការនៅទីភ្នាក់ងារសារព័ត៌មាន អា.កា.ប៉េ ខាងអាមេរិកបានបញ្ចូលឈ្មោះក្រុមគ្រួសារខ្ញុំទៅក្នុងក្រុមទីមួយ ។ អ្នកដែលនៅក្នុងក្រុមនេះជាអតីតមន្ត្រីរាជការនិងទាហាន ហើយបានចាកចេញទៅប្រទេសទីបីមុន ។ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៩ ប្តីខ្ញុំ ខ្ញុំ និងកូនបីនាក់បានទៅដល់សហរដ្ឋអាមេរិក រីឯម្តាយ និងប្អូនខ្ញុំបីនាក់ទៀតត្រឡប់មកប្រទេស

កម្ពុជាវិញរង់ចាំនៅស្វាយស៊ីសុផុន ។ ប្អូនស្រីទីបីរបស់ខ្ញុំឈ្មោះ សួស្តី ត្រឡប់ទៅស្រុកចម្ការលើវិញដើម្បីសម្រាលកូន ។

ខ្ញុំរស់នៅសហរដ្ឋអាមេរិកមិនបានស្ងប់ចិត្តទេ ពីព្រោះបងប្អូនខ្ញុំនៅស្រុកខ្មែរនៅឡើយ ។ ខ្ញុំបានផ្ញើសំបុត្រទៅអង្គការនានា នៅជំរំនិងទៅនារីម្នាក់ដែលមានប្តីជាតម្រួតថៃនៅជំរំណងចាន់ ។ សំបុត្រនោះក៏បានទៅដល់ដៃប្អូនស្រីទីពីររបស់ខ្ញុំដែលរកស៊ីនៅព្រំដែនថៃ ។ នាងបាននាំសំបុត្រខ្ញុំទៅចែកចាយបងប្អូនខ្ញុំនៅស្វាយស៊ីសុផុន ។ ម្តាយនិងប្អូនៗខ្ញុំបានទទួលដំណឹងនេះហើយផ្ញើសំបុត្រត្រឡប់មកខ្ញុំវិញ ។ យើងក៏ចាប់ផ្តើមមានទំនាក់ទំនងគ្នា ។ មិនយូរប៉ុន្មានខ្ញុំបានរកអ្នកជួយខបត្តម្ភដើម្បីធានាប្អូននិងម្តាយខ្ញុំមកសហរដ្ឋអាមេរិក ។ ប្អូនស្រីពៅរបស់ខ្ញុំនៅស្រុកចម្ការលើបានទទួលដំណឹងក្រោយគេ នាងធ្វើដំណើរមកព្រំដែនថៃដើម្បីធ្វើសម្ភាសន៍ទៅប្រទេសកាណាដា ។

ពេលខ្ញុំទៅដល់សហរដ្ឋអាមេរិកដំបូង ខ្ញុំមិនមានពេលវេលាធ្វើការនៅខាងក្រៅទេ ពីព្រោះជាប់រវល់មើលថែកូននៅផ្ទះ ។ បន្ទាប់ពីប្អូននិងម្តាយខ្ញុំទៅដល់សហរដ្ឋអាមេរិក ខ្ញុំក៏ឲ្យម្តាយខ្ញុំជួយមើលកូនឲ្យខ្ញុំ ហើយខ្ញុំទៅធ្វើការជាអ្នកសម្អាតផ្ទះ ។ ក្រោយមកខ្ញុំបានការងារធ្វើនៅហាងនំរបស់មិត្តភក្តិខ្ញុំ ។ ខ្ញុំធ្វើការផងរៀនផង ។ ២ឆ្នាំក្រោយមក ខ្ញុំដាក់ពាក្យចូលបម្រើការងារនៅផ្នែកសេវាសង្គម និងធ្វើការងារនេះរហូតដល់សព្វថ្ងៃ ។

អ្វីដែលធ្វើឲ្យខ្ញុំមិនអាចបំភ្លេចបាននៅក្នុងរបបខ្មែរក្រហមគឺខ្លាចអង្គការយកទៅសម្លាប់ ។ ខ្ញុំភ័យខ្លាចណាស់ យប់ឡើងខ្ញុំឮសូរតែស្នូររទេះគោបរឌឺតង៉ឺតៗ ហបៗ បើរទេះឈប់ទ្រឹងនៅមុខផ្ទះណា ផ្ទះនោះនឹងមានមនុស្សបាត់ខ្លួនជាមិនខាន ។ នៅពេលរទេះបរទៅផុតខ្ញុំត្រេកអរណាស់ ព្រោះដឹងថាខ្ញុំបានរស់មួយយប់ទៀតហើយ ។ មិនថាតែប្រជាជនថ្មីទេដែលអង្គការយកទៅសម្លាប់ សូម្បីតែកម្មាភិបាលដូចគ្នាក៏ត្រូវអង្គការបោសសម្អាតដែរ ឲ្យតែអ្នកនោះងាកចេញពីផ្លូវរបស់អង្គការបន្តិច ។

តាំងពីខ្ញុំដឹងក្តីមកខ្ញុំមិនដែលឃើញរបបណាសាហាវឃោរឃៅដូចរបបខ្មែរក្រហមទេ ។ ខ្ញុំស្ទើរតែមិនអាចរកពាក្យមករៀបរាប់បាន ខ្ញុំចង់រកមុខនរណាដែលនាំឲ្យរបបនេះកើតឡើង ។ ខ្ញុំមិនចង់ឲ្យរបបនេះកើតឡើងមកវិញម្តងទៀតទេ ខ្ញុំចង់ឲ្យមនុស្សជំនាន់ក្រោយបានដឹងបានយល់ និងចង់ឲ្យមានតុលាការមួយដើម្បីឲ្យអ្នកនៅក្នុងនិងក្រៅប្រទេសបានយល់ច្បាស់ និងរែកមុខរកអ្នកទទួលខុសត្រូវចំពោះអំពើដែលកើតឡើងទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ◆◆◆

## សំ ស៊ីនថៃ
## អតីតប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម

*ស៊ីនថៃ ជាកូនទី៣នៅក្នុងចំណោមបងប្អូន៩នាក់ ។ ស៊ីនថៃ ត្រូវខ្មែរក្រហមយកទៅរៀនសូត្រនៅក្នុងឆ្នាំ១៩៧៥ ។ តាមរយៈប្រវត្តិរូបរបស់ សំ ស៊ីនថៃ មួយសន្លឹកដែលសល់ពីរបបខ្មែរក្រហមបានកត់ត្រាថា ស៊ីនថៃ ត្រូវបានអង្គការឃាត់ខ្លួននៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ នៅព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ហើយយកទៅឃុំខ្លួននៅផ្ទះ ក០៧ បន្ទប់លេខ១ មន្ទីរស-២១ ។ សំ ស៊ីម៉ន ជាប្អូនស្រីរបស់ ស៊ីនថៃ បានបង្ហាញនូវរូបថតរៀបការមួយសន្លឹកដែលសេសសល់ពីរបបមុន ។ វាជារូបថតតែមួយគត់ដែលគាត់នៅសល់ គឺរូបថតរៀបការរបស់ សំ ស៊ីនថៃ និងកូនក្រមុំឈ្មោះ ហួត ដាន់ណារី ដែលថតជាមួយសាច់ញាតិទាំងសងខាង ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ ស៊ីម៉ន ÷*

រូបនេះថតនៅក្នុងពិធីរៀបការរបស់ បងថៃ ។ ក្រោយពេលរៀបការហើយ រូបថតទាំងនោះទុកនៅផ្ទះខាងស្រី ។ មុនពេលរំដោះទីក្រុងភ្នំពេញ បងថៃ ផ្ញើរូបថតមួយសន្លឹកនេះមកឲ្យក្រុមគ្រួសារខ្ញុំ ។ នៅក្នុងរបបខ្មែរក្រហម ម្តាយខ្ញុំលាក់រូបថតនេះនៅក្នុងប្រអប់គ្រែ ។ មានឈ្លបមកឆែកឆេរផ្ទះដែរ ប៉ុន្តែរកមិនឃើញរូបថតទេ គឺឆែករកឃើញតែមាសនិងលុយបន្តិចបន្តួចប៉ុណ្ណោះ ។

បងថៃ គឺជាមនុស្សឆ្លាត និងស្រលាញ់ក្រុមគ្រួសារ ។ មុនឆ្នាំ១៩៧០ បងថៃ ទៅរៀនសាលាកសិកម្មនៅខេត្តកំពង់ចាម ។ បងខ្ញុំជួលផ្ទះនៅ ហើយផ្ទះនោះមានកូនក្រមុំម្នាក់ឈ្មោះ ហួត ដាន់ណារី ។ បងថៃ បានស្រលាញ់គ្នាជាមួយ បងណារី ។ បងណារីមានចរិតសុភាពរម្យទមនិងមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ។ គាត់ជាគ្រូកីឡានៅក្នុងសាលារៀនខេត្តកំពង់ចាម ។ នៅពេលដែលសម្តេចឪទៅទស្សនកិច្ចនៅទីរួមខេត្តកំពង់ចាមម្តងៗ បងណារី ទៅទទួលនិងបំពាក់កម្រងផ្កាថ្វាយទ្រង់ ។ ឪពុកម្តាយរបស់ បងណារី ក៏ពេញចិត្ត

បងថៃ ដែរ ។ ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងឪពុកម្តាយទាំងសងខាង បងថៃ និង បងណារី បានរៀបការតាមប្រពៃណីខ្មែរនៅផ្ទះខាងស្រីនៅខេត្តកំពង់ចាម ។ ក្រោយពេលរៀបការហើយ បងថៃ រៀនបន្តនៅខេត្តកំពង់ចាមរហូតដល់ចប់ ទើបទាំងពីរនាក់ប្តីប្រពន្ធផ្លាស់មករស់នៅទីក្រុងភ្នំពេញ ។

នៅភ្នំពេញ បងថៃ និងប្រពន្ធរបស់គាត់រស់នៅផ្ទះជួលនៅសង្កាត់ទឹកល្អក់ ។ បងថៃ រៀនបន្តនៅសាលាកសិកម្មចម្ការដូង និងសាលាព្រែកលៀប ។ ក្រោយពេលរៀនចប់ បងថៃ ចូលបម្រើការងារនៅក្រសួងកសិកម្ម ។ ក្រៅពីប្រាក់បៀវត្សរ៍គាត់ទទួលបានរបស់របរហូបចុកមួយចំនួនដូចជាត្រីខកំប៉ុងនិងទឹកដោះគោជាដើម ។ ប្រាក់បៀវត្សរ៍របស់ បងថៃ មិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាពរបស់គាត់ទេ ។ ពេលខ្លះគ្រួសារ បងថៃ ជួបការខ្វះខាតក្នុងជីវភាព ហើយឪពុកម្តាយនិងបងរបស់ខ្ញុំក៏ជួយឧបត្ថម្ភប្រាក់បន្ថែមដល់គាត់ ។

នៅឆ្នាំ១៩៧៣ បងថៃ បានចេញទៅបំពេញកម្មសិក្សានៅប្រទេសជប៉ុន ។ បងណារី ត្រឡប់ទៅរស់នៅផ្ទះម្តាយគាត់នៅឯខេត្តកំពង់ចាមវិញ ។ ពេលនោះគាត់មានកូនបីនាក់ ។ នៅប្រទេសជប៉ុន បងថៃ បានសុំសិទ្ធិពីក្រសួងការបរទេសជប៉ុនដើម្បីធានាប្រពន្ធនិងកូនរបស់គាត់ទៅរស់នៅទីនោះ ប៉ុន្តែខាងជប៉ុនមិនអនុញ្ញាត ព្រោះ បងណារី ចង់យកទាំងឪពុកម្តាយរបស់គាត់ទៅដែរ ។ នៅពេល បងថៃ រៀនចប់ហើយវិលត្រឡប់មកប្រទេសកម្ពុជា បងណារី បានត្រឡប់មករស់នៅជាមួយ បងថៃ នៅទីក្រុងភ្នំពេញវិញ ។ បងថៃ បានទទួលការចាត់តាំងឲ្យទទួលមុខតំណែងជាប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម ។ គាត់ចុះឡើងភ្នំពេញ-កំពង់ចាមក្នុងរយៈពេល១ឬ២សប្តាហ៍ម្តង ។

នៅពេលដែលខ្មែរក្រហមកាន់កាប់ប្រទេស ក្រុមគ្រួសារ បងថៃ មានបំណងធ្វើដំណើរមកស្រុកកំណើតនៅស្រុកខ្សាច់កណ្តាល ប៉ុន្តែមកដល់បានពាក់កណ្តាលផ្លូវ អង្គការបានហៅ បងថៃ ទៅរៀនសូត្រនៅខេត្តពោធិសាត់ ។ បងថៃ បាត់ដំណឹងរហូតតាំងពីពេលនោះមក ។ នៅក្នុងភូមិកំណើត ខ្ញុំទាំងអាជ្ញាធរភូមិនិងប្រជាជនបានដឹងទាំងអស់គ្នាអំពីការងាររបស់ បងថៃ កាលពីមុន ។ ពេលអង្គការចាប់ បងថៃ បងណារី មានផ្ទៃពោះ៣ខែ ។ ពេលនោះអង្គការប្រាប់ បងណារី ថាត្រឡប់ទៅរង់ចាំនៅមូលដ្ឋានសិនចុះ អង្គការនឹងឲ្យប្តីរបស់គាត់ធ្វើដំណើរទៅតាមក្រោយ ។ បងណារី និងកូនៗបានធ្វើដំណើរមកស្រុកកំណើតនៅឯស្រុកខ្សាច់កណ្តាលដើម្បីរង់ចាំប្តីរបស់គាត់ ប៉ុន្តែចាំបាត់យូរទៅៗមិនឃើញប្តីរបស់គាត់ត្រឡប់មកវិញសោះ ។


រូបថតអាពាហ៍ពិពាហ៍របស់ សំ ស៊ីនថៃ និង ហួត ផាន់ណារី ក្នុងឆ្នាំ១៩៦៨

ពេលមួយ សាច់ញាតិរបស់ខ្ញុំម្នាក់បានទៅរកត្រីនៅមាត់ស្វាយអាត់ បានជួបអ្នកទោសម្នាក់ដែលត្រូវអង្គការឲ្យទៅអូសមង ។ សាច់ញាតិខ្ញុំបានលួចសួរអ្នកទោសនោះក្រែងលោបានជួបបងថៃ ។ អ្នកទោសរូបនោះបានប្រាប់ថា បងថៃ ត្រូវអង្គការឃុំខ្លួននៅក្នុងវត្តមួយក្បែរនោះដែរ ។ ដំណឹងនេះបានដឹងទៅដល់ បងណារី ។ ដោយការរង់ចាំចេះតែមិនឃើញ បងថៃ ត្រឡប់មកវិញ ហើយគួបផ្សំនឹងគាត់បានទទួលដំណឹងថា បងថៃ ជាប់ឃុំឃាំង បងណារី សន្និដ្ឋានថា បងថៃ ពិតជាត្រូវអង្គការសម្លាប់ហើយ ។ ពេល បងណារី មកដល់ភូមិខ្ញុំដំបូង អង្គការចែកអង្ករឲ្យហូប ប៉ុន្តែ ២-៣ខែក្រោយមកអង្គការប្រមូលរបស់របរទាំងអស់យកទៅដាក់រួម ។ បងណារី ធ្វើការនៅក្នុងសហករណ៍ជាមួយខ្ញុំ កូនតូចៗរបស់គាត់ត្រូវអង្គការបញ្ជូនទៅមណ្ឌលកុមារដែលមានមនុស្សចាស់ជាអ្នកថែរក្សា ។ យើងមិនដែលបានហូបឆ្អែតទេ ។ ក្នុងមួយឆ្នាំយើងបានហូបបាយតែរយៈពេល១ខែប៉ុណ្ណោះ គឺនៅពេលប្រមូលផលស្រូវ ។ ក្រៅពីនោះយើងហូបបបរ ។ ពេលខ្លះ បងណារី លាក់របបរបស់គាត់ទុកឲ្យកូនហូប ។ ទោះបីបានដំណឹងថា បងថៃ ត្រូវអង្គការសម្លាប់ក៏ដោយ ក៏ បងណារី នៅតែបន្តស៊ើបសួរអំពីដំណឹង បងថៃ ជានិច្ច ។ គណៈសហករណ៍ហៅ បងណារី ទៅទិតៀនជាញឹកញាប់ ព្រោះគាត់មិនសូវចេះធ្វើការងារ ។ តាមពិតគាត់ធ្វើការទាំងយប់ទាំងថ្ងៃស្ទើរគ្មានពេលសម្រាក ។

ក្រោយឆ្នាំ១៩៧៩ ខ្ញុំបានឃើញសៀវភៅរូបផ្តិតមនុស្សដែលសរសេរចំណងជើងថា "គុកទួលស្លែង" ដែលប្រជាជនយកមកមើលនៅស្រុកនេះ ។ ក្នុងសៀវភៅនោះមានឈ្មោះ បងថៃ ដែលអង្គការដាក់ថាជាវិស្វករ ប៉ុន្តែខ្ញុំមិនបានចាំច្បាស់ថាបងខ្ញុំត្រូវអង្គការចាប់ខ្លួននិងសម្លាប់នៅខែណាឆ្នាំណាទេ ។ ខ្ញុំយល់ថា បងថៃ ត្រូវខ្មែរក្រហមសម្លាប់ហើយ ព្រោះខ្ញុំដឹងថាអង្គការមិនទុកឲ្យអ្នកចេះដឹងរស់បានយូរទេ ។

រូបម្នាក់ឈរនៅខាងឆ្វេងបង្អស់គឺបង សំ ស៊ីនធី ។ នៅមុនរំដោះទីក្រុងភ្នំពេញឆ្នាំ១៩៧៥ បងធី ទៅរស់នៅភ្នំពេញជាមួយ បងថៃ ។ បងថៃ បានបបួល បងធី ចូលធ្វើទាហានលន់នល់ ប៉ុន្តែ បងធី មិនចង់ធ្វើទេព្រោះនៅសមរភូមិមានគ្រោះថ្នាក់ច្រើន ។ គាត់ប្រឡងចូលរៀនផ្នែកពេទ្យ ។

នៅពេលជម្លៀសចេញពីទីក្រុងភ្នំពេញ បងធី ក៏ធ្វើដំណើរទៅជាមួយក្រុមគ្រួសារ បងថៃ ដែរ ។ បងធី ត្រូវអង្គការចាត់តាំងឲ្យធ្វើការងារនៅក្នុងការដ្ឋានស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។ គាត់បានសុំអង្គការផ្លាស់មកធ្វើការនៅក្បែរ បងណារី ដើម្បីបានជួយមើលថែរក្សា បងណារី និងកូនៗ ។ ក្រោយមកមិត្តភក្តិម្នាក់ធ្វើការនៅក្នុងក្រុមជាមួយ បងធី លួចរត់ចេញពីកង ហើយអង្គការតាមចាប់បាន ។ បងធី ដឹងខ្លួនថាយូរឬឆាប់អង្គការពិតជាតាមចាប់គាត់ដែរ ដូច្នេះគាត់សម្រេចចិត្ត រត់ចេញដើម្បីរួចផុតពីការចាប់ខ្លួន ។ មុនពេលចេញដំណើរគាត់មកសំពះលា បងណារី និងម្ដាយខ្ញុំ ។ ខ្ញុំបានជួបគាត់នៅរោងបាយ ហើយឲ្យពោតទៅគាត់ខ្លះទុកហូប ។ គាត់ផ្ដាំផ្ញើខ្ញុំថា បើមានអ្នកណាសួររកគាត់ ខ្ញុំត្រូវឆ្លើយថាមិនដឹងគាត់ទៅណាទេ ។ គាត់សុំយកប៊ីដុងទឹកតូចមួយដើម្បីដាក់ស្ករទុកហូបតាមផ្លូវ ។ ២-៣ថ្ងៃក្រោយមក បងធី ក៏បាត់ខ្លួនរហូត ។ ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ទៀតទេ ។ អង្គការហៅខ្ញុំទៅប្រជុំសួរនាំអំពី បងធី ខ្ញុំឆ្លើយថាខ្ញុំមិនដឹងទេ ។ ចាប់តាំងពីពេលនោះមកអង្គការក៏ឈប់ដេញដោលសួរខ្ញុំទៀត ។ ពេលអង្គការហៅទៅនោះខ្ញុំភិតភ័យណាស់ ខ្ញុំស្លៀកពាក់ខោអាវច្រើនជាន់គិតក្នុងចិត្តថា ប្រសិនបើត្រូវអង្គការសម្លាប់ខ្ញុំមានខោអាវក្រាស់បន្តិច ។

នៅពេលបែកខ្មែរក្រហមឆ្នាំ១៩៧៩ មានអ្នកស្រុកឃើញ បងធី ជិះឡានកងទ័ពនៅម្ដុំគីឡូម៉ែត្រលេខ៩ ។ ពេលនោះបងខ្ញុំស្លៀកខោអាវទាហានពណ៌កាគី ។

ក្រោយពីខ្ញុំត្រឡប់មកភូមិកំណើតវិញ ផ្ទះរបស់ម្ដាយខ្ញុំនៅទីនេះ៣ខ្នងត្រូវរុះរើខ្ទេចខ្ទីអស់នៅសល់តែជញ្ជាំង ។ អង្គការយកផ្ទះម្ដាយខ្ញុំធ្វើជាសហករណ៍ ហើយជម្លៀសម្ដាយខ្ញុំទៅរស់នៅកន្លែងផ្សេង ។ ចំណែកឪពុកខ្ញុំស្លាប់តាំងពីមុនឆ្នាំ១៩៧៥ ។

សព្វថ្ងៃ បងណារី កំពុងរស់នៅសហរដ្ឋអាមេរិក ជាមួយកូន៣នាក់ ។ គាត់នៅតែចង់បានដឹងព័ត៌មានអំពី បងថៃ ហើយគាត់ស្រាវជ្រាវរកឯកសារទាក់ទងនឹង បងថៃ ។

ខ្ញុំយល់ថា បងធី និង បងថៃ ពិតជាស្លាប់ហើយ ។ បើសិនជាគាត់ទាំងពីរនៅរស់មែន គាត់ពិតជាវិលត្រឡប់មកភូមិកំណើតវិញ ព្រោះគាត់ស្រលាញ់ក្រុមគ្រួសារណាស់ ។

**ប៊ាង ពីច័ន និង ស៊ីុ សាទីណា**

# ស្វែងរករូបថតជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ FM102MHz ទីក្រុងភ្នំពេញ វិទ្យុ FM93.25MHz ខេត្តកំពត វិទ្យុ FM99MHz ខេត្តព្រះវិហារ និងវិទ្យុFM ១០៣.២៥MHz ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះយើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ



ឈឹម វ៉េត និងក្រុមគ្រួសារ

យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួនតែប៉ុណ្ណោះ ។ រូបថតទាំងនោះចាំបាច់ ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មក នឹងប្រគល់ រូបថតដើមជូនទៅលោកអ្នកវិញ ។

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល truthpivoine@dccam.org ។

សូមអរគុណ ។

# សង្ឃឹមថានឹងបានជួបបងប្រុសវិញ

បងប្រុសរបស់ ឃួន យន ឈ្មោះ ឃួន រឿង បានបាត់ខ្លួននៅដើមឆ្នាំ១៩៧៩ ។ យន បានខិតខំស្រាវជ្រាវរកបងប្រុសអស់ជាច្រើនឆ្នាំមកហើយ ប៉ុន្តែគាត់មិនដែលបានទទួលដំណឹងពីបងប្រុសគាត់សោះ ។ យន រកឃើញតែរូបថតប្រាំសន្លឹកគឺរូបថតរបស់ រឿង ជាមួយប្រពន្ធ និងមិត្តរួមការងារមួយចំនួនកាលគាត់ទៅធ្វើការនៅភ្នំពេញក្នុងរបបខ្មែរក្រហម ។ រូបថតទាំងនេះត្រូវបានមិត្តភក្តិរបស់ រឿង ដែលរស់នៅក្រុងប៉ៃលិនថែរក្សាទុក ។ យន បានសុំយករូបថតទាំងនេះមកវិញនៅពេលដែលគាត់តាមរកបងប្រុសរហូតដល់ក្រុងប៉ៃលិន ។


ឃួន រឿន និងប្រពន្ធឈ្មោះ យាម

ខ្ញុំបានទៅជួប យន ដល់ស្រុកកំណើតរបស់គាត់ជាមួយនឹងប្រវត្តិរូបពីរសន្លឹក គឺប្រវត្តិ រូបរបស់ ឃួន យន និងប្រវត្តិរូបបងប្រុសគាត់ឈ្មោះ ឃួន រឿង ។ យន កំពុងតែច្រូតស្រូវនៅវាលស្រែក្បែរផ្ទះរបស់គាត់ ។ គ្រាន់តែបានឮដំណឹងថាមានមនុស្សចុះមកស្រាវជ្រាវរកបងប្រុសរបស់ខ្លួនភ្លាម យន រត់មកពីវាលស្រែយ៉ាងលឿន គាត់និយាយទាំងដង្ហក់ ក្រែងលោក្រុមស្រាវជ្រាវរបស់ខ្ញុំបានទទួលដំណឹងពីបងប្រុសរបស់គាត់ ។

យន និង រឿង បានទៅធ្វើការនៅមន្ទីរពេទ្យ១៧មេសា ជាមួយគ្នាក្នុងរបបខ្មែរក្រហម ។ យន និងបងប្រុសរបស់គាត់ចូលបដិវត្តន៍នៅខែមេសា ឆ្នាំ១៩៧៥ គឺនៅពេលដែលខ្មែរក្រហម ដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ ។ យន ចូលបម្រើបដិវត្តន៍តាមការចាត់តាំងរបស់ប្រធានភូមិឈ្មោះ អែម និង ញ៉ុក ។ នៅពេលនោះ យន មានការពេញចិត្តនឹងចូលបដិវត្តន៍ ដោយគាត់យល់ថានឹងអាចជួយឲ្យការរស់នៅរបស់គាត់បានប្រសើរម្យ៉ាងទៀតគាត់ឃើញប្រជាជនទូទៅក៏ចូលបដិវត្តន៍ដែរ ។ យន និង បងប្រុស ជាមនុស្សពីរនាក់ក្នុងចំណោមអ្នកភូមិ ជាច្រើននាក់ទៀតដែលត្រូវបានជ្រើសរើសឲ្យទៅធ្វើការនៅភ្នំពេញ ។ មុនពេលចេញទៅភ្នំពេញ យន ត្រូវទៅសំណាក់នៅភូមិក្បៀរ ខាងលិចស្វាយលែង ដែលជាកន្លែងប្រមូលផ្តុំនិងជាកន្លែងព្យាបាលអ្នកជំងឺដ៏ធំមួយរបស់ខ្មែរក្រហមក្នុងស្រុកគងពិសី ។ បន្ទាប់មកអ្នកដែលត្រូវបានជ្រើសរើសត្រូវដឹកតាមរថយន្តធំៗពីរគ្រឿងទៅទីក្រុងភ្នំពេញ ។

យន និងបងប្រុស ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរពេទ្យ១៧មេសា (សព្វថ្ងៃជាមន្ទីរពេទ្យព្រះបាទនរោត្តម សីហនុ) ។ យន មិនត្រូវបានអនុញ្ញាតឲ្យទៅធ្វើការនៅក្នុងមន្ទីរពេទ្យភ្លាមទេ ។ គាត់ត្រូវបានចាត់តាំងឲ្យដាំដុះបន្លែនៅម្ខាងផ្លូវទល់មុខនឹងមន្ទីរ-ពេទ្យសិន ។ បន្ទាប់ពីធ្វើការខាងដាំដុះបានរយៈពេលប្រហែលប្រាំមួយខែ យន ត្រូវផ្លាស់ឲ្យមកនៅខាងផ្ទះបាយដើម្បីធ្វើម្ហូបអាហារសម្រាប់បុគ្គលិកមន្ទីរពេទ្យនិងអ្នកជំងឺ ។ យន បានប្រាប់ថា គាត់តែងតែលួចទុកបាយនិងម្ហូបឆ្ងាញ់ៗឲ្យបងប្រុសរបស់គាត់ជានិច្ច ។

រឿង ធ្វើការជាជាងសំណង់ក្នុងមន្ទីរពេទ្យ ។ រឿង បានរៀបការជាមួយនារីពេទ្យម្នាក់ ឈ្មោះ យាម ដែលមានដើមកំណើតនៅខេត្តតាកែវ ។ អ្នកទាំងពីររៀបការក្នុងឆ្នាំ១៩៧៧ ។

បន្ទាប់ពីធ្វើការនៅក្នុងផ្ទះបាយអស់មួយរយៈមក យន ត្រូវអង្គការផ្លាស់ឲ្យមកនៅថែទាំនិងព្យាបាលកុមារកំព្រា ។ យន មិនចេះក្បួនពេទ្យអ្វីឲ្យបានច្បាស់លាស់ទេ គ្រាន់តែទទួលការ

ណែនាំបន្តិចបន្តួចពីរបៀបប្រើប្រាស់ថ្នាំនិងព្យាបាលពីប្រធានក្រុមរបស់គាត់ប៉ុណ្ណោះ ។ យន និយាយថា "ខ្ញុំទទួលបានការអប់រំច្រើនតែអំពីរឿងនយោបាយ ការងារ និងសីលធម៌" ។ ពឿន ដែលជាគណៈគ្រប់គ្រងមន្ទីរពេទ្យជាអ្នកបង្រៀននយោបាយ ។ យន បានបន្តថា "ពឿន ជាអាណាព្យាបាលរបស់កម្មាភិបាលពេទ្យទាំងអស់" ។

ធ្វើការនៅក្នុងមន្ទីរពេទ្យ១៧មេសា យន បានជួបមនុស្សប្លែកមុខជាច្រើន ។ គាត់បានឃើញទីប្រឹក្សាចិនជាច្រើនមកជួយបង្ហាត់បង្រៀនបុគ្គលិកពេទ្យ និងមានថ្នាំពេទ្យចិនជាច្រើនត្រូវបានបញ្ជូនចូលក្នុងមន្ទីរពេទ្យ ។ ជួនកាលគាត់ឃើញសិក្ខាកាមមកពីតាមបណ្តាខេត្តមកហាត់រៀនក្បួនពេទ្យពីទីប្រឹក្សាចិន ។ នៅឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហមដែលត្រូវរបួសជាច្រើននាក់ ត្រូវបានបញ្ជូនមកសម្រាករបួសនៅក្នុងមន្ទីរពេទ្យ ដោយសារតែមានការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាម ។

វត្តមានរបស់កងទ័ពរបួសទាំងនេះធ្វើឲ្យការងាររបស់ យន កាន់តែមមាញឹកឡើង ។ ទោះជាយ៉ាងនេះក្តី ការរស់នៅរបស់គាត់ក្នុងមន្ទីរពេទ្យ១៧មេសាមានលក្ខណៈប្រសើរច្រើនបើប្រៀបធៀបទៅនឹងប្រជាជននៅតាមទីជនបទ ។ យន ទទួលបានបាយមួយថ្ងៃពីរពេល ។ ប៉ុន្តែនៅពេលខ្វះខាតម្តងៗ គាត់ត្រូវហូបបបរឬនំបុ័ងជំនួស តែការហូបរបៀបនេះមានរយៈពេលខ្លីតែប៉ុណ្ណោះ ។

យន និង រឿង ធ្វើការនៅក្នុងមន្ទីរពេទ្យ១៧មេសា រហូតដល់កងទ័ពវៀតណាមវាយចូលទីក្រុងភ្នំពេញ នៅដើមខែមករា ឆ្នាំ១៩៧៩ ។ យន បានភៀសខ្លួនតាមរថភ្លើងទៅព្រំដែនកម្ពុជា-ថៃ ។ នៅពេលចេញដំណើរ យន និងបងប្រុស បានបែកគ្នា ព្រោះពេលនោះមានសភាពច្របូកច្របល់ខ្លាំងណាស់ ។ យន បានរត់ហូតដល់ស្រុកថ្មគោល ខេត្តបាត់ដំបង ហើយមានបំណងរត់ទៅប្រទេសថៃទៀត ។ ប៉ុន្តែគាត់មិនបានសម្រេចគោលបំណងរបស់គាត់ទេ ដោយសារគ្មានម្ហូបអាហារ និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ធ្វើដំណើរ ។ មានមនុស្សជាច្រើនស្លាប់នៅតាមផ្លូវដោយសារតែខ្វះអាហារ ជំងឺ និងរបួស ។ យន និងមិត្តភក្តិរបស់គាត់ប្រហែល៣០នាក់ផ្សេងទៀត សម្រេចចិត្តរត់ត្រឡប់មកក្រោយវិញ ។ ក្រុមរបស់គាត់មកដល់ខេត្តពោធិសាត់ ពួកគាត់ត្រូវកងទ័ពវៀតណាមចាប់បាន ហើយបាននាំក្រុមគាត់ទៅអប់រំនិងបន្ទាប់មកដោះលែងឲ្យមកស្រុកកំណើតរៀងៗខ្លួនវិញ ។


ឃួន យន

យន បានវិលត្រឡប់មកដល់ស្រុកកំណើតវិញនៅឆ្នាំ១៩៨០ ។ សព្វថ្ងៃ យន ជាកសិកររស់នៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។ សព្វថ្ងៃ យន មានអាយុ៥០ឆ្នាំហើយ ។ គាត់មិនទាន់រៀបការទេ ដោយសារតែគាត់មានបន្ទុកចិញ្ចឹមក្មួយកំព្រាបីនាក់ (ប្រុសម្នាក់និងស្រីពីរនាក់) ។ ម្តាយរបស់កុមារទាំងនេះបានទទួលមរណភាពនៅពេលសម្រាលកូនស្រីពៅបានពីរខែ ។ ចំណែកឪពុករបស់ក្មេងទាំងនេះបានរៀបការជាមួយប្រពន្ធមួយទៀត ហើយទៅរស់នៅខេត្តផ្សេង ដោយទម្លាក់បន្ទុកក្នុងការបីបាច់ថែរក្សាកូនឲ្យមក យន ។ ជីវភាពរបស់ យន មានការលំបាកជាខ្លាំងណាមួយត្រូវទិញទឹកដោះគោមកបំបៅក្មួយស្រីពៅដែលមិនទាន់ផ្តាច់ទឹកដោះ ណាមួយត្រូវរកប្រាក់សម្រាប់ឲ្យក្មួយពីរនាក់ទៀតដែលដល់វ័យចូលរៀនឲ្យបានចូលសាលានឹងគេ ។

ក្រៅពីក្មួយទាំងបីនេះ និង រឿង យន មិនមានសាច់ញាតិណាទៀតទេ ។ ទោះបីជា រឿង បានបាត់ខ្លួនជិត៣០ឆ្នាំហើយក៏ដោយ ក៏គាត់នៅតែសង្ឃឹមថាបងប្រុសគាត់នៅតែនៅរស់រានមានជីវិតនៅឡើយ ហើយថ្ងៃណាមួយនឹងវិលត្រឡប់មកជួបគាត់វិញ ។ នេះជាក្តីសង្ឃឹមតែមួយគត់របស់គាត់ ។ យន តែងយករូបថតមកមើល នៅពេលដែលគាត់នឹកបងប្រុសគាត់ម្តងៗ ។

**ឌី ខាំបូលី**

## ពាក្យស្លោកខ្មែរក្រហម

- ប្តេជ្ញាដើរតាមបក្សដោយឥតលក្ខខណ្ឌ។
- បក្សនេះហើយជាអ្នករំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីការជិះជាន់នានាកសាងកម្ពុជាថ្មី។

*(សៀវភៅកំណត់ហេតុលេខ១១៥)*

# ការកេណ្ឌកុមារឱ្យធ្វើទាហាន និង ឧក្រិដ្ឋកម្មសង្គ្រាម : ការសម្រេចចិត្តទៅលើរឿងក្ដីដំបូងនៅក្នុងតុលាការពិសេស សម្រាប់ប្រទេសសៀរ៉ាឡេអូន អំពីកង្វះយុត្តាធិការ

## ១) *សេចក្ដីផ្ដើម*

*នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ តុលាការ**ពិសេស**សម្រាប់ប្រទេសសៀរ៉ាឡេអូនបានចេញសេចក្ដីសម្រេចថា ការកេណ្ឌកុមារឲ្យធ្វើទាហានគឺជាបទឧក្រិដ្ឋ ។ នេះគឺជារឿងក្ដីសិទ្ធិមនុស្សដំបូងនិងដ៏ចម្រូងចម្រាស់របស់ពិភពលោក ។*

*គោលបំណងសំខាន់នៃអត្ថបទនេះគឺវាយតម្លៃភាពត្រឹមត្រូវនៃការវិនិច្ឆ័យ ជាពិសេសកម្រិតដែលអាចទទួលយកបាននៃកិច្ចខិតខំប្រឹងប្រែងនិងសេចក្ដីសម្រេចរបស់តុលាការ ។ ទីមួយ អត្ថបទនេះនឹងវាយតម្លៃអំពីរបៀបដែលតុលាការសម្រេចថាការហាមឃាត់ការកេណ្ឌកុមារធ្វើទាហានត្រូវចាត់ចូលក្នុងបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងកម្រិតដែលអាចទទួលយកបាននៃសេចក្ដីសម្រេចនេះ ។ ទីពីរ អត្ថបទនេះនឹងពិភាក្សាថាតើតុលាការបានចាត់វិធានការសមរម្យដែរឬទេក្នុងការកំណត់ថាការកេណ្ឌកុមារធ្វើទាហានគឺជាបទឧក្រិដ្ឋនៅក្រោមច្បាប់អន្តរជាតិ ។ ផ្នែកនេះនឹងពិភាក្សាជាបន្តអំពីទំនាក់ទំនងរវាងច្បាប់ទំនៀមទម្លាប់អន្តរជាតិនិងច្បាប់សន្ធិសញ្ញាអន្តរជាតិ ។ ចុងបញ្ចប់ អត្ថបទនេះនឹងពិនិត្យមើលវិធីដែលតុលាការដោះស្រាយគោលការណ៍នីត្យានុកូលភាពដែលជាគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ។ ដើម្បីពិភាក្សាបំណុចទាំងអស់នេះបាន ខ្ញុំ (អ្នកនិពន្ធ) ចាំបាច់ត្រូវបង្កើតដែនកំណត់មួយ ដោយប្រើប្រាស់សាលក្រមរបស់តុលាការអន្តរជាតិ ព្រមទាំងទស្សនៈរបស់អ្នកនិពន្ធអត្ថបទកាសែតឬទស្សនាវដ្ដី ។ ការវិភាគអំពីបទចោទប្រកាន់ចំនួន៧ទៀតប្រឆាំងនឹងជនជាប់ចោទន័រមែនមិនស្ថិតនៅក្នុងការពិភាក្សានេះទេ ។ គោលបំណងរបស់អត្ថបទនេះគឺមិនមែនដើម្បីពិភាក្សាបញ្ហាទៅលើការសន្និដ្ឋានបទដ្ឋានហាមប្រាមការកេណ្ឌកុមារចូលធ្វើទាហានមុនឆ្នាំ១៩៩៦ ហើយក៏មិនមែនដើម្បីបង្ហាញការប៉ះទង្គិចដែលអាចនឹងកើតមានរវាងគោលការណ៍នៃច្បាប់និងគោលការណ៍សីលធម៌ ព្រមទាំងដំណោះស្រាយក្រោយជម្លោះដែលសហគមន៍អន្តរជាតិត្រូវបន្តធ្វើបន្ទាប់ពីការបង្កើតលក្ខន្តិកៈច្បាប់និងតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនទេ ។ គោលបំណងសំខាន់នៃអត្ថបទនេះគឺផ្ដោតសំខាន់ទៅលើបញ្ហានីតិវិធីអន្តរជាតិដែលតុលាការយកមកប្រើ ដើម្បីសម្រេចគោលបំណង ពោលគឺការដកចេញបណ្ដឹងដំបូងដោយសំអាងទៅលើកង្វះយុត្តាធិការច្បាប់ក្នុងការកាត់ទោសជនជាប់ចោទពីបទកេណ្ឌកុមារធ្វើទាហានក្នុងមាត្រា១៤នៃលក្ខន្តិកៈ តុលាការ ។ មុននឹងពិភាក្សាបញ្ហាសំខាន់ទាំងនេះ ចាំបាច់ត្រូវយល់បញ្ហាចម្បងនៃរឿងនេះជាមុនសិន ។*

## ២) *សេចក្ដីសង្ខេបការវិនិច្ឆ័យរបស់តុលាការ*

*ក្នុងរឿងក្ដីន័រមែន សាលាឧទ្ធរណ៍នៃតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនយល់ឃើញថា ការកេណ្ឌកុមារធ្វើទាហានគឺជាឧក្រិដ្ឋកម្មសង្គ្រាមនិងជាការរំលោភច្បាប់អន្តរជាតិ ។ ក្នុងចំណោមបញ្ហាដទៃទៀត មេធាវីចុងចោទជំទាស់ថា តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនគ្មានយុត្តាធិការច្បាប់កាត់ទោសចុងចោទពីបទឧក្រិដ្ឋក្នុងមាត្រា៤នៃលក្ខន្តិកៈហាមប្រាមការកេណ្ឌកុមារក្រោមអាយុ១៥ឆ្នាំឲ្យចូលបម្រើក្នុងជួរកងទ័ពទេ ដោយសារតែឧក្រិដ្ឋកម្មនេះមិនមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលចេញដីកាចោទប្រកាន់ចុងចោទ ។ ការជំទាស់បានបន្តទៀតថា បើទោះបីជាពិធីសារបន្ថែមទី២នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៧៧ និងអនុសញ្ញាស្ដីអំពីសិទ្ធិកុមារឆ្នាំ១៩៩០បានផ្ដល់កាតព្វកិច្ចឲ្យភាគីរដ្ឋទប់ស្កាត់ការកេណ្ឌកុមារធ្វើទាហានក៏ដោយ ក៏លិខិតូបករណ៍ទាំងនេះមិនបានបង្ហាញថាការកេណ្ឌកុមារធ្វើទាហានជាបទឧក្រិដ្ឋឡើយ ។ នៅចុងបញ្ចប់ មេធាវីចុងចោទបានលើកឡើងថា ទោះបីជាលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ១៩៩៨ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រែក្លាយការកេណ្ឌកុមារធ្វើទាហានជាបទឧក្រិដ្ឋក៏ដោយ ក៏លក្ខន្តិកៈនេះមិនបានប្រមូលទំនៀមទម្លាប់*

អន្តរជាតិយកមកចងក្រងជាច្បាប់ទេ ។

មេធាវីដើមចោទបានអះអាងថា ឧក្រិដ្ឋកម្មកេណ្ឌកុមារធ្វើទាហានគឺជាផ្នែកមួយក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលពាក់ព័ន្ធនឹងការចោទប្រកាន់ ហើយថា លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិពិតជាបានប្រមូលចងក្រងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ រដ្ឋអាជ្ញាបានកត់សម្គាល់សម្តីរបស់រដ្ឋអាជ្ញានៅក្នុងរឿងក្តី ថាឌីក នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីថា "ក្នុងករណីណាក៏ដោយ ក៏ការទទួលខុសត្រូវជាបុគ្គលលើបទឧក្រិដ្ឋអាចកើតឡើងបាន បើទុកជាមានកង្វះខាតបទបញ្ញត្តិនៅក្នុងសន្ធិសញ្ញានិយាយជាពិសេសដល់ការទទួលខុសត្រូវជាបុគ្គលក៏ដោយ" ។ មេធាវីដើមចោទបន្ថែមទៀតថា ការទទួលខុសត្រូវជាអន្តរជាតិចំពោះការកេណ្ឌកុមារមានប្រភពមកពីលិខិតូបករណ៍ច្បាប់ជាច្រើន ហើយមិនដូចជាប្រព័ន្ធច្បាប់ក្នុងស្រុកទេ ច្បាប់អន្តរជាតិពុំមានសភាដែលមានអំណាចនីតិបញ្ញត្តិ ហេតុដូច្នេះហើយបានជាគ្មានលក្ខន្តិកៈដែលប្រកាសថា ទង្វើនេះជាបទឧក្រិដ្ឋក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ។ និយាយម្យ៉ាងទៀត មេធាវីដើមចោទបានទាញហេតុផលថា គោលការណ៍ច្បាប់របស់ទីក្រុងខេបថោន ដែលអនុម័តដោយសន្និសីទស្តីអំពីការទប់ស្កាត់កុមារមិនឲ្យចូលបម្រើក្នុងជួរកងទ័ព ការរំសាយកងទ័ព និងការធ្វើសមាហរណកម្មកងទ័ពវ័យក្មេងនៅប្រទេសអាហ្វ្រិក បានបង្កើតឲ្យការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលនៅត្រឹមថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧ ។ ក្នុងករណីនេះ មេធាវីដើមចោទបានចោទប្រកាន់បន្ថែមថា ១) ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលលើការកេណ្ឌកុមារធ្វើទាហានបានបង្កើតនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៨ ចំពេលដែលប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិថ្កោលទោសការជ្រើសរើសទាហានក្មេងៗ និងអំពាវនាវឲ្យភាគីទាំងអស់បញ្ចេញសកម្មភាពប្រឆាំងដោយអនុវត្តទៅតាមកាតព្វកិច្ចរបស់ខ្លួននៅក្រោមច្បាប់អន្តរជាតិព្រមទាំងអំពាវនាវឲ្យកាត់ទោសអ្នកដែលទទួលខុសត្រូវចំពោះបទល្មើសក្រោមច្បាប់មនុស្សធម៌អន្តរជាតិ និង ២) ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលចំពោះការកេណ្ឌកុមារធ្វើទាហានបានបង្កើតឡើងនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ បន្ទាប់ពីការអនុម័តលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។

សាលាឧទ្ធរណ៍សង្កេតឃើញថា មុនខែវិច្ឆិកា ឆ្នាំ១៩៩៦ ការហាមប្រាមលើការកេណ្ឌកុមារធ្វើទាហានជារឿងធម្មតានៅក្នុងច្បាប់អន្តរជាតិ ។ តុលាការបានសម្គាល់ឃើញថា ប្រទេសសៀរ៉ាឡេអូនបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវស្តីអំពីការគាំពារជនស៊ីវិលនៅក្នុងអំឡុងពេលសង្គ្រាម និងបានសម្គាល់ឃើញថា មាត្រា១៤និង២៤កំណត់ថា ភាគីដែលរៀបចំកិច្ចព្រមព្រៀងត្រូវតែការពារកុមារដែលមានអាយុក្រោម១៥ឆ្នាំឲ្យផុតពីឥទ្ធិពលសង្គ្រាម ។ ម្យ៉ាងទៀត តុលាការសម្គាល់ឃើញទៀតថា ប្រទេសសៀរ៉ាឡេអូនបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ស្តីអំពីការការពារជនរងគ្រោះដោយជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារបន្ថែមទីមួយ) ហើយពិធីសារបន្ថែមស្តីអំពីការការពារជនរងគ្រោះដោយជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ។ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន សង្កេតឃើញថា ពិធីសារទាំងនេះក៏បានជួយទប់ស្កាត់ការកេណ្ឌកុមារធ្វើទាហានដែរ ។

ដោយឈរលើមូលដ្ឋាននៃការអនុវត្តរបស់រដ្ឋដែលជាធាតុផ្សំមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ តុលាការបានសម្គាល់ឃើញថា បញ្ជីឈ្មោះរដ្ឋដែលមានច្បាប់ទាក់ទិននឹងការកេណ្ឌទាហានថ្មី ឬការចុះឈ្មោះក្នុងបញ្ជីដោយចេតនា បង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ស្ទើរតែគ្រប់រដ្ឋទាំងអស់បានហាមប្រាម (និងអនុវត្តបែបនេះជាយូរមកហើយ) ការកេណ្ឌកុមារអាយុក្រោម១៥ឆ្នាំឲ្យធ្វើទាហាន ។ ដោយរដ្ឋចំនួន១៨៥ រួមទាំងប្រទេសសៀរ៉ាឡេអូន បានក្លាយជាសមាជិកនៃអនុសញ្ញាទីក្រុងហ្សឺណែវមុនឆ្នាំ១៩៩៦ បទបញ្ញត្តិនៃអនុសញ្ញាទាំងនោះ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។

តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនកត់សម្គាល់ទៀតថា រដ្ឋទាំងអស់លើកតែរដ្ឋចំនួន៦ បានឲ្យសច្ចាអនុម័តលើអនុសញ្ញាស្តីអំពីសិទ្ធិកុមារក្នុងឆ្នាំ១៩៩៦ ។ ទាក់ទិននឹងអនុសញ្ញានេះ តុលាការបញ្ជាក់ថា ការទទួលស្គាល់និងទទួលយកជាសកលនៃបទដ្ឋានហាមប្រាមការកេណ្ឌកុមារធ្វើទាហាននៅក្នុងពិធីសារបន្ថែមទីពីរ និងអនុសញ្ញាស្តីអំពីសិទ្ធិកុមារ ផ្តល់ភ័ស្តុតាងយ៉ាងជាក់

ច្បាស់ថា បទដ្ឋានអនុសញ្ញាបានចូលក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៩៦ ។ ប្រការដែលថាពុំមាន "ខ" រក្សាសិទ្ធិណាមួយដើម្បីបន្ថយកាតព្វកិច្ចច្បាប់ក្រោមមាត្រា៣៨នោះ គឺជាបទបញ្ញត្តិមួយក្នុងចំណោមបទបញ្ញត្តិអនុសញ្ញាតិចបំផុតដែលអាចអះអាងអំពីការទទួលយកជាសកល ។

ដោយយល់ឃើញថាការកេណ្ឌកុមារធ្វើទាហានបានក្លាយទៅជាបទឧក្រិដ្ឋមុនការកេណ្ឌនោះត្រូវបានហាមប្រាមក្នុងច្បាប់សន្ធិសញ្ញាដែលចុះនៅខែវិច្ឆិកា ឆ្នាំ១៩៩៦ ដែលជាចំណុចនៃពេលវេលាទាក់ទិននឹងដីកាចោទប្រកាន់ តុលាការបានច្រានចោលនូវបណ្តឹងដំបូងដែលសំអាងទៅលើកង្វះយុត្តាធិការច្បាប់ ។

ចៅក្រម ជើហ្វ្រី រូបឺតសុន ជំទាស់ថា ការកេណ្ឌកុមារធ្វើទាហានមិនមែនជាបទឧក្រិដ្ឋនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិទេមុនពេលមានការបង្កើតលក្ខន្តិកៈក្រុងរ៉ូមក្នុងឆ្នាំ១៩៩៨ដែលនាំឲ្យមានការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនោះ ។ ផ្នែកបន្ទាប់នេះនឹងពិនិត្យពិច័យទៅលើបទដ្ឋានច្បាប់ទំនៀមទម្លាប់ និងវាយតម្លៃថាតើតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនកំណត់ការហាមប្រាមការកេណ្ឌកុមារធ្វើទាហានដែលមានក្នុងលក្ខន្តិកៈច្បាប់ទំនៀមទម្លាប់អន្តរជាតិតាមវិធីណា ហើយការវាយតម្លៃនឹងធ្វើឡើងអនុលោមទៅតាមករណីយុត្តិសាស្ត្រ និងអត្ថបទស្រាវជ្រាវផ្នែកច្បាប់ ។

### ៣) ការកេណ្ឌកុមារធ្វើទាហាននិងបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ

ទោះបីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិមានការផ្លាស់ប្តូរជាប់ជានិច្ច និងមិនអាចយកមកធ្វើជាប្រធានបទនៃការវាយឈ្មោះយ៉ាងច្បាស់លាស់ក៏ដោយ នៅតែមានមតិយល់ស្របទៅលើធាតុផ្សំដើម្បីបង្កើតនូវបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ។ យោងតាមគណៈកម្មការច្បាប់អន្តរជាតិ គោលការណ៍ទាំងនេះរួមមាន ៖ ក) ការអនុវត្តស្របគ្នាមួយដោយភាគីរដ្ឋមួយចំនួនយោងទៅតាមស្ថានភាពមួយក្នុងវិស័យទំនាក់ទំនងអន្តរជាតិ ខ) ការបន្តអនុវត្តឬការអនុវត្តដដែលៗក្នុងអំឡុងពេលវែងណាមួយ គ) គំនិតដែលការអនុវត្តត្រូវតាមនិងស្របតាមច្បាប់មូលដ្ឋានអន្តរជាតិ ឃ) ការស្រុះស្រួលដែលអនុវត្តដោយភាគីរដ្ឋដទៃទៀត ។

ជាមួយគ្នានេះដែរ សាស្ត្រាចារ្យ អៀន ប្រោនលី បានពិសោធន៍ឃើញមានធាតុផ្សំ៤ដូចគ្នាក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺ រយៈពេល ការឯកភាពគ្នានិងការអនុវត្តដូចៗគ្នា ភាពទូលំទូលាយនៃការអនុវត្ត និងការអនុវត្តប្រកបដោយកាតព្វកិច្ច ។ ដើម្បីពន្យល់អំពីបញ្ហានេះ អ្នកជំនាញច្បាប់ដ៏ល្បីល្បាញម្នាក់បានសរសេរថា "ភ័ស្តុតាងល្អបំផុតបញ្ជាក់ថាមានវិធានទំនៀមទម្លាប់មួយនៃច្បាប់អន្តរជាតិ គឺត្រូវស្វែងយល់នូវអ្វីដែលភាគីរដ្ឋគិតថាច្បាប់ គឺជាអ្វីដែលរដ្ឋទាំងនោះនិយាយ ហើយរដ្ឋទាំងនោះកំពុងធ្វើអ្វីឬមិនធ្វើអ្វីទាក់ទងនឹងវិធាននោះ" ។

ស្របពេលគ្នានេះដែរ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនយល់ថាការបង្កើតច្បាប់ទំនៀមទម្លាប់នេះតម្រូវឲ្យមានទាំងការអនុវត្តរបស់រដ្ឋ និងការស្គាល់ពីកាតព្វកិច្ចដែលមានពីមុន ហើយ "ការយល់អំពីកាតព្វកិច្ច និងមិនអនុវត្តតាមទម្លាប់ គឺគ្មានអ្វីប្រសើរជាងវោហារសព្វបូកនឹងការអនុវត្តរបស់រដ្ឋដោយគ្មានបង្កប់កាតព្វកិច្ចដែលគ្រាន់តែជាទម្លាប់នោះទេ" ។ ចំពោះការអនុវត្តរបស់រដ្ឋប្រការដែលថា តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនលើកឡើងអំពីរដ្ឋមួយចំនួនបានឲ្យសច្ចាអនុម័តលើអនុសញ្ញា និងសន្ធិសញ្ញាដូចជាពិធីសារបន្ថែមទីពីរនៃអនុសញ្ញាហ្សឺណែវនិងអនុសញ្ញាស្តីអំពីសិទ្ធិកុមារ ធម្មនុញ្ញអាហ្វ្រិកស្តីអំពីសិទ្ធិ និងសុខុមាលភាពរបស់កុមារគឺទាក់ទិនទៅនឹងរឿងក្តីនេះ ។ សន្ធិសញ្ញាគឺជាផ្នែកមួយនៃការអនុវត្តរបស់រដ្ឋ និងអាចបង្កើតច្បាប់ទំនៀមទម្លាប់ តួយ៉ាងប្រសិនបើសន្ធិសញ្ញាឬអត្ថបទច្បាប់រៀបចំគាក់តែងសន្ធិសញ្ញានេះអះអាងថា សន្ធិសញ្ញានេះសម្រេចយកច្បាប់ទំនៀមទម្លាប់ពីមុន ។ ពេលខ្លះទៀត សន្ធិសញ្ញាដែលមិនត្រូវបានអនុវត្តតាមកាតព្វកិច្ច ឬច្បាប់អាចត្រូវបានអនុវត្តនៅពេលក្រោយទៀត ។ ក្នុងករណីបែបនេះមិនមែនសន្ធិសញ្ញាទេ ដែលបង្កើតច្បាប់ទំនៀមទម្លាប់ គឺការអនុវត្តជាបន្តបន្ទាប់ទេ ដែលជាអ្នកបង្កើតច្បាប់ទំនៀមទម្លាប់នេះឡើង ។

ទោះជាតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនយល់អំពីបទបញ្ញត្តិនៃសន្ធិសញ្ញាក៏ដោយ ក៏តុលាការពិសេសនេះមិនបង្ហាញនូវភ័ស្តុតាងណាមួយអំពីការអនុវត្តច្បាប់ជាក់ស្តែងនិងភ័ស្តុតាងនៃកាតព្វកិច្ចចាំបាច់ដើម្បីបង្ហាញវត្តមានបទដ្ឋាននៃច្បាប់ទំនៀមទម្លាប់ហាមប្រាមការកេណ្ឌកុមារធ្វើទាហានដែរ ។

តុលាការនេះចាំបាច់ត្រូវបង្កើតឲ្យមានការពិនិត្យពិច័យជាទូទៅ និងច្បាប់ទំនៀមទម្លាប់ក្នុងស្រុកដែលទាក់ទិននឹងការកេណ្ឌកុមារធ្វើទាហានដែលនឹងត្រូវលើកយកមកពិភាក្សានៅខាងក្រោមនេះ ។

### ការពិនិត្យពិច័យជាទូទៅ

ប្រការដែលមានការអនុវត្តញឹកញយឬជាទម្លាប់តែមួយគឺមិនគ្រប់គ្រាន់ឡើយ ។ មានសកម្មភាពជាអន្តរជាតិជាច្រើនទៀតគួយ៉ាងដូចជា នៅក្នុងឯកសារពិធីផ្លូវការនិងពិធីសារដែលធ្វើឡើងដូចៗគ្នាស្ទើរតែទាំងអស់ ក៏ប៉ុន្តែត្រូវជំរុញដោយភាពទិន្នលំទោនការគួរសម ឬប្រពៃណី និងមិនមែនធ្វើដោយការយល់ដឹងពីកិច្ចការច្បាប់ឡើយ ។

ប្រការដែលរដ្ឋាភិបាលមិនអនុវត្តនូវអ្វីដែលខ្លួនបាននិយាយនោះគឺមិនមានអ្វីដែលគួរភ្ញាក់ផ្អើលឡើយ ។ តាមពិត យើងនឹងភ្ញាក់ផ្អើលទៅវិញប្រសិនបើរដ្ឋាភិបាលបានធ្វើនូវអ្វីដែលខ្លួនបាននិយាយយ៉ាងហោចណាស់ក្នុងតំបន់មួយចំនួន ។ ក៏ប៉ុន្តែ តាមវិធាននៃច្បាប់អន្តរជាតិបែបវិជ្ជមាននិយម យើងជាមេធាវីត្រូវបានស្នើសុំឲ្យកំណត់ថាតើអ្វីដែលសន្មតថាជាគោលការណ៍ច្បាប់ទំនៀមទម្លាប់ពិតជាឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តជាទូទៅ និងដែលមានលក្ខណៈដូចគ្នាដោយភាគីរដ្ឋដែលផុសចេញពីការយល់ដឹងអំពីកាតព្វកិច្ចច្បាប់ដែរឬទេ ។ កាតព្វកិច្ចនេះ "ការអនុវត្តប្រកបដោយកាតព្វកិច្ច" សុំឲ្យមានការជឿជាក់ពីរដ្ឋដែលត្រូវការអនុវត្តជាចាំបាច់ក្នុងស្មារតីច្បាប់ដែលតម្រូវឲ្យមានការអនុវត្តបែបនេះ ។ ផ្អែកតាមសាលក្រមតុលាការអន្តរជាតិ "អំពើតែមួយមុខមិនមានន័យថាជាគន្លងសម្រាប់អនុវត្តនោះទេ ។ ត្រូវបន្ថែមការអនុវត្តដូចៗគ្នាដែលជាភស្តុតាងបញ្ជាក់អំពីជំនឿថា ការអនុវត្តបែបនេះគឺជាការបំពេញកាតព្វកិច្ចតាមរយៈវិធាននៃច្បាប់ដែលតម្រូវយ៉ាងដូចនេះ" ។ សាលក្រមនេះបញ្ជាក់អំពើនិងការអនុវត្តដដែលបង្កើតឲ្យមានទំនៀមទម្លាប់ឡើង ហើយការអនុវត្តនេះអាចបង្កើតនូវជំនឿថាវាបានក្លាយទៅជាកាតព្វកិច្ចថែមទៀត ។ លោកស្រី ហ្គ្រេខាម៉ាឆែល ដែលជាអ្នកសរសេររបាយការណ៍នៃអគ្គការសហប្រជាជាតិស្តីអំពីឥទ្ធិពលនៃជម្លោះប្រដាប់អាវុធទៅលើកុមារ បានប៉ាន់ប្រមាណថា នៅក្នុងឆ្នាំ១៩៩៥ និង១៩៩៦ កុមារចំនួន២៥ម៉ឺននាក់បានចូលបម្រើទាំងក្នុងជួរកងទ័ពរដ្ឋាភិបាលនិងក្នុងកងកម្លាំងប្រឆាំង ។ អ្នកនិពន្ធបានចាត់ការចូលរួមរបស់ទាហានកុមារនៅក្នុងសង្គ្រាមជានិន្នាការដ៏គួរឲ្យព្រួយបារម្ភបំផុតមួយក្នុងជម្លោះប្រដាប់ អាវុធ ។ ពាក្យសម្តីនេះបានក្លាយជាការពិត ។ នៅឆ្នាំ២០០១ ក្នុងបណ្តាប្រទេសជាង៤០នៅលើពិភពលោក មានកុមារជាង៣សែននាក់ បានតស៊ូប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលនិងក្រុមប្រដាប់អាវុធនានា ។ ជាក់ស្តែង កុមារក្នុងប្រទេសចំនួន៨៧ ត្រូវបានជ្រើសឲ្យចូលក្នុងកងទ័ពរដ្ឋាភិបាល យោធាប្រតិព័ទ្ធកងជីវពលស៊ីវិល និងក្រុមប្រដាប់អាវុធមិនស្ថិតក្នុងក្របខ័ណ្ឌរដ្ឋ ។ តាមរបាយការណ៍ពិភពលោកស្តីអំពីទាហានកុមារដែលបានធ្វើការវិភាគការកេណ្ឌធ្វើទាហានដោយរដ្ឋាភិបាល និងក្រុមប្រដាប់អាវុធក្នុងប្រទេសចំនួន ១៨០ មានរដ្ឋចំនួន៨៧បានកេណ្ឌកុមារឲ្យចូលក្នុងកងទ័ពរដ្ឋាភិបាល យោធាប្រតិព័ទ្ធ កងជីវពលស៊ីវិល និងក្រុមប្រដាប់អាវុធមិនស្ថិតក្នុងក្របខ័ណ្ឌរដ្ឋ ។

### ទំនៀមទម្លាប់ក្នុងស្រុក

ទាក់ទិននឹងទំនៀមទម្លាប់ក្នុងស្រុក តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន មិនបានស្រាវជ្រាវត្រឹមត្រូវលើការអនុវត្តច្បាប់ក្នុងស្រុកឲ្យបានពិតប្រាកដ ជាមួយការស្គាល់ពីកាតព្វកិច្ចឡើយ ដែលតាមប្រសាសន៍របស់លោកសាស្ត្រាចារ្យ វ៉ូដលី គឺថា "រដ្ឋគិតថា វិធានគឺជាអ្វីដែលខ្លួននិយាយ ហើយរដ្ឋទាំងនោះកំពុងតែធ្វើអ្វីដែលខ្លួននិយាយ" ។ ប្រទេសភាគច្រើននៅទ្វីបអាហ្វ្រិកបាន និងកំពុងតែអនុវត្តការកេណ្ឌកុមារធ្វើទាហាន ។ តាមការប្រមើលបច្ចុប្បន្ននេះមានកុមារជាង១២ម៉ឺននាក់ ដែលខ្លះមានអាយុតិចជាង៧ឬ៨ឆ្នាំ កំពុងតែតស៊ូប្រយុទ្ធនៅក្នុងជម្លោះប្រដាប់អាវុធទូទាំងទ្វីបអាហ្វ្រិក ក្នុងនោះរួមមានប្រទេសអង់ហ្គោឡា ប៊ូរុនឌី កុងហ្គោ-ប្រាហ្សាវីល សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ អេត្យូពី លីបេរីយ៉ា រ៉្វាន់ដា សៀរ៉ាឡេអូន ស៊ូដង់ និងយូហ្គាន់ដា ទោះបីជាប្រទេសជាច្រើននៃប្រទេសទាំងនោះបានចុះហត្ថលេខានិងអនុម័តពិធីសារបន្ថែមលើអនុសញ្ញាស្តីអំពីសិទ្ធិកុមារ ឬពិធីសារបន្ថែមទីពីរនៃអនុសញ្ញាទីក្រុងហ្សឺណែវក៏ដោយ ។ ជាក់ស្តែង នៅក្នុងប្រទេសសៀរ៉ាឡេអូនមានកុមារ៥ពាន់នាក់បានបម្រើក្នុងរដ្ឋាភិបាលនិងកងកម្លាំងប្រឆាំងក្នុងអំឡុងពេលមានជម្លោះ និងកុមារ៥ពាន់នាក់ទៀតកំពុងត្រូវបានកេណ្ឌធ្វើជាកម្លាំងទ័ពក្នុងក្រុមប្រដាប់អាវុធនានា ។ បញ្ហា

ដែលសំខាន់ គឺរដ្ឋទាំងនោះចុះហត្ថលេខា និងអនុម័តសន្ធិសញ្ញាដែលមានជាប់ពាក់ព័ន្ធជាច្រើនទៀត ។

ភាពខុសគ្នាក៏អាចជាបញ្ហាដែរ ក៏ប៉ុន្តែតាមទិន្នន័យដែលទទួលបាន មានការខ្វែងគំនិតគ្នានិងភាពខុសគ្នាទៅលើការហាមប្រាមការកេណ្ឌកុមារចូលធ្វើទាហាននៅក្នុងតំបន់ ។ ហេតុដូច្នេះហើយ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនខកខានមិនបានបង្កើតទំនៀមទម្លាប់ដូចៗគ្នាដែលហាមការកេណ្ឌនិងប្រើប្រាស់ទាហានកុមារ ។ តុលាការពិភពលោកក្នុងរឿងក្តីស្តីអំពីការសុំសិទ្ធិជ្រកកោនសម្រេចថា ទំនៀមទម្លាប់មិនអាចកើតឡើងបានទេ ប្រសិនបើមានភាពមិនច្បាស់លាស់និងការខ្វែងគំនិតគ្នា ។ ក្នុងរឿងនេះដែរ បន្ទាប់ពីរដ្ឋប្រហារមិនបានសម្រេចនៅប្រទេសប៉េរូ ក្នុងឆ្នាំ១៩៤៨ មេដឹកនាំចលនាខុទ្ទាមបានស្វែងជម្រកលាក់ខ្លួន និងសិទ្ធិជ្រកកោន ផ្នែកការទូតនៅស្ថានទូតកូឡុំប៊ីក្នុងទីក្រុងលីម៉ា ដែលជារដ្ឋធានីនៃប្រទេសប៉េរូ ។ រដ្ឋាភិបាលប៉េរូបានបដិសេធជាបន្តបន្ទាប់នូវការផ្តល់សុវត្ថិភាពសម្រាប់មេដឹកនាំខុទ្ទាម ហើយជម្លោះនេះនាំឲ្យមានកិច្ចព្រមព្រៀងមួយស្នើសុំការសម្រេចរបស់តុលាការអន្តរជាតិ ។ បញ្ហាមួយគឺថា តើទំនៀមទម្លាប់ក្នុងស្រុកមានអត្ថិភាពក្នុងទ្វីបអាមេរិកឡាទីន អនុញ្ញាតឲ្យរដ្ឋមួយមានសិទ្ធិផ្តល់សិទ្ធិជ្រកកោនផ្នែកនយោបាយ និងការគាំពារចំពោះអ្នកស្វែងរកសិទ្ធិជ្រកកោនដែរឬទេ ។

ដោយសារតែកត្តាភស្តុតាង តុលាការយុត្តិធម៌អន្តរជាតិបានបដិសេធថាពុំមានទំនៀមទម្លាប់ក្នុងស្រុកដែលអនុញ្ញាតឲ្យផ្តល់សិទ្ធិបែបនេះឡើយ ។

“តុលាការយល់ឃើញថាមានភាពមិនច្បាស់លាស់ភាពខ្វែងគំនិតគ្នា ការប្រែប្រួល និងភាពមិនស្របគ្នាក្នុងការអនុវត្តសិទ្ធិជ្រកកោនការទូត និងក្នុងទស្សនៈផ្លូវការតាមពេលវេលាផ្សេងៗ និងមានភាពមិនស្របគ្នាជាច្រើនក្នុងសេចក្តីសម្រេចយ៉ាងឆាប់រហ័សនៃអនុសញ្ញាស្តីអំពីសិទ្ធិជ្រកកោនដែលរដ្ឋមួយចំនួនបានអនុម័តនិងរដ្ឋមួយចំនួនទៀតបានច្រានចោលព្រមទាំងការពិនិត្យពិច័យអំពីកាលានុវត្តន៍ដែលមានក្នុងរឿងក្តីផ្សេងៗទៀតបានជះឥទ្ធិពលដល់ការអនុវត្តនេះ ដែលមិនអាចដឹងច្បាស់អំពីការអនុវត្តច្បាប់តែមួយនិងដូចគ្នាទាក់ទិននឹងវិធានស្តីអំពីកម្រិតបទល្មើសជាឯកតោភាគី និងច្បាស់លាស់ដែលអាចទទួលបានសិទ្ធិជ្រកកោន ដោយមិនប្រើប្រាស់បទដ្ឋានទំនៀមទម្លាប់ក្នុងការអំពាវនាវសុំឲ្យមានការអនុវត្តច្បាប់ពីរដ្ឋ និងដោយគ្រាន់តែនិយាយយោងលើសេចក្តីសម្រេចនៃច្បាប់អនុសញ្ញាអន្តរជាតិ ក្រោមអនុសញ្ញាស្តីអំពីសិទ្ធិកុមារនិងសន្ធិសញ្ញាដទៃទៀត ក្រុមប្រឹក្សាសន្តិសុខបានច្រានចោលសញ្ញាណដែលថាមានទំនៀមទម្លាប់អន្តរជាតិប្រឆាំងនឹងការកេណ្ឌកុមារធ្វើទាហាន ។

ដោយរួមបញ្ចូលសេចក្តីសម្រេចនិងដំបូន្មានរបស់តុលាការពិភពលោកជាមួយនឹងអ្នកនិពន្ធអត្ថបទកាសែតនិងទស្សនាវដ្តីមានធាតុផ្សំបួនសម្រាប់ឲ្យទំនៀមទម្លាប់កើតបាន ៖ ការអនុវត្តរបស់រដ្ឋ ការស្របគ្នានៃការអនុវត្តជាមួយនឹងការពិនិត្យពិច័យទូទៅ និងជាក់លាក់រយៈពេលនៃការអនុវត្ត និងការអនុវត្តបង្កប់ដោយកាតព្វកិច្ច ។

សំណើសុំការពិនិត្យសម្រេចរបស់មេធាវីដើមចោទនិងការសន្និដ្ឋានរបស់តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនដែលថាឧក្រិដ្ឋកម្មកេណ្ឌកុមារធ្វើទាហានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ (មុនពេលការបង្កើតតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន) មិនបានពិចារណាអំពីព័ត៌មានដែលថារដ្ឋជាច្រើនបានអនុម័តសន្ធិសញ្ញា ក៏ប៉ុន្តែរដ្ឋទាំងនោះមិនបានបំពេញកាតព្វកិច្ចដែលខ្លួនសន្មតស្ថិតនៅក្រោមលិខិតូបករណ៍ទាំងនោះឡើយ ។ ប្រការនេះជួយផ្តល់ហេតុផលបន្ថែមទៅលើមូលហេតុដែលថាការយោងបទបញ្ញត្តិសន្ធិសញ្ញាហាមប្រាមការកេណ្ឌកុមារធ្វើទាហានមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្កើតការអនុវត្តរបស់រដ្ឋដែលចាំបាច់សម្រាប់បង្កើតទំនៀមទម្លាប់អន្តរជាតិឡើយ ។ ម្យ៉ាងវិញទៀត ដោយសំអាងលើការអនុវត្តក្នុងស្រុកនៃរដ្ឋតុលាការ ពិសេសនៅប្រទេសសៀរ៉ាឡេអូន មិនចាត់ទុកការអនុវត្តបង្កប់ ដោយកាតព្វកិច្ចជាធាតុផ្សំចាំបាច់សម្រាប់បង្កើតទំនៀមទម្លាប់អន្តរជាតិឡើយ ។ បញ្ហាចុងក្រោយគឺថា ភាពមិនស្របគ្នាក្នុងការអនុវត្តអាចបន្ថយភាពត្រឹមត្រូវនៃការសម្រេចសេចក្តីនេះ ។ តាមរយៈការវាយតម្លៃនេះឃើញថា សេចក្តីសម្រេចរបស់តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន រួមមានការអនុវត្តពីរដ្ឋដោយយោងតាមចំនួនរដ្ឋដែលអនុម័តសន្ធិសញ្ញា និងរយៈពេលអនុវត្ត

ដោយមិនរាប់បញ្ចូលការមិនបង្ហាញច្បាស់លាស់អំពីចំណុចពេលវេលាទាក់ទងនឹងការហាមប្រាមការកេណ្ឌកុមារធ្វើទាហានថាមានលក្ខណៈជាទំនៀមទម្លាប់អន្តរជាតិឡើយ ។ ប៉ុន្តែចំណុចសំខាន់បំផុតក្នុងកំណត់សម្គាល់នោះគឺសេចក្តីសម្រេចរបស់តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនមិនបានពិចារណាធាតុផ្សំនៃការពិនិត្យពិច័យជាទូទៅនិងទំនៀមទម្លាប់ក្នុងស្រុក ព្រមទាំងការអនុវត្តប្រកបដោយកាតព្វកិច្ច ។

រដ្ឋមួយចំនួនបានតាក់តែងច្បាប់ដែលទាក់ទិននឹងការកេណ្ឌកុមារធ្វើទាហានដោយស្ម័គ្រចិត្ត និងរដ្ឋជាភាគីមួយចំនួនដូចជាប្រទេសសៀរ៉ាឡេអូនបានចុះហត្ថលេខលើអនុសញ្ញាទីក្រុងហ្សឺណែវមុនឆ្នាំ ១៩៩៦ ពិធីសារបន្ថែមទីពីរ អនុសញ្ញាស្តីពីសិទ្ធិកុមារនិងធម្មនុញ្ញអាហ្វ្រិកស្តីអំពីសិទ្ធិនិងសុខុមាលភាពកុមារ ។ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនបានសន្និដ្ឋានថា ការហាមប្រាមការកេណ្ឌកុមារធ្វើទាហានមានលក្ខណៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៩៦ ។ ជាការពិត ដូចដែលយោបល់ជំទាស់បានពន្យល់ថាអនុសញ្ញាទាំងនោះអាចដាក់កាតព្វកិច្ចឲ្យភាគីរដ្ឋទប់ស្កាត់ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិ ប៉ុន្តែបញ្ហាសំខាន់ដែលត្រូវយកមកពិចារណានៅទីនេះគឺថា តើការហាមប្រាមការកេណ្ឌកុមារធ្វើទាហានបណ្តាលឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលដែរឬទេក្នុងពេលនោះ (ឆ្នាំ១៩៩៦) ។ ដើម្បីសាកល្បងសម្មតិកម្មនេះ ជាដំបូងត្រូវកំណត់ថាការកេណ្ឌកុមារធ្វើទាហានជាបទព្រហ្មទណ្ឌអន្តរជាតិក្រោមច្បាប់អន្តរជាតិ ។ ផ្នែកបន្ទាប់ទៀតនេះនឹងពិភាក្សាទៅលើលក្ខណៈវិនិច្ឆ័យបទល្មើសដែលជាបទព្រហ្មទណ្ឌអន្តរជាតិជាពិសេសឧក្រិដ្ឋកម្មសង្គ្រាម ហើយនឹងពិភាក្សាថាតើតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនបានចាត់វិធានការសមស្របដែរឬទេ ក្នុងការសម្រេចសេចក្តី ។

## ៤) ការកេណ្ឌកុមារធ្វើទាហាន និង ឧក្រិដ្ឋកម្មសង្គ្រាម

ទោះបីគ្មានមតិស្របគ្នាជាមូលដ្ឋានសម្រាប់កំណត់បទព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏អ្នកសិក្សាស្រាវជ្រាវច្បាប់ដ៏ល្បីល្បាញម្នាក់យល់ថាបទឧក្រិដ្ឋអន្តរជាតិ គឺជាទង្វើមួយដែលសហគមន៍អន្តរជាតិទទួលស្គាល់ថា មិនត្រឹមតែជាការរំលោភច្បាប់ព្រហ្មទណ្ឌរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចាត់ទុកជាទង្វើដ៏ធ្ងន់ធ្ងរមួយដែលត្រូវបានចាត់ទុកជាការព្រួយបារម្ភមួយរបស់អន្តរជាតិ ។ អ្នកនិពន្ធជាច្រើនគឺថា មិនអាចទុកបញ្ហានេះឲ្យភាគីរដ្ឋដែលមានយុត្តាធិការលើបទឧក្រិដ្ឋនេះដោះស្រាយឡើយ ។ ហេតុផលទាំងនោះរួមមានប្រសិទ្ធភាពច្បាប់ ការអនុវត្តច្បាប់ និងការព្រួយបារម្ភពីការកាត់ទោសដែលអាចនឹងកើតមានឡើងដោយសាររដ្ឋដែលមានសមត្ថកិច្ច ។ លោកក៏ទទួលស្គាល់ថា ឧក្រិដ្ឋកម្មអន្តរជាតិស្ទើរតែទាំងអស់មានលក្ខណៈរំលោភបំពានលើសិទ្ធិមនុស្ស ហើយឧក្រិដ្ឋកម្មជាច្រើនទៀតមានលក្ខណៈរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិដែលកត្តានេះធ្វើឲ្យគោលការណ៍ ឬដែនកំណត់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិពុំមានលក្ខណៈច្បាស់លាស់ ។ ឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួនកំពុងរីករាលដាលយ៉ាងឆាប់រហ័សចាប់តាំងពីទសវត្សទី៤០ ក៏ប៉ុន្តែនៅមានការខ្វែងគំនិតគ្នាទៅលើលក្ខណៈច្បាស់លាស់នៃបទល្មើសទាំងនោះ ។ អ្នកនិពន្ធជាច្រើនបានអះអាងថា ដើម្បីបញ្ជាក់ថាបទឧក្រិដ្ឋមួយមិនមែនជាឧក្រិដ្ឋកម្មអន្តរជាតិបាន លុះត្រាណាតែបទឧក្រិដ្ឋនោះមិនត្រូវបានកាត់ទោសនៅក្នុងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិពិសេស ឬអចិន្ត្រៃយ៍ (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉ាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ) ក៏ប៉ុន្តែការកំណត់បែបនេះនឹងមិនរាប់បញ្ចូលនូវបទឧក្រិដ្ឋអន្តរជាតិចាស់ៗមួយចំនួន ដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយដូចជាចោរកម្មសមុទ្រជាដើម ។ ដូចនេះហើយបានជាអ្នក និពន្ធពីររូប គឺ ដេន និង សិតស៍ យល់ឃើញថាការកំណត់បែបនេះ គឺគ្រាន់តែជាចំណុចផ្តើមមួយប៉ុណ្ណោះ ។ អ្នកទាំងពីរទទួលស្គាល់ថា “ឧក្រិដ្ឋកម្មអន្តរជាតិនីមួយៗមានប្រភពមកពីសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ គោលការណ៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬការផ្សំចូលគ្នាទាំងពីរ” ។ សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិមានលក្ខណៈច្បាស់លាស់ និងឆ្លើយតបទៅនឹងវិបត្តិណាមួយដូចជាអំពើប្រល័យពូជសាសន៍ការប្លន់យន្តហោះការធ្វើទារុណកម្ម ។ ដោយឡែក “ច្បាប់ទំនៀមទម្លាប់អន្តរជាតិគ្មានសណ្ឋានពិតប្រាកដ និងពិបាកយល់ព្រមទាំងដែលអាចបត់បែនបានថែមទៀត” ។ ជាការពិតណាស់ អំពើប្រល័យពូជសាសន៍ជាបទឧក្រិដ្ឋអន្តរជាតិមួយក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយអំពើនេះស្ថិតក្រោមដែន

សមត្ថកិច្ចសកល ។ ទោះបីជារដ្ឋមួយមិនមែនជាសមាជិកនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏រដ្ឋនោះមានកាតព្វកិច្ចច្បាប់ក្នុងការទប់ស្កាត់ និងផ្តន្ទាទោសឧក្រិដ្ឋជនប្រល័យពូជសាសន៍ដែរ ។

ទន្ទឹមគ្នានោះដែរ វានៅតែមានការលំបាកក្នុងការកំណត់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយទើបតែថ្មីៗនេះដែលគេនៅអាចកំណត់ប្រព័ន្ធច្បាប់ព្រហ្មទណ្ឌអន្តរជាតិជាលើកដំបូង ប៉ុន្តែប្រព័ន្ធនេះនៅក្មេងខ្ចីនៅឡើយ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបន្ថែមការយល់ដឹងអំពីប្រព័ន្ធច្បាប់នោះ ក៏ប៉ុន្តែតុលាការនេះ នៅមានកង្វះខាតការដាក់ទោសទណ្ឌឲ្យបានទូលំទូលាយភ្ជាក់ផារ ឬយុទ្ធសាស្ត្រអនុវត្តច្បាប់ និងកិច្ចព្រមព្រៀងសកលទាក់ទិននឹងវិសាលភាពនៃបទល្មើស ។ ទោះបីជាតុលាការព្រហ្មទណ្ឌអន្តរជាតិបានដំណើរការជាច្រើនឆ្នាំក៏ដោយ ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅត្រូវការភាគីទីបី (រដ្ឋ) ឲ្យអនុវត្តទៅតាម តុលាការក្នុងស្រុករបស់ខ្លួន ។ ម្យ៉ាងទៀត កម្រិតច្បាប់ព្រហ្មទណ្ឌអន្តរជាតិតែងមានការផ្លាស់ប្តូរជានិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសិទ្ធិអាទិភាពថ្មីៗរបស់សហគមន៍អន្តរជាតិទាំងតាមរយៈសន្ធិសញ្ញា និងតាមរយៈការបង្កើតវិធានការនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ ប្រព័ន្ធច្បាប់ណាក៏ដោយតម្រូវឲ្យមានវិធានជាមូលដ្ឋាន គោលការណ៍ច្បាប់ គោលគំនិត និងនីតិវិធីមូលដ្ឋាន ហើយតម្រូវការទាំងនេះ ត្រូវបានមើលឃើញក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនតុលាការព្រហ្មទណ្ឌអន្តរជាតិកើតមានឡើង ដោយបញ្ចូលបទពិសោធន៍ពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសម្រាប់ប្រទេសរ៉្វាន់ដា ។ ទោះបីជាយ៉ាងណាក៏ដោយ មានការខ្វះខាតភាពទូលំទូលាយនិងភាពស្របគ្នាលើកិច្ចប្រឹងប្រែងរកដំណោះស្រាយ និងលើការបកស្រាយអត្ថន័យ ។

តាមការការពិនិត្យពិច័យទៅលើសារជាតិបទឧក្រិដ្ឋអន្តរជាតិក្នុងអង្គច្បាប់ព្រហទណ្ឌអន្តរជាតិ គេអាចសួរបន្ថែមថាតើឧក្រិដ្ឋកម្មសង្គ្រាមមានសារសំខាន់យ៉ាងដូចម្តេច ហើយថាតើការកេណ្ឌទាហានកុមារគឺជាឧក្រិដ្ឋកម្មសង្គ្រាមក្រោមច្បាប់អន្តរជាតិមុនឆ្នាំ១៩៩៦ដែរឬទេ ។

បើនិយាយឲ្យចំទៅឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានទុកជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សង្គ្រាម ដែលហៅថាយ៉ាងសាមញ្ញ ច្បាប់មនុស្សធម៌អន្តរជាតិ ដែលបុគ្គលម្នាក់ៗអាចឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។

អ្នកច្បាប់ម្នាក់បានអះអាងថា ដើម្បីឲ្យការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌ អន្តរជាតិក្លាយជាឧក្រិដ្ឋកម្មសង្គ្រាម ចាំបាច់ត្រូវធ្វើឲ្យការរំលោភបំពាននោះត្រូវបានចែងថាជាបទឧក្រិដ្ឋជាមុនសិន ។ បញ្ហាបន្ទាប់គឺនីតិវិធីកំណត់ថា តើមានបទឧក្រិដ្ឋនេះដែរឬទេ ។

ទោះបីជាឧក្រិដ្ឋកម្មកេណ្ឌកុមារធ្វើទាហានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ មេធាវីដើមចោទក្នុងរឿងក្តីនេះបានស្នើសុំឲ្យពិនិត្យ ច្បាប់អន្តរជាតិ ដែលខុសពីប្រព័ន្ធច្បាប់ជាតិគ្មានសភាដែលមានអំណាចនីតិបញ្ញត្តិទាក់ទិននឹងពិភពលោកទាំងមូលឡើយ ហើយដូចនេះបានជាគ្មានលក្ខន្តិកៈ ប្រកាសបទល្មើសឧក្រិដ្ឋដាក់ឲ្យនៅក្រោមច្បាប់ទំនៀមទម្លាប់ក្នុងកាលបរិច្ឆេទជាក់លាក់ឡើយ ។ ជាការពិតណាស់ ច្បាប់អន្តរជាតិនៅខ្វះស្ថាប័នផ្លូវការជាច្រើននៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកដូចជាគ្មានអង្គការនីតិបញ្ញត្តិផ្លូវការ គ្មានប្រព័ន្ធចាត់តាំងតុលាការមានសមត្ថកិច្ច និងគ្មានកងកម្លាំងនគរបាល ហើយជួនកាលមានបញ្ហាជម្លោះជាច្រើន រវាងភាគីរដ្ឋដែលកើតមានឡើងដោយសារតែច្បាប់អន្តរជាតិ ដែលគ្រប់គ្រងបទល្មើសនោះមិនមានលក្ខណៈច្បាស់លាស់ ។ ជាងនេះទៀតភាគីរដ្ឋប្រព្រឹត្តខុសច្បាប់ដោយសេរី ។ ក៏ប៉ុន្តែនៅក្នុងរឿងក្តីនេះ វាមិនមែនជាបញ្ហារបស់ប្រព័ន្ធតុលាការទន់ខ្សោយនោះទេ វាទាក់ទងនឹងវិធីសាស្ត្រក្នុងការបកស្រាយច្បាប់អន្តរជាតិទៅវិញទេ ។ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន មានសិទ្ធិអំណាចពេញលេញក្នុងការដាក់ទោសជនម្នាក់ៗដែលត្រូវចោទប្រកាន់ពីការប្រព្រឹត្តបទឧក្រិដ្ឋតាមលក្ខន្តិកៈច្បាប់របស់ខ្លួនដែលប្រមូលចងក្រងបទឧក្រិដ្ឋដែលមានលក្ខណៈផ្ទុយទៅនឹងបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីការអនុម័តច្បាប់នោះមក ។ តុលាការនេះគួរតែបង្ហាញថាការកេណ្ឌកុមារធ្វើទាហានបានក្លាយឧក្រិដ្ឋកម្មមុនឆ្នាំ១៩៩៦ ដែលសេចក្តីសម្រេចថ្មីៗចាត់ទុកថាមិនសមហេតុផល និងមិនច្បាស់លាស់ ។

ជាការពិត ឧក្រិដ្ឋកម្មអន្តរជាតិ ជាពិសេសឧក្រិដ្ឋកម្មសង្គ្រាម

អាចត្រូវបានគេសម្រេចដោយវិធីពីរយ៉ាងតាមរយៈសន្ធិសញ្ញា ឬតាមច្បាប់ទំនៀមទម្លាប់ ។

## ច្បាប់ទំនៀមទម្លាប់

យោងទៅលើចៅក្រម កាសសេស ដើម្បីឲ្យបទល្មើសមួយក្លាយជាឧក្រិដ្ឋកម្មសង្គ្រាម ស្ថានភាពជាច្រើនចាំបាច់ត្រូវតែញែកឲ្យបានច្បាស់លាស់ ។ ទីមួយ ការរំលោភបំពានត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាមដោយតុលាការជាតិនិងតុលាការអន្តរជាតិ ។ កាសសេស បាននិយាយថា "រឿងក្តីឧក្រិដ្ឋកម្មសង្គ្រាមលើបញ្ហាជាក់លាក់មួយដូនកាលត្រូវបានគេគិតថាមានលក្ខណៈគ្រប់គ្រាន់ដើម្បីឲ្យការរំលោភបំពានក្លាយជាឧក្រិដ្ឋកម្មសង្គ្រាមក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលក្នុងករណីនេះត្រូវមានភស្តុតាងទូលំទូលាយបញ្ជាក់ថារដ្ឋនានាអាចផ្តន្ទាទោសបទល្មើសបែបនេះថាជាឧក្រិដ្ឋកម្មសង្គ្រាមជាទម្លាប់ក្រោមវិធាននៃច្បាប់អន្តរជាតិដែលមានលក្ខណៈចាប់បង្ខំ" ។

ទឡ្ហីករណ៍ទាំងនេះគាំទ្រដោយចៅក្រម រ៉ូបឺតសុន ដែលមានមតិជុំយទៅនឹងមតិភាគច្រើន ។ លោកបានអះអាងថា ការកេណ្ឌកុមារធ្វើទាហានដោយមិនបង្ខំមិនបានចាត់ចូលក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិឡើយ រហូតដល់សន្ធិសញ្ញាទីក្រុងរ៉ូម សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងនៅខែកក្កដា ឆ្នាំ១៩៩៨ ។ ចៅក្រម រ៉ូបឺតសុន បានរកឃើញថា អត្ថបទរៀបចំបង្កើតសន្ធិសញ្ញាដែលនាំឲ្យមានការអនុម័តលក្ខន្តិកៈតុលាការពិសេសបានបញ្ជាក់ថា លក្ខណៈច្បាប់អន្តរជាតិនៅឆ្នាំ១៩៩៦ ដែលទាក់ទិននឹងការកេណ្ឌកុមារធ្វើទាហានមានចរិតមិនច្បាស់លាស់ឡើយ ហើយសូម្បីតែអគ្គលេខា ធិការអង្គការសហប្រជាជាតិក៏ទទួលស្គាល់បញ្ហានេះដែរ ។ រ៉ូបឺតសុន បានបង្ហាញថា បញ្ហាដែលថា "អំពើមួយចូលជាបទឧក្រិដ្ឋ" គួរតែបែកឲ្យដាច់ពី "ការប្រព្រឹត្តដែលគួរជាបទឧក្រិដ្ឋ" និងគួរតែធ្វើការពិចារណាឲ្យបានដិតដល់ទៅលើគោលការណ៍ច្បាប់ "ពុំមានទោសបើគ្មានច្បាប់ចែង" ។ លោកបានបន្តពិនិត្យមើលច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងបានសង្កត់ធ្ងន់លើសំណួរដែលចោទសួរថា តើការកេណ្ឌកុមារធ្វើទាហានជាច្បាប់ព្រហ្មទណ្ឌដែលត្រូវហាមប្រាមដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៩៦ដែរឬទេ ។ រ៉ូបឺតសុន បានតាមរកប្រភពច្បាប់សន្ធិសញ្ញា និងព្រឹត្តិការណ៍សំខាន់ ដែលមានរហូតដល់ឆ្នាំ១៩៩៦ និងយល់ឃើញថា លក្ខន្តិកៈទីក្រុងរ៉ូម ជាព្រឹត្តិការណ៍សំខាន់មួយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយការកេណ្ឌកុមារធ្វើទាហានដែលជាបទឧក្រិដ្ឋតម្រូវឲ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គល ។

ច្បាប់ទំនៀមទម្លាប់ និងគោលការណ៍ទាំងពីរនេះ គេអាចទាញចេញពីករណីយុត្តិសាស្ត្រដែលភាគច្រើនចេញពីតុលាការក្នុងស្រុក ។ មានការលំបាកជាខ្លាំងក្នុងការស្វែងរកនូវទស្សនៈនិងគំនិតតែមួយ និងដូចគ្នាសម្រាប់បង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារតុលាការរដ្ឋនីមួយៗហាក់ដូចជាចង់អនុវត្តបទបញ្ញត្តិមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌក្នុងស្រុកនៅពេលវិនិច្ឆ័យលើបទឧក្រិដ្ឋអន្តរជាតិ ។ រីឯគោលការណ៍ទំនៀមទម្លាប់ក៏មានលក្ខណៈដូចគ្នាដែរ ។

ផ្អែកលើទស្សនៈវិជ្ជាច្បាប់ខាងលើឧក្រិដ្ឋកម្មសង្គ្រាម គឺជាការរំលោភបំពានលើច្បាប់ទំនៀមទម្លាប់ ឬច្បាប់សន្ធិសញ្ញានៃច្បាប់មនុស្សធម៌អន្តរជាតិស្តីអំពីជម្លោះប្រដាប់អាវុធ ។ ដូចដែលសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានកំណត់នៅក្នុងរឿងក្តី ថាឌីក ឧក្រិដ្ឋកម្មសង្គ្រាម ពិតជាមាន"ការរំលោភទៅលើ"ច្បាប់អន្តរជាតិ ហើយការរំលោភនេះ ពិតជាមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះជនរងគ្រោះ ។ ច្បាប់ដែលត្រូវបានបំពានត្រូវតែមានចែងក្នុងច្បាប់ទំនៀមទម្លាប់ និងក្នុងសន្ធិសញ្ញាមានអានុភាពអនុវត្ត ។ ស្ថិតនៅក្រោមច្បាប់ទំនៀមទម្លាប់ ឬច្បាប់អនុសញ្ញា ការរំលោភបំពានត្រូវមានការទទួលខុសត្រូវលើបទឧក្រិដ្ឋជាបុគ្គលចំពោះជនដែលប្រព្រឹត្តបទល្មើស ។ និយាយម្យ៉ាងទៀតថា ការប្រព្រឹត្តបទល្មើសរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ ត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ ។

អ្នកនិពន្ធមួយរូបបានសរសេរថា ការមិនអនុវត្តបទបញ្ញត្តិច្បាប់មនុស្សធម៌អន្តរជាតិដែលដាក់ជូនតុលាការ ឬនីតិវិធីព្រហ្មទណ្ឌទាក់ទិននឹងការរំលោភច្បាប់ មិនមែនជាបញ្ហាសំខាន់នោះទេ ។ អ្វីដែលជាបញ្ហានោះ គឺតុលាការយោធា ឬព្រហ្មទណ្ឌពិតជាបានកាត់សេចក្តីការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ ។

**ច្បាប់សន្ធិសញ្ញា**

ដូចដែលចៅក្រម កាសសេស បានស្នើស្ថានភាពទីពីរ គឺការរំលោភបំពានត្រូវបានច្បាប់បង្កើតតុលាការអន្តរជាតិចែងថាជាឧក្រិដ្ឋកម្មសង្គ្រាម ។ ក្នុងករណីនេះ បើទោះបីជាការរំលោភបំពាននេះមិនបានប្តឹងផ្តល់នៅក្នុងតុលាការជាតិ ឬអន្តរជាតិក៏ដោយការរំលោភនេះក៏អាចចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាមដែរ ។ ក្នុងរឿងក្តីថ្មីៗនេះ ច្បាប់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន បានចាត់ទុកទង្វើកេណ្ឌកុមារធ្វើទាហានជាបទឧក្រិដ្ឋ ។ ក្នុងមាត្រា៤(គ) នៃច្បាប់នេះ តុលាការពិសេសមានសិទ្ធិអំណាចកាត់ទោសជនដែលបានប្រព្រឹត្តបទល្មើសបំពានលើច្បាប់មនុស្សធម៌អន្តរជាតិ ដូចជា“កេណ្ឌកុមារក្រោម អាយុ ១៥ឆ្នាំឲ្យចូលបម្រើក្នុងជួរកងទ័ព ឬក្រុមប្រដាប់អាវុធផ្សេងៗដោយបានប្រើប្រាស់កុមារទាំងនោះ ឲ្យចូលរួមយ៉ាងសកម្មក្នុងជម្លោះយោធា” ។ ប៉ុន្តែ ច្បាប់នេះត្រូវបានអនុម័តក្រោយបទឧក្រិដ្ឋប្រព្រឹត្តមុនឆ្នាំ១៩៩៦ ដែលមានក្នុងដីកាចោទប្រកាន់ ។ គោលការណ៍ទទួលខុសត្រូវលើបទឧក្រិដ្ឋជាបុគ្គលចំពោះការបំពានបទដ្ឋានអន្តរជាតិ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រមែប្រមូលចងក្រងនូវបទល្មើសជាច្រើនថាជាបទល្មើសព្រហ្មទណ្ឌអន្តរជាតិ ។

ស្ថានភាពទីបីដែលមានភាពលំបាកជាងគេ គឺនៅពេលដែលករណីយុត្តិសាស្ត្រនិងលក្ខន្តិកៈច្បាប់តុលាការអន្តរជាតិពុំមានចែងអំពីបញ្ហានោះ តួយ៉ាងការហាមប្រាមការប្រើប្រាស់អាវុធដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ ឬដែលបង្កឲ្យមានរបួសស្នាមដោយពុំមានភាពចាំបាច់ ។ បញ្ហានេះជាប់ពាក់ព័ន្ធទៅនឹង នីតិវិធីនៃការសម្រេចចិត្តរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ។ ក្នុងស្ថានភាពបែបនេះ តើប្រទេសនីមួយៗត្រូវកំណត់ការរំលោភបំពានលើបំរាមនៃច្បាប់មនុស្សធម៌អន្តរជាតិថាជាឧក្រិដ្ឋកម្មសង្គ្រាមតាមរបៀបណា? ដោយយោងទៅលើករណីយុត្តិសាស្ត្រនានាក្នុងនោះរួមមានរឿងក្តី លីស និងរឿងក្តីផ្សេងៗទៀត (ករណីចំណាប់ខ្មាំង) , ចន ស្តុលហ្វ័, ថាឌីក (បណ្តឹងឧទ្ធរណ៍) និង ប្លេសឃីក ហើយនិងគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ចៅក្រម កាសសេស បានស្នើសុំឲ្យតុលាការពិនិត្យប្រភពព័ត៌មានផ្សេងៗរួមមាន ក) សៀវភៅក្បួនយោធា ខ) នីតិកម្មក្នុងស្រុកនៃរដ្ឋដែលមានប្រព័ន្ធច្បាប់សំខាន់ៗ នៅលើពិភពលោក ឬបើមានខ្វះខាតធាតុផ្សំទាំងនេះ គ) គោលការណ៍មូលដ្ឋានយុត្តិធម៌ព្រហ្មទណ្ឌទាក់ទិននឹងបណ្តាប្រទេសក្នុងពិភពលោក ដូចមានចែងក្នុងលិខិតូបករណ៍អន្តរជាតិ សកម្មភាពអន្តរជាតិ សេចក្តីសម្រេច និងឯកសារដែលស្រដៀងនេះ និង ឃ) នីតិកម្មនិងការអនុវត្ត ខាងតុលាការនៃរដ្ឋដែលមានជនជាប់ចោទជាសមាជិក ឬដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តដោយខុសច្បាប់នៅលើទឹកដីរបស់ខ្លួន ។

ដោយពិនិត្យមើលទៅស្ថានភាពបីខាងលើទាក់ទិននឹងបទឧក្រិដ្ឋកម្មសង្គ្រាម គេមិនគួរចាត់វិធានដ៏សាមញ្ញដូចដែលតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន ធ្លាប់បានធ្វើឡើយ ។ គេអាចអះអាងបានថា មិនមែនរាល់ការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិទាំងអស់ជាបទឧក្រិដ្ឋកម្មសង្គ្រាមឡើយ ។ ចៅក្រម កាសសេស ដែលបានបដិសេធចំពោះការសេចក្តីសន្និដ្ឋាននោះ អះអាងបញ្ជាក់ថា ៈ

“ប្រការសំខាន់ដែលត្រូវកត់សម្គាល់ទាក់ទងនឹងភាពមិនចាំបាច់ក្នុងការចៀសវាងការសន្និដ្ឋានយ៉ាងសាមញ្ញដែលកំណត់ថាតើការប្រព្រឹត្តណាមួយអាចហៅថាឧក្រិដ្ឋកម្មសង្គ្រាមបាន ឬគ្រាន់តែសម្រេចថាការប្រព្រឹត្តនោះរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិ ” ។

និយាយឲ្យខ្លី ក្រៅពីការទទួលខុសត្រូវរបស់រដ្ឋ (ប្រសិនបើការប្រព្រឹត្តនោះត្រូវបានធ្វើឡើង ដោយភ្នាក់ងាររដ្ឋ) ដើម្បីសម្រេចថាការរំលោភបំពានលើអង្គការច្បាប់នោះជាបទឧក្រិដ្ឋដែរ ការរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិមានតម្លៃស្មើនឹងឧក្រិដ្ឋកម្មសង្គ្រាមពុំមានមូលដ្ឋានគ្រប់គ្រាន់ឡើយផ្អែកលើករណីយុត្តិសាស្ត្រនិងគោលការណ៍ទូទៅនៃយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសគោលការណ៍នីត្យានុកូលភាព (ពុំមានបទល្មើសបើគ្មានច្បាប់ចែង) ។

ទាក់ទិននឹងកង្វះខាតការអនុវត្តដូចគ្នានៃរដ្ឋ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន មិនបានបង្កើតវិធានទំនៀមទម្លាប់នៃច្បាប់អន្តរជាតិហាមប្រាមការកេណ្ឌកុមារធ្វើទាហានឡើយ ។ នៅក្នុងស្ថានភាពបែបនេះ ដំណោះស្រាយដែលប្រសើរសម្រាប់តុលាការ

ពិសេសនៅប្រទេសសៀរ៉ាឡេអូន គឺត្រូវអនុវត្តគោលការណ៍ទូទៅនៃយុត្តិធម៌ព្រហ្មទណ្ឌទាក់ទិននឹងបណ្ដាប្រទេសលើពិភពលោកជាជាងអះអាងថាមានច្បាប់ទំនៀមទម្លាប់ដែលប្រែក្លាយការកេណ្ឌកុមារធ្វើទាហានជាបទឧក្រិដ្ឋ ។ ទោះជាយ៉ាងណាក៏ដោយ គេនៅមានមន្ទិលសង្ស័យថា នៅតែមានបញ្ហាក្នុងការបង្ហាញថាការកេណ្ឌកុមារធ្វើទាហាន ទោះបីជាតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន បានប្រើប្រាស់ដំណោះស្រាយបែបនេះក៏ដោយ ជាបទឧក្រិដ្ឋបើតុលាការនេះប្រើវិធីសាស្ត្រ និងការស្រាវជ្រាវតិចតួចបែបនេះ ។

ម្យ៉ាងវិញទៀត តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនបានអះអាងបញ្ជាក់ថា ការបង្ហាញមនសិការសាធារណៈ គឺមានសារសំខាន់ក្នុងការកំណត់អ្វីជាអំពើឧក្រិដ្ឋ ។ ធ្វើដូចនេះវាងាយពេកហើយ ។ តាមការអះអាងនេះ ការគ្រប់គ្រងច្បាប់កំពុងតែមានការធ្លាក់ចុះ និងពុំចាំបាច់ធ្វើសច្ចាអនុម័តលើសន្ធិសញ្ញា ឬអនុសញ្ញា ឬប្រមូលចងក្រងច្បាប់ទំនៀមទម្លាប់ឡើយ ។ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន គួរតែពិចារណាឲ្យបានដិតដល់ជាងមុននូវករណីយុត្តិសាស្ត្រ និងការអនុវត្តច្បាប់ដែលទទួលស្គាល់ជាទូទៅ ។ ច្បាប់ទំនៀមទម្លាប់ក្នុងស្រុកក៏មានទំនាក់ទំនងដ៏ល្អដែរ ។

ដោយគ្មានជំហរផ្នែកច្បាប់ ក្រៅពីការអះអាងពីរដំបូងខាងលើ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន យល់ថាការទទួលខុសត្រូវជាបុគ្គលលើបទឧក្រិដ្ឋកេណ្ឌកុមារធ្វើទាហានត្រូវបានត្រូវបានសម្រេចនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧ ដោយយោងលើកាលបរិច្ឆេទដែលក្រុមការងារច្បាប់នៃអង្គការមិនមែនរដ្ឋាភិបាលអនុម័តគោលការណ៍ច្បាប់ទីក្រុងខេបថោន ដែលចែងថា "ជនដែលទទួលខុសត្រូវចំពោះការកេណ្ឌកុមារធ្វើទាហានដោយខុសច្បាប់គួរតែត្រូវនាំមកកាត់ទោស" ។ ដោយមិនគិតអំពីកម្លាំងច្បាប់នៃគោលការណ៍នេះ វាពិតជាពុំមានការទាក់ទងនឹងកាលបរិច្ឆេទនៃការអនុម័តនេះឡើយ ពីព្រោះវាមានរយៈពេល៩ខែបន្ទាប់ពីបទឧក្រិដ្ឋត្រូវបានចោទប្រកាន់ ។ ការទទួលខុសត្រូវនេះមិនអាចសូម្បីតែចាត់ទុកជាប្រភពច្បាប់ទន់ក្នុងការបង្កើតលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិទីក្រុងរ៉ូម និងលក្ខន្តិកៈនៃតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន ។ ដូចនេះ ច្បាប់នេះគឺមិនមានអានុភាពចំពោះដីកាចោទប្រកាន់ឡើយ ។

តាមការអះអាងទី៤ ការទទួលខុសត្រូវជាបុគ្គលលើបទឧក្រិដ្ឋកេណ្ឌកុមារធ្វើទាហានត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៨ ជាថ្ងៃដែលប្រធានក្រុមប្រឹក្សាសន្តិសុខបានធ្វើការថ្កោលទោសលើការប្រើប្រាស់ទាហានកុមារ និងបានអំពាវនាវភាគីទាំងអស់ឲ្យអនុវត្តទៅតាមកាតព្វកិច្ចរបស់ខ្លួនដែលនៅក្រោមច្បាប់អន្តរជាតិ ព្រមទាំងផ្ដន្ទាទោសចំពោះអ្នកដែលទទួលខុសត្រូវលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរច្បាប់មនុស្សធម៌អន្តរជាតិ ។ ជាចុងក្រោយ គេបានពិនិត្យឃើញចំណុចដែលត្រឹមត្រូវ ក៏ប៉ុន្តែនៅមានបញ្ហាទាក់ទិននឹងពេលវេលា "ការទទួលខុសត្រូវជាបុគ្គលលើបទឧក្រិដ្ឋកេណ្ឌកុមារធ្វើទាហានត្រូវបានសម្រេចនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ នៅពេលដែលលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានអនុម័ត" ។ ជាការពិតណាស់ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ គឺជាកាតព្វកិច្ចរបស់ភាគីរដ្ឋជាសមាជិកទាំងអស់ ក៏ប៉ុន្តែអានុភាពនៃសេចក្ដីសម្រេចនេះមិនខុសអ្វីទៅនឹងការអំពាវនាវឲ្យរដ្ឋជាសមាជិកអនុម័តច្បាប់ប្រែក្លាយសកម្មភាពការកេណ្ឌកុមារធ្វើទាហានទៅជាបទឧក្រិដ្ឋនោះឡើយ ដែលស្ដែងឲ្យឃើញយ៉ាងច្បាស់ថាបទដ្ឋានច្បាប់ទំនៀមទម្លាប់ស្ថិតក្នុងដំណើរដ៏វែងឆ្ងាយ ដើម្បីឆ្ពោះទៅរកពេលវេលាដ៏ត្រឹមត្រូវ ។

វិធានការដែលតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនបានធ្វើ គឺសុទ្ធតែជាពាក្យសម្ដីបំផ្លើស ហើយរឿងក្ដីភាគីច្រើនមិនមានក្នុងក្របខណ្ឌច្បាប់នៃច្បាប់អន្តរជាតិឡើយ ។ ដូចនេះ តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន គួរតែមានភាពប្រាកដនិយមជាងនេះ និងពិភាក្សាលើច្បាប់ឲ្យបានខ្លាំងជាងនេះ ដោយយោងទៅរកច្បាប់ដែលមានពីមុន និងអ្នកនិពន្ធអត្ថបទទស្សនាវដ្ដី ឬកាសែតដែលមានសមត្ថភាពខ្ពស់ ។

ជារួម តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនមិនបានបង្កើតច្បាប់ទំនៀមទម្លាប់ អន្តរជាតិដែលធ្វើឲ្យការកេណ្ឌកុមារធ្វើទាហានក្លាយទៅជាបទឧក្រិដ្ឋ ហើយសន្ធិសញ្ញា និងគោលការណ៍ទាំងនេះពុំមានអានុភាពគតិយុត្តិឡើយ ។ ទោះបីជាយ៉ាងនេះក៏ដោយ មានដំណោះស្រាយមួយទៀតដែលតុលាការពិសេសនេះអាចយកមកអនុវត្តបាននោះ គឺត្រូវបង្ហាញចំណុចដែលសន្ធិសញ្ញា

ទីក្រុងរ៉ូម មានទំនាក់ទំនងទៅនឹងច្បាប់ទំនៀមទម្លាប់ទាក់ទងនឹងការកេណ្ឌកុមារឲ្យធ្វើទាហាន ។

### ទំនាក់ទំនងរវាងច្បាប់ទំនៀមទម្លាប់និងច្បាប់សន្ធិសញ្ញា

ជាទូទៅ ច្បាប់ទំនៀមទម្លាប់ និងច្បាប់សន្ធិសញ្ញាមិនប្រកួតប្រជែងគ្នាទេ ។ ច្បាប់ទាំងនេះមានគោលបំណងសំខាន់ផ្សេងៗគ្នា និងបំពេញគ្នាទៅវិញទៅមកដូចដែលតុលាការអន្តរជាតិបានបង្ហាញដំណាក់កាលសម្រេចលើអង្គសេចក្តីក្នុងរឿងក្តីសកម្មភាពយោធា និងកងជីវពលប្រឆាំងប្រទេសនីការ៉ាហ្គ័រ ដែលពិភាក្សាអំពីទំនាក់ទំនងគ្នារវាងច្បាប់ទំនៀមទម្លាប់ និងច្បាប់សន្ធិសញ្ញា ។ តុលាការអន្តរជាតិបានកំណត់ថា "ទោះបីជាបទដ្ឋានច្បាប់ពីរមានប្រភពមកពីច្បាប់អន្តរជាតិពីរដែលមានខ្លឹមសារដូចគ្នា ហើយច្បាប់ទាំងពីរត្រូវចាំបាច់ឲ្យរដ្ឋមានកាតព្វកិច្ចអនុវត្តដោយផ្អែកលើកម្រិតច្បាប់សន្ធិសញ្ញា និងកម្រិតច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏បទដ្ឋានច្បាប់ពីរទាំងនេះ នៅតែមានលក្ខណៈដាច់ដោយឡែកពីគ្នាដែរ" ។

ច្បាប់សន្ធិសញ្ញាអាចចងក្រងទំនៀមទម្លាប់ ឬអាចនាំឲ្យមានការបង្កើតច្បាប់ទំនៀមទម្លាប់ថ្មីតាមរយៈកម្លាំងនៃការអនុវត្តជាក់ស្តែងរបស់រដ្ឋ ។ ជាវិធានទូទៅ ច្បាប់សន្ធិសញ្ញាគ្រាន់តែចាប់បង្ខំរដ្ឋដែលជាភាគីនៃសន្ធិសញ្ញានោះតែប៉ុណ្ណោះ ដោយឡែកច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់បង្ខំរដ្ឋទាំងអស់ បើគ្មានទំនៀមទម្លាប់ក្នុងស្រុកណាមួយ ឬមានការជំទាស់ដែលមានប្រសិទ្ធភាព និងដែលចេះតែមានបន្តនោះ ។

ប្រសិនបើសន្ធិសញ្ញាបញ្ជាក់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬប្រសិនបើសន្ធិសញ្ញាត្រូវបានសម្រេចតាមបំណងរបស់អ្នកដែលបានធ្វើសេចក្តីព្រាងសន្ធិសញ្ញានេះ សន្ធិសញ្ញានេះ អាចធ្វើជាភស្តុតាងដ៏ត្រឹមត្រូវបញ្ជាក់ពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន ។ ទម្ងន់នៃសន្ធិសញ្ញានេះ ខុសគ្នាទៅតាមចំនួនភាគីចូលរួម និងលក្ខណៈភស្តុតាងដែលដូចគ្នានិងខុសគ្នាទាក់ទងនឹងស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបានមកពីប្រភពផ្សេង ដូចជាសេចក្តីសម្រេចរបស់តុលាការ ឬលិខិតឆ្លងឆ្លើយផ្នែកការទូតជាដើម ។

តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន បានខិតខំបង្ហាញថាសន្ធិសញ្ញាទីក្រុងរ៉ូម សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រមូលចងក្រងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលប្រែក្លាយការកេណ្ឌកុមារធ្វើទាហានជាបទឧក្រិដ្ឋ ។ ប្រការនេះទាក់ទងនឹងចំណុចដែលកំពុងពិភាក្សាដែលថា តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន បានជ្រើសរើសយកសន្ធិសញ្ញាទីក្រុងរ៉ូមជាមូលដ្ឋានច្បាប់ជាជាងឯកសារយោងផ្សេង តួយ៉ាងគោលការណ៍ច្បាប់ខេបថៅនជាដើម ។ ក៏ប៉ុន្តែ ដោយពុំមានភស្តុតាងបញ្ជាក់តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនមិនបានបង្ហាញថា សន្ធិសញ្ញានេះបញ្ជាក់អំពីច្បាប់ទំនៀមទម្លាប់ឡើយ ។ អ្នកជំនាញការច្បាប់ និងអ្នកប្រាជ្ញល្បីល្បាញជាច្រើន ដូចជាចៅក្រម កាសសេស និងរ៉ូបឺតសុន បានប្រានចោលទាំងស្រុងចំពោះការអះអាងដែលថាលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិត្រង់មាត្រា៨ មានបំណងប្រមូលចងក្រងច្បាប់ទំនៀមទម្លាប់ ។ សូម្បីតែអគ្គលេខាធិការអង្គការសហប្រជាជាតិក៏មិនបានដឹងច្បាស់ពីសារជាតិបទឧក្រិដ្ឋកេណ្ឌកុមារធ្វើទាហាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចដែលបានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិផង ។

តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន មិនបានបង្ហាញពីពេលវេលាដែលការកេណ្ឌកុមារនេះ បានក្លាយជាបទឧក្រិដ្ឋដើម្បីកំណត់អំពើឧក្រិដ្ឋកម្មដែលតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន មានសមត្ថកិច្ចកាត់សេចក្តីឡើយ ។ ដូចបានពិភាក្សាខាងដើម ដើម្បីឲ្យបទល្មើសមួយជាបទឧក្រិដ្ឋកម្មសង្គ្រាម ចាំបាច់ត្រូវមានលក្ខណៈវិនិច្ឆ័យមួយចំនួនដែលតុលាការពិសេសនេះមិនទាន់បានបញ្ជាក់ ។ ជាលទ្ធផល គោលការណ៍សំខាន់ដែលជាវិធានទូទៅនៃច្បាប់អន្តរជាតិអាចត្រូវបានរំលោភបំពានហើយ ។ ផ្នែកបន្ទាប់នេះ នឹងពិភាក្សាទៅលើគោលការណ៍នីត្យានុកូលភាព (គ្មានបទល្មើសបើគ្មានច្បាប់ចែង និងគ្មានទោសបើគ្មានច្បាប់ចែង) ដែលពាក់ព័ន្ធនឹងលក្ខន្តិកៈច្បាប់ក្នុងមាត្រា៤(គ) នៃលក្ខន្តិកៈតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន ។

### ៥) លក្ខន្តិកៈតុលាការពិសេសនិងគោលការណ៍នីត្យានុកូលភាព

វាជារឿងធម្មតាទៅហើយក្នុងយុត្តាធិការជាច្រើន ជាពិសេសនៅទ្វីបអ៊ឺរ៉ុប មានការពិភាក្សាអំពីគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌដែលចែងថា "គ្មានបទល្មើសបើគ្មានច្បាប់ចែង" ជួនកាល

គេស្គាល់ថាជាគោលការណ៍នីត្យានុកូលភាព ។ ក៏ប៉ុន្តែ ដោយយោងទៅលើសារជាតិនៃគោលការណ៍នីត្យានុកូលភាពដែលមានទ្រង់ទ្រាយធំមានការបែងចែកគោលការណ៍ជាបីផ្សេងគ្នា។ គឺ "គោលការណ៍អប្រតិសកម្ម" "គោលការណ៍ពិតប្រាកដអតិបរមា" និង "គោលការណ៍តាក់តែងច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង" ។ គោលការណ៍ពីរចុងក្រោយនិយាយអំពី "ការឲ្យដឹងជាមុនត្រឹមត្រូវ និងការកំណត់បទល្មើសត្រឹមត្រូវ ព្រមទាំងការគោរពចំពោះពលរដ្ឋដែលយល់ពីហេតុផលដោយខ្លួនឯង និងជនដែលមានតួនាទីនៅក្នុងសង្គម និងនយោបាយ" មិនត្រូវបានយកមកបកស្រាយនៅក្នុងនេះទេ ។

សារសំខាន់នៃគោលការណ៍អប្រតិសកម្ម គឺជនគ្រប់រូបមិនត្រូវបានផ្តន្ទាទោសឡើយ លើកលែងតែស្របតាមបទល្មើសដែលត្រូវបានប្រកាសមុនៗ ។ គោលការណ៍នេះក៏មានចែងក្នុងអនុសញ្ញាអឺរ៉ុប ស្តីអំពីសិទ្ធិមនុស្សមាត្រា៧ "គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសលើបទព្រហ្មទណ្ឌទាក់ទិននឹងបទល្មើសសកម្ម និងបទល្មើសអសកម្មដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិនៅក្នុងពេលប្រព្រឹត្តឡើយ ។ ដោយមានប្រកាសនៅក្នុងមាត្រា១នៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក គោលការណ៍នេះហាមការតាក់តែងច្បាប់បង្កើតបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តមុនពេលអនុម័តច្បាប់ ។ ទាក់ទិននឹងឆន្ទានុសិទ្ធិរបស់តុលាការ តុលាការមិនគួរបង្កើតបទល្មើសនិងបន្ទាប់មកផ្តន្ទាទោសជនទាំងឡាយចំពោះការប្រព្រឹត្តបទល្មើសដែលមានឈ្មោះថ្មី ។ តុលាការអង់គ្លេសលែងមានអំណាចបង្កើតបទល្មើសឧក្រិដ្ឋ ដោយទទួលយកដាក់លាក់នូវគោលការណ៍អប្រតិសកម្ម ។

អត្ថបទពុំបានពិភាក្សាអំពីនីត្យានុកូលភាពនៃបទបញ្ញត្តិទាំងអស់ចែងនៅក្នុងលក្ខន្តិកៈច្បាប់នៃតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនឡើយ ។ ផ្នែកនេះផ្តោតជាសំខាន់តែទៅលើមាត្រា ៤(គ) ប៉ុណ្ណោះ ។ ដោយផ្អែកលើចំណុចផ្តើមដូចបានពន្យល់ខាងលើដំណោះស្រាយតែមួយគត់ដែលតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនអាចផ្តន្ទាទោស នរ៉ម៉ែន ចំពោះបទល្មើសកេណ្ឌកុមារធ្វើទាហានដោយខុសច្បាប់មុនឆ្នាំ១៩៩៦ គឺមានតែមាត្រា៤នេះនឹងនាំយើងឈានដល់កិច្ចពិភាក្សាអំពីសិទ្ធិរបស់ចុងចោទ ។

តាមទិដ្ឋភាពជាទូទៅ ទិសដៅសំខាន់នៃគោលការណ៍នីត្យានុកូលភាព គឺត្រូវការការជូនដំណឹង ដែលជាផ្នែកមួយនៃការការពារជាទូទៅ និងការជូនដំណឹងអំពីភាពត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ ។ ព័ត៌មានយុត្តិធម៌របស់ជនជាប់ចោទមានបំណងកំណត់សេចក្តីសម្រេចរបស់រដ្ឋអាជ្ញា និងតុលាការ ដោយគ្មានសេចក្តីប្រកាសជាក់លាក់អំពីកាតព្វកិច្ចច្បាប់ដែលលាតសន្ធឹងហួសពីព្រំដែនច្បាប់កំណត់ ។ ប្រសិនបើ នរ៉ម៉ែន ត្រូវបានផ្តន្ទាទោសលោកនឹងត្រូវប្រឈមមុខនឹងការទទួលខុសត្រូវបទឧក្រិដ្ឋ និងទោសព្រហ្មទណ្ឌក្រោលក្ខន្តិកៈច្បាប់ ។ នរ៉ម៉ែន ធ្លាក់ចូលទៅក្នុងអំពើអយុត្តិធម៌ដោយមិនដឹងច្បាស់លាស់ ពីបទចោទប្រកាន់ដែលខ្លួនប្រឈមមុខ និងទោសទណ្ឌប្រសិនបើគាត់ត្រូវបានតុលាការរកឃើញថាមានទោស ។ ដូចនេះ តាមការអះអាងរបស់ បាសស៊ីអ៊ូនី ក្តីសង្ឃឹមទទួលបានពីភាពជាក់លាក់នៃច្បាប់ និងទោសទណ្ឌ គឺជាទិសដៅសំខាន់ដែលគោលការណ៍នីត្យានុកូលភាពដែលត្រូវតែការពារ ។

ជាទូទៅ ច្បាប់អន្តរជាតិបង្កើតឧក្រិដ្ឋកម្មអន្តរជាតិតាមរយៈអនុសញ្ញា និងច្បាប់ទំនៀមទម្លាប់ ។ គោលការណ៍ច្បាប់ទូទៅក៏ជាប្រភពច្បាប់សំខាន់មួយនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែរ ប៉ុន្តែពុំងាយនឹងកំណត់ជាក់លាក់តាមផ្លូវច្បាប់ដូចសន្ធិសញ្ញានិងច្បាប់ទំនៀមទម្លាប់ឡើយ ។ ទោះជាប្រភពច្បាប់ណាមួយក៏ដោយ ការដាក់ឲ្យនៅក្រោមច្បាប់ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិត្រូវតែបំពេញតាមតម្រូវការនៃគោលការណ៍នីត្យានុកូលភាព ។

គោលការណ៍ទាំងនេះចែងថា គ្មានបទឧក្រិដ្ឋបើគ្មានច្បាប់ចែង គ្មានការផ្តន្ទាទោសបើគ្មានច្បាប់ចែង និងគ្មានការអនុវត្តច្បាប់ក្រោយបទឧក្រិដ្ឋ ។ ដើម្បីសម្រេចគោលការណ៍ទាំងនេះ បទឧក្រិដ្ឋត្រូវតែកំណត់ឲ្យបានត្រឹមត្រូវដើម្បីជូនដំណឹងថាអំពើណាមួយជាបទព្រហ្មទណ្ឌ ។ ដូចនេះគោលការណ៍នីត្យានុកូលភាពត្រូវកំណត់អត្តសញ្ញាណកម្មឲ្យច្បាស់អំពីបទល្មើសដែលហាមឃាត់ ។ ម្យ៉ាងវិញទៀត គោលការណ៍ទាំងនេះ ត្រូវបានចាត់ទុកជាផ្នែកមួយនៃយុត្តិធម៌ ពីព្រោះវាការពារប្រឆាំងនឹងការរំលោភបំពានលើតុលាការ និងការអនុវត្តច្បាប់តាមតែអំពើចិត្ត ។

អគ្គលេខាធិការអង្គការសហប្រជាជាតិក៏មានទស្សនៈស្រដៀងគ្នាដែរ "ការអនុវត្តនូវគោលការណ៍ គ្មានបទឧក្រិដ្ឋ បើគ្មានច្បាប់ចែងតាមតារសាលាជំនុំជម្រះក្តីអន្តរជាតិអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ

ដែលជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់ ទើបបញ្ហានៃការអនុវត្តដោយរដ្ឋមួយចំនួនចំពោះអនុសញ្ញាដ៏ជាក់លាក់ណាមួយមិនកើតមានឡើង" ។ ការអនុវត្តនេះហាក់ដូចជាមានសារសំខាន់ក្នុងបរិបទនៃសាលាជម្រះក្តីកូនកាត់ដែលកំពុងពិភាក្សានេះ ។

គំនិតជាមូលដ្ឋានអំពីភាពត្រឹមត្រូវ និងយុត្តិធម៌មានចែងយ៉ាងច្បាស់ក្នុងច្បាប់ស្តីអំពីសិទ្ធិមនុស្សក្នុងតំបន់ និងអន្តរជាតិ ។ មាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបាន ចែងថាៈ

"គ្មានជនណាម្នាក់មានទោសកំហុសពីបទល្មើសសកម្ម និងអសកម្ម ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌនៅពេលប្រព្រឹត្តក្រោមច្បាប់ក្នុងស្រុកនិងអន្តរជាតិ ។ គ្មានទោសកំហុសព្រហ្មទណ្ឌណាមួយត្រូវផ្តន្ទាទោសធ្ងន់ធ្ងរជាងទោសព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្តចំពេលដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនោះ ។ ប្រសិនបើក្រោយពីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមានការចែងអំពីទោសបញ្ញត្តិស្រាលជាងមុន ជនជាប់ចោទត្រូវទទួលផលប្រយោជន៍នេះ ។

យោងលើគោលការណ៍ច្បាប់មូលដ្ឋានដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ មាត្រានេះពុំមានភាពលំអៀងទៅលើការកាត់ទោស និងការផ្តន្ទាទោសជនណាម្នាក់ចំពោះការប្រព្រឹត្តបទល្មើសសកម្ម និងអសកម្មក្នុងពេលនោះឡើយ" ។

ធម្មនុញ្ញអាហ្វ្រិកស្តីអំពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនមានចែងការហាមប្រាមស្រដៀងគ្នានេះដែរ "គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីការប្រព្រឹត្តបទល្មើសសកម្ម និងអសកម្មដែលមិនមែនជាបទល្មើសនៅពេលប្រព្រឹត្តឡើយ" ។

លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិទីក្រុងរ៉ូម ចងក្រងគោលការណ៍ទាំងនេះក្នុងមាត្រា២២ និង២៣ ។ ការហាមប្រាមច្បាប់ព្រហ្មទណ្ឌដែលប្រតិសកម្មមានការទាក់ទងនឹងសិទ្ធិទទួលបានការជម្រះក្តី ដោយយុត្តិធម៌ ។ ភាពជឿជាក់តាមផ្លូវច្បាប់តម្រូវឲ្យបទល្មើសឧក្រិដ្ឋមានចែងក្នុងច្បាប់ជាមុន ។

ដូចដែលចៅក្រម រ៉ូបឺតសុន បានរំឭកបញ្ហាមួយដែលសហការីរបស់គាត់ហាក់ដូចជាបំភ្លេចនោះ គឺថាសិទ្ធិមនុស្សក៏ក្តោបទាំងសិទ្ធិរបស់ជនជាប់ចោទដែរ ។ សេចក្តីសម្រេចរបស់មតិភាគច្រើនបំពានគោលការណ៍ច្បាប់ ពុំមានទោសបើគ្មានច្បាប់ចែងមានន័យថា គ្មានការប្រព្រឹត្តបទល្មើសណាមួយត្រូវបានផ្តន្ទាទោសក្នុងនាមជាបទល្មើសព្រហ្មទណ្ឌឡើយប្រសិនបើច្បាប់ព្រហ្មទណ្ឌមិនមានចែង ។ ម៉្យាងទៀត ការធ្វើបែបនេះនឹងជាការបើកច្រកដល់ការកាត់ទោសឥតព្រំដែនកំណត់ដោយផ្អែកលើ"បទដ្ឋានទំនៀមទម្លាប់" ដែលមានលក្ខណៈស្រពេចស្រពិលដែលចុងចោទមិនបានដឹងព័ត៌មានរហូតដល់ពេលចោទប្រកាន់ ។ ការកេណ្ឌកុមារធ្វើទាហាន គឺជាការប្រមាថដោយចំហដល់អារ្យជន ក៏ប៉ុន្តែកាលពីមុនការកេណ្ឌនេះមិនមែនជាបទឧក្រិដ្ឋទេ ទើបតែឆ្នាំ១៩៩៨ប៉ុណ្ណោះ ហើយគណៈវិនិច្ឆ័យបានពន្លាតបទល្មើសនេះយ៉ាងគ្រោះថ្នាក់ទៅលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ក្នុងគោលបំណងផ្តន្ទាទោស ការរំលោភបំពានជម្លោះនៅសៀរ៉ាឡេអូន ។

រដ្ឋអយ្យការបានលើកឡើង ហើយតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន បានសន្និដ្ឋានថា ប្រការដែលជនជាប់ចោទមិនអាចដឹងជាមុននូវការបង្កើតសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ ពុំមានផលប៉ះពាល់អ្វីឡើយដរាបណាជនជាប់ចោទអាចដឹងថាបទឧក្រិដ្ឋអាចផ្តន្ទាទោសបាន ។ ម៉្យាងវិញទៀត ជនដែលពុំចាំបាច់ដឹងពីការរៀបរាប់បទល្មើស ហើយ"មនសិកាសាធារណ៍" គឺមានសារសំខាន់ក្នុងការកំណត់អ្វីដែលមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ។

សេចក្តីសន្និដ្ឋាននេះគឺផ្ទុយទាំងស្រុងទៅនឹងសាលក្រមរបស់តុលាការអឺរ៉ុប ទាក់ទិននឹងរឿងក្តីផ្សេងៗគ្នាមួយចំនួនដែលយោងទៅមាត្រា៧(១) ។ ចំពោះតុលាការអឺរ៉ុប មាត្រា៧(១) មិនគ្រាន់តែហាមប្រាម"ការអនុវត្តច្បាប់ព្រហ្មទណ្ឌជាលក្ខណៈប្រតិសកម្មឲ្យខូចអត្ថប្រយោជន៍របស់ជនជាប់ចោទ" ថែមទាំង"តំណាងឲ្យគោលការណ៍ដែលច្បាប់អាចកំណត់បទល្មើសព្រហ្មទណ្ឌ និងការដាក់ទោសទណ្ឌ (ពុំមានបទល្មើស និងពុំមានទោសបើគ្មានច្បាប់ចែង) ទុកជាមុន ព្រមទាំងគោលការណ៍ដែលថាច្បាប់ព្រហ្មទណ្ឌបកស្រាយឲ្យខូចប្រយោជន៍ដល់ជនជាប់ចោទតាមរយៈការប្រៀបធៀបហួសព្រំដែន ។

## ៦) សេចក្តីសន្និដ្ឋាន

ក្នុងបរិបទរឿងក្តី ហាដេនដ័ហ្វ ឆ្នាំ១៩៤៦ អ្នកសរសេររបាយការណ៍ច្បាប់ស្តីអំពីសវនាជម្រះក្តីឧក្រិដ្ឋកម្មក្រោយសង្គ្រាមលោកលើកទីពីរ ដែលត្រូវបានជ្រើសរើស និងចាត់តាំងដោយ

គណៈកម្មការ ឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ បាន អង្កេតឃើញថា “មិនមែនគ្រប់តែការរំលោភបំពាន” លើច្បាប់ទម្លាប់សង្គ្រាម “ត្រូវតែជាបទល្មើសដែលត្រូវផ្តន្ទាទោសនោះទេ” ។ អត្ថបទនេះបានធ្វើការវាយតម្លៃលើនីតិវិធីអន្តរជាតិដែលសាលាជំនុំជម្រះរួមបានប្រើប្រាស់ ដើម្បីដកសំណើលើកដំបូងដោយសំអាងលើកង្វះយុត្តាធិការ ដែលលោក ន័រមែន បានប្តឹងឧទ្ធរណ៍ ។ ហេតុផលសំខាន់បីនៃការសន្និដ្ឋាននេះគឺ ១) នៅឆ្នាំ១៩៩៦ ការហាមប្រាមការកេណ្ឌកុមារធ្វើទាហានទទួលបាននូវលក្ខណៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ២) ការកេណ្ឌកុមារធ្វើទាហានជាឧក្រិដ្ឋកម្មអន្តរជាតិ ក្រោមច្បាប់អន្តរជាតិ និង៣) ការសង្កត់ធ្ងន់ទៅលើការប្រព្រឹត្តបទល្មើសជាជាងការពិពណ៌នាពីបទល្មើសក្នុងច្បាប់ព្រហ្មទណ្ឌពិសេសមានការពាក់ព័ន្ធយ៉ាងខ្លាំង ។ ហេតុផលទាំងបីសំខាន់ខាងលើនេះបង្ហាញអំពីការវាយតម្លៃទៅលើភាពខុសប្លែកគ្នានៃរបៀបបកស្រាយផ្សេងៗគ្នា ។ សេចក្តីសន្និដ្ឋានចេញពីការស្រាវជ្រាវខាងលើមានដូចខាងក្រោម ៖

១) តុលាការគួរតែស្វែងរកប្រភពនៃការវិវត្តបទដ្ឋានច្បាប់ទំនៀមទម្លាប់ ដែលហាមប្រាមការកេណ្ឌកុមារមុនឆ្នាំ១៩៩៦ ដោយមានការប្រុងប្រយ័ត្នជាងមុន ។

២) តុលាការគួរតែពិនិត្យពិច័យនូវភាពស្មុគស្មាញនៃធាតុផ្សំនៃបទដ្ឋានច្បាប់ទំនៀមទម្លាប់ (ការពិនិត្យពិច័យជាទូទៅ និងដាក់លាក់ប្រកបដោយន័យកាតព្វកិច្ច) ។

៣) តុលាការគួរតែដឹងភាពខុសគ្នារវាងច្បាប់ទំនៀមទម្លាប់ហាមប្រាមការកេណ្ឌកុមារ និងច្បាប់ ដែលផ្តន្ទាទោស និងចែងថាជាបទល្មើសព្រហ្មទណ្ឌចំពោះការកេណ្ឌកុមារធ្វើទាហាន ។

៤) គោលការណ៍ទូទៅនៃច្បាប់អន្តរជាតិគួរតែលើកយកមកនិយាយជំនួសច្បាប់ទំនៀមទម្លាប់សម្រាប់ការហាមប្រាមការកេណ្ឌកុមារធ្វើទាហាន ។

៥) ចំពោះសន្និសញ្ញា និងគោលការណ៍ដែលឆ្លុះបញ្ចាំងបទដ្ឋានច្បាប់ទំនៀមទម្លាប់ដែលចែងថាការកេណ្ឌកុមារជាបទល្មើសព្រហ្មទណ្ឌ គួរតែកំណត់ឡើងឲ្យបានត្រឹមត្រូវ ។

៦) ប្រសិនបើតុលាការមិនបង្ហាញភ័ស្តុតាងមានការទាក់ទិននោះទេ មាត្រា៤(គ) នៃលក្ខន្តិកៈ ប្រាកដជានឹងផ្ទុយទៅនឹងគោលការណ៍ទូទៅនៃច្បាប់ គ្មានបទល្មើស និងគ្មានទោស បើគ្មានច្បាប់ចែងដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានសវនាការជម្រះក្តីត្រឹមត្រូវ (រួមទាំងមុនពេលធ្វើសវនាការ) ដែលមានសារសំខាន់សម្រាប់សង្គម ដែលមាននីតិរដ្ឋ ។ ពិតណាស់ លក្ខន្តិកៈច្បាប់នេះជួយពង្រឹង និងពង្រីកសារជាតិបទឧក្រិដ្ឋទាំងឡាយនៃការកេណ្ឌកុមារធ្វើទាហានឲ្យក្លាយជាឧក្រិដ្ឋកម្មសង្គ្រាមសម្រាប់ភាគីដែលបង្កសង្គ្រាមទាំងបច្ចុប្បន្ន និងអនាគត ហើយលក្ខន្តិកៈច្បាប់នេះ ប្រើប្រាស់ជារបាំងការពារការប្រព្រឹត្តបែបនេះ ដូចជា “ការផ្តល់ព័ត៌មានត្រឹមត្រូវជាមុន” និង “ការព្យាករណ៍ច្បាប់ទុកជាមុន” ។ ក៏ប៉ុន្តែ អ្នកនិពន្ធស្នើជាយោបល់ថា ការកេណ្ឌកុមារធ្វើទាហានមុនឆ្នាំ១៩៩៦ មិនអាចជាបទឧក្រិដ្ឋឡើយ ប្រសិនបើគ្មានការស្វែងយល់ផ្នែកច្បាប់ឲ្យស៊ីជម្រៅជាងនេះទេនោះ ។

**ស៊ូ ប៊ុនស៊ូ**

# ពន្យល់ពាក្យខ្មែរក្រហម

◆**យោធាបដិវត្តល្អ** ៖ យោធាដែលបំពេញភារកិច្ចគ្រប់មុខបានល្អដោយគ្មានលក្ខខណ្ឌ ពេលមាន ពេលអត់ ពេលស្រួល ពេលលំបាក ពេលឈ្នះ ពេលចាញ់ជាបណ្តោះអាសន្ន ពេលឈ្នះទាំងស្រុង ចូលទីក្រុង ក៏គ្មានលក្ខខណ្ឌ ។ *(កំណត់ហេតុលេខ១០៨)*

◆**ធាតុពិតជាប់ជិតស្និទ្ធនឹងមហាជន** ៖ មានមហាជននៅជាមួយបក្ស ។ គណៈកម្មាធិការបក្សមួយនៅក្នុងអង្គភាពមួយ បើគ្មានមហាជននៅជាមួយមិនខ្លាំងទេ ។ នៅជាមួយក្នុងន័យសតិអារម្មណ៍នៅជាមួយ នយោបាយនៅជាមួយចាត់តាំងនៅជាមួយ ។

*(ទង់បដិវត្តលេខ៧ ខែកក្កដា ឆ្នាំ១៩៧៦)*

◆**ឧបាយកល** ៖ បន្ទំសុំចរចាដើម្បីដកខ្លួនរៀបចំកម្លាំងមួយសាទៀតទស្សនៈសភាពការណ៍បដិវត្តកម្មជាបច្ចុប្បន្ននិងភារកិច្ចរបស់យើង ។

◆**សកម្មនឹងស្លុះស្លាញ** ៖ ប្រយុទ្ធនឹងវាយសម្រុក ដោយឈរលើសន្ទុះឈ្នះ ឈរលើជំហរមានប្រៀបដាច់ខាតលើខ្មាំងនឹងលើសុទិដ្ឋិនិយម បដិវត្តឥតឆាករេ ។ តែធំបំផុតសកម្មនឹងស្លុះស្លាញត្រូវឲ្យចំទិស ។

*(សៀវភៅការងារពង្រឹងនិងកែលម្អគោលជំហរ និងអាកប្បកិរិយាដឹកនាំនិងធ្វើការងាររបស់បក្ស)*

# យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា

## សេចក្តីផ្តើម

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារខ្ញុំចេញពីភ្នំពេញទៅស្រុកកោះធំ ខេត្តកណ្តាល ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ ក្រុមគ្រួសាររបស់ខ្ញុំបន្តរស់នៅក្នុងស្រុកកោះធំ ។ ឆ្នាំ១៩៧៩ ខ្ញុំមានអាយុ ៦ឆ្នាំ ។ ខ្ញុំនៅចាំថា កាលនោះម្តាយរបស់ខ្ញុំអនុញ្ញាតឲ្យខ្ញុំលេងតែជាមួយបងប្អូនសាច់ញាតិជាពិសេសបងប្អូនជីដូនមួយរបស់ខ្ញុំតែប៉ុណ្ណោះ ។ ម្តាយរបស់ខ្ញុំហាមខ្ញុំមិនឲ្យសេពគប់ឬលេងជាមួយកូនរបស់អ្នកជិតខាងឡើយ ពីព្រោះឪពុកម្តាយរបស់កុមារទាំងនោះគឺជាអតីតឈ្លបខ្មែរក្រហម ។ ម្តាយរបស់ខ្ញុំពន្យល់មូលហេតុដែលគាត់ហាមខ្ញុំថា បើខ្ញុំលេងជាមួយកុមារទាំងនោះហើយមានទំនាស់ ឪពុកម្តាយរបស់កុមារទាំងនោះនឹងមកវាយធ្វើបាបខ្ញុំជាមិនខាន ។ ខ្ញុំឆ្ងល់យ៉ាងខ្លាំងហើយសួរទៅគាត់ថា “ហេតុអ្វី?” ។ ម្តាយខ្ញុំឆ្លើយប្រាប់ខ្ញុំវិញថា ឪពុកម្តាយរបស់កុមារទាំងនោះជាខ្មែរក្រហម ជាមនុស្សអាក្រក់ ជាឃាតករសម្លាប់ប្រជាជន ដែលក្នុងនោះរួមទាំងពូរបស់ខ្ញុំចំនួន ៤នាក់ផង ។

ឆ្នាំ១៩៨១ ក្រុមគ្រួសាររបស់ខ្ញុំចាកចេញពីស្រុកកោះធំមករស់នៅក្នុងទីក្រុងភ្នំពេញ ។ ១៥ឆ្នាំក្រោយមក ខ្ញុំរៀនចប់ថ្នាក់បរិញ្ញាប័ត្រនៅសាកលវិទ្យាល័យភ្នំពេញ ។ ខ្ញុំបានចូលបម្រើការងារជាអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលបំពេញការងារចម្បងពីរ ។ ទីមួយគឺរៀបចំចងក្រងនិងថែរក្សាប្រវត្តិសាស្ត្រដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ទីពីរគឺ ផ្តល់ឯកសារជូនដល់សាធារណជនគ្រប់រូបដែលមានបំណងស្វែងយល់ និងទាមទារឲ្យមានការទទួលខុសត្រូវចំពោះមុខច្បាប់នូវការកាប់សម្លាប់ដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ។ កិច្ចការទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបម្រើគោលដៅចម្បងពីរគឺការចងចាំនិងយុត្តិធម៌ ។

ក្នុងតួនាទីជាអ្នកស្រាវជ្រាវ ខ្ញុំបានជួបសម្ភាសជាមួយអតីតជនដៃដល់និងជនរងគ្រោះនៃរបបខ្មែរក្រហមជាច្រើននាក់ ។ ខ្ញុំយល់ឃើញថា ប្រជាជនកម្ពុជាសព្វថ្ងៃមានការលំបាកក្នុងការសម្រេចចិត្ត ថាតើត្រូវកាត់ទោសអតីតជនដៃដល់ខ្មែរក្រហម



ពិធីបង្សុកូលជូនវិញ្ញាណក្ខន្ធជនរងគ្រោះ

ដើម្បីស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះ ឬត្រូវបំភ្លេចរឿងដើម ហើយបង្រួបបង្រួម ។ កុំ អាយុ៤៥ឆ្នាំ ជាស្ត្រីមេម៉ាយ ដោយសារប្ដីរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ ។ ចំពោះ កុំ ការបំភ្លេចរឿងរ៉ាវ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាការលំបាកបំផុត ។ កុំ មានប្រសាសន៍ថា "តើឲ្យខ្ញុំបំភ្លេចរឿងដើមហើយសប្បាយចិត្តម្ដេចកើត បើ ដុច ដែលជាអ្នកយកប្ដីខ្ញុំទៅសម្លាប់ រស់នៅយ៉ាងសប្បាយហើយជិះកង់កាត់មុខផ្ទះខ្ញុំរាល់ថ្ងៃ" ។ សំ អតីតយុទ្ធជនកងការពារមន្ទីរឃុំឃាំងសម្ងាត់របស់ខ្មែរក្រហម (មន្ទីរស-២១) មានការសោកស្ដាយនិងខ្មាសអៀនយ៉ាងខ្លាំងចំពោះក្រុមគ្រួសារនិងអ្នកភូមិរបស់គាត់នូវអ្វីដែលគាត់បានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម ។ សំ មិនដែលនិយាយអំពីការងាររបស់គាត់នៅមន្ទីរស-២១ប្រាប់នរណាម្នាក់ឡើយ សូម្បីតែប្រពន្ធរបស់គាត់ក៏ដោយ ។ គាត់បារម្ភថា ការដឹងឮអំពីការពិតនិងចំនួនប្រជាជនដែលត្រូវបានសម្លាប់នៅមន្ទីរស-២១នឹងធ្វើឲ្យអ្នកស្រុកកាន់តែខឹងនិងស្អប់គាត់ខ្លាំងឡើង ។ សំ បញ្ជាក់ថា "តាមពិត កាលនោះយុទ្ធជនខ្មែរក្រហមទាំងគេទាំងខ្ញុំគឺត្រូវតែគោរពតាមបញ្ជាដើម្បីបានរស់" ។ ខេង អតីតយុទ្ធមិត្តរួមការងារនៅមន្ទីរ ស-២១ ជាមួយ សំ បញ្ជាក់បន្ថែមថា "អ្នកធ្លាប់ធ្វើការជាមួយខ្ញុំជាច្រើននាក់នៅមន្ទីរស-២១ក៏ត្រូវគ្នាឯងសម្លាប់នៅទីនោះដែរ ។ ខ្ញុំចង់ឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីជួយរកយុត្តិធម៌ឲ្យគ្នាខ្ញុំដែលបានស្លាប់ទៅ ។ ប្រសិនអ្នកទាំងនោះ នៅរស់វិញគឺកាន់តែចង់ឲ្យមានតុលាការជាងខ្ញុំទៅទៀត ពីព្រោះកាលនោះគ្នាពិបាកណាស់" ។

កុំ យល់ឃើញខុសពី ខេង និង សំ ដែលចង់ឲ្យមានតុលាការកាត់ទោសតែមេដឹកនាំខ្មែរក្រហម ។ កុំ ចង់ឲ្យមានតុលាការកាត់ទោសជនដៃដល់ខ្មែរក្រហមទាំងអស់ ជាពិសេស ដុច ដែលជាអ្នកសម្លាប់ប្ដីរបស់គាត់ ។ កុំ, ខេង និង សំ យល់ឃើញនិងចង់បានប្រភេទតុលាការផ្សេងពីគ្នា ប៉ុន្តែអ្វីដែលអ្នកទាំងបីទាមទារដូចគ្នានោះគឺយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ប្រជាជនកម្ពុជាមួយចំនួនទាមទារយុត្តិធម៌ដោយយល់ថា យុត្តិធម៌អាចជួយលុបបំបាត់វប្បធម៌គ្មានទោសពៃរ៍ចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងកសាងមូលដ្ឋានគ្រឹះសម្រាប់ដំណើរការផ្សះផ្សា និងបង្រួបបង្រួមជាតិ ។ ខ្ញុំ(អ្នកនិពន្ធ) ក៏យល់ឃើញបែបនេះដែរ ពេលដែលខ្ញុំបម្រើការជាបុគ្គលិកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ទាប់ពីខ្ញុំបានបន្តការសិក្សាអំពីសន្តិភាពនិងការផ្សះផ្សាបង្រួបបង្រួមនៅសាកលវិទ្យាល័យខូវិនទ្រី ប្រទេសអង់គ្លេស ខ្ញុំយល់ឃើញផ្សេងពីនេះទៅវិញ ។ ជំនឿរបស់ខ្ញុំចំពោះតួនាទីយុត្តិធម៌នៅក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួម គឺមានកំណត់ ។

នេះគឺជាអត្ថបទសិក្សាអំពីតួនាទីយុត្តិធម៌នៅក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា ។ ជាដំបូងអត្ថបទសិក្សានេះបង្ហាញអំពីភាពខ្លាំងនិងភាពខ្សោយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងប្រព័ន្ធតុលាការប្រជាជនហៅថា កាឆាឆា នៅក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសរ៉្វាន់ដា ។ ទីពីរ អត្ថបទនេះសិក្សាប្រៀបធៀបចំណុចខ្លាំងនិងចំណុចខ្សោយរបស់តុលាការខាងលើទៅនឹងករណីនៅក្នុងប្រទេសកម្ពុជា បន្ទាប់មកបង្ហាញទស្សនៈរបស់ប្រជាជនកម្ពុជាចំពោះតួនាទីរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា ។ ជាចុងក្រោយ អត្ថបទសិក្សានេះបញ្ជាក់អះអាងថា ដូចតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាដែរ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមពិតជាមិនអាចនាំមកនូវការផ្សះផ្សាបង្រួបបង្រួមជាតិយូរអង្វែងឡើយ ។ ដើម្បីការធានានិងការបង្រួបបង្រួមយូរអង្វែង គណៈកម្មការស្វែងរកការពិតសម្រាប់កម្ពុជានិងកម្មវិធីគាំទ្រដទៃទៀតត្រូវតែបង្កើតហើយប្រតិបត្តិការ ដើម្បីជាជំនួយដល់ដំណើរការតុលាការ ។ សំណួរពាក់ព័ន្ធដែលអត្ថបទនេះវិភាគដោះស្រាយរួមមាន តើចំណុចអ្វីខ្លះដែលប្រទេសកម្ពុជាអាចរៀនសូត្រអំពីបទពិសោធន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងប្រព័ន្ធតុលាការកាឆាឆានៃប្រទេសរ៉្វាន់ដា? ហេតុអ្វីបានជាយុត្តិធម៌ដែលផ្ដល់ឲ្យដោយតុលាការមិនគ្រប់គ្រាន់ក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួម? ហេតុអ្វីបានជាគណៈកម្មការស្វែងរកការពិតសម្រាប់កម្ពុជានិងកម្មវិធីគាំទ្រដទៃផ្សេងទៀតត្រូវតែបង្កើតឡើងហើយប្រតិបត្តិការជាជំនួយដល់ដំណើរការ

តុលាការ ?

ដើម្បីឆ្លើយតបសំណួរពាក់ព័ន្ធខាងលើ ខ្ញុំចែកអត្ថបទសិក្សានេះជាបួនផ្នែក ។ ផ្នែកទីមួយគឺជាមាតិកា ។ ផ្នែកនេះ បង្ហាញនិងពន្យល់អំពីតួនាទីរបស់យុត្តិធម៌ក្នុងដំណើរការផ្សះផ្សានិងបង្រួបបង្រួម ។ ផ្នែកទីមួយចែកចេញជាបីចំណុចផ្សេងគ្នា ។ ចំណុចទីមួយពន្យល់និងកំណត់តួនាទីរបស់យុត្តិធម៌ ។ ចំណុចទីពីរកំណត់និយមន័យនិងតួនាទីនៃពាក្យបង្រួបបង្រួមជាតិ និងចំណុចទីបី បង្ហាញអំពីផលវិបាកនិងភាពមិនចុះសម្រុងនៅក្នុងដំណើរការផ្សះផ្សានិងបង្រួបបង្រួម ។ ផ្នែកទីពីរវិភាគចំណុចខ្លាំងនិងចំណុចខ្សោយរបស់យុត្តិធម៌ដែលផ្តល់ឲ្យដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងប្រព័ន្ធតុលាការកាឆាឆា ។ ផ្នែកទីបីក្រឡេកមើលទស្សនៈរបស់ប្រជាជនកម្ពុជាចំពោះតួនាទីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ យោងតាមការពិភាក្សានៅក្នុងផ្នែកទីពីរនិងផ្នែកទីបី ផ្នែកបញ្ចប់នៃអត្ថបទនេះអះអាងថា ដើម្បីការផ្សះផ្សានិងបង្រួបបង្រួមយូរអង្វែង គណៈកម្មការស្វែងរកការពិតសម្រាប់កម្ពុជានិងកម្មវិធីគាំទ្រផងទៃទៀតត្រូវតែបង្កើតហើយប្រតិបត្តិការជាជំនួយដល់ដំណើរការតុលាការ ។

## ជំពូកមួយ

## យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួម

### ១) យុត្តិធម៌

យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមមានទំនាក់ទំនងជិតស្និទ្ធ ប៉ុន្តែមានអត្ថន័យខុសគ្នា ។ អ្នកសិក្សាស្រាវជ្រាវជាច្រើនបានសិក្សាអំពីតួនាទីនិងទំនាក់ទំនងរវាងយុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួម ប៉ុន្តែការសិក្សាហាក់ពុំទាន់ស៊ីជម្រៅនិងពុំទាន់ទទួលបានលទ្ធផលជាដុំកំភួននៅឡើយ ។ មូហាម៉ាត់ អាប៊ូនីមើ, អាប់ឌុល អាហ្ស៊ីសសេដ, និង ឡាក់ស៊ីថា ប្រើលីស ទទួលស្គាល់ថា “យើងបានសិក្សានិងកំណត់រូបមន្តអំពីមូលហេតុដែលបង្កឲ្យមានជម្លោះនិងអំពើហិង្សា ប៉ុន្តែយើងមិនទាន់កំណត់បានរូបមន្តដោះស្រាយជម្លោះ ផ្សះផ្សានិងបង្រួបបង្រួមនៅឡើយទេ” ។ ចូហាន ហ្គាល់តុង បានឯកភាពនឹងទស្សនៈខាងលើនេះ ។ ហ្គាល់តុង បញ្ជាក់ថា “នេះជាការពិត ។ រហូតមកដល់សព្វថ្ងៃនេះ គ្មាននរណាម្នាក់អាចកំណត់រូបមន្តសម្រាប់ដោះស្រាយជម្លោះនិងបង្រួបបង្រួមបានជោគជ័យឡើយ” ។

រីឆាដ ហ្គូលស្តូន អតីតប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសប៊ូស្នៀនិងរ៉្វាន់ដា យល់ឃើញថា យុត្តិធម៌តាមផ្លូវតុលាការគឺជាឱសថព្យាបាលជំងឺផ្លូវចិត្តរបស់ជនរងគ្រោះ ។ ឱសថនេះមានប្រសិទ្ធភាពខ្ពស់ចំពោះជនរងគ្រោះផ្លូវចិត្តដែលធ្លាប់ទទួលរងការរំលោភបំពានពីអតីតកាល ។ ហ្គាល់តុង យល់ថា “អត្ថន័យរបស់យុត្តិធម៌មានការប្រែប្រួលទៅតាមការកំណត់របស់ភាគីជម្លោះ ។ “យុត្តិធម៌” នៅក្នុងវិស័យច្បាប់គឺជាការអនុវត្តដើម្បីបង្ហាញឲ្យឃើញនូវភាពអយុត្តិធម៌នៃអតីតកាលនិងបញ្ជាក់អំពីសិទ្ធិស្មើភាព” ។

យុត្តិធម៌មានលក្ខណៈច្រើនយ៉ាង ។ វេនឌី ឡាមបូន កំណត់ថា តាមផ្លូវតុលាការ “យុត្តិធម៌” គឺជាវិធីដោះស្រាយជម្លោះដោយដាក់ទោសអំពើអាក្រក់និងលើកទឹកចិត្តអំពើល្អ ។ នៅក្នុងសតវត្សរ៍ទី២០ និយមន័យនេះត្រូវបានកំណត់ត្រឹមតែជាវិធីដោះស្រាយជម្លោះដោយការដាក់ទោសប៉ុណ្ណោះ ។ យុត្តិធម៌តាមផ្លូវផ្សះផ្សាខុសពីយុត្តិធម៌តាមផ្លូវតុលាការ ។ យុត្តិធម៌តាមផ្លូវផ្សះផ្សាគឺជាវិធីដោះស្រាយជម្លោះបែបមនុស្សធម៌ បានសេចក្តីថាគ្រប់ភាគីជម្លោះជាមនុស្សដែលតែងមានកំហុសជាធម្មតា ។ គោលបំណងនៃការដោះស្រាយជម្លោះគឺដើម្បីព្យាបាលស្នាមរបួសដែលបន្សល់ទុកពីជម្លោះ ។

ដេសមុន ទូទូ ប្រធានគណៈកម្មការស្វែងរកការពិតសម្រាប់អាហ្វ្រិកខាងត្បូង ពន្យល់អត្ថន័យយុត្តិធម៌តាមផ្លូវផ្សះផ្សាដោយប្រើប្រាស់ពាក្យ អ៊ូប៊ុនទុ (Ubuntu) “ដែលសំដៅដល់ការអប់រំកែប្រែពិរុទ្ធជនឲ្យក្លាយជាមនុស្សល្អសម្រាប់សង្គមជាតិជាជាងការដាក់ទោសលើពិរុទ្ធជន” ។ នេះបានសេចក្តីថា “ការអត់ឱនអធ្យាស្រ័យនិងយល់អំពីតម្លៃនៃមនុស្សជាតិដូចគ្នាអាចបង្កើតឲ្យមានទំនាក់ទំនងល្អនិងសន្តិភាព” ។

ដូណាល់ ស្រ៊ីវ៉ឺ, ឡាមបូន, និង ហូវ៉ាដ ហ្សេរ ពិណ៌នាយុត្តិធម៌តាមផ្លូវផ្សះផ្សាដូច ដេសមុន ទូទូ ដែរ ។ អ្នកទាំងបីយល់ថា យុត្តិធម៌តាមផ្លូវតុលាការឬដោយការដាក់ទោសមិនមែនជាវិធីល្អសម្រាប់ដំណើរការផ្សះផ្សានិងបង្រួបបង្រួមជាតិឡើយ ។ យុត្តិធម៌សម្រាប់ការផ្សះផ្សានិងបង្រួបបង្រួមរួមមានការដាក់ទោសចំពោះឧក្រិដ្ឋជន

ប៉ុន្តែជាការដាក់ទោសតាមបែបមនុស្សធម៌ និងយល់អធ្យាស្រ័យ ដោយផ្អែកតាមកាលៈទេសៈនិងស្ថានភាពជាក់ស្តែង ។ ទិសដៅចម្បងនៃការដាក់ទោសមិនមែនដើម្បីសងសឹកទេ ប៉ុន្តែគឺដើម្បីស្តារបនាឡើងវិញនូវទំនាក់ទំនងដែលបែកបាក់ បញ្ចប់ការរំលោភបំពាន និងរស់នៅជាមួយគ្នាក្នុងសន្តិភាព ។ ស្រ៊ីរ៉ិ បញ្ជាក់ថា "បើចង់បានយុត្តិធម៌ គឺត្រូវតែស្វែងរកយុត្តិធម៌" ។

## ២) ការផ្សះផ្សាបង្រួបបង្រួម

នៅក្នុងភាសាអង់គ្លេស ពាក្យ "ផ្សះផ្សាបង្រួបបង្រួម" (Reconciliation) មានដើមកំណើតពី ភាសាឡាតាំង "Conciliare" ដែលមានន័យថា "ការរួមរស់ជាមួយគ្នា" ចំណែកឯ "Re" មានន័យថា "ការវិលត្រឡប់ទៅវក" ។ ចនប៉ូល ឡឺដឺរ៉ាក ពន្យល់ថា "ការវិលត្រឡប់ទៅវក" គឺសំដៅដល់ការវិលត្រឡប់ទៅរកភាពសុខដុមរមនាដែលធ្លាប់មានពីមុនមក មិនមែនសំដៅដល់ការវិលត្រឡប់ទៅរកភាពមិនចុះសម្រុងដែលធ្លាប់មានពីមុននោះឡើយ ។ ឡឺដឺរ៉ាក បញ្ជាក់ថា ទីណាមានសន្តិភាព យុត្តិធម៌ និងការយល់អធ្យាស្រ័យ ទីនោះមានការផ្សះផ្សាបង្រួបបង្រួម ។

ចូសេប ម៉ុនវីល យល់ថា ការកសាងទំនាក់ទំនងជាថ្មីមានសារសំខាន់សម្រាប់ការផ្សះផ្សាបង្រួបបង្រួម ។ ក្នុងអត្ថបទដែលមានចំណងជើងថា "ការជួយព្យាបាលជំងឺផ្លូវចិត្តគឺជាវិធីមួយនៅក្នុងដំណោះស្រាយជម្លោះនយោបាយ" ម៉ុនវីល ពន្យល់ថា ការផ្សះផ្សាបង្រួបបង្រួមអាចកើតមានប្រសិនបើគូបដិបក្ខយល់ច្បាស់អំពីស្ថានភាពដែលភាគីខ្លួននិងភាគីម្ខាងទៀតទទួលរងគ្រោះ ។ នេះបានសេចក្តីថា ទាំងសងខាងគឺជាជនរងគ្រោះ ហើយភាគីទាំងពីរត្រូវការទំនាក់ទំនងល្អនឹងគ្នាឡើងវិញដើម្បីភាពសម្បូរសប្បាយ និងសន្តិភាពសម្រាប់ទាំងអស់គ្នា ។

ហ៊ុគាស អាសេហ្វា យល់ថា "ការផ្សះផ្សាបង្រួបបង្រួមមិនមែនត្រឹមតែជាការដោះស្រាយជម្លោះដែលធ្លាប់មានពីមុននោះទេ ។ ការផ្សះផ្សាបង្រួបបង្រួមគឺជាការកសាងនិងថែរក្សាទំនាក់ទំនងថ្មីឲ្យបានស្ថិតស្ថេរ ។ ការផ្សះផ្សាបង្រួបបង្រួមត្រូវការចាំបាច់នូវការចូលរួមរបស់គ្រប់ភាគីជម្លោះដើម្បីស្វែងរកដំណោះស្រាយ" ។ ឡឺដឺរ៉ាក បញ្ចេញយោបល់ថា យុត្តិធម៌មានតួនាទីសំខាន់ក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួម ប៉ុន្តែយុត្តិធម៌មិនមែនជាការបង្រួបបង្រួមឡើយ ។ ការផ្សះផ្សាបង្រួបបង្រួមត្រូវការយុត្តិធម៌ និងការយល់អធ្យាស្រ័យដើម្បីកសាងទំនាក់ទំនងល្អឡើងវិញទាំងផ្លូវកាយនិងផ្លូវចិត្ត ។ ដូច្នេះការផ្សះផ្សាបង្រួបបង្រួមតម្រូវឲ្យភាគីដែលបានប្រព្រឹត្តខុសទទួលស្គាល់កំហុសឆ្គង ដែលខ្លួនបានប្រព្រឹត្ត ហើយភាគីជនរងគ្រោះយល់ព្រមសន្តោសប្រណីបន្ទាប់ពីបានដឹងការពិតនិងការសុំទោស ។ ការសន្តោសប្រណីមិនមែនបានសេចក្តីថាត្រូវលើកលែងទោសដល់គ្រប់ឧក្រិដ្ឋជនឡើយ ។ បុគ្គលជាមេដឹកនាំនិងជាជនដៃដល់ដែលទទួលខុសត្រូវចំពោះការរំលោភបំពានធ្ងន់ធ្ងរត្រូវតែទទួលទោសតាមផ្លូវច្បាប់ ។

## ៣) ទំនាក់ទំនងរវាងយុត្តិធម៌និងការបង្រួបបង្រួម

តើយុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមមានទំនាក់ទំនងបែបណា? តើយុត្តិធម៌តាមផ្លូវតុលាការមានតួនាទីសំខាន់ក្នុងដំណើរការបង្រួបបង្រួមដែរឬទេ? ចម្លើយរបស់ អាសេហ្វា គឺយុត្តិធម៌មានតួនាទីសំខាន់ក្នុងដំណើរការបង្រួបបង្រួម ។ "គ្មានយុត្តិធម៌គឺគ្មានការបង្រួបបង្រួម" ប៉ុន្តែ "យុត្តិធម៌តែមួយមុខ មិនអាចបង្កើតឲ្យមានការផ្សះផ្សាបង្រួបបង្រួមឡើយ" ។ អត្ថបទសិក្សានេះទទួលយកការបកស្រាយនិងគំនិតដែលវិភាគជុំវិញទំនាក់ទំនងរវាងយុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួម ប៉ុន្តែខ្ញុំគាំទ្រគំនិតទីពីរដែលថា យុត្តិធម៌តែមួយគត់មិនគ្រប់គ្រាន់សម្រាប់ការផ្សះផ្សាបង្រួបបង្រួមឡើយ ។ ខ្ញុំនឹងពន្យល់មូលហេតុនៃការគាំទ្រគំនិតនេះនៅក្នុងវគ្គបន្តបន្ទាប់ ។

## ៤) បញ្ហារវាងយុត្តិធម៌និងការបង្រួបបង្រួម

ការសិក្សារបស់ ម៉ៃឃើល ប៉ាលីវលាត, អេនឌ្រូ រីដប៊ី, ឡឺដឺរ៉ាក, ម៉ាថា មីណូ, ហ៊្វូច ម៉ាយអ៊ិល, អូលីវ៉ី រ៉ាមបូថាម និង ថមវូដហៅ បញ្ជាក់ថា ដំណើរការស្វែងរកយុត្តិធម៌តែងតែមានលក្ខណៈស្មុគស្មាញនិងគំរាមកំហែងដល់ស្ថានភាពសន្តិភាពនិងការពិត ។ ឧទាហរណ៍ ការប៉ុនប៉ងចាប់ខ្លួនឧក្រិដ្ឋជនដើម្បីផ្តន្ទាទោសអាចបង្កឲ្យឧក្រិដ្ឋជនមិនហ៊ានរស់នៅក្នុងភូមិស្រុក ហើយរត់ភៀសខ្លួនចូលព្រៃបង្កអសន្តិសុខនិងសង្គ្រាមម្តងទៀត ។ ឧទាហរណ៍មួយផ្សេងទៀតគឺការស្វែងរកយុត្តិធម៌អាចរំខាននិងរាំងខ្ទប់ការពិត ។ ឧក្រិដ្ឋជនមិនហ៊ានរៀបរាប់អំពីការពិតឬអ្វីដែលបានកើតឡើងដោយសារការនិយាយរបស់គាត់អាចបណ្តាលឲ្យគាត់ប្រឈមមុខ

នឹងការកាត់ទោស ។ ប៉ាលីវ៉ាលាត យល់ថា វិធីសាស្ត្រល្អក្នុងការដោះស្រាយការរំលោភបំពានពីអតីតកាលគឺវិធីសាស្ត្រដែលបានថ្លឹងថ្លែងយ៉ាងសុក្រឹតរវាងស្ថានភាពនយោបាយ និងយុត្តិធម៌ ។ នេះបានសេចក្តីថា វិធីសាស្ត្រនោះផ្តល់ឲ្យជនរងគ្រោះទាំងយុត្តិធម៌ និងសន្តិភាព ពីព្រោះថា "យុត្តិធម៌អាចគំរាមកំហែងដល់សន្តិភាព ជាពិសេសសន្តិភាពសម័យអន្តរកាល និងសន្តិភាពដែលមិនទាន់រឹងមាំ" ។

បន្ទាប់ពីការកាប់សម្លាប់អំពើប្រល័យពូជសាសន៍ បញ្ហាយុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមត្រូវបានលើកយកមកពិភាក្សាយ៉ាងសស្រាក់សស្រាំ ។ ជនរងគ្រោះស្រែកទាមទាររកយុត្តិធម៌ ដោយពន្យល់ថាមានយុត្តិធម៌ទើបមានការផ្សះផ្សាបង្រួបបង្រួម ។ ប្រជាជនដែលទាមទារយុត្តិធម៌និងអ្នកគាំទ្រចលនាស្វែងរកយុត្តិធម៌ រៀបរាប់អំពីសារសំខាន់របស់ យុត្តិធម៌ដូចខាងក្រោម ÷

**ក) លុបបំបាត់វប្បធម៌លើកលែងទោស**

ការដាក់ទោសឧក្រិដ្ឋជនអាចបញ្ជាក់អំពីសុឆន្ទៈរបស់រដ្ឋាភិបាលក្នុងការកសាងមូលដ្ឋានច្បាប់និងនីតិរដ្ឋ ។ ការលើកលែងទោសឬមិនផ្តន្ទាទោសឧក្រិដ្ឋជនគឺជាការជាន់ពន្លិចច្បាប់ទម្លាប់បន្តភាពសោកសៅក្នុងជីវិតរបស់ប្រជាជន ។ នេះគឺជាមហន្តរាយយ៉ាងធំចំពោះសង្គមជាតិ ។ ហេតុផលខាងលើនេះ ត្រូវបានលើកឡើងជាញឹកញាប់ដោយបណ្តាប្រទេសដែលទើបឆ្លងផុតពីការកាប់សម្លាប់ ជាពិសេសនៅក្នុងមូលហេតុនៃការស្ថាបនាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី (ICTY) និងរ៉្វាន់ដា (ICTR) នៅទីក្រុងឡាអេ (Hague) និងនៅទីក្រុងអារូហ្សា (Arusha) រួមទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ (ICC) ។

**ខ) ការទទួលទោសជាបុគ្គល**

ការដាក់ទោសចំពោះបុគ្គលដែលទទួលខុសត្រូវចំពោះការកាប់សម្លាប់អាចជួយលុបលាងនិងបញ្ជាក់អំពីភាពបរិសុទ្ធរបស់ជនស្លូតត្រង់ដែលស្ថិតនៅក្នុងក្រុមជាមួយឧក្រិដ្ឋជន ។ ឧទាហរណ៍ ការដាក់ទោសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ទៅលើបុគ្គលបានជួយបញ្ជាក់អំពីភាពគ្មានទោសពៃរ៍របស់ប្រជាជនសញ្ជាតិ ហ៊ូទូ, ទុតស៊ី, ស៊ឹប និង មូស្លីមដទៃទៀត ដែលមិនបានចូលរួមប្រព្រឹត្តអំពើកាប់សម្លាប់ ។ និយាយឲ្យខ្លី ជនដែលតុលាការកាត់ទោសគឺជាឧក្រិដ្ឋជននិងជាឃាតករ ។ ការដឹងឮនិងទទួលស្គាល់ភាពគ្មានទោសមានសារសំខាន់ក្នុងការធ្វើឲ្យប្រជាជនដែលធ្លាប់មានជម្លោះអស់មន្ទិលសង្ស័យរវាងគ្នា ហើយយល់ព្រមកសាងទំនាក់ទំនងល្អនឹងគ្នាឡើងវិញ ។

**គ) ចៀសវាងការសងសឹកជាលក្ខណៈបុគ្គល**

ការដាក់ទោសរបស់តុលាការចំពោះឧក្រិដ្ឋជនដែលទទួលខុសត្រូវការកាប់សម្លាប់អាចជួយលុបបំបាត់ការសងសឹកជាបុគ្គល ឬការស្វែងរកយុត្តិធម៌ដោយខ្លួនឯង ។

**ឃ) ជាកាតព្វកិច្ចដែលត្រូវបំពេញជូនជនរងគ្រោះ**

អ្នកគាំទ្រចំពោះយុត្តិធម៌តាមផ្លូវតុលាការអះអាងថា ជនរងគ្រោះទាមទារយុត្តិធម៌ដើម្បីសងសឹកជនដែដល់ដែលបានរំលោភបំពានមកលើខ្លួន ហើយយុត្តិធម៌នេះអាចជួយព្យាបាលជំងឺផ្លូវចិត្តជនរងគ្រោះឲ្យធូរស្បើយ ។ ម្យ៉ាងទៀត ការដាក់ទោសឧក្រិដ្ឋជនក៏អាចជួយជនរងគ្រោះឲ្យមានជំនឿចិត្តលើខ្លួនឯងឡើងវិញបន្ទាប់ពីបានដឹងថាទុក្ខវេទនារបស់ខ្លួនត្រូវបានដឹងឮ និងទទួលស្គាល់ជាទូទៅ ហើយអ្នកដែលបានប្រព្រឹត្តអំពើអាក្រក់មកលើខ្លួនត្រូវបានរកឃើញ និងដាក់ទោស ។

**ង) ទប់ស្កាត់មិនឲ្យការកាប់សម្លាប់កើតឡើងជាថ្មីម្តងទៀត**

ការដាក់ទោសឧក្រិដ្ឋជនគឺជាវិធីទប់ស្កាត់ដ៏មានប្រសិទ្ធភាពមិនឲ្យការកាប់សម្លាប់កើតឡើងជាថ្មីម្តងទៀត ។ និយាយឲ្យខ្លី ការដាក់ទោសគឺជាការព្រមានចំពោះប្រជាជនទូទៅថា បើមានការប្រព្រឹត្តខុសគឺត្រូវតែមានការកាត់ទោសនិងដាក់ទោស ។ ឧទាហរណ៍ របាយការណ៍ឆ្នាំ២០០១របស់ការិយាល័យតំណាងរាស្ត្រនិងការបរទេសនៃចក្រភពអង់គ្លេស (British Foreign and Commonwealth Office) ស្តីអំពីសភាពការណ៍នៅអតីតប្រទេស យូហ្គោស្លាវី បានសរសេរថា ការកាត់ទោសឧក្រិដ្ឋជន "គឺជាមេរៀននិងជាការព្រមានដើម្បីទប់ស្កាត់របប ប៉ុល ពត និងរបប សាដាម ហ៊ូសេន មិនឲ្យកើតមានជាថ្មីម្តងទៀត" ។ ◆

ការដាក់ទោសឧក្រិដ្ឋជនមានសារប្រយោជន៍ច្រើនយ៉ាង ប៉ុន្តែការដាក់ទោសមិនអាចធ្វើឡើងដោយងាយៗនិងគ្រប់កាលៈទេសៈឡើយ ។ នេះបានសេចក្តីថា ស្ថានភាពសន្តិសុខនិងនយោបាយជាក់ស្តែងតម្រូវឲ្យមេដឹកនាំនយោបាយមួយចំនួនរារែកក្នុងការ

ចាត់វិធានការផ្តល់យុត្តិធម៌ជូនជនរងគ្រោះតាមផ្លូវតុលាការ ។ នៅក្នុងស្ថានភាពនយោបាយនិងសន្តិសុខដែលមិនទាន់រឹងប៉ឹងការកាត់ទោសមិនត្រឹមតែមិនអាចនាំមកនូវការផ្សះផ្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចបង្កឲ្យមានសង្រ្គាមនិងអំពើកាប់សម្លាប់ជាថ្មីម្តងទៀត ។ ម្យ៉ាងទៀត ការកាត់ទោសអាចធ្វើឲ្យប្រជាជនមិនអាចយល់ដឹងបានអំពីការពិតឬអ្វីដែលបានកើតឡើងពិតប្រាកដព្រោះថា ការកាត់ទោសបង្កឲ្យឧក្រិដ្ឋជនភ័យខ្លាច មិនហ៊ាននិយាយប្រាប់ការពិត ។ ខាងក្រោមនេះគឺជាផលវិបាកដែលអះអាងដោយប្រជាជនដែលមិនគាំទ្រការកាត់ទោសឬការបង្កើតឲ្យមានតុលាការដើម្បីកាត់ទោសឧក្រិដ្ឋជន ៖

**ក) ជនដៃដល់គឺជាមុខសញ្ញារបស់តុលាការ**

ការកាត់ទោសផ្តោតសំខាន់លើអំពើដែលកើតឡើងពីអតីតកាល ហើយស្វែងរកចាប់ខ្លួនឧក្រិដ្ឋជនដែលបានប្រព្រឹត្តខុសដើម្បីផ្តន្ទាទោស ។ ការធ្វើបែបនេះនាំឲ្យជនរងគ្រោះមិនអាចបំភ្លេចរឿងដើម ហើយមិនអាចកសាងជីវិតថ្មីឡើងវិញ ដោយសារជនរងគ្រោះគិតតែទន្ទឹងរង់ចាំយុត្តិធម៌ ។

**ខ) យុត្តិធម៌សម្រាប់អ្នកឈ្នះ**

រដ្ឋាភិបាលថ្មីឬអ្នកមានអំណាចគឺជាអ្នករៀបចំតុលាការដើម្បីកាត់ទោសអ្នកចាញ់ឬរដ្ឋាភិបាលចាស់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងពេលកាន់អំណាច ។ ឧទាហរណ៍ គោលបំណងនៃការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាគឺដើម្បីកាត់ទោសអតីតរដ្ឋអំណាចជាជនជាតិ ហ៊ូទូ ដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិទុតស៊ី ។ សំណួរមួយសួរថា ហេតុអ្វីបានជាតុលាការមិនកាត់ទោសជនជាតិទុតស៊ីដែលបានឆ្លៀតឱកាសសម្លាប់ជនជាតិហ៊ូទូអស់រាប់ពាន់នាក់ ដើម្បីជាការសងសឹកក្នុងអំឡុងពេលសង្រ្គាមផង?

**គ) ការកាត់ទោសបង្កឲ្យជនរងគ្រោះកើតទុក្ខម្តងទៀត**

នៅក្នុងដំណើរការជំនុំជម្រះក្តី តែងតែមានការសួរនាំជាច្រើនលើកច្រើនសា ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់រកការពិត ។ ការរកនឹកគិតឆ្លើយសំណួររបស់តុលាការធ្វើឲ្យជនរងគ្រោះកើតទុក្ខជាថ្មីម្តងដោយសារខ្លួនត្រូវរៀបរាប់អំពីការលំបាកនិងការឈឺចាប់ម្តងហើយម្តងទៀត ។ លើសពីនេះទៀត ជនរងគ្រោះមួយចំនួនខកចិត្តនៅពេលដែលការទាមទាររកយុត្តិធម៌ត្រូវបរាជ័យដោយសារករណីបណ្តឹងរបស់គាត់ខ្វះភ័ស្តុតាងនិងដោយសារភាពចន្លោះប្រហោងនៃច្បាប់ ។

**ឃ) ការកាត់ទោសអាចបង្កឲ្យប្រវត្តិសាស្ត្រស្រពេចស្រពិល**

មេធាវីដើមចោទនិងចុងចោទប្រឹងប្រែងរិះរកមធ្យោបាយធ្វើយ៉ាងណាឲ្យកូនក្តីរបស់ខ្លួនទទួលជោគជ័យ ។ កាន់តែប្រឹងប្រែងជជែកពិភាក្សាគឺកាន់តែធ្វើឲ្យប្រវត្តិសាស្ត្រឬរឿងរ៉ាវដែលបានកើតឡើងក្លាយទៅស្រពិចស្រពិល ។ តាមការបញ្ជាក់របស់ អៀន ប៊ូរូម៉ា ការស្វែងរកយុត្តិធម៌តាមផ្លូវតុលាការ គឺពិតជាពិបាកចៀសវាងការប៉ះពាល់លើប្រវត្តិសាស្ត្រ ។ ប៊ូរូម៉ា បញ្ជាក់ថា “តើធ្វើបែបណាដើម្បីទទួលបានយុត្តិធម៌ដោយមិនរំលោភច្បាប់ ហើយតុលាការដែលធ្វើឡើងដោយអ្នកឈ្នះនឹងមិនរំលោភប្រវត្តិសាស្ត្រ?” ។

**ង) បញ្ហាលំបាកផ្នែកធនធាននិងសម្ភារ**

ប្រទេសដែលទើបឆ្លងផុតអំពីសង្រ្គាមនិងការកាប់សម្លាប់តែងស្ថិតក្នុងស្ថានភាពខ្វះខាតទាំងធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ។ ជាក់ស្តែង បន្ទាប់ពីសង្រ្គាម ប្រទេសរ៉ាន់ដាមានការខ្វះខាតយ៉ាងខ្លាំង ជាពិសេសធនធានមនុស្សបម្រើក្នុងវិស័យច្បាប់ ដូច្នេះដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះមានការយឺតយ៉ាវបំផុត ។ ក្នុងចំណោមអ្នកទោសចំនួន១២៥.០០០នាក់ ដែលត្រូវបានចាប់ខ្លួន មានអ្នកទោសត្រឹមតែ៦.៤០០នាក់ប៉ុណ្ណោះដែលត្រូវតុលាការជំនុំជម្រះក្តី ។ ភាពយឺតយ៉ាវរបស់តុលាការធ្វើឲ្យជនរងគ្រោះរអ៊ូរទាំនិងរិះគន់ថា “តុលាការយឺតយ៉ាវក្នុងការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ” ។

**ច) ចំណុចខ្វះខាតនិងការប្រថុយប្រថាន**

នៅពេលខ្លះ ការដាក់ទោសឧក្រិដ្ឋជនអាចបង្កផលលំបាកនិងរាំងស្ទះដល់ដំណើរការផ្សះផ្សាបង្រួបបង្រួម ។ នៅក្នុងសម័យអន្តរកាលដែលទើបឆ្លងផុតពីសង្រ្គាមនិងអំពើកាប់សម្លាប់ អ្នកដឹកនាំនយោបាយមួយចំនួនព្រមព្រៀងជាមួយភាគីជម្លោះរបស់ខ្លួនបំភ្លេចនូវរឿងដែលកើតឡើងពីអតីតកាល ។ នេះបានសេចក្តីថា គ្មានការបង្កើតតុលាការកាត់ទោសអំពើដែលបានប្រព្រឹត្តខុសកន្លងមកដើម្បីរកខុសត្រូវឬសខ្មៅឡើយ ។ អ្នកនយោបាយ

ទាំងនោះយល់ថា ការបង្កើតតុលាការកាត់ទោសអាចបង្កការលំបាកដល់ប្រជាជននិងប្រទេសជាតិ ដោយសារបន្ទាប់ពីសង្គ្រាម ប្រទេសជាតិស្ថិតក្នុងសភាពមិនទាន់មានស្ថិរភាពពេញលេញ ម្យ៉ាងទៀតប្រព័ន្ធច្បាប់ក៏ស្ថិតក្នុងសភាពទន់ខ្សោយ ។ លើសពីនេះទៀត ការកាត់ទោសអាចរំលោភលើច្បាប់ទម្លាប់និងប្រពៃណីវប្បធម៌របស់ប្រទេសថែមទៀត ។ ដេសមុន ទូទូ បញ្ចេញប្រតិកម្មថា យុត្តិធម៌តាមផ្លូវតុលាការមិនមែនជាវប្បធម៌របស់ជនជាតិអាហ្វ្រិកឡើយ ។ ការពិត យុត្តិធម៌តាមផ្លូវតុលាការក៏មិនមែនជាវប្បធម៌និងប្រពៃណីរបស់ប្រជាជនកម្ពុជាដែរ ។ ការសិក្សាបញ្ជាក់ថា ប្រជាជនកម្ពុជារារែកចិត្តក្នុងការកាត់ទោសអតីតជនដៃដល់ខ្មែរក្រហមដោយសារមូលហេតុសំខាន់ពីរ ។ ទីមួយ មានការលំបាកក្នុងការបែងចែករវាងជនដៃដល់និងជនរងគ្រោះនៃរបបខ្មែរក្រហម ។ ទីពីរ ប្រជាជនកម្ពុជាគោរពព្រះពុទ្ធសាសនាជឿលើកម្មផល ។ ដូច្នេះប្រជាជនយល់ថា ការរងទុក្ខរបស់ខ្លួនគឺជាផលនៃកម្មដែលខ្លួនបានកសាងពីជាតិមុន ហើយការសងសឹករមែងនាំមកនូវកម្មផលបន្ថែមទៅជាតិខាងមុខទៀត ។ ករណីខាងលើនេះហើយបានជាយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាតាមផ្លូវផ្សះផ្សាហាក់ដូចជាសមស្របនិងពេញនិយមជាងយុត្តិធម៌តាមផ្លូវតុលាការ ។

ចំពោះ ឡាមប៊ូន ឧទាហរណ៍ល្អបំផុតបញ្ជាក់អំពីយុត្តិធម៌តាមផ្លូវផ្សះផ្សា គឺប្រព័ន្ធតុលាការប្រជាជន (តុលាការកាឆាឆា) នៅប្រទេសរ៉្វាន់ដា ។ ឡាមប៊ូន ពន្យល់ថា យុត្តិធម៌តាមផ្លូវផ្សះផ្សាមិនផ្តោតសំខាន់លើការដាក់ទោសលើភាគីដែលមានកំហុសទេ ។ វិធីនេះសំដៅដល់ការអប់រំណែនាំជនមានកំហុសឲ្យភ្ញាក់រឭក ហើយកសាងទំនាក់ទំនងថ្មីជាមួយគ្នាឡើងវិញ ។

អាប៊ូនីមើ, សេដ និង ប្រីលីស យល់ស្របតាម ឡាមប៊ូន ។ អ្នកទាំងបីបន្ថែមថា ការពឹងផ្អែកទាំងស្រុងឬការចម្លងវិធីសាស្ត្រដោះស្រាយជម្លោះដែលបង្កើតដោយប្រទេសមួយយកទៅអនុវត្តនៅក្នុងប្រទេសមួយផ្សេងទៀតមិនមែនជាវិធីល្អឡើយ ដោយសារតែភាពខុសគ្នានៃវប្បធម៌និងប្រពៃណី ។ អ្នកទាំងបីបញ្ជាក់ថា កត្តាវប្បធម៌និងប្រពៃណីគឺជាកត្តាសំខាន់ ដូច្នេះវិធីសាស្ត្រដោះស្រាយជម្លោះគួរតែមានលក្ខណៈសមស្របតាមកត្តាទាំងពីរ ។ ឧទាហរណ៍ ប្រព័ន្ធតុលាការកាឆាឆា នៅប្រទេសរ៉្វាន់ដា, តុលាការ ស៊ូល (Sulh) នៅប្រទេសមជ្ឈិមបូព៌ា, តុលាការ ហូអូ ប៉ូណូប៉ូណូ (Ho O’ ponopono) នៅហាវ៉ៃ និងតុលាការ ឆីវថាន (Chieftan) នៅប្រទេសហ្គាណា សុទ្ធតែមានលក្ខណៈសមស្របនឹងវប្បធម៌ប្រពៃណីរបស់ប្រទេសនីមួយៗ ហើយមានការគាំទ្រច្រើនពីប្រជាជន ។

ដាវីដ ប៊្លូមហ្វៀល សង្កេតឃើញថា បណ្តាប្រទេសមួយចំនួនបង្វែរពីការចម្លងវិធីសាស្ត្រដោះស្រាយជម្លោះរបស់ប្រទេសដទៃទៅបង្កើតវិធីសាស្ត្ររបស់ខ្លួនដោយផ្អែកលើធនធាននិងវប្បធម៌ផ្ទាល់ដែលខ្លួនមាន ។ មូលហេតុទីមួយគឺដោយសារវិធីសាស្ត្រដែលបង្កើតឡើងដោយខ្លួនឯងមានលក្ខណៈសមស្របនឹងធនធានដែលខ្លួនមាន ចំណាយតិចជាងវិធីសាស្ត្រចម្លងពីបរទេស ។ មូលហេតុទីពីរគឺដោយសារវិធីសាស្ត្រនេះស្របតាមវប្បធម៌និងប្រពៃណី ដូច្នេះប្រជាជនចូលរួមនិងគាំទ្រ ហើយវិធីសាស្ត្របែបនេះ តែងតែទទួលបានលទ្ធផលល្អប្រសើរ ។

តាមការសង្កេតរបស់អ្នកសិក្សាស្រាវជ្រាវដែលបានបង្ហាញខាងលើ យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ។ ការស្វែងរកយុត្តិធម៌តាមផ្លូវតុលាការតែងតែមានលក្ខណៈស្មុគស្មាញនិងលំបាក ជាពិសេសក្នុងស្ថានភាពប្រទេសដែលសន្តិភាពមិនរឹងមាំ ។ ម្យ៉ាងទៀត ការស្វែងរកយុត្តិធម៌តាមផ្លូវតុលាការក៏អាចបង្កការរាំងស្ទះដល់ការពិតដែរ ។ និយាយឲ្យខ្លី យុត្តិធម៌តាមផ្លូវតុលាការមានសារសំខាន់ក្នុងដំណើរការផ្សះផ្សានិងបង្រួបបង្រួម ប៉ុន្តែយុត្តិធម៌តែមួយគត់ពិតជាមិនគ្រប់គ្រាន់សម្រាប់ដំណើរការផ្សះផ្សានិងបង្រួបបង្រួមឡើយ ។

ចំណុចទីមួយនៃជំពូកបន្ទាប់គឺជាការសិក្សាអំពីទំនាក់ទំនងរវាងយុត្តិធម៌និងការបង្រួបបង្រួម ដោយប្រើប្រាស់ករណីប្រទេសរ៉្វាន់ដាជាឧទាហរណ៍ ។ ចំណុចទីពីរគឺជាការវិភាគអំពីមូលហេតុដែលបញ្ជាក់ថា យុត្តិធម៌តាមផ្លូវតុលាការតែមួយមិនគ្រប់គ្រាន់សម្រាប់ការផ្សះផ្សានិងបង្រួបបង្រួមឡើយ ។

## ជំពូកទីពីរ

## ចំណុចខ្លាំងនិងចំណុចខ្សោយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងប្រព័ន្ធតុលាការប្រជាជន (កាឆាឆា) នៅប្រទេសរ៉្វាន់ដា

## ១) ប្រវត្តិនៃជម្លោះ

នៅឆ្នាំ១៩៥៩ បីឆ្នាំបន្ទាប់ពីទទួលបានឯករាជ្យពីប្រទេសបែលហ្ស៊ិក ជនជាតិហ៊ូទូដែលជាប្រជាជនភាគច្រើននៅក្នុងប្រទេសរ៉្វាន់ដា បានផ្តួលរំលំរបបគ្រប់គ្រងដោយស្តេចដែលជាជនជាតិទុតស៊ី ។ បន្ទាប់ពីហេតុការណ៍នេះ ជនជាតិទុតស៊ីជាច្រើនពាន់នាក់ត្រូវបានសម្លាប់ជាបន្តបន្ទាប់ ហើយប្រមាណ១៥ម៉ឺននាក់ផ្សេងទៀតបង្ខំចិត្តរត់ភៀសខ្លួនទៅជ្រកកោននៅប្រទេសជិតខាង ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៦០រហូតដល់ឆ្នាំ១៩៩០ ជនជាតិទុតស៊ីដែលរស់នៅក្នុងប្រទេសជិតខាងរ៉្វាន់ដា បានប្រមូលគ្នាបង្កើតជារណសិរ្សស្នេហាជាតិរ៉្វាន់ដា ហើយវាយលុកជាច្រើនលើកច្រើនសាចូលប្រទេសរ៉្វាន់ដាដើម្បីដណ្តើមអំណាចដែលកាន់កាប់ដោយរដ្ឋអំណាចហ៊ូទូ ។

ប្រធានាធិបតី កាយីបាន់ដា ត្រូវឧត្តមសេនីយ៍ហ៊ូទូ ធ្វើរដ្ឋប្រហារទម្លាក់ និងដណ្តើមអំណាចនៅឆ្នាំ១៩៧៣ ។ បន្ទាប់ពីព្រឹត្តិការណ៍រដ្ឋប្រហារនោះ កាយីបាន់ដា និងអ្នកគាំទ្រជាជនជាតិទុតស៊ីជាច្រើននាក់ត្រូវចាប់ខ្លួននិងសម្លាប់ ។ ក្នុងរវាងខែកញ្ញានិងខែតុលា ឆ្នាំ១៩៩០ កម្លាំងរណសិរ្សស្នេហាជាតិរ៉្វាន់ដា ប្រមាណពី៥ពាន់ទៅ១ម៉ឺននាក់ បានវាយលុកពីព្រំដែនប្រទេសអ៊ុយហ្គាន់ដាចូលប្រទេសរ៉្វាន់ដា ។ ឆ្លើយតបចំពោះការវាយប្រហារនេះ រដ្ឋាភិបាលរ៉្វាន់ដាដែលដឹកនាំដោយប្រធានាធិបតី ហាប៊ីយ៉ា រីមាណា បានចាប់ខ្លួននិងឃុំឃាំងអ្នកគាំទ្រពលរណសិរ្សប្រមាណ ១ម៉ឺននាក់ ។ សង្គ្រាមរវាងរណសិរ្សស្នេហា ជាតិរ៉្វាន់ដា និងរដ្ឋាភិបាលរ៉្វាន់ដា បានអូសបន្លាយរហូតដល់ឆ្នាំ១៩៩២ និងសម្លាប់មនុស្សអស់ជាច្រើនពាន់នាក់ ។ ក្នុងអំឡុងពេលសង្គ្រាម ហាប៊ីយ៉ា រីមាណា បានសុំឲ្យរដ្ឋាភិបាលបែលហ្ស៊ិក និងបារាំងជួយធ្វើអន្តរាគមន៍ផ្តួចផ្តើមការចរចា និងចេញបទឈប់បាញ់រវាងរដ្ឋាភិបាល និងក្រុមរណសិរ្សនៅចុងឆ្នាំ១៩៩០ ។ នៅខណៈនោះ ចំណុចសំខាន់និងចម្រូងចម្រាសនៅក្នុងការចរចា គឺជោគវាសនានៃជនភៀសខ្លួន ទុតស៊ីនៅក្រៅប្រទេស ។ ក្រុមរណសិរ្សទាមទារឲ្យរដ្ឋាភិបាលទទួលយកនិងប្រគល់ដីធ្លីឲ្យជនភៀសខ្លួន ប៉ុន្តែរដ្ឋាភិបាលរ៉្វាន់ដា បដិសេធដោយហេតុផលថា គ្មានដីទំនេរសម្រាប់ជនភៀសខ្លួនទាំងនោះទេ ។ ការចរចាបានអូសបន្លាយ ហើយទីបំផុតរដ្ឋាភិបាលយល់ព្រមទទួលយកជនភៀសខ្លួនទាំងនោះ ។ កិច្ចព្រមព្រៀងពីបទឈប់បាញ់ត្រូវបានចុះហត្ថលេខាម្តងទៀតនៅពាក់កណ្តាលឆ្នាំ១៩៩២ ហើយជំរុញឲ្យមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងអារូហ្សា ប្រទេសតង់ហ្សានីក្នុងខែសីហា ឆ្នាំ១៩៩៣ ។

ក្រោមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងអារូហ្សាឆ្នាំ១៩៩៣ ប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា បន្តកាន់កាប់អំណាច ។ ពិធីបន្តអំណាចជាផ្លូវការត្រូវបានប្រារព្ធឡើងនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៩៤ ប៉ុន្តែសភាជាតិនិងគណៈរដ្ឋមន្ត្រីសម្រាប់សម័យអន្តរកាលត្រូវជាប់ផុងនិងដោះស្រាយមិនរួច ។ បាតុកម្មទាមទារឲ្យរដ្ឋាភិបាលនិងក្រុមរណសិរ្សស្វែងរកដំណោះស្រាយទម្លាយភាពទាល់ច្រកបានកើតឡើងជាបន្តបន្ទាប់ ។ ព្រមជាមួយគ្នានេះការចាប់ខ្លួនជនប្រឆាំង ការបំភិតបំភ័យផ្នែកនយោបាយនិងការរំលោភបំពានលើប្រជាជនក៏បានកើតឡើងដែរ ។

នៅរវាងខែមករានិងខែមេសា ឆ្នាំ១៩៩៤ អសន្តិសុខកើតឡើងនៅទូទាំងប្រទេស ។ ពេលនោះប្រធានាធិបតី ហាប៊ីយ៉ា រីមាណា ស្ថិតក្រោមសម្ពាធរបស់ប្រជាជនក៏ដូចជាប្រទេសជិតខាងក្នុងតំបន់និងសហគមន៍អន្តរជាតិឲ្យដោះស្រាយភាពទាល់ច្រក ហើយអនុវត្តកិច្ចព្រមព្រៀងទីក្រុងអារូហ្សា ។ នៅទីបំផុតប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា បានសម្រេចចិត្តជួបប្រជុំជាមួយមេដឹកនាំក្នុងតំបន់នៅទីក្រុងអារូហ្សា ។ បន្ទាប់ពីកិច្ចប្រជុំ ប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា បានធ្វើដំណើរតាមយន្តហោះពិសេសរបស់ខ្លួនវិលត្រឡប់មកទីក្រុងគីកាលី ប្រទេសរ៉្វាន់ដាវិញ ។ យន្តហោះរបស់គាត់ត្រូវបាញ់ទម្លាក់ដោយគ្រាប់រ៉ុក្កែតក្នុងពេលព្យាយាមចុះចតនៅព្រលានយន្តហោះក្នុងទីក្រុងគីកាលីនៅវេលាម៉ោង៦ៈ៣០នាទី ។

ព្រមពេលជាមួយហេតុការណ៍នេះ ការសម្លាប់ជនជាតិទុតស៊ី និងអ្នកនយោបាយប្រឆាំងជនជាតិហ៊ូទូ បានកើតឡើងទូទាំងប្រទេស ។ របាយការណ៍ជាច្រើនពិពណ៌នាការសម្លាប់នេះថាមានផែនការទុកជាមុន ជាពិសេសផែនការញុះញង់តាមវិទ្យុផ្សាយសំឡេងដែលឃោសនាឲ្យប្រជាជនហ៊ូទូ មានការរើសអើងនិងកាប់សម្លាប់ជនជាតិទុតស៊ី ។ នៅពេលនោះ ជនដៃដល់ភាគច្រើន

គឺជាសមាជិកក្រុមសេនាជនដែលមានឈ្មោះថា អ៊ីនតេរ៉ាហាមវេ (ឬអ្នកវាយប្រហាររួមគ្នា) និងក្រុមអ៊ីមពូសាមូហ្គាមបី (ឬអ្នកមានបំណងដូចគ្នា) ។ ក្រុមសេនាជន ទាំងពីរនេះបង្កើតឡើងរួមគ្នារវាងគណបក្សកាន់អំណាច MRND និងក្រុមដែលមានឈ្មោះថា សម្ព័ន្ធភាពដើម្បីការពារសាធារណរដ្ឋ (CDR) និងកងការពារប្រធានាធិបតី ។ អំពើប្រល័យពូជសាសន៍បានកើតឡើងទូទាំងប្រទេសរ៉្វាន់ដា ដោយសារតែទីមួយគ្មានការទប់ស្កាត់ពីសហគមន៍អន្តរជាតិ និងទីពីរការកាត់បន្ថយចំនួនកងរក្សាសន្តិសុខអង្គការសហប្រជាជាតិ បន្ទាប់ពីកងរក្សាសន្តិសុខអង្គការសហប្រជាជាតិមកពីប្រទេសបែលហ្ស៊ិកចំនួន១០នាក់ ត្រូវបានសម្លាប់ ។

អំពើកាប់សម្លាប់របស់ក្រុមនិយមជ្រុលនៃរដ្ឋាភិបាលរ៉្វាន់ដាលើប្រជាជនទុតស៊ី និងសង្គ្រាមរវាងរណសិរ្សស្នេហាជាតិនិងរដ្ឋាភិបាលរ៉្វាន់ដា ចាប់តាំងពីថ្ងៃទី៦ ខែមេសា រហូតដល់ពាក់កណ្តាលខែកក្កដាឆ្នាំ១៩៩៤ បណ្តាលឲ្យប្រជាជនពី៨សែនទៅ ១លាននាក់បាត់បង់ជីវិត ។ ប្រជាជនប្រមាណ២លាននាក់ដែលភាគច្រើនជាជនជាតិហ៊ូទូបានភៀសខ្លួនទៅជ្រកកោននៅប្រទេសជិតខាងដូចជាប្រទេស កុងហ្គោ, បូរុនឌី និង តង់ហ្សានី ហើយប្រមាណមួយលាននាក់ផ្សេងទៀតរស់នៅដោយគ្មានទីជម្រក មានជំងឺផ្លូវចិត្តដោយសារការរំលោភផ្លូវភេទនិងការបាត់បង់សមាជិកគ្រួសារ ។

នៅមុនពេលមានសង្គ្រាម ទីក្រុងគីកាលីមានប្រជាជនរស់នៅប្រមាណបីសែននាក់ ។ បន្ទាប់ពីសង្គ្រាម ទីក្រុងគីកាលីប្រែទៅជាស្ងាត់ជ្រងំ ។ ប្រជាជនដែលរស់នៅទីនោះមានត្រឹមតែប្រាំម៉ឺននាក់ ហើយពាក់កណ្តាលរស់នៅដោយគ្មានទីជម្រក ។ សង្គ្រាមបានសម្លាប់កុមារបីសែននាក់ បន្សល់ទុកកុមារកំព្រាចំនួន១សែននាក់និងស្ត្រីមេម៉ាយ២សែន៥ម៉ឺននាក់ ។ កុមារដែលនៅរស់ភាគច្រើនគ្មានសង្ឃឹមថាខ្លួនអាចមានជីវិតរស់ឡើយ ព្រោះកុមារទាំងនោះសុទ្ធតែធ្លាប់ទទួលរងការធ្វើបាប ។ ក្នុងចំណោមកុមារដែលនៅរស់៣០០នាក់ ភាគច្រើនមានអាយុក្រោម១០ឆ្នាំនិងជាប់ពាក់ព័ន្ធក្នុងអំពើប្រល័យពូជសាសន៍ ។ ក្រោយសង្គ្រាម ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលក្រសួង-មន្ទីរ គ្មានដំណើរការដោយសារខ្វះខាតសម្ភារៈ តុ កៅអី និងសូម្បីតែក្រដាសសម្រាប់បំពេញការងារ ។

១០ឆ្នាំបន្ទាប់ពីសង្គ្រាម ហេដ្ឋារចនាសម្ព័ន្ធនិងវិស័យផ្សេងៗ ជាពិសេសវិស័យសេដ្ឋកិច្ច ត្រូវបានយកចិត្តទុកដាក់និងស្តាបនាឡើងវិញ ប៉ុន្តែដំណើរការស្វែងរកយុត្តិធម៌និងផ្សះផ្សាបង្រួបបង្រួមរវាងជនជាតិហ៊ូទូ និងទុតស៊ី មិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ ។

### ៣) យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួម

ចាប់តាំងពីឆ្នាំ១៩៩៦រហូតដល់ឆ្នាំ២០០៣ រដ្ឋាភិបាលរ៉្វាន់ដានិងសហគមន៍អន្តរជាតិបានបង្កើតយុទ្ធសាស្ត្រសំខាន់ពីរដើម្បីផ្សះផ្សានិងបង្រួបបង្រួមភាគីជម្លោះ ។ យុទ្ធសាស្ត្រទាំងពីរគឺ ១)បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ដើម្បីកាត់ទោសជនឧក្រិដ្ឋប្រល័យពូជសាសន៍ និង ២) បង្កើតប្រព័ន្ធតុលាការប្រជាជនហៅថា កាឆាឆា ដើម្បីបង្ហាញការពិតអំពីអ្វីដែលបានកើតឡើង និងជំរុញឲ្យប្រជាជនយល់អធ្យាស្រ័យ និងអត់ទោសចំពោះជនដៃដល់ថ្នាក់ក្រោមបន្ទាប់ពីជនដៃដល់ទាំងនោះសារភាពកំហុស ប្រាប់ការពិត និងសុំអភ័យទោស ។ **(នៅមានត)**

**អៀ ម៉េងទ្រី**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# សវនាការដំបូងគឺជាយុត្តិធម៌សម្រាប់មនុស្សគ្រប់រូប

## ១) ប្រវត្តិសង្ខេបនៃការប៉ុនប៉ងបង្កើតតុលាការពិសេសដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម

របបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) បានកាន់អំណាចនៅប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៥ ។ នៅក្នុងអំឡុងពេលបីឆ្នាំប្រាំបួនខែ (ពីខែមេសាឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩) រដ្ឋាភិបាលនេះបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សកម្រិតធ្ងន់ដែលពិភពលោកមិនធ្លាប់ជួបប្រទះចាប់តាំងពីសង្គ្រាមលោកលើកទីពីរផុតរលត់ទៅ ។ ទម្រាំតែរបបដ៏គួរឲ្យព្រឺព្រួចនេះត្រូវបញ្ចប់ ប្រជាជនកម្ពុជាប្រមាណពាលាននាក់បានបាត់បង់ជីវិតដោយសារត្រូវបង្ខំឲ្យធ្វើការហួសកម្លាំង ការបង្អត់អាហារ និងការសម្លាប់ ។

អស់រយៈកាលជាង២៥ឆ្នាំ អ្នកដែលទទួលខុសត្រូវក្នុងការផ្ដើមគំនិតនិងប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិបែរជាបន្តរស់នៅយ៉ាងសប្បាយដោយគ្មានទុក្ខទោស ។ អ្វីដែលបន្សល់ពីបទឧក្រិដ្ឋគឺវប្បធម៌លើកលែងទោសដែលនៅតែវិលវល់រហូតដល់បច្ចុប្បន្ន ។ សារជាតិឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តគឺជាករណីឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលត្រូវចាត់ថ្នាក់ថាជាគោលការណ៍ *Jus Cogens* ។ ការលើកលែងទោសចំពោះករណីប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនអាចទទួលយកបានឡើយ ។ ហេតុដូច្នេះហើយ តាមរយៈការនាំជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មតាមគោលការណ៍ *Jus Cogens* គឺមានសារសំខាន់ណាស់ក្នុងការចែកចាយភាពយុត្តិធម៌ដល់ជនរងគ្រោះកម្ពុជានិងជាការបិទទំព័រអតីតកាល ។ យុត្តិធម៌គឺជាធាតុមួយយ៉ាងសំខាន់សម្រាប់ជួសជុលឡើងវិញនូវការបំផ្លិចបំផ្លាញក្រោមរូបភាពជាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរមកលើសង្គមកម្ពុជា និងដើម្បីជំរុញការផ្សះផ្សាជាតិ ។ ម្យ៉ាងវិញទៀត ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងអាចដើរតួនាទីជាសកម្មភាពការពារមួយយ៉ាងសំខាន់នៅកម្ពុជា តាមរយៈការបង្ហាញថា ជនដែលទទួលខុសត្រូវចំពោះបទល្មើសទាំងនេះចាំបាច់ត្រូវតែប្រឈមមុខនឹងការដាក់ទណ្ឌកម្ម ដើម្បីបង្កឲ្យមានការចាប់អារម្មណ៍របស់ប្រជាជនទៅលើបញ្ហាយុត្តិធម៌និងនីតិរដ្ឋ ។ គួរឲ្យសោកស្ដាយ ឧក្រិដ្ឋកម្មដ៏សាហាវនេះត្រូវបានទុកចោលមិនអើពើអស់រយៈកាលជាងពីរទសវត្សរ៍ ។ តុលាការមួយដែលគោរពតាមកម្រិតអន្តរជាតិគួរតែត្រូវបានបង្កើតឡើងតាំងពីយូរយារណាស់មកហើយ ប៉ុន្តែបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានវៀតណាមផ្តួលរំលំនៅឆ្នាំ១៩៧៩ សហរដ្ឋអាមេរិកនិងចិនបែរជាដឹកនាំកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិដើម្បីស្នើឲ្យវៀតណាមដកកម្លាំងទ័ពចេញពីទឹកដីកម្ពុជា និងបន្តទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យថាជារដ្ឋាភិបាលស្របច្បាប់នៃប្រទេសកម្ពុជាថែមទៀត ។ ថ្វីបើសារធាតុនៃមហន្តរាយជីវិតនិងសិទ្ធិមនុស្សកើតឡើងក្នុងអំឡុងរបបនោះត្រូវបានពិភពលោកដឹងឮយ៉ាងច្បាស់ក៏ដោយ ក៏សហរដ្ឋអាមេរិកខិតខំប្រឹងប្រែងរក្សាកៅអីខ្មែរក្រហមនៅក្នុងអង្គការសហប្រជាជាតិ ដែលនេះនាំឲ្យមានការពួតដៃជាមួយនឹងជនមួយចំនួនទៀតដើម្បីតស៊ូប្រឆាំងនឹងការកាន់កាប់របស់បរទេសរហូតដល់ឆ្នាំ១៩៩១ ។

គួរតែរំឭកឡើងវិញថា សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១មិនបានសង្កត់ធ្ងន់អំពីសារសំខាន់នៃការដាក់ឲ្យមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវចំពោះមុខច្បាប់នូវការរំលោភបំពានលើសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ដែលត្រូវចាត់ទុកថាជាអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ។ មិនត្រឹមតែប៉ុណ្ណោះ កម្ពុជាប្រជាធិបតេយ្យត្រូវបានផ្ដល់ឲ្យនូវតំណែងស្របច្បាប់មួយនៅឧត្តមក្រុមប្រឹក្សាជាតិរហូតទាល់តែកម្ពុជាប្រជាធិបតេយ្យស្ម័គ្រចិត្តដកខ្លួនចេញពីដំណើរការសន្តិភាពនិងការបោះឆ្នោតនៅឆ្នាំ១៩៩៣ ។

សំណើរបស់អាជ្ញាធរកម្ពុជាស្តែងឡើងតាមរយៈសំបុត្រចុះការបរិច្ឆេទនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រីទីមួយ គឺទ្រង់ នរោត្តម រណឫទ្ធិ និងនាយករដ្ឋមន្ត្រីទីពីរ សម្ដេច ហ៊ុន សែន បានស្នើសុំរកជំនួយធនធាននិងជំនាញការ

ពីអង្គការសហប្រជាជាតិក្នុងគោលបំណងនាំយកអ្នកទទួលខុសត្រូវនៃអំពើរំលោភសិទ្ធិមនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៅដាក់ទោស ។ នៅខែមិថុនា ឆ្នាំ១៩៩៨ អគ្គលេខាធិការអង្គការសហប្រជាជាតិបានឆ្លើយតបដោយការតែងតាំងក្រុមអ្នកជំនាញការមកពិគ្រោះយោបល់ថាតើគួរដំណើរការយ៉ាងណា ។

ការចរចាបានធ្វើឡើងជាច្រើនលើកច្រើនសា រវាងក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយឧបនាយករដ្ឋមន្ត្រី សុខ អាន និងក្រុមអង្គការសហប្រជាជាតិដឹកនាំដោយលោក ហេន ខូរ៉ែល ជាប្រធានក្រុមប្រឹក្សាច្បាប់និងជាអគ្គលេខាធិការរងអង្គការសហប្រជាជាតិ ។ មកដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ អង្គការសហប្រជាជាតិបានប្រកាសដកខ្លួនចេញពីដំណើរការចរចាជាឯកតោភាគី ។ អង្គការសហប្រជាជាតិបានលើកឡើងនូវចំណុចសំខាន់ៗមួយចំនួនដែលមានលក្ខណៈបច្ចេកទេស ជាមូលហេតុដើម្បីបដិសេធការចុះហត្ថលេខាលើកិច្ចព្រមព្រៀង ប៉ុន្តែមូលហេតុដែលចម្បងគឺអង្គការសហប្រជាជាតិយល់ថា រាជរដ្ឋាភិបាលកម្ពុជាខ្វះភាពសុចរិតក្នុងការចរចា ហើយថា បើទោះជាតុលាការនេះត្រូវបង្កើតឡើងក៏មិនបំពេញបានតាមបទដ្ឋានយុត្តិធម៌អន្តរជាតិដែរ ។

តាមដែលដឹងមកថា រដ្ឋប្រាំមួយដែលជាសមាជិកអង្គការសហប្រជាជាតិបានជួបជាមួយអគ្គលេខាធិការនិងអគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិដើម្បីដាក់សម្ពាធឲ្យអង្គការសហប្រជាជាតិវិលមករកការចរចាជាមួយនឹងភាគីកម្ពុជាវិញ ។

## ២) ការកាត់សេចក្តីដោយយុត្តិធម៌

ខ្ញុំសូមលើកសេចក្តីផ្តើមអំពីការកាត់ក្តីដោយយុត្តិធម៌ ។ ជាទូទៅសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ត្រូវបានទទួលស្គាល់ថាគឺជាបទដ្ឋាននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលគាត់តែងឡើងដើម្បីការពារបុគ្គលពីការកាត់បន្ថយសិទ្ធិសេរីភាពតាមតែទំនើងចិត្តនិងមិនស្របច្បាប់ ។ សិទ្ធិនេះត្រូវបានធានាដោយមាត្រាទី១៤នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ (ICCPR) ដែលចែងថា ៖ "ជនគ្រប់រូបមានសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌និងជាសាធារណៈតាមរយៈតុលាការឯករាជ្យ មានសមត្ថភាព និងមិនលម្អៀងដែលបង្កើតឡើងតាមផ្លូវច្បាប់" ។ សិទ្ធិទទួលការកាត់សេចក្តីដោយយុត្តិធម៌អាចអនុវត្តបានអាស្រ័យទៅលើសិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលទៅតាមផ្លូវច្បាប់ និងអាស្រ័យលើបទចោទប្រកាន់ប្រឆាំងនឹងបុគ្គលនោះ ។ ពាក្យ "ទៅតាមផ្លូវច្បាប់" សំដៅទៅលើប្រភេទផ្សេងៗនៃតុលាការ រួមបញ្ចូលទាំងចំណាត់ការផ្នែករដ្ឋបាលផង ។

បទដ្ឋានដាក់លាក់មួយត្រូវបានបង្កើតឡើងដើម្បីដំណើរការតុលាការយុត្តិធម៌មួយ ប៉ុន្តែបទដ្ឋាននោះមានភាពស្មុគស្មាញនិងមប្រែប្រួលមិនឈប់ឈរ ។ ដើម្បីបំពេញបទដ្ឋានទាំងនេះយើងប្រហែលជាត្រូវរួមផ្សំកាតព្វកិច្ចទាំងឡាយដែលមាននៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សដែលភាគីរដ្ឋជាសមាជិក ។ ក៏ប៉ុន្តែ បទដ្ឋាននេះអាចមាននៅក្នុងឯកសារ រួមទាំងឯកសារដែលមិនសូវសំខាន់និងអាចយកមកបង្ហាញអំពីទិសដៅដែលច្បាប់កំពុងតែវិវត្តទៅរក ។ ការកាត់ក្តីដោយយុត្តិធម៌អាចត្រូវបានវាយតម្លៃដោយផ្អែកទៅលើច្បាប់នៃប្រទេសដែលអង្គជំនុំជម្រះតាំងនៅ និងផ្អែកលើសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សដែលភាគីរដ្ឋជាសមាជិកនិងបទដ្ឋានច្បាប់ទម្លាប់អន្តរជាតិ ។ ចំណុចដែលយើងអាចវាយតម្លៃសង្ខេបអំពីតុលាការយុត្តិធម៌រួមមាន ÷ ១) ច្បាប់រដ្ឋធម្មនុញ្ញ ជាពិសេសចំណុចដែលចែងអំពីសិទ្ធិមនុស្សនិងប្រព័ន្ធតុលាការ ២) ក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ លក្ខន្តិកៈនៃការបង្កើតតុលាការនិងយុត្តាធិការនៃតុលាការ និងលក្ខន្តិកៈនៃការបង្កើតការិយាល័យរដ្ឋអាជ្ញាសាធារណៈ ៣) សេចក្តីសម្រេចចិត្តរបស់តុលាការសមស្របនឹងសិទ្ធិមនុស្ស ។

## ៣) សិទ្ធិមានមេធាវីការពារខ្លួននៅក្រោមច្បាប់កម្ពុជា

វិជ្ជាជីវៈច្បាប់នៅកម្ពុជាត្រូវបានបំផ្លាញទាំងស្រុងដោយរបបខ្មែរក្រហម ។ ក្រោយការដួលរលំនៃរបបនេះនៅឆ្នាំ១៩៧៩ កម្ពុជានៅសល់តែចៅក្រម មេធាវី និងអ្នកជំនាញច្បាប់ តែបួនដប់នាក់ប៉ុណ្ណោះ ។ នៅពេលដែលរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជាខិតខំប្រឹងប្រែងស្តាបនាប្រព័ន្ធច្បាប់ឡើងវិញ ដោយចម្លងតាមគោលការណ៍ច្បាប់របស់សូវៀតដែលនាំមកឲ្យដោយវៀតណាម មានសេចក្តីរាយការណ៍ថា មានអ្នកជំនាញច្បាប់ដែលមានការហ្វឹកហ្វឺនត្រឹមត្រូវតែប្រាំរូបប៉ុណ្ណោះ

នៅទូទាំងប្រទេស ក្រៅពីនោះគឺជាកម្មាភិបាលគ្មានជំនាញដែលត្រូវបានគណបក្សប្រជាជនកម្ពុជាតែងតាំងជាចៅក្រមនៅក្នុងតុលាការប្រជាជន ។

មកដល់ដើមខែមិថុនា ឆ្នាំ១៩៩៩ ចំនួនមេធាវីនិងអ្នកច្បាប់ដែលមានសញ្ញាបត្រត្រឹមត្រូវនៅប្រទេសកម្ពុជាបានកើនដល់ ២១៦នាក់ ។ នៅក្នុងចំណោមមេធាវីទាំង២១៦នាក់នេះ ៤០នាក់កំពុងតែបម្រើការនៅក្នុងស្ថាប័ននីតិបញ្ញត្តិឬនីតិប្រតិបត្តិនៃរដ្ឋាភិបាល ។ ដោយសារការងាររដ្ឋមិនស៊ីសង្វាក់នឹងស្វ័យភាពដែលអ្នកច្បាប់ត្រូវតែមាន មេធាវី៤០នាក់នេះមិនត្រូវបានចាត់ទុកថាជាមេធាវីមានជំនាញឡើយ ។ ដូច្នេះទូទាំងប្រទេសនៅសល់តែមេធាវីប្រមាណ១៧៦ នាក់ប៉ុណ្ណោះដែលចាត់ទុកថាមានជំនាញ ។ មេធាវីពី៧៥ ទៅ៨០នាក់បំពេញការងារនៅក្នុងអង្គការច្បាប់ ឬអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ។ ក្រៅពីនោះ មេធាវីប្រហែល ១០០នាក់ទៀត ប្រកបការងារជាមេធាវីឯកជនឬធ្វើការនៅក្នុងការិយាល័យផ្តល់សេវាច្បាប់តូចតាច ។ (តួលេខខាងលើនេះគិតត្រឹមឆ្នាំ១៩៩៩ ។ ព័ត៌មានបន្ថែមអំពីការកើនឡើងនូវចំនួនមេធាវីដែលមានសញ្ញាប័ត្រត្រឹមត្រូវសូមទាក់ទងគណៈមេធាវីកម្ពុជា) ។

ចាប់តាំងពីឆ្នាំ១៩៩៥មក ការអនុវត្តច្បាប់នៅប្រទេសកម្ពុជាត្រូវបានបញ្ញត្តិដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមប្រឹក្សាគណៈមេធាវី ។ ក្រុមប្រឹក្សាគណៈមេធាវីបានរៀបចំច្បាប់គ្រប់គ្រងមេធាវីនិងធានានូវការអនុវត្តតាមច្បាប់ ។ លោក សួន វិសាល មេធាវីដែលទទួលបានការគោរព និងធ្លាប់បម្រើការជានាយកបច្ចេកទេសនៃគម្រោងការពារចុងចោទរបស់អង្គការជំនួយច្បាប់កម្ពុជាដែលផ្តល់សេវា ផ្នែកច្បាប់ដល់ជនក្រីក្រ បានជាប់ឆ្នោតជាប្រធានគណៈមេធាវីកម្ពុជា ក៏ប៉ុន្តែលោក គី តិច ប្រធានគណៈមេធាវីកម្ពុជាដែលកំពុងកាន់តំណែង បានបដិសេធមិនប្រគល់តំណែងនេះទៅឲ្យលោក សួន វិសាល ។ ជម្លោះនេះបានទៅដល់តុលាការ ។ តុលាការសាលាឧទ្ធរណ៍ បានចេញសាលក្រមបដិសេធលទ្ធផលនៃការបោះឆ្នោតហើយរក្សា លោក គី តិច ឲ្យកាន់តំណែងដដែល ។ សាលក្រមនេះ ត្រូវបានអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិរិះគន់យ៉ាងខ្លាំង ។ ជម្លោះផ្លូវច្បាប់រវាងលោក សួន វិសាល និងលោក គី តិច នៅតែបន្ត ហើយបណ្តាលឲ្យគាំងដំណើរការនិងតួនាទីរបស់គណៈមេធាវីកម្ពុជា ។

សិទ្ធិទទួលបានមេធាវីនៅដំណាក់កាលមុនពេលមានសវនាការត្រូវបានភ្ជាប់ទៅនឹងសិទ្ធិទទួលបានការការពារនៅអំឡុងពេលមានសវនាការ ដែលចែងនៅក្នុងមាត្រាទី១៤(៣)(D) របស់កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ ។ កតិកាសញ្ញានេះបញ្ជាក់យ៉ាងច្បាស់ថា ដើម្បីជាប្រយោជន៍យុត្តិធម៌នៅគ្រប់រឿងក្តីទាំងអស់ ជនជាប់ចោទមានសិទ្ធិដឹងឮអំពីការចោទប្រកាន់ណាមួយមកលើខ្លួន មានសិទ្ធិទទួលការកាត់ទោសដោយចំពោះមុខ មានសិទ្ធិការពារក្តីដោយខ្លួនឯងឬតាមរយៈអ្នកជំនួយការច្បាប់ដែលខ្លួនជ្រើសរើស មានសិទ្ធិទទួលដំណឹងអំពីសិទ្ធិនេះ និងមានសិទ្ធិទទួលបានអ្នកជំនួយការច្បាប់ដោយឥតគិតកម្រៃ ។

ជាក់ស្តែង សិទ្ធិទទួលបានការណែនាំអំពីច្បាប់ត្រូវបានធានាក្រោមច្បាប់រដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ។ មាត្រាទី៣៨នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា ÷ "ពលរដ្ឋកម្ពុជាគ្រប់រូបមានសិទ្ធិទទួលបានអ្នកការពារតាមរយៈជំនួយពីតុលាការ ។ មាត្រា៧៥នៃក្រមព្រហ្មទណ្ឌរបស់រដ្ឋកម្ពុជាចែងថា÷ "ពេលដែលជនជាប់ចោទបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបអង្កេតត្រូវតែប្រាប់ជនជាប់ចោទឲ្យដឹងអំពីបទចោទប្រកាន់ និងទទួលចម្លើយពីជនជាប់ចោទបន្ទាប់ពីបានប្រាប់ឲ្យជនជាប់ចោទដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយឬមិនឆ្លើយដោយគ្មានជំនួយពីមេធាវី ដែលជនជាប់ចោទជ្រើសរើសដោយខ្លួនឯង ឬដែលចាត់តាំងដោយស្វ័យប្រវត្តិ ។ មាត្រា៧៦នៃច្បាប់នីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជាបានចែងថា "ប្រសិនបើជនជាប់ចោទប្រាប់ចៅក្រមថាគាត់នឹងជ្រើសរើសមេធាវីដោយខ្លួនឯង ឬក៏ស្នើសុំឲ្យរដ្ឋាភិបាលតែងតាំងមេធាវីឲ្យខ្លួន ចៅក្រមស៊ើបអង្កេតត្រូវតែពន្យារពេលសួរចម្លើយនិងកោះហៅមេធាវីភ្លាមដើម្បីសួរចម្លើយជនជាប់ចោទនៅចំពោះមុខមេធាវី" ។ សិទ្ធិទទួលបានមេធាវីត្រូវបានបង្ហាញកាន់តែច្បាស់នៅក្នុងមាត្រា១០នៃច្បាប់អ៊ុនតាក់ដែលចែងថា÷ "សិទ្ធិទទួលបានជំនួយពីមេធាវីឬស្មាក្តីត្រូវបានធានាជូនដល់ជនជាប់ចោទបទល្មើសមជ្ឈិមនិងបទល្មើសព្រហ្មទណ្ឌ ។ គ្មានជនណាអាចត្រូវឃុំឃាំងលើសពី៤៨ម៉ោង (បច្ចុប្បន្នចំណុចនេះត្រូវបានកែទៅជា៧២ម៉ោង) នៅក្នុងទឹកដីកម្ពុជាដោយគ្មានជំនួយពីមេធាវី ឬ

ស្មាក្តីមិនថាជាបទចោទប្រកាន់ណាមួយឡើយ" ។

គួរកត់សម្គាល់ដែរថា កម្ពុជាក៏ជាប្រទេសហត្ថលេខីមួយនៃលិខិតូបករណ៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិដែរ ។ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់សេចក្តីប្រកាសសិទ្ធិមនុស្សនៅឆ្នាំ១៩៤៨ និងលិខិតូបករណ៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិដទៃទៀត ។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ និងកតិកាសញ្ញាផ្សេងៗទៀតរបស់គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។ ពិធីសារបន្ថែមនេះអនុញ្ញាតឲ្យពលរដ្ឋកម្ពុជាអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅក្រោមច្បាប់អន្តរជាតិ ។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាមិនបានអនុវត្តខ្ជាប់ខ្ជួននូវកាតព្វកិច្ចដែលចែងនៅក្នុងសន្ធិសញ្ញានេះឡើយ ។

បើទោះជាច្បាប់ចែងយ៉ាងច្បាស់អំពីសារសំខាន់នៃមេធាវីការពារក្តីនៅគ្រប់ដំណាក់កាលរឿងក្តីឧក្រិដ្ឋកម្មដើម្បីធានាឲ្យមានយុត្តិធម៌ ប៉ុន្តែតាមការអនុវត្តជាក់ស្តែងភាគច្រើនអាជ្ញាធរកម្ពុជាបរាជ័យក្នុងការផ្តល់មេធាវីឬស្មាក្តីដល់ជនជាប់ចោទ ។ សិទ្ធិទទួលបានមេធាវីតាមបំណងរបស់ជនជាប់ចោទ (ក្នុងករណីដែលជននោះខ្វះខាតហិរញ្ញវត្ថុ ជននោះមានសិទ្ធិទទួលបានមេធាវីដែលតែងតាំងដោយតុលាការដោយមិនគិតកម្រៃ ព្រោះនេះជាតម្រូវការចាំបាច់នៅក្នុងការគ្រប់គ្រងរដ្ឋបាលយុត្តិធម៌) មិនត្រូវបានធានាទេនៅពេលដែលជនជាប់ចោទមិនមានមេធាវីដោយខ្លួនឯង ។

ដោយសារអង្គជំនុំជម្រះវិសាមញ្ញដែលនឹងកើតឡើងនាពេលខាងមុខនេះគឺជាតុលាការចម្រុះ នេះជាការបារម្ភចម្បងបំផុត ។ ការពិភាក្សារបស់ខ្ញុំផ្តោតទៅលើបញ្ហាថាតើសិទ្ធិទទួលបានមេធាវីតាមផ្លូវច្បាប់ត្រូវបានអនុវត្ត និងធានាយ៉ាងដូចម្តេចនៅពេលដែលអង្គជំនុំជម្រះចាប់ផ្តើមដំណើរការជាក់ស្តែង ។ ខ្ញុំអាចលើកបញ្ហាមួយចំនួនដែលទំនងជានឹងកើតឡើងដូចជាកង្វះខាតបទពិសោធន៍និងការយល់ដឹងអំពីប្រព័ន្ធតុលាការអន្តរជាតិ កង្វះខាតឯករាជ្យភាពនិងភាពមិនលម្អៀងនៃមេធាវី បញ្ហាភាសា និងអឆន្ទៈជាដើម ។

ក) "មេធាវីដែលជ្រើសរើសដោយជនជាប់ចោទ"

សំអាងលើការវិភាគរបស់ខ្ញុំ ពាក្យ "មេធាវីដែលជ្រើសរើសដោយជនជាប់ចោទ" មានន័យថា ជនជាប់ចោទគ្រប់រូបត្រូវបានផ្តល់សិទ្ធិឲ្យស្នើសុំជំនួយពីមេធាវីដែលមានសមត្ថភាពគ្រប់គ្រាន់ស្របតាមជម្រើសរបស់ជនជាប់ចោទដើម្បីការពារខ្លួននៅគ្រប់ដំណាក់កាលនៃសវនាការរបស់បណ្តឹងព្រហ្មទណ្ឌ ។ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពរកអ្នកមេធាវីដោយខ្លួនឯង អាជ្ញាធរត្រូវតែផ្តល់មេធាវីដល់ជនជាប់ចោទដោយមិនគិតថ្លៃ ដើម្បីតម្រូវតាមបទដ្ឋានយុត្តិធម៌ ។ មិនថាប្រយោជន៍ក្នុងការស្វែងរកយុត្តិធម៌ទាមទារការចាត់តាំងបែបនោះឬក៏យ៉ាងណាទេ វាអាស្រ័យជាចម្បងលើសភាពពិតនៃបទល្មើសនិងភាពធ្ងន់ធ្ងរនៃទោសបញ្ញត្តិ ។

ទោះជាយ៉ាងនេះក៏ដោយ ក៏នៅតែមានភាពមិនជាក់លាក់និងមានកង្វះចន្លោះនៃការធ្វើអត្ថាធិប្បាយដែរ ។ គោលការណ៍ "មេធាវីដែលជ្រើសរើសដោយជនជាប់ចោទ" ទំនងដូចជាមិនអាចធានាបានទេនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ យោងទៅតាមមាត្រា៩នៃច្បាប់ស្តីអំពីវិជ្ជាជីវៈមេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានតែមេធាវីសញ្ជាតិកម្ពុជាប៉ុណ្ណោះ ដែលអាចតំណាងឲ្យចុងចោទរបស់ខ្លួននៅចំពោះមុខតុលាការ ។ សំអាងលើមាត្រានេះ គោលការណ៍ "មេធាវីដែលជ្រើសរើសដោយជនជាប់ចោទ" ហាក់ដូចជាមិនអាចធានាបានដោយសារថា ជនជាប់ចោទមិនមានលទ្ធភាពរកមេធាវីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនលម្អៀង និងអាចឲ្យគាត់ជឿជាក់បាន ។ ជាងនេះទៅទៀត ជនជាប់ចោទប្រហែលជាមិនចង់ជ្រើសរើសមេធាវីសញ្ជាតិកម្ពុជាដោយសារគាត់យល់ឃើញថាមេធាវីកម្ពុជាមិនអាចរកយុត្តិធម៌ឲ្យគាត់ ។ ទាំងនេះហើយដែលបង្កើតនូវការប៉ះទង្គិចនៃច្បាប់ (ច្បាប់អង្កិន) ។ តាមការយល់ឃើញរបស់ខ្ញុំ នៅពេលដែលទំនាស់នៃច្បាប់លេចឡើង សិទ្ធិទទួលយកយុត្តិធម៌របស់ជនជាប់ចោទពិតជាត្រូវប៉ះពាល់ ហើយគោលការណ៍យុត្តិធម៌របស់តុលាការមិនត្រូវបានធានា ។ គួរតែកត់សម្គាល់ដែរថា "បុគ្គលគ្រប់រូបដែលជាប់ទោសឧក្រិដ្ឋ សុទ្ធតែមានសិទ្ធិជាចម្បង និងគ្មានដែនកំណត់ រួមទាំងសិទ្ធិក្នុងការការពារខ្លួនផង" ។ ហេតុនេះហើយ ជនជាប់ចោទត្រូវបានច្បាប់ផ្តល់សិទ្ធិឲ្យមានមេធាវីមានសមត្ថភាពសម្រាប់ការពារ ។ សិទ្ធិនេះនឹងមិនត្រូវបានការពារឬគោរពតាមទេ លុះត្រាតែមាន

ការកែតម្រូវភាពមិនស៊ីសង្វាក់គ្នារវាងច្បាប់របស់គណៈមេធាវី និងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ ។

### ១) កង្វះខាតបទពិសោធន៍និងចំណេះដឹងអំពីតុលាការអន្តរជាតិ

បច្ចុប្បន្នមានមេធាវីកម្ពុជាមិនច្រើនទេដែលធ្លាប់បានហ្វឹកហាត់ច្បាប់អន្តរជាតិ ដូចជាច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ច្បាប់ទម្លាប់អន្តរជាតិ សន្ធិសញ្ញា អនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិសំខាន់ៗ ដែលជាញឹកញាប់ដើរតួនាទីជាប្រភពឯកសារពិគ្រោះយ៉ាងសំខាន់ ។ មេធាវីកម្ពុជាភាគច្រើនមិនមានបទពិសោធន៍ក្នុងការបង្ហាញរឿងក្តី ឬចាត់ការរឿងក្តីនៅក្នុងតុលាការអន្តរជាតិ ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវីដែលគាំទ្រដោយអង្គការសហប្រជាជាតិជាដើម ទោះបីជាច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញអនុញ្ញាតឲ្យអនុវត្តច្បាប់និងនីតិវិធីដែលមានរួចហើយក៏ដោយ ។ ការហ្វឹកហ្វឺនតែមួយមុខមិនគ្រប់គ្រាន់ឲ្យមេធាវី ឬអ្នកច្បាប់ទាំងនោះការពារបានគ្រប់ជ្រុងជ្រោយ នៅក្នុងរឿងក្តីព្រហ្មទណ្ឌកម្រិតអន្តរជាតិឡើយ មានតែបទពិសោធន៍និងចំណេះដឹងខាងចំណាត់ការក្នុងតុលាការអន្តរជាតិទេទើបមានអត្ថប្រយោជន៍សំខាន់ដល់ជនជាប់ចោទ ។ បើទោះជាមេធាវីបរទេសត្រូវបានអនុញ្ញាតឲ្យធ្វើជាជំនួយការរបស់មេធាវីកម្ពុជាក៏ដោយ ក៏កង្វះចន្លោះនៅតែមានក្នុងបញ្ហាទំនាក់ទំនង ការយោគយល់គ្នា និងជាពិសេសនៅពេលការពារក្តី ។ ម្យ៉ាងវិញទៀត ក្នុងពេលការពារក្តីនៅក្នុងសវនាការ មេធាវីកម្ពុជានឹងត្រូវប្រឈមមុខនឹងសហចៅក្រមដែលមានខ្មែរនិងបរទេស ។ ការណ៍នេះទាមទារឲ្យមេធាវីត្រូវតែមានភាពរហ័សរហួន ។ ខ្ញុំសូមផ្តល់យោបល់ថា គណៈមេធាវីគួរតែកែច្បាប់របស់គណៈមេធាវីដើម្បីសម្រួលដល់មេធាវីបរទេស ក្នុងការការពារកូនក្តីរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និងដើម្បីបង្កើតតំណែង"សហមេធាវី" ដោយយោងទៅតាមច្បាប់អង្គជំនុំជម្រះវិសាមញ្ញដែលតម្រូវឲ្យមាន "សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា" ។ ខ្ញុំសូមស្នើថា ករណីលើកលែងមួយនេះ អាចប្រើបានតែនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះដើម្បីចៀសវាងការដណ្តើមការងារពីសំណាក់មេធាវីបរទេសដែលមានលក្ខណៈសម្បត្តិនិងបទពិសោធន៍គ្រប់គ្រាន់ ។ យើងដឹងថា ទោះបីជាបច្ចុប្បន្ននេះកម្ពុជាខ្វះខាតមេធាវីក៏ដោយ ក៏គណៈមេធាវីកម្ពុជាមិនចង់ជ្រើសរើសមេធាវីបន្ថែមទៀតទេក្នុងគោលបំណងបង្កើតការងារថ្មីៗសម្រាប់មេធាវីដែលមានស្រាប់ ។

### គ) ឯករាជ្យភាពនិងភាពមិនលម្អៀងរបស់មេធាវី

ឯករាជ្យភាពនិងភាពមិនលម្អៀងរបស់មេធាវីកម្ពុជាត្រូវបានដេញដោលសួរពីសំណាក់មនុស្សជាច្រើន ជាពិសេសជនជាប់ចោទ ។ យ៉ាងហោចណាស់មានមេធាវីម្នាក់ឬពីរនាក់រាប់បញ្ចូលខ្លួនឯងថាជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកខ្លះអាចសួរថាតើមេធាវីម្នាក់ពិតជាការពារកូនក្តីខ្លួនដោយស្មោះត្រង់ដែរឬទេប្រសិនបើមេធាវីរូបនោះដឹងច្បាស់ថាកូនក្តីរបស់ខ្លួនបានប្រព្រឹត្តអំពើឃាតកម្ម ឬកូនក្តីរបស់ខ្លួនជាអ្នកដែលធ្វើឲ្យសាច់ញាតិរបស់ខ្លួនបាត់បង់ជីវិតតាមរយៈការបង្ខំឲ្យធ្វើការហួសកម្លាំងនិងការបង្អត់អាហារ? នៅពេលដែលភាពឯករាជ្យមិនលម្អៀងរបស់មេធាវីត្រូវបានចោទជាសំណួរ ទំនាស់ផលប្រយោជន៍នឹងកើតមានឡើង ។ ដូច្នេះផលប្រយោជន៍យុត្តិធម៌របស់ជនជាប់ចោទនឹងមានបញ្ហា ។ សូម្បីតែជនជាប់ចោទមានសិទ្ធិក្នុងការផ្លាស់ប្តូរមេធាវីរបស់ខ្លួនប្រសិនបើគិតថា មេធាវីនោះមិនអាចស្វែងរកយុត្តិធម៌ឲ្យខ្លួនបានក៏ដោយ ក៏ការផ្លាស់ប្តូរតែម្យ៉ាងមិនអាចជួយអ្វីច្រើនឡើយ ពីព្រោះជនជាប់ចោទត្រូវទ្រាំទ្រនឹងការប៉ះទង្គិចអារម្មណ៍ ដោយសារថាខ្លួនមិនបានទទួលការការពារដោយឯករាជ្យនិងមិនលម្អៀង ។ ក៏ប៉ុន្តែ ជនជាប់ចោទអាចរើសយកជម្រើសមួយប្រសើរជាងមិនបានរើសសោះ ។ ខ្ញុំចង់មានន័យថា មិនមែនខ្ញុំគ្មានទំនុកចិត្តលើមេធាវីកម្ពុជាទេ ប៉ុន្តែនេះជាអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ដោះស្រាយរឿងក្តីពិសេស ។ តើអង្គជំនុំជម្រះវិសាមញ្ញនិងគណៈមេធាវីធ្វើយ៉ាងណាដើម្បីធានាឯករាជ្យភាពនិងភាពមិនលម្អៀងរបស់មេធាវី? តើគួរតែដាក់ឲ្យប្រតិបត្តិក្រមសីលធម៌មេធាវីដែរឬទេ?

### ឃ) ភាសា

សិទ្ធិមានអ្នកបកប្រែគឺសំខាន់ណាស់ក្នុងការធានាឲ្យបាននូវអង្គជំនុំជម្រះមួយដែលមិនលម្អៀង ។ មាត្រា១៤(3)(f) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីច្បាប់ស៊ីវិលនិងនយោបាយចែងថា នៅគ្រប់ករណីចោទប្រកាន់ទាំងអស់ ជនជាប់ចោទគ្រប់រូបមានសិទ្ធិទទួលបានជំនួយសេវាបកប្រែដោយមិនបង់ប្រាក់ប្រសិនបើជន

នោះ មិនយល់អំពីភាសាដែលកំពុងប្រើប្រាស់នៅក្នុងសវនាការ ។ យោងទៅតាមមាត្រាទី៤៥ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញ និងមាត្រាទី២៦ កថាខ័ណ្ឌទី២ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ភាសាប្រើប្រាស់ជាផ្លូវការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺភាសាខ្មែរ ភាសា អង់គ្លេស និងភាសាបារាំង ។ បញ្ហាចម្បងនៅត្រង់ចំណុចនេះគឺការបកប្រែត្រូវតែត្រឹមត្រូវតាមពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងសវនាការ ។ ដោយសារអង្គសវនាការដំណើរការដោយផ្ទាល់មាត់ ការបកប្រែចាំបាច់ត្រូវតែបញ្ជាក់ឲ្យច្បាស់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មិនមានចែងអំពីសិទ្ធិទទួលបានការបកប្រែពីឯកសារជាក្រដាស (ឯកសារភស្តុតាងនិងឯកសារបញ្ជាក់) ឡើយ ។ ការបកប្រែពីឯកសារភស្តុតាងត្រូវចំណាយអស់ថវិកាច្រើន និងទាមទារភាពត្រឹមត្រូវតាមផ្លូវច្បាប់ ។ សំណួរគឺថាតើអ្នកណានឹងទទួលខុសត្រូវលើការចំណាយសម្រាប់បកប្រែនិងសម្រាប់រក្សាភាពត្រឹមត្រូវតាមផ្លូវច្បាប់? អង្គជំនុំជម្រះវិសាមញ្ញមានកង្វល់ដ៏ធំក្នុងការជ្រើសរើសអ្នកបកប្រែដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធ្លាប់មានការហ្វឹកហ្វឺនផ្នែកច្បាប់ និងមានចំណេះដឹងខាងពាក្យបច្ចេកទេសច្បាប់ ។ នៅក្នុងប្រទេសកម្ពុជាមិនមានអ្នកបកប្រែដែលមានចំណេះដឹងច្បាប់ យល់អំពីដំណើរការតុលាការ និងអាចបកប្រែទាន់ដំណើរប្រព្រឹត្តទៅនៃសវនាការទេ ។ បញ្ហាភាសាគឺជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនដែលអង្គជំនុំជម្រះវិសាមញ្ញប្រឈមមុខ ។ អង្គជំនុំជម្រះវិសាមញ្ញចាំបាច់បង្កើតច្បាប់សម្រាប់ការបកប្រែនៅក្នុងសវនាការថាតើគួរបកប្រែដំណាលគ្នាឬក៏បកប្រែជាដំណាក់ៗ ។ ប្រហែលជាចាំបាច់ត្រូវឲ្យអ្នកបកប្រែទទួលការបំពាក់បំប៉នពាក្យបច្ចេកទេសច្បាប់និងនីតិវិធីនៅក្នុងតុលាការមុនពេលដែលអ្នកទាំងនោះត្រូវបានតែងតាំងមុខតំណែង ។

**មុត ចាន់ថា**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី "វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" លើកទី២ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះ សូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ ÷

◆រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍សេចក្តីទុក្ខ ការខឹងគុំកួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែល : dccam@online.com.kh ។ សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខ : ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។

សូមអរគុណ ។

# អំពីពិធីប្រគល់អគារធ្វើការនិងបរិវេណសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និងជាលេខាធិការប្រតិបត្តិក្រុមការងាររបស់រាជរដ្ឋាភិបាលសម្រាប់ការកាត់សេចក្ដីខ្មែរក្រហម

**(កំបូល, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦)**

នៅថ្ងៃពុធ ទី១៨ ខែមករា ឆ្នាំ២០០៦នេះ មានការប្រារព្ធពិធីប្រគល់ទីកន្លែងមួយផ្នែករបស់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដែលស្ថិតនៅភូមិកន្ទោក សំរាប់ប្រើប្រាស់ក្នុងដំណើរការកាត់សេចក្ដីខ្មែរក្រហម ។ អគារចំនួន២ខ្នងរួមជាមួយបរិវេណជុំវិញអគារនោះ នឹងត្រូវបានប្រើប្រាស់ជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ECCC) ។

ពិធីប្រគល់នេះជាការកត់ចំណាំមួយយ៉ាងសំខាន់ក្នុងប្រវត្តិសាស្រ្តដ៏យូរនៃការនាំមកនូវភាពទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងឡាយ ដែលបានប្រព្រឹត្តក្នុងកំឡុងពេលប្រមាណ៣០ឆ្នាំមុននេះ ។ ការកាត់សេចក្ដីដែលជិតនឹងមកដល់នេះមានគោលបំណងបីគឺ : ផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះនិងជនដែលនៅរស់រានមានជីវិត ដើម្បីធ្វើការទប់ស្កាត់អំពើយង់ឃ្នងបែបនេះកុំឲ្យកើតមានក្នុងពេលអនាគត និងផ្ដល់ឲ្យយុវជនជំនាន់ក្រោយនូវរូបភាពប្រត្យក្សអំពីអ្វីដែលបានកើតឡើងរួចមកហើយ ។ យុវជនជំនាន់ក្រោយទាំងអស់បានចម្រើនវ័យ និងកំពុងតែស្វែងរកពត៌មានអំពីអ្វីដែលបានកើតឡើង ហើយនរណាគួរទទួលខុសត្រូវ ។

ជំនួសមុខឲ្យក្រុមការងារដែលមានឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ជាប្រធាន យើងខ្ញុំសូមសំដែងនូវការកោតសរសើរដល់កងយោធពលខេមរភូមិន្ទ ចំពោះការយល់ព្រមពន្យារពេលបីឆ្នាំក្នុងការប្រើប្រាស់ទីតាំងអគ្គបញ្ជាការថ្មីនេះដែលពួកគេកំពុងទន្ទឹងរង់ចាំ ។ ភាគីកម្ពុជានិងភាគីអង្គការសហប្រជាជាតិជឿជាក់ថា នេះជាទីកន្លែងដែលល្អវិសេសសម្រាប់ធ្វើជាទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មានកន្លែងចាំបាច់សម្រាប់ការិយាល័យ និងបន្ទប់សវនាការស្ថិតក្នុងបរិវេណតែមួយ លើសពីនេះទៀតគឺ ប្រកបដោយសុវត្ថិភាពជាងនិងជួយកាត់បន្ថយភាពរំខានដល់ប្រជាជនក្នុងក្រុងភ្នំពេញក្នុងកំឡុងពេលនៃដំណើរការជំនុំជម្រះក្ដី ។



អគារធ្វើការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានចុះហត្ថលេខាប្រគល់នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦

ឆ្លៀតក្នុងឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់ប្រទេសជាម្ចាស់អំណោយទាំងអស់ ទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈអង្គការសហប្រជាជាតិ ទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈភាគីកម្ពុជា ក្នុងនោះយើងខ្ញុំបានទទួលវិភាគទានពីសហគមន៍អឺរ៉ុបចំនួន ១,២លានដុល្លារសហរដ្ឋអាមេរិក និងពីប្រទេសថៃចំនួន ២៥,០០០ដុល្លារសហរដ្ឋអាមេរិក បំពេញបន្ថែមលើវិភាគទានដែលបានទទួលពីប្រទេសឥណ្ឌាចំនួន១លានដុល្លារសហរដ្ឋអាមេរិក និងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាចំនួន១,៥លានដុល្លារសហរដ្ឋអាមេរិក ។ យើងខ្ញុំមានការជឿជាក់ថា មូលនិធិដែលនៅសេសសល់នឹងត្រូវបានធានាក្នុងពេលឆាប់ៗនេះ ។

យើងខ្ញុំកំពុងបង្កើតក្រុមចាប់ផ្តើមការងាររួមមួយសម្រាប់ការិយាល័យរដ្ឋបាល ។ ដៃគូរបស់យើងដឹកនាំ ដោយលោកស្រី មីសែល លី នាយករងនៃការិយាល័យរដ្ឋបាលមកពីអង្គការសហប្រជាជាតិ នឹងមកដល់ភ្នំពេញក្នុងកំឡុងពេលប៉ុន្មានអាទិត្យខាងមុខនេះ ហើយយើងខ្ញុំមានបំណងនឹងចូលមកធ្វើការក្នុងទីតាំងនេះនាដើមខែកុម្ភៈ បន្ទាប់ពីការកែប្រែក្នុងទ្រង់ទ្រាយតូចបានរួចរាល់ហើយ ។

ចំពោះផ្នែកច្បាប់និងតុលាការ ដំណាក់កាលចុងក្រោយនៃការតែងតាំងចៅក្រមជាតិនិងអន្តរជាតិសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតកំពុងតែដំណើរការ ហើយយើងខ្ញុំរំពឹងទុកថានឹងអាចប្រកាសឈ្មោះរបស់ពួកគេ ក្នុងពេលដ៏ខ្លីខាងមុខនេះ ។ ការត្រៀមលក្ខណៈផ្សេងៗទៀតក៏កំពុងតែដំណើរការដូចជាការចងក្រងប្រមូលឯកសារច្បាប់ជាមូលដ្ឋានជាង ១០០ ជាភាសាផ្លូវការនៅក្នុងតុលាការ (ទទួលការឧបត្ថម្ភពីរដ្ឋាភិបាលប្រទេសន័រវេស) និងកម្មវិធីផ្សព្វផ្សាយព័ត៌មានតាមតំបន់ (ឧបត្ថម្ភពីរដ្ឋាភិបាលប្រទេសអូស្ត្រាលី) ។

ថ្ងៃនេះ បានបញ្ជាក់ច្បាស់ពីការសម្រេចលទ្ធផលនៃការរង់ចាំអស់រយៈកាលដ៏យូរ ដើម្បីបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់ដំណើរការកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

យើងខ្ញុំដឹងថាភារកិច្ចនៅចំពោះមុខរបស់បុគ្គលិកនិងមន្ត្រីតុលាការទាំងអស់ ជាកិច្ចការមួយសំខាន់ ដែលចាំបាច់ត្រូវប្រើឲ្យអស់លទ្ធភាពនូវបទពិសោធន៍ ការប្រឹងប្រែងនិងភាពអត់ធ្មត់ ប៉ុន្តែយើងខ្ញុំសន្យាថា នឹងខិតខំឲ្យអស់ពីសមត្ថភាពដើម្បីទទួលខុសត្រូវនូវរាល់កាតព្វកិច្ចដែលបានចាត់តាំងក្នុងន័យសបញ្ជាក់ថា ភាពយឺតយូរក្នុងការរកយុត្តិធម៌នឹងមិនមានន័យថាមិនមានយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជានោះទេ ។



បន្ទប់សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ

# រឿងរ៉ាវខ្ញុំក្នុងរបប ប៉ុល ពត

## ភ្នំពេញ

មុនពេលខ្មែរក្រហមចូលមកកាន់អំណាច ស្នូរកាំភ្លើង និងគ្រាប់បែកផ្ទុះលាន់ឮជារៀងរាល់ថ្ងៃ ។ កម្លាំងរដ្ឋាភិបាលលន់នល់កាន់តែចុះខ្សោយមិនអាចទប់ទល់នឹងការវាយប្រហាររបស់កងទ័ពខ្មែរក្រហមដែលចូលកាន់តែកៀកទីក្រុងភ្នំពេញបានឡើយ ។ ស្ថានភាពនយោបាយនៅពេលនោះគឺស្ថិតនៅក្នុងសភាពតានតឹងជាខ្លាំង ។ សង្គ្រាមបានធ្វើឲ្យប្រជាកសិករមិនអាចដាំដុះបាន ។ ការដឹកជញ្ជូនស្បៀងអាហារមកពីខេត្តក៏មិនអាចធ្វើបានដែរ ដោយសារផ្លូវជាតិត្រូវខ្មែរក្រហមកាត់ផ្តាច់អស់ទៅហើយ ។ ទំនិញឡើងថ្លៃ៥០ដងដូចជាប្រេងកាតមួយលីត្រតម្លៃ១០រៀល ឡើងថ្លៃរហូតដល់៥០០រៀល ។ ប្រជាជនមិនសប្បាយចិត្តគ្រប់គ្នា ផ្ទុយទៅវិញឈ្មួញហាក់ដូចជារីករាយ ។ អំពើពុករលួយរីកដុះដាលដូចផ្សិត ។ បាតុកម្មប្រឆាំងនឹងរដ្ឋាភិបាលកើតឡើងគ្រប់ទីកន្លែង ។

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ទាហានអាមេរិកនិងជនជាតិអាមេរិកនៅប្រទេសកម្ពុជាបានឡើងឧទ្ធម្ភាគចក្រត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ។ នៅទីបំផុត ទោះបីជាយើងមិនចូលចិត្តខ្មែរក្រហមក៏ដោយ ក៏យើងគ្មានជម្រើសផ្សេងណាក្រៅពីនេះដែរ ។ របបកុម្មុយនិស្តចាប់ផ្តើមពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

## ការជម្លៀស

នៅថ្ងៃទី១៧ ខែមេសា ខ្ញុំមិនបានទៅធ្វើការនៅក្រសួងអប់រំទេ ព្រោះទីក្រុងកំពុងតែជ្រួលច្របល់ខ្លាំង ។ នៅម៉ោង៩ព្រឹក ខ្ញុំឃើញទាហានលន់នល់រត់ត្រឡប់ចូលទីក្រុងវិញ ។ រថក្រោះនិងរថយន្តទាហានទាំងនោះមានដោតទង់ជ័យស ។ កងទ័ពខ្មែរក្រហមដែលមានទឹកមុខមាំនិងកាចសាហាវ បានចូលមកដល់ទីក្រុង ។ នៅម៉ោង១០ព្រឹកថ្ងៃដដែល កងទ័ពខ្មែរក្រហមប្រកាសថា ៖ "សុំបងប្អូនទាំងអស់គ្នាចេញពីទីក្រុងភ្នំពេញ ព្រោះកងទ័ពយើងត្រូវការបោសសម្អាតទីក្រុង ។ បងប្អូននឹងបានត្រឡប់មកវិញក្នុងរយៈពេលបីថ្ងៃ" ។ ឮដូច្នោះខ្ញុំនិងអ្នកជិតខាងនាំគ្នាដើររករទេះ និងស៊ីក្លូសម្រាប់ដឹក អីវ៉ាន់របស់យើង ប៉ុន្តែយើងរកមិនបានទេ ព្រោះប្រជាជនដទៃទៀតក៏កំពុងតែត្រូវការយានជំនិះដែរ ។ ត្រឡប់មកផ្ទះវិញយើង រៀបចំរបស់របរប្រើប្រាស់គ្រប់មុខ ព្រោះយើងគ្មានសង្ឃឹមថា នឹងបានវិលត្រឡប់មកផ្ទះម្តងទៀតទេ ។ យើងបង្ខំចិត្តចាកចោល ផ្ទះទាំងស្តាយស្រណោះ ។

យើងជិះលើឡានក្រុងមួយ ប៉ុន្តែឡានក្រុងនោះស៊ីសាំងច្រើនណាស់ ។ យើងធ្វើដំណើរយឺតជាងដើរទៅទៀត ។ ការធ្វើដំណើររបស់យើងអាស្រ័យលើបញ្ជារបស់កងទ័ពខ្មែរក្រហម ។ នៅតាមផ្លូវមនុស្សកុះករដូចស្រមោច ។ មិនត្រឹមតែនៅតាមផ្លូវទេ សូម្បីតែក្រោមដើមឈើឬក្រោមសំយាបផ្ទះក៏មានមនុស្សកកកុញដែរ ។ យើងកំពុងតែត្រូវបញ្ជូនឲ្យទៅរស់នៅតាមជនបទ ។ នៅម៉ោង៥ល្ងាចទើបយើងទៅដល់មុំវត្តផ្ទុំមូលក្បាលថ្នល់ ហើយឈប់សម្រាកហូបបាយល្ងាចនៅទីនោះ ។

នៅថ្ងៃទី១៨ ប្រហែលជាម៉ោងពីររសៀល យើងចាប់ផ្តើមបន្តដំណើរជាមួយនឹងហ្វូងមនុស្សតទៅទៀត ។ មិនថាពេលថ្ងៃឬពេលយប់ទេ ចំនួនមនុស្សនៅតែកុះករដដែល ។ ជួនកាលកងទ័ពខ្មែរក្រហមជេរប្រមាថយើងដោយប្រើសម្តីគំរោះគំរើយ ។

ភ្លាមៗនោះ កងទ័ពខ្មែរក្រហមបួននាក់ស្ទុះមកពទ្ធ័រថយន្តក្រុងដែលយើងកំពុងជិះ ហើយចាប់ខ្លួននារីពីរនាក់ដែលជាទាហានលន់នល់ ។ មួយសន្ទុះក្រោយមក យើងឮស្នូរកាំភ្លើងចម្ងាយប្រហែលមិនលើសពី១០០ម៉ែត្រពីផ្លូវ ។ នោះគឺជាស្នូរកាំភ្លើងដែលកងទ័ពខ្មែរក្រហមបាញ់សម្លាប់នារីទាំងពីរនាក់នោះ ។ មេក្រុមកងទ័ពខ្មែរក្រហមត្រឡប់មករកឡានក្រុងម្តងទៀត ហើយសួរថា អ្នកណាជាលោកធំ? (គឺខ្ញុំ) ។ ឃើញស្ថានការណ៍មិនស្រួល ខ្ញុំប្រញាប់គេចចុះពីលើឡាន ។ កងទ័ពខ្មែរក្រហមចាប់ខ្លួនបុរសម្នាក់ដែលមានមាឌធំប្រហាក់ប្រហែលខ្ញុំដែរ ។ ហេតុការណ៍ដ៏តក់ស្លុតនេះ ធ្វើឲ្យប្រពន្ធខ្ញុំភ័យរហូតទៅជាវង្វេងវង្វាន់ ។

ទៅដល់បឹងស្នោ ប្រពន្ធរបស់ខ្ញុំលេបថ្នាំងងុយដេកអស់១៤គ្រាប់រហូតដល់ស្លឹកខ្លួន ។ ពេលនោះមនុស្សនៅលើឡានក្រុងរួមទាំងកូនៗខ្ញុំផង ស្រែកយំទ្រហឹង ។ ម៉ោង១០ព្រឹកយើងទៅ



ដល់ភូមិកំពង់ភ្នំលើ ។ យើងចុះពីឡានក្រុងនិងដេករង់ចាំអស់មួយយប់ទើបបានឆ្លងទន្លេមេគង្គទៅភូមិព្រែកខ្សាយ ។ យើងដើរដោយក្តីលំបាកវេទនា ពីភូមិព្រែកខ្សាយជាង៨គីឡូម៉ែត្រ ទើបទៅដល់ភូមិស្ទឹងស្លូត ហើយសម្រាកនៅទីនេះមួយយប់ទៀត ។ ប្រជាជននៅទីនោះភ្ញាក់ផ្អើលដែលឃើញប្រពន្ធខ្ញុំឆ្កួតវង្វេងវង្វាន់ ។ ព្រឹកឡើង យើងឡើងជិះឡានហ្សេ.អឹម.សេ. ដែលខ្មែរក្រហមយកមកដឹកប្រជាជនជម្លៀស ។ ឡាននេះដឹកយើង បានប្រហែល១០គីឡូម៉ែត្រ ។ បន្ទាប់មកយើងត្រូវចុះដើរតាមផ្លូវជាតិលេខ១១ ទៅទិសខាងត្បូង ។ យើងឈប់នៅវត្តតាញ៉ែកអស់ពីរថ្ងៃ បន្ទាប់មកទៅដល់វត្តព្រះស្រី ។ នៅទីនោះ ខ្ញុំត្រូវបានអង្គការឲ្យប្រមូលផ្តុំក្នុងកងមួយដែលមានមនុស្ស៣៨នាក់ រួមទាំងកុមារនិងមនុស្សចាស់ ដែលសុទ្ធតែជាគ្រួសារអតីតមន្ត្រីរដ្ឋការក្នុងរបបលន់នល់ ។ សមាជិកគ្រួសារខ្ញុំត្រូវកាត់សក់ខ្លីទាំងអស់គ្នា ។ កងទ័ពខ្មែរក្រហមនិយាយថា “បងប្អូនទាំងអស់គ្នាមកនេះ ដើម្បីជួយអង្គការកសាងប្រទេសជាតិ” ។ ដោយសារយើងមាននិន្នាការខាង លន់ នល់ យើងគិតថាពាក្យសម្តីដែលខ្មែរក្រហមនិយាយចេញមកសុទ្ធតែមិនពិត ។ យើងស្នាក់នៅវត្តព្រះស្រី អស់រយៈពេលបួនថ្ងៃទើបត្រូវជម្លៀសបន្តទៀត ។

នៅតាមផ្លូវពីវត្តព្រះស្រីទៅព្រៃស្វាវាលតាប្រុញ កងទ័ពខ្មែរក្រហមភ្ជង់កាំភ្លើងអាអ៊ែ១៥បង្ខំឲ្យយើងដើរឲ្យលឿន ។ យើងអស់កម្លាំងណាស់ ប៉ុន្តែដោយខ្លាចកងទ័ពក្មេងៗទាំងអស់នោះ យើងចេះតែបន្តដំណើរទាំងត្រដាបត្រដួស ។ យើងចំណាយពេលដើរពីរថ្ងៃ ។ យើងសម្រាកនៅវត្តតាយោកជាកន្លែងដែលខ្មែរក្រហមសម្តែងសិល្បៈពីវប្បធម៌ថ្មីឲ្យយើងបានជ្រួតជ្រាប ។ ខ្ញុំភ្ញាក់ផ្អើលនឹងការស្លៀកពាក់របៀបនិយាយស្តី និងម៉ូតសក់ដ៏ខ្លីដូចចិនរបស់អ្នកសម្តែង ។ យើងគ្មានសកម្មភាពអ្វីទាំងអស់ក្រៅពីចំហមាត់មើល ។ ព្រឹកឡើងយើងបន្តដំណើរទៅតាមទិសខាងជើង ។

### ធ្វើដំណើរចូលគុក

ពេលថ្ងៃត្រង់ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៥ យើងបានទៅដល់ព្រៃស្វាក្នុងតំបន់២៤ ។ កន្លែងនេះមានចំងាយ១៥គីឡូម៉ែត្រពីឃុំកំពង់ត្របែក ។ តាមការពិតទីនេះគឺជាគុកមួយដែលព័ទ្ធជុំវិញដោយរបងឫស្សីនិងលួសបន្លា ។ យើងធ្លាក់ក្នុងអន្ទាក់របស់អង្គការ ។

ពេលរសៀល ប្រធានសន្តិសុខតំបន់២៤ហៅខ្ញុំទៅសួរចម្លើយ ។ គាត់ជក់បារីស្លឹកសង្កែដ៏ធំមួយដើម ។ គាត់សួរពីប្រវត្តិរូបខ្ញុំអស់ជាងកន្លះម៉ោង ខ្ញុំឆ្លើយប្រាប់ត្រង់ទាំងអស់ ។ ខ្ញុំដឹងថាលាក់មិនជិតទេ ព្រោះស្រុកកំណើតរបស់ខ្ញុំនៅឃ្លាតពីទីនេះតែ១០គីឡូម៉ែត្រប៉ុណ្ណោះ ។ ចុងបញ្ចប់ ប្រធានសន្តិសុខប្រាប់ខ្ញុំថា “មិត្តឯងត្រូវទៅរៀនសូត្រ” ។ ខ្ញុំឆ្ងល់ថាតើរៀនយ៉ាងម៉េច បើគ្មានប៊ិចគ្មានសៀវភៅដូចនោះ ។

នៅថ្ងៃទីពីរ ខ្ញុំបានជួបបុរសមិនស្គាល់ឈ្មោះម្នាក់ ។ គាត់ឃើញមុខខ្ញុំដូចបងប្រុសខ្ញុំដែលនៅស្រុកកំណើត ទើបគាត់និយាយប្រាប់ខ្ញុំពីរឿងបងប្រុសរបស់ខ្ញុំដែលជាប់គុកតាំងពីឆ្នាំ១៩៧២ ដោយជាប់ចោទថាជាបណ្តាញរបស់លន់នល់ ។ គាត់ប្រាប់ខ្ញុំឲ្យទ្រាំចាំពីរបីថ្ងៃនឹងបានរួចខ្លួនហើយ ។ គាត់ផ្តែផ្តាំខ្ញុំថា “បើហូបអំបិលកុំហូបសម្ល បើហូបសម្លកុំហូបអំបិល” និងពាក្យសំខាន់បីម៉ាត់ទៀតគឺ “គោរពអង្គការវិន័យ ខិតខំធ្វើការងារ និងកុំនិយាយស្តី” ។

តាមពិត វាពិបាកណាស់ក្នុងការធ្វើតាមដំបូន្មានរបស់គាត់ ព្រោះយើងគ្មានទំនោរទៅខាងហ្នឹង ។ ពីរបីថ្ងៃក្រោយមកទើបខ្ញុំដឹងថារបបនេះយកដីធ្វើសៀវភៅនិងមែកឈើជាប៊ិច ។ នៅក្នុងគុក ខ្ញុំជួបឧត្តមសេនីយ៍ អាន និល, រដ្ឋ សយ ជាញាតិមិត្តរបស់ខ្ញុំ និងលោកមេបញ្ជាការ ជា សឿន ។ មន្ត្រីរាជការទាំងបីនេះក្រោយមកត្រូវបញ្ជូនទៅគុកព្រៃចម្ការ ។

### ទណ្ឌកម្ម

យើងទាំងអស់គ្នារស់នៅក្នុងជង្រុកស្រូវចាស់មួយ គ្មានបង្អួចងងឹតស្អុបមិនថាយប់ឬថ្ងៃ ។ នៅក្នុងអំឡុងពេលបីខែ អ្នកដែលរស់នៅក្នុងជង្រុកនេះទាំងអស់កើតជំងឺរាកឈាមដោយសារឆ្លងមេរោគ ប៉ុន្តែយើងមិនដែលមានថ្នាំសង្កូវអ្វីក្រៅពីថ្នាំបុរាណដែលគ្មានប្រសិទ្ធភាព ហើយមានចំនួនមិនគ្រប់គ្រាន់ទៀត ។ យើងត្រូវអង្គការបែងចែកជាកងឲ្យធ្វើការ ។ ការងាររបស់ស្ត្រីគឺដើរប្រមូលឈើងាប់ៗនិងកាប់ដីស្រែដោយប្រើដៃឬជើងផ្ទាល់ ។

អ្នកទោសបុរសត្រូវលើកទំនប់ដែលមានកម្ពស់បីម៉ែត្រ ។ អង្គការដាក់កំហិតឲ្យម្នាក់ៗជីកដីឲ្យបានបីម៉ែត្រក្នុងមួយថ្ងៃ ។ យើងគ្មានអាហារ និងថ្នាំសង្កូវទេ ។ ខ្មែរក្រហមឲ្យយើងហូបបបរពរកក្លួកតែបន្តិចបន្តួច ។

ខ្ញុំចេះតែដណ្តឹងសួរខ្លួនឯងថា បើយ៉ាងហ្នឹងតើខ្ញុំរស់ដូចម្តេចទៅ? ជង្រុកស្រូវខ្ញុំដែលខ្ញុំរស់នៅស្ថិតនៅទល់មុខជង្រុកស្រូវរបស់អង្គការ ។ ព្រឹកព្រហាមខ្ញុំលួចអង្ករខ្លះយកមកដាំហូបជាមួយនឹងអំបិល ។ យើងមិនដែលបានហូបសាច់ទេ ។ ខ្លួនប្រាណខ្ញុំស្គមកំព្រឹងមានតែស្បែកដណ្តប់ឆ្អឹង ។ ពីមុនខ្ញុំមានទម្ងន់ ៨៤គីឡូក្រាម ឥឡូវនេះទម្ងន់ខ្ញុំនៅសល់តែ៥៨គីឡូក្រាម ។ យើងរស់នៅទាំងអស់សង្ឃឹម ។ យើងធ្វើការមិនឈប់លើកលែងតែពេលយប់ ។ នៅក្បែរកន្លែងខ្ញុំស្នាក់នៅ សត្វជ្រូកស៊ីគំនរសាកសពដែលនៅរាយប៉ាយលើដីដោយសារគ្មានរណ្តៅសម្រាប់កប់ ។

លោក ហេង, លោក ពៀច សុន, និងលោក ងិន អុន ត្រូវអង្គការបណ្តើរយកទៅសម្លាប់នៅវាលតាប្រុញនៅម៉ោង ៥ ទៀបភ្លឺ ។ មួយខែក្រោយមកទៀត អ្នកទោសដទៃត្រូវបញ្ជូនទៅគុកធំជាបន្តបន្ទាប់ ទាំងអស់គ្នាស្ទើរតែស្លាប់ដោយសារជំងឺរាករូស ។

## ប្រឹងទម្លាប់នឹងភាពស្រេកឃ្លាន

បញ្ហាប្រចាំថ្ងៃរបស់យើងគឺឃ្លាន ។ ក្រពះរបស់យើងរមួលជានិច្ច ។ យើងលួចហូបស្លឹកឈើនិងសត្វផ្សេងៗដូចជា ពស់ ក្តាម ដែលយើងអាចរកបាននៅតាមវាលស្រែ ។ ខ្ញុំនឹកទៅដល់ជីវិតនៅទីក្រុង ទៅមើលកុន អានកាសែត សៀវភៅ ស្តាប់វិទ្យុ មើលវីដេអូ ។

មួយខែក្រោយមក អង្គការចាត់តាំងឲ្យអ្នកទោសទាំងអស់លើកទំនប់មួយទៀត ។ មានអ្វីកើតឡើងនៅថ្ងៃដំបូង? ខ្ញុំបានធ្វើឲ្យបាក់ប៉ែលចូកដី ។ ខ្ញុំភ័យណាស់ខ្លាចអង្គការធ្វើទារុណកម្ម ។

ដៃគូសែងដីជាមួយខ្ញុំ គឺជាអតីតសិស្សវិទ្យាល័យ១៨មីនាម្នាក់ ។ មិត្តនោះជាកូនរបស់លោក ហេង លេខារបស់អតីតនាយករដ្ឋមន្ត្រី ឡុង បូរ៉េត ។ យើងដាក់វេនគ្នាជីកនិងរែកដី ។ យើងធ្វើការទាំងភ័យខ្លាច ។

ថ្ងៃមួយ ពេលយើងកំពុងលើកទំនប់ ប្រជាជនមូលដ្ឋានបានយកអាហារមកឲ្យយើងហូប ។ យើងសប្បាយចិត្តណាស់ ព្រោះខានបានបាយម្ហូបទទួលទានអស់ជាច្រើនខែហើយ ។ ដោយសារអាហារមិនគ្រប់គ្រាន់ កូនលោក ហេង បានស្លាប់នៅខែបន្ទាប់ ។ ចាប់ពីពេលនោះមកខ្ញុំឯកោ ។ អង្គការចាត់តាំងឲ្យខ្ញុំធ្វើការងារថ្មី គឺវាស់ដីចែកឲ្យអ្នកទោសធ្វើការ ។

ជារៀងរាល់យប់ខ្ញុំលើកដៃបន់ស្រន់ "សូមលោកឪពុកនៅឋានសួគ៌ជួយខ្ញុំឲ្យរួចពីសេចក្តីស្លាប់ផង" ។ ពីរខែកន្លងផុតទៅ យើងខំប្រឹងធ្វើការណាស់ ។ នៅចុងខែទីបី បន្ទាប់ពីបង្ហើយការងារនៅស្រែ អង្គការប្រមូលអ្នកទោសហើយប្រកាសថា "នៅក្នុងចំណោមអ្នកទាំងអស់គ្នា អង្គការមើលឃើញមិត្តម្នាក់ ប៉ុន្តែខ្ញុំមិនដឹងថាជាមិត្តណាទេ" ។ គ្រាន់តែឮដូចនោះ ខ្ញុំគិតថាម្តងនេះខ្ញុំពិតជាមិនរួចពីសេចក្តីស្លាប់ទេ ។ ៩៣ថ្ងៃក្រោយមកខ្ញុំត្រូវបានដោះលែង ។

## ផ្ទះបាក់បែក

ម៉ោង៧ព្រឹក ក្រុមគ្រួសារខ្ញុំត្រូវបញ្ជូនទៅសហករណ៍ ។ សាកសពប្អូនប្រុសរបស់ខ្ញុំដែលទើបនឹងស្លាប់ដោយជំងឺរាកមិនទាន់ត្រូវបានកប់នៅឡើយ ។ មុនពេលចេញដំណើរ ខ្ញុំសុំអង្គការយកសាកសពប្អូនរបស់ខ្ញុំទៅជាមួយ សំណាងល្អអង្គការយល់ព្រម ។ ខ្ញុំអៀវសាកសពនៅលើស្មា ចំណែកកូនស្រីច្បងរបស់ខ្ញុំពបប្អូននៅចង្កេះ ។

ទៅដល់ពាក់កណ្តាលផ្លូវ យើងរអិលដួលដោយសារផ្លូវនោះមានភក់ ។ ខ្ញុំដាក់សាកសពនៅលើខ្នងទំបន់តូចមួយហើយជួយលើកសមាជិកគ្រួសារ ។ ចំណែកឯប្រពន្ធវិកលចរិតរបស់ខ្ញុំដើរហួសទៅមុខធ្វើមិនដឹង ។ យើងឈប់សម្រាកនៅក្បែរផ្ទះមួយដែលជារបស់ស្ត្រីពិការភ្នែកម្នាក់ ។ គាត់ប្រហែលជាដឹងថាយើងជាប្រជាជនថ្មីដែលទើបនឹងរួចពីគុក ។ យើងនៅសម្រាកទីនោះរហូតដល់ម៉ោង១២ទើបឃើញបុរសម្នាក់ស្លៀកពាក់ខោអាវខ្មៅ ដើរចូលមកនិយាយថា "មិត្តឯងមកតាមខ្ញុំ" ។ បុរសនោះជាប្រធានសន្តិសុខភូមិ ។ ខ្ញុំខ្លាចគាត់ណាស់ ។

ផ្ទះដែលប្រធានភូមិប្រគល់ឲ្យគ្រួសារខ្ញុំរស់នៅមានសភាពបាក់បែកស្ទើរតែទាំងស្រុង ។ ផ្ទះនេះជារបស់ យឹម ។ កាលពីមុន យឹម គឺជាចោរនៅក្នុងភូមិ ឥឡូវនេះ បានក្លាយជាប្រធានកង ។ យឹម បានប្រគល់ផ្ទះនេះឲ្យអង្គការ ហើយទៅសង់ផ្ទះថ្មីមួយទៀត

សម្រាប់ខ្លួនឯង ។ ដំបូលផ្ទះនេះធ្លុះធ្លាយអាចមើលឃើញផ្កាយ និងព្រះចន្ទយ៉ាងច្បាស់ ។ ខ្ញុំចាំបាច់ត្រូវតែជួសជុលផ្ទះនេះ ។ យឹម បានបញ្ជាឲ្យខ្ញុំកាប់ឫស្សីនិងកាប់មែកឈើ ។ ពេលនោះខ្ញុំទាល់ច្រក ព្រោះមិនចេះឡើងដើមឈើ ។ ប្រជាជនមូលដ្ឋានមើលងាយ គ្រួសារខ្ញុំណាស់ ។ កូនស្រីអ្នកជិតខាងម្នាក់ឈ្មោះ លឹម អាយុ ១២ឆ្នាំ ស្តោះទឹកមាត់ដាក់ខ្ញុំពេលខ្ញុំចេញទៅភ្ជួរស្រែ ។

ប្រជាជនទាំងអស់ត្រូវតែចេញទៅធ្វើការនៅការដ្ឋាន ។ យើង ធ្វើការច្រើន ប៉ុន្តែបានហូបតិចតួចមិនសមនឹងកម្លាំងពលកម្ម ។

ខ្ញុំធ្វើការនៅក្នុងក្រុមភ្ជួររាស់ដីដែលមានសមាជិក៨នាក់ ដឹកនាំដោយឈ្មោះ មឿន ជាប្រជាជនមូលដ្ឋាន ។ ថ្ងៃមួយក្របី មួយក្បាលឈឺមិនព្រមស៊ីស្មៅ ។ ឃើញដូច្នោះខ្ញុំស្នើប្រធានក្រុម ឲ្យយកក្របីនោះត្រឡប់ទៅភូមិវិញ ។ គាត់ក៏ព្រមឲ្យក្មេងម្នាក់ ឈ្មោះ ឡុង ដឹកក្របីនោះទៅភូមិ ។

មួយខែក្រោមមក អង្គការអនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅផ្ទះវិញ ។ ពេលដែលខ្ញុំទៅដល់ភូមិ ម្ចាស់ក្របីសួរខ្ញុំអំពីមូលហេតុដែលក្របី ស្លាប់ ។ ខ្ញុំប្រាប់គាត់ថាខ្ញុំបានមើលថែវាយ៉ាងល្អហើយ ប៉ុន្តែមិន ដឹងហេតុអ្វីបានជាវាងាប់ ។

**គ្មានព្រះសង្ឃ គ្មានបុណ្យសព**

តើខ្មែរក្រហមធ្វើយ៉ាងម៉េចចំពោះសាកសព? ខ្មោចមនុស្ស ដែលស្លាប់ដួលរណែលដូចដើមឈើងាប់គ្មានអ្នកណារវីរវល់ ។ កូន ប្រុសខ្ញុំស្លាប់តាំងពីម៉ោង៦ព្រឹក តែគ្មានអ្នកណាមកយកសាកសព ទៅកប់សោះ ។ ខ្មោចតម្កល់នៅផ្ទះរហូតដល់ម៉ោង៥ល្ងាចទើប ប្រធានភូមិឈ្មោះ មឿន មកយកទៅកប់ ។

**បាត់បង់ភាពថ្លៃថ្នូរ អស់តម្លៃ**

ពីមុនខ្ញុំមិនដឹងអ្វីទៅជាសហករណ៍ឡើយ ។ ខ្ញុំគិតថាបានរួច ពីគុកមុខជាមានហូបឆ្អែត តែតាមពិតខ្ញុំយល់ខុសទាំងស្រុង ភាព អត់ឃ្លាននៅតែមានដដែល ។ អង្គការបែងចែកស្រូវឲ្យប្រជាជន តាមគ្រួសារ ។ គ្រួសារខ្ញុំមានសមាជិកប្រាំនាក់ទទួលបានតែអង្ករ ៣៥គីឡូក្រាមប៉ុណ្ណោះសម្រាប់រយៈពេលមួយខែ ។ អង្ករនេះមិន គ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារយើងឡើយ ។ ប្រាំបួនខែក្រោយ មកខ្មែរក្រហមបង្កើតរោងបាយរួម ។ ឯកូនៗខ្ញុំក្លាយទៅជាស្គម ស្គាំងខ្វះជីវជាតិ ។ រស់នៅក្នុងផ្ទះនោះបានតែមួយខែកន្លះ គ្រួសារ ខ្ញុំត្រូវបាត់បង់សមាជិកអស់បីនាក់គឺ ប្អូនប្រុសរបស់ខ្ញុំអាយុ២១ ឆ្នាំ កូនប្រុសខ្ញុំអាយុ៨ឆ្នាំ និងកូនស្រីអាយុ៤ឆ្នាំ ។

ថ្ងៃមួយក្នុងឆ្នាំ១៩៧៧ វេលាម៉ោង៧ល្ងាច បន្ទាប់ពីទទួល ទានអាហារល្ងាចរួចខ្ញុំនៅតែឃ្លាន ។ របបអាហារនៅរោងបាយ តិចហួស ។ ខ្ញុំលួចចូលទៅក្នុងផ្ទះបាយរកមើលរបស់ដែលអាច ហូបបាន ។ ទៅដល់ខ្ញុំជួបស្ត្រីចុងភៅហើយសុំបានបាយខ្លះ ។ ខ្ញុំ ហូបបាយនោះតែម្នាក់ឯងមិនចែកឲ្យប្រពន្ធដែលកំពុងតែមានផ្ទៃ ពោះឡើយ ។ ប្រពន្ធខ្ញុំស្រែកយំខ្លាំងៗ ប៉ុន្តែខ្ញុំធ្វើជាមិនឮ ។ ដោយ សារតែការស្រេកឃ្លាន ខ្ញុំក្លាយជាមនុស្សខ្វាក់ គ ថ្លង់ ។ ខ្ញុំចង់សងសឹកនឹងប្រពន្ធខ្ញុំ ព្រោះពីលើកមុននាងបានដំឡូងហូប តែជាមួយកូនៗមិនចែកខ្ញុំទេ ។

រាល់ពេលដែលខ្មែរក្រហមកាប់ជ្រូកឬក្របី ខ្ញុំប្រញាប់ ប្រញាល់ទៅសុំសាច់ខ្លះពីចុងភៅយកមកហូប ។ ខ្ញុំមិនបានចម្អិន សាច់នោះឲ្យឆ្អិនល្អទេ គឺគ្រាន់តែឆ្អើរលើភ្លើងតែមួយភ្លែតក៏យក មកហូបភ្លាម ព្រោះខ្លាចអ្នកដទៃឃើញ ។ នៅក្នុងភូមិនេះរបប អាហាររបស់យើងអាស្រ័យលើកម្លាំងពលកម្ម ។ បើយើងឈឺ អង្គការកាត់របបអាហារយើងពាក់កណ្តាល ។

អង្គការតាមដានរាល់សកម្មភាពរបស់យើង មិនថាយើង និយាយអ្វីឬធ្វើអ្វីទេ អង្គការដឹងទាំងអស់ ។ នៅពេលយប់មាន ក្មេងស្រីម្នាក់អាយុប្រមាណ១០ឆ្នាំ មកអង្គុយក្រោមផ្ទះខ្ញុំចាំ ស្តាប់យើងនិយាយគ្នា ។ អង្គការចូលចិត្តប្រើកុមារជាភ្នែកជា ច្រមុះណាស់ ។

**ការស្លៀកពាក់**

ប្រជាជនមូលដ្ឋាន ប្រធានភូមិ និងប្រធានក្រុម ស្លៀកពាក់ ពណ៌ខ្មៅរលើប និងបង់កក្រមាពណ៌ក្រហម ចំណែកប្រជាជនថ្មី ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅពក្លក់និងមានបំណះរយ៉ៃ ។ គួរឲ្យ អស់សំណើចដែរ ក្មេងស្រីតូចៗនៅក្នុងភូមិចេះស្រឡាញ់កងទ័ព ខ្មែរក្រហមកំលោះៗ ។ ក្មេងស្រីទាំងនោះចាក់មួកស្លឹកត្នោតឲ្យ កងទ័ពដែលជាគូស្នេហ៍របស់ខ្លួន ។

ច្រើនខែកន្លងផុតទៅ ខោអាវរបស់យើងពុកផុយ ស្លៀក ពាក់លែងកើត យើងអស់ខោអាវស្លៀកពាក់ ។ អង្គការមិនរវីរវល់ និងកង្វះខាតរបស់យើងទាល់តែសោះ មានតែបក្ខពួករបស់

អង្គការទេដែលបានទទួលការយកចិត្តទុកដាក់ ។ ចំណែកយើងវិញ ខែវស្សាគ្មានអាវ គ្មានស្បែក ជើង ពាក់ និងគ្មានភួយដណ្តប់ ។

***វិលមកភូមិកំណើត***

នៅដើមឆ្នាំ១៩៧៩ ក្រោយពីរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជារំដោះទឹកដីពីរបបខ្មែរក្រហម ខ្ញុំត្រឡប់ទៅភូមិកំណើតវិញ ។ ពេលទៅដល់ទីនោះខ្ញុំឮដំណឹងអាក្រក់ថា សាច់ញាតិរបស់ខ្ញុំបាត់បង់ជីវិតអស់២៧នាក់រួមមាន ម្តាយ បងប្អូនបង្កើត ក្មួយស្រី ក្មួយប្រុស និងបងប្អូនថ្លៃជាច្រើននាក់ ។ តើមានអ្នកណាឃើញចាប់ដាច់ខ្ញុំទៀត?

**គីម ខាម ហៅ កុសល**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តនៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងទិសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យព័ត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទផ្សេងៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ជនជាតិចាមប្រជុំនៅមជ្ឈមណ្ឌលឯកសារកម្ពុជា



ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនប្រុសឈ្មោះ ឡាំ សំអ៊ិន


ឡាំ យឿន
មុនឆ្នាំ១៩៧៥

នាងខ្ញុំឈ្មោះ ឡាំ យឺន អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិឡទឹកត្រី ឃុំកំពង់ឆ្នាំង ស្រុក កំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មុនរបបកម្ពុជាប្រជាធិបតេយ្យរស់នៅភូមិក្រងដិល ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ នាងខ្ញុំសូមសួររកប្អូនប្រុសឈ្មោះ ឡាំ សំអ៊ិន ដែលបានបែកគ្នាក្នុងពេលខ្មែរក្រហមជម្លៀសពីប្រឡាយមាសទៅស្រុកកំពង់លែង ។ មុនរបបកម្ពុជាប្រជាធិបតេយ្យ ប្អូនបួសជាសង្ឃនៅវត្តប្រឡាយមាសក្នុងស្រុកកំណើតបានបីវស្សា បន្ទាប់មកលាចាកសិក្ខាបទនៅឆ្នាំ១៩៧៥ក្នុងអាយុ២១ឆ្នាំ ។

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ខ្ញុំបានទទួលដំណឹងពីឈ្មោះ ឆឹង កូន និង លោកពូស៊ុន នៅក្នុងភូមិជាមួយគ្នាថាគាត់បានជួប សំអ៊ិន នៅសំឡូតខេត្តបាត់ដំបង ហើយបានបបួល សំអ៊ិន ត្រឡប់មកផ្ទះវិញ ប៉ុន្តែ សំអ៊ិន ប្រកែកថាមិនហ៊ានមកទេខ្លាចខ្មែរក្រហមឃើញតាមផ្លូវសម្លាប់ចោល ។ ខ្ញុំថែមទាំងដឹងទៀតថា ប្អូនបានប្តូរឈ្មោះពី ឡាំ សំអ៊ិន ទៅជា អ៊ិន កំសត់ ។ បើប្អូន ឡាំ សំអ៊ិន បានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានដឹងដំណឹងអំពី ឡាំ សំអ៊ិន ឬ (អ៊ិន កំសត់) សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំនៅភូមិឃុំខាងលើ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារលេខ ០២៣ ២១០ ៣៥៨ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនស្រី ឈឹម ឆត

ខ្ញុំបាទឈ្មោះ ឈឹម សុខុម ឪពុកឈ្មោះ ឈឹម គ្រីប និងម្តាយឈ្មោះ ពៅ (ស្លាប់ឆ្នាំ១៩៧៧ដោយសារជំងឺ) ។ សព្វថ្ងៃរស់នៅភូមិស្រែចិន្តា ឃុំព្រះស្រែ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ សូមប្រកាសសួររកប្អូនស្រីឈ្មោះ ឈឹម ឆត ហៅ សុផល ដែលបាត់ខ្លួនក្នុងរបបកម្ពុជាប្រធិបតេយ្យ ។ សុផល បានចូលបម្រើខ្មែរក្រហមតាំងពីឆ្នាំ១៩៧៤នៅឯមន្ទីរឃុំ តាមរយៈបងប្រុសឈ្មោះ ឈឹម សុង ជាគណៈឃុំ ។ ក្រោយមកឆ្នាំ១៩៧៦ សុផល ត្រូវបានបញ្ជូនទៅធ្វើការនៅមន្ទីរពេទ្យ១៧មេសានៅឯភ្នំពេញ ។ ក្នុងឆ្នាំដដែល សុផល បានមកលេងម្តាយដែលឈឺរយៈពេល៥ថ្ងៃនៅឯភូមិនេះ រួចក៏បានត្រឡប់ទៅវិញ ហើយក៏បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ ប្រសិនបើប្អូនស្រីបានឃើញនូវការប្រកាសនេះ ឬក៏បងប្អូនណាបានស្គាល់ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើឬមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១៨៧៥ ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ម៉ាន ម៉ុន

យស ដេង អាយុ៧២ឆ្នាំ ត្រូវជាម្តាយ ព្រមទាំងកូនស្រី ម៉ាន ម៉ន អាយុ៤៥ឆ្នាំ សូមប្រកាសសួរកូនប្រុសឈ្មោះ ម៉ាន ម៉ុន ដែលបានចេញពីផ្ទះតាំងពីឆ្នាំ១៩៧៦ បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ ដើមឆ្នាំ១៩៧៦ ម៉ាន ម៉ុន ត្រូវខ្មែរក្រហមបង្ខំឲ្យសឹក បន្ទាប់មកត្រូវបានបញ្ជូនទៅធ្វើការក្នុងកងដំឡូងនៅម្តុំភ្នំពាមជាំង ស្រុកព្រះស្តេច ។ តាំងពីពេលនោះមក ម៉ាន់ ម៉ុន មិនបានត្រឡប់មកផ្ទះវិញទេ ។

ប្រសិនបើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬទូរស័ព្ទលេខ ៨៥៥ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

## អត្ថន័យបដិរូបជាផ្លូវការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

បដិរូបតំណាងឲ្យអង្គជំនុំជម្រះវិសាមញ្ញជាមួយការពិពណ៌នានូវប្រព័ន្ធរដ្ឋបាលយុត្តិធម៌កម្ពុជាក្នុងអំឡុងសករាជអង្គរ រួមនឹងកម្រងផ្ការបស់អង្គការសហប្រជាជាតិនៃស្លឹកអូលីវ ជានិមិត្តរូបនៃសន្តិភាព ។ ពណ៌ជាផ្លូវការគឺខៀវចាស់ ។

រូបអង្គុយលើបល្ល័ង្កនិងកំពុងកាន់ដាវ ដើម្បីតំណាងឲ្យសិទ្ធិអំណាចតុលាការ ។ វាជារូបគំនូរដែលនៅចំកណ្តាលនៅក្នុងសាលសវនាការសាលាឧទ្ធរណ៍សម័យមុនក្នុងក្រសួងយុត្តិធម៌នាទីក្រុងភ្នំពេញ ជាទីកន្លែងដែលព្រះអង្គត្រូវបានអមដោយជំនួយការចំនួនពីរនាក់ដែលយោងទៅនឹងច្បាប់ចារនៅលើសាស្ត្រាស្លឹករឹត ។



## អត្ថន័យត្រាជាផ្លូវការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

ត្រាជាផ្លូវការបង្ហាញពីបដិរូបដែលព័ទ្ធជុំវិញដោយរង្វង់ពីរដែលត្រូវបានសរសេរជាភាសាខ្មែរនូវឈ្មោះពេញ “អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” ជាមួយនឹងពាក្យបំព្រួញជាភាសាអង់គ្លេស អ៊ី.ស៊ី.ស៊ី.ស៊ី. ។

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដែន និងសហរដ្ឋអាមេរិក